# ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១

## ខណៈកូវីដ១៩ និងមេរោគបំប្លែងថ្មីផ្ទុះខ្លាំង អាជ្ញាធរមានសមត្ថកិច្ចថៃសម្រុក បញ្ជូនចេញពលករខ្មែរ

https://www.rasmeinews.com/ 29 June, 20210

ដោយៈភ្នំស្វាយ / ព្រំដែនកម្ពុជា ថៃ: ខណៈកូវីដ១៩ និងមេរោគបំប្លែងថ្មីផ្ទុះខ្លាំង អាជ្ញាធរមានសមត្ថកិច្ចថៃសម្រុកបញ្ជូនចេញពលករបរទេស រួមទាំងពលករខ្មែរដែលមានចំនួនច្រើនលំដាប់ទី២ បន្ទាប់ពីពលករភូមា។ យោងសារព័ត៌មានថៃ និងដោយឡែកសម្រាបប់ច្រកព្រំដែនធន្តរជាតិឆងចមខេត្តសុរិន្ទ ឈមគ្នានឹងច្រកព្រំដែនអន្តរជាតិអូរស្មាច់ខេត្តឧត្តរមានជ័យបានឱ្យដឹងថ្ងៃទី ២៩ ខែមិថុនាថា អាជ្ញាធរមានសមត្ថកិច្ចថៃបានដឹកកម្មករខ្មែរ២០០នាក់មកទម្លាក់ចោលនៅព្រំដែនថៃ-ខ្មែរ (ឆងចម ) នាខេត្តសុរិន្ទ ។ ការចាប់បញ្ជូនដោយបង្ខំ ហើយមិនចាំបាច់ត្រួតពិនិត្យសុខភាពនេះ ជាការងារគ្រាអាសន្ន គឺដោយសារកូវីដ១៩ មានសន្ទុះខ្លាំងពេកនៅប្រទេសថៃ។ ជាមួយគ្នានេះដែរ យោងតាមសារព័ត៌មានថៃ បានផ្សាយថា រដ្ឋបាលថៃបានប្រកាសនៅថ្ងៃទី២៧ -២៨ ខែមិថុនា ឆ្នាំ២០២១ បានដឹងថាក្រោយពីរដ្ឋបាលថៃប្រកាសបិទកន្លែងធ្វើការ និងស្នាក់នៅរបស់ពលករបរទេស ដែលធ្វើការសំណង់នៅតំបន់ទីក្រុងបាងកក រយៈពេល១ខែចាប់ពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ តទៅនោះ ធ្វើអោយមានពលករខ្មែរផងដែររាប់រយនាក់បានធ្វើដំណើរប្រឡប់ទៅប្រទេសកម្ពុជាវិញតាមច្រកព្រំដែននៅខេត្តសុរិន ទល់មុខនឹងខេត្តឧត្តរមានជ័យរបស់ប្រទេសកម្ពុជា។

ក្នុងហេតុការណ៍គ្រាអាសន្នដែលមកពីការផ្ទុះមេរោគ/ជម្ងឺកូវីដ១៩ ពិសេសមេរោគបំប្លែងថ្មី Delta មានប្រភពពីប្រទេសឥណ្ឌានេះបង្កផលប៉ះពាល់ខ្លាំងដែរដល់ពលករខ្មែរដែលធ្វើការនៅប្រទេសថៃដែរ ។ ក្នុងនោះពលករខ្លះត្រូវថៅកែដឹកចេញឬអោយចេញ ហើយយកទៅទុកចោលនៅតាមផ្លូវ ហើយត្រូវបានប៉ូលិសថៃដឹកបញ្ជូនយកត្រឡប់ទៅប្រទេសកម្ពុជាវិញ ៕សរន

## ពលករត្រឡប់ពីថៃ យ៉ាងតិច៣00នាក់ក្នុងមួយថ្ងៃ ខណៈថៃបិទខ្ទប់ ដោយសារកូវីដ-១៩កាន់តែខ្លាំង

https://thmeythmey.com/ 29, Jun 2021 , 10:29 pm

ភ្នំពេញ៖ លោក ឃុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស របស់អង្គការសង់ត្រាល់ បានបញ្ជាក់ថា ពលករសម្រុកត្រឡប់វិញនេះ ដោយសារពួកគេគ្មានការងារធ្វើ ខណៈថៃកំពុងរាតត្បាតកូវីដ-១៩កាន់តែខ្លាំង។ ការសម្រុកមកនេះ ពួកគេប្រឈមនឹងការកេងប្រវ័ញ្ចលើមធ្យោបាយធ្វើដំណើរនិងការឆ្លងកូវីដ-១៩។ ក្នុងកិច្ចសម្ភាសន៍ជាមួយសារព័ត៌មានថ្មីៗ លោក ឃុន ថារ៉ូ បានបញ្ជាក់ថា នាពេលថ្មីៗនេះ ពលករខ្មែរបានសម្រុកមកកម្ពុជាវិញ ប្រមាណ៣០០នាក់ ក្នុងមួយថ្ងៃ ពិសេសពលករដែលធ្វើការផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការសម្រុកមកវិញនេះ គឺដោយសារថៃកំពុងរាលដាលកូវីដ-១៩ រួមទាំងចាត់វិធានការរឹតបន្តឹងនិងបិទខ្ទប់ទីក្រុងបាងកក។ «ពលករភាគច្រើនដែលត្រឡប់មកវិញ គឺអ្នកធ្វើការសេដ្ឋកិច្ចក្រៅប្រព័ន្ធ កម្មករសំណង់ អ្នកធ្វើការតាមហាង និងផ្សារជាដើម ដោយសារពួកគេមិនមានកិច្ចគាំពារសង្គម ខណៈការបិទទីក្រុងបាងកក គឺត្រូវឲ្យបិទការដ្ឋានសំណង់។

លើសពីនេះ ពួកគេព្រួយបារម្ភការស្នាក់នៅដោយគ្មានច្បាប់ត្រឹមត្រូវនិងការឆ្លងរាលដាលកូវីដ-១៩ ទើបបង្ខំចិត្តត្រឡប់វិញ»។ នេះបើតាមការលើកឡើងរបស់លោក ថារ៉ូ ដោយបន្ថែមថា ពួកគេងាយនឹងចាញ់បោកមេខ្យល់ ដោយសារការធ្វើដំណើរត្រឡប់មកវិញ មិនបានត្រៀមទុក ពិសេសគឺ ការឆ្លងរាលដាលកូវីដ-១៩។ទន្ទឹមនឹងការសម្រុកត្រឡប់មកវិញរបស់ពលករខ្មែរ ក៏មានពលករខ្មែរជាច្រើននាក់ ព្យាយាមឆ្លងដែនខុសច្បាប់ ដើម្បីស្វែងរក

ការងារធ្វើនៅតាមខេត្តជាប់ព្រំដែនកម្ពុជា។ បើតាមលោក ថារ៉ូ ពលករដែលឆ្លងដែនខុសច្បាប់ទៅធ្វើនៅអំឡុងពេលនេះ ភាគច្រើនទៅធ្វើការប្រមូលផលកសិកម្មដំណាំផ្លែឈើ ដើម្បីដោះស្រាយជីវភាពខ្វះខាត ពិសេសអំឡុងពេលវិបត្តិកូវីដ-១៩។

ជុំវិញស្ថានភាពពលករខ្មែរនៅក្រៅប្រទេសសារព័ត៌មានថ្មីៗមិនទាក់ទងសុំព័ត៌មានលម្អិតពី លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឡើយ។ ដោយឡែក លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិប្រាប់សារព័ត៌មានថ្មីៗតាមទូរស័ព្ទថា លោកពុំទាន់មានរបាយការណ៍ជុំវិញពលករក្រៅប្រទេសនោះទេ។

បើតាមលោក ថារ៉ូ បច្ចុប្បន្ននេះមានពលករខ្មែរនៅប្រទេសថៃប្រមាណ៤០០នាក់ ហើយបានឆ្លងកូវីដ-១៩។ ក្រៅពីពលករខ្មែរ កើតកូវីដ-១៩ នេះ ក៏មានពលករខ្មែរ៣០នាក់បានស្លាប់ ដោយសារគ្រោះថ្នាក់ការងារ បើគិតពីដើមឆ្នាំ២០២១មក។ នេះជាការបញ្ជាក់របស់លោក ថារ៉ូ។

ជាមួយគ្នានេះលោក កែ វណ្ណថន អគ្គនាយករង និងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានប្រាប់សារព័ត៌មានថ្មីៗថា គិតត្រឹមថ្ងៃ២០ ធ្នូ ២០២០ ដល់ថ្ងៃទី១០ មិថុនា ២០២១នេះ ពលរដ្ឋខ្មែរត្រឡប់ពីថៃ មានជាង ៤.៤ម៉ឺននាក់។ ជាមួយគ្នានេះ អាជ្ញាធរថៃ ក៏បានបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ៤ពាន់នាក់ មកអាជ្ញាធរកម្ពុជាវិញដែរ។

## ពលករ៤០នាក់ ដែលព្យាយាមឆ្លងខុសច្បាប់ទៅថៃ ត្រូវបានឃាត់ខ្លួន

https://thmeythmey.com/ 28, Jun 2021 , 12:59 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ ពលករខ្មែរ៤០នាក់ បានព្យាយាមឆ្លងដែនខុសច្បាប់ តាមច្រកព្រំដែនបាត់ដំបង និងបន្ទាយមានជ័យ ដើម្បីស្វែងរកការងារធ្វើនៅថៃនោះ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន។ នេះបើតាមអគ្គនាយកដ្ឋាននគរបាលជាតិ។ កម្លាំងសមត្ថកិច្ចល្បាតតាមជួរព្រំដែន បានឃាត់ពលករខ្មែរ៣២នាក់ ដែលបម្រុងលួចឆ្លងដែនខុសច្បាប់ តាមក្រុងប៉ោយប៉ែត និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៥មិថុនា។ ក្នុងចំណោមពួកគេទាំង៣២នាក់ មាន ២៧នាក់ ត្រូវសមត្ថកិច្ចអប់រំណែនាំ និងបញ្ជូនទៅធ្វើចត្តាឡីស័ក ខណៈមនុស្ស៥នាក់ទៀត កំពុងស្ថិតក្នុងការសាកសួរ ដើម្បីស្រាវជ្រាវរកមេខ្យល់ រួមទាំងចាត់វិធានការតាមច្បាប់។

ដោយឡែកពលករ៨រូបទៀត ដែលព្យាយាមឆ្លងដែនខុសច្បាប់ទៅធ្វើការនៅថៃ តាមច្រកព្រំដែនស្រុកសំពៅលូន ក៏ត្រូវសមត្ថកិច្ចព្រំដែនខេត្តបាត់ដំបងឃាត់ខ្លួន និងអប់រំដែរ ។ បច្ចុប្បន្ននៅតាមព្រំដែន កម្លាំងសមត្ថកិច្ចបានពង្រឹងការល្បាតតាមបន្ទាត់ព្រំដែនទាំងយប់និងថ្ងៃ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ ពិសេសគឺទប់ស្កាត់ការរាលដាលកូវីដ-១៩ចូលសហគមន៍។ គិតត្រឹមថ្ងៃ២០ធ្នូ ២០២០ ដល់ថ្ងៃទី១០មិថុនា ២០២១នេះ ពលរដ្ឋខ្មែរត្រឡប់ពីថៃ មានជាង៤.៤ម៉ឺននាក់។ ជាមួយគ្នានេះ អាជ្ញាធរថៃ ក៏បានបញ្ជូនពលករខ្មែរឆ្លងដែនខុសច្បាប់ ៤ពាន់នាក់ មកអាជ្ញាធរកម្ពុជាវិញដែរ។ នេះបើតាមលោក កែ វណ្ណថន អគ្គនាយករង និងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលផ្តល់របាយការណ៍ឱ្យសារព័ត៌មានថ្មីៗ៕

## ពលករចំនួន ៦នាក់ បម្រុងឆ្លងដែនខុសច្បាប់ ត្រូវបានឃាត់ខ្លួន ដោយកម្លាំងតំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ

https://cen-news.com/ Posted ByPen Srey Neat June 30, 2021

ខេត្តបន្ទាយមានជ័យ ៖ ពលករបម្រុងឆ្លងដែនទៅប្រទេសថៃ ចំនួន ៦នាក់ ក្នុងនោះស្រី ២នាក់ ត្រូវបានឃាត់ខ្លួនដោយកម្លាំង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ នៅវេលាម៉ោង ៤:០០នាទីព្រឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ត្រង់ភូមិសាស្ត្រ អូរព្រំដែន ភូមិភ្នំ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ក្រោមបញ្ជាផ្ទាល់

របស់លោក ឧត្តមសេនីយ៍ ត្រី ជឹម ប៊ុនអាន មេបញ្ជាការចាត់តាំង លោក វរសេនីយ៍ឯក រិទ្ធ រ៉ម មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងបន្ទាយមានជ័យ ទទួលទិសម៉ាឡៃ ដឹកនាំកម្លាំងល្បាតជាប់ជាប្រចាំ ដោយអនុវត្តតាមបទបញ្ជាមេបញ្ជាការ លោកបានដឹកនាំកម្លាំងល្បាត២៤ម៉ោងលើ២៤ម៉ោង ដោយប្តូរវេនគ្នា សហការជាមួយកម្លាំង កម្លាំងផ្នែកសឹករងម៉ាឡៃ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ និងទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ មិនឲ្យចូលទៅក្នុងសហគមន៍។ ជាក់ស្តែង ព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លោកអនុសេនីយ៍ត្រី ឡា ប៊ុនហឿង មេក្រុមគោលដៅ ដឹកនាំកម្លាំងដើរល្បាតក៏ជួប ពលករដែលបម្រុងឆ្លងដែនចេញទៅប្រទេសថៃ ត្រូវបានកម្លាំង យើងឃាត់ខ្លួនបានតែម្តង ។

សូមបញ្ជាក់ថា ចាប់តាំងពីកងកម្លាំង តំបន់ប្រតិបត្តិការសឹករងខេត្ត ត្រូវបានបញ្ជូនទៅបំពេញប្រតិបត្តិការសហការជាមួយកម្លាំងចម្រុះ ទប់ស្កាត់ពលករលួចឆ្លងដែន និងទប់ស្កាត់ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ បានឃាត់ខ្លួនពលករឆ្លងដែនបញ្ជូនទៅមណ្ឌលចត្តាឡីស័កជាបន្តបន្ទាប់ និងឃាត់ខ្លួនមេខ្យល់បានមួយចំនួនបញ្ជូនទៅសមត្ថកិច្ចជំនាញចាត់វិធានការតាមផ្លូវច្បាប់ ។ ចំណែកពលករទាំង ៦នាក់ ក្រោយពីបានសួរនាំរួច ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កចំនួន១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កស្រុកម៉ាឡៃនិងបន្តស្រាវជ្រាវរកមេខ្យល់ទៀត៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ខេត្តជាប់ព្រំដែនចាប់ផ្តើមពង្រីកមណ្ឌលចត្តាឡីស័កបន្ថែម សម្រាប់ដាក់ពលករខ្មែរមកពីថៃ

https://www.kampucheathmey.com/ ថ្ងៃពុធ ៣០ មិថុនា ២០២១ដោយ Kang Tola

នៅជាប់ព្រំដែនកម្ពុជាថៃ បានចាប់ផ្តើមរៀបចំពង្រីកមណ្ឌលចត្តាឡីស័កឲ្យបានច្រើនថែមទៀតសម្រាប់ត្រៀមដាក់ពលករខ្មែរដែលវិលត្រឡប់មកពីថៃមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ក្នុងនោះអាជ្ញាធរខេត្តបាត់ដំបងក៏បានធ្វើការណែនាំដល់ក្រុងស្រុកនីមួយៗត្រូវរៀបចំមណ្ឌលចត្តាឡីស័ក ដែលអាចដាក់បានមនុស្សពី៥០០ទៅ១ពាន់នាក់ សម្រាប់ត្រៀមដាក់ពលករខ្មែរមកពីប្រទេសថៃ ខណៈបច្ចុប្បន្ននៅតាមស្រុកក្រុងអាចដាក់បានតែ១០០ទៅ២០០នាក់ប៉ុណ្ណោះ។

លោក សៀម ប៊ុនរឿ្ធី អភិបាលរងខេត្តបាត់ដំបង បានមានប្រសាសន៍នៅថ្ងៃទី៣០ មិថុនានេះថា បច្ចុប្បន្ននៅខេត្តបាត់ដំបងមានអ្នកកំពុងធ្វើចត្តាឡីស័កនៅក្នុងមណ្ឌលទាំង១៩កន្លែង ប្រមាណជាង២២០០នាក់ ក្នុងនោះមានពលករខ្មែរឆ្លងដែនមកពីប្រទេសថៃជាង២ពាន់នាក់ និងអ្នកជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈជាង២០០នាក់។ លោកអភិបាលរងខេត្តបានបន្តថា អាជ្ញាធរបានយកពលករខ្មែរ និងអ្នកជាប់ពាក់ព័ន្ធសហគមន៍ដាក់ដាច់ដោយឡែកពីគ្នារួចហើយដើម្បីបង្ការការឆ្លងរាលដាលជំងឺបំប្លែងខ្លួនថ្មីដែលតានៅក្នុងមណ្ឌលចត្តាឡីស័ក។ លោកអភិបាលរងខេត្តបានបន្តទៀតថា រដ្ឋបាលខេត្តបាននឹងកំពុងរៀបចំផែនការឱ្យតាមបណ្តាស្រុកក្រុងទាំងអស់រៀបចំមណ្ឌលចត្តាឡីស័កដែលអាចដាក់មនុស្សបានចាប់ពី៥០០នាក់ដល់១០០០ពាន់ហើយនៅទូទាំងខេត្តឲ្យបានពី៨០០០នាក់ទៅ១ម៉ឺននាក់ ដើម្បីត្រៀមបង្ការពេលមានពលករខ្មែរសម្រុកមកពីថៃច្រើនខណៈបច្ចុប្បន្ននៅតាមស្រុកក្រុងអាចដាក់បានតែ១០០ ទៅ២០០នាក់ ប៉ុណ្ណោះទៅតាមស្រុកក្រុងធំតូច។ លោកអភិបាលរងខេត្តបានបន្ថែមថា «យើងបានណែនាំដល់ក្រុងស្រុកនីមួយៗធ្វើយ៉ាងណារកទីតាំងដូចជាសាលារៀនអីហ្នឹងសម្រាប់ត្រៀមរៀបចំជាមណ្ឌលចត្តាឡីស័កអាចដាក់មនុស្សបានយ៉ាងហោចណាស់ពី៥០០នាក់ ទៅជិត១ពាន់នាក់ក្នុងស្រុកក្រុងនីមយៗដើម្បីត្រៀមបង្ការពេលមានពលករខ្មែរសម្រុកមកពីថៃច្រើន»។

ការរៀបចំផែនការធ្វើមណ្ឌលចត្តាឡីស័កបន្ថែមនេះ បានធ្វើឡើងបន្ទាប់ពីរដ្ឋាភិបាលតម្រូវឱ្យខេត្តជាប់ព្រំដែនកម្ពុជា ថៃរៀបចំមណ្ឌលចត្តាឡីស័កដាច់ដោយឡែកសម្រាប់ដាក់ពលករខ្មែរមកពីថៃដើម្បីទប់ស្កាត់ការឆ្លងរាល

ដាលនៃមេរោគកូវីដ១៩បំប្លែងខ្លួនថ្មីប្រភេទ Delta ចូលក្នុងសហគមន៍ខណៈមានពលករខ្មែរធ្វើដំណើរមកពីប្រទេសថៃ ត្រូវបានរកឃើញមេរោគបំប្លែងខ្លួនថ្មីនេះជាច្រើនករណី។

លោក អគ្គបណ្ឌិតសភាចារ្យ អូនព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មការប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនិងជំងឺកូវីដ១៩ បានណែនាំដល់អាជ្ញាធរខេត្តជាប់ព្រំដែនកម្ពុជាថៃឲ្យរៀបចំជាបន្ទាន់មណ្ឌលចត្តាឡីស័កបន្ថែមនៅតាមមាត់ច្រកព្រំដែនកម្ពុជាថៃជាពិសេសសម្រាប់ខេត្តដែលពុំទាន់មានកន្លែងធ្វើចត្តាឡីស័កគ្រប់គ្រាន់សម្រាប់ដាក់ឱ្យដាច់ដោយឡែកពីគ្នា រវាងអ្នកដំណើរឆ្លងដែនចូលមកកម្ពុជាតាមព្រំដែននានា ពិសេសពលករខ្មែរមកពីប្រទេសថៃ និងអ្នកជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ ២០២១ដើម្បីបង្ការការចម្លងជាយថាហេតុនៃមេរោគបម្លែងខ្លួនថ្មីនេះ នៅក្នុងមណ្ឌលចត្តាឡីស័ក។ ជាមួយគ្នានេះដែរ លោកអគ្គបណ្ឌិតសភាចារ្យ អូនព័ន្ធមុនីរ័ត្ន បានណែនាំឱ្យអាជ្ញាធរធ្វើការសហការជាមួយខេត្តជាប់ព្រំដែនកម្ពុជាថៃ ដើម្បីពង្រឹងការគ្រប់គ្រងរំហូរចូលនៃប្រជាជននិងពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃចូលមកកម្ពុជានិងដើម្បីជៀសវាងការលួចចូលឆ្លងដែនដោយខុសច្បាប់។

គួរបញ្ជាក់ថា រហូតមកដល់ពេលនេះកម្ពុជាមានអ្នកឆ្លងមេរោគកូវីដ១៩បំប្លែងខ្លួនថ្មីប្រភេទ Delta ចំនួន ២២ករណីដែលជាអ្នកដំណើរឆ្លងដែនមកពីប្រទេសថៃ៕ *ដោយ ៖ សំអឿន*

## ស្ថានទូតខ្មែរនៅថៃ អំពាវដល់ពលករខ្មែរកុំបារម្ភ និងកុំចល័ត ព្រោះវិធានបិទខ្ទប់បង្ការជំងឺកូវីដ ១៩ របស់អាជ្ញាធរថៃ

https://m.postkhmer.com/ ឡុង គីមម៉ារីតា29 June 2021 | 17:16 ICT

**ភ្នំពេញៈ** ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានអំពាវនាវដល់ពលករខ្មែរដែលកំពុងស្នាក់នៅក្នុងប្រទេសថៃ ជាពិសេសតំបន់ដែលមានហានិភ័យខ្ពស់ កុំឲ្យមានការមានភ័យខ្លាច និងធ្វើការចល័តទីតាំងក្នុងអំឡុងពេលដែលរដ្ឋាភិបាលថៃ ដាក់ចេញវិធានការបណ្ដោះអាសន្នតាមការដ្ឋានសំណង់ក្នុងទៅក្រុងបាងកក និងខេត្តមួយចំនួន។ ការអំពាវនាវនេះ បានធ្វើឡើងបន្ទាប់ពីមានពលករខ្មែរដែលធ្វើការក្នុងវិស័យសំណង់នៅប្រទេសថៃ បានសម្រុកវិលត្រឡប់ចូលមកប្រទេសវិញតាមច្រកព្រំដែនអូរស្មាច់ ច្រកអូរបីជាន់ ច្រកព្រំដែនបឹងត្រកួន និងច្រករបៀងតូចៗផ្សេងទៀតជាប់ខេត្តសុរិន្ទរបស់ថៃ។

ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានបង្ហោះលើហ្វេសបុករបស់ស្ថានទូតថា សេចក្ដីសម្រេចស្ដីពីការគ្រប់គ្រងជំងឺកូវីដ ១៩ ក្នុងតំបន់ដែលមានហានិភ័យខ្ពស់ដោយរដ្ឋាភិបាលថៃ បានសម្រេចបិទខ្ទប់ការដ្ឋានសំណង់ និងកន្លែងស្នាក់នៅ កម្មករ សំណង់រយៈពេល ៣០ ថ្ងៃ និងហាមមិនឲ្យចល័តកម្មករផងដែរ។ អនុលោមតាមវិធានការតឹងរ៉ឹងនេះ គឺត្រូវបានអនុវត្តនៅក្នុងទីក្រុងបាងកក ខេត្តណាក់ខនប៉ាក់ធុម ខេត្តនុនបុរី ខេត្តប៉ាក់ធុមថានី ខេត្តសមុទ្រប្រាកាន ខេត្តសាមុទ្រសាខន ខេត្តណារ៉ាត់ធីវ៉ាត់ ខេត្តប៉ាត់តានី ខេត្តយ៉ាក់ឡា និងខេត្តស៊ុងក្លា។

ឆ្លើយតបជាមួយវិធានការថ្មីនេះ ស្ថានទូតកម្ពុជាបានអះអាងថា នឹងបន្តសហការជាមួយបណ្ដាស្ថាប័នដែលពាក់ព័ន្ធរបស់ថៃ ដើម្បីតាមដានអន្តរាគមន៍ជួយដោះស្រាយ និងសម្រាលការលំបាករបស់បងប្អូនក្នុងពេលមានវិបត្តិនេះ ដោយស្នើសុំដល់បងប្អូនពលករកុំមានការភ័យខ្លាច និងកុំចល័តដោយសារតែការអនុវត្តវិធានការបណ្ដោះអាសន្នតាមការដ្ឋានសំណង់ ដើម្បីទប់ស្កាត់ជំងឺកូវីដ ១៩ នេះ។ ស្ថានទូតកម្ពុជា បានអះអាងថា៖ «ស្ថានទូតកម្ពុជាសូមថ្លែងអំណរគុណដល់បងប្អូនពលករខ្មែរទាំងអស់ ដែលបានចូលរួមអនុវត្ត និងសហការជាមួយរាជរដ្ឋាភិបាលថៃក្នុងការទប់ស្កាត់ និងការពារការរីករាលដាលជំងឺកូវីដ ១៩ អស់រយៈពេលជាង ១ ឆ្នាំកន្លងមក។ រាជរដ្ឋាភិបាលថៃបានយកចិត្តទុកដាក់ថែទាំ និងព្យាបាលពលករគ្រប់គ្នា។ ចំពោះពលរកដែលមិនមានឯកសារគ្រប់គ្រាន់ ភាគីថៃ នឹងពុំយកទោសពៃរ៍ ហើយថែមទាំងរៀបចំឲ្យក្លាយជាពលករស្របច្បាប់»។

លោក លឹង សុផុន ក្រុមការងារនៃអង្គការសង់ត្រាល់ប្រចាំប្រទេសថៃ បានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២៨ មិថុនាថា ដោយសារតែការរីករាលដាលជំងឺកូវីដ ១៩ នៅក្នុងប្រទេសថៃ កាន់តែច្រើនទៅៗ ដូច្នេះ ពលករខ្មែរ មានការព្រួយបារម្ភ និងភ័យខ្លាចខ្លាំង។ ដោយសារតែមូលហេតុបែបនេះ លោកសង្កេតឃើញថា ពលករខ្មែរ បានសម្រុកត្រឡប់ទៅកម្ពុជាវិញ ច្រើនជាងសព្វដង ខណៈដែលការប្រកាសបិទរបស់រដ្ឋាភិបាលថៃ គឺបិទការដ្ឋានសំណង់ដែលសម្បូរទៅដោយពលករខ្មែររស់នៅ។ លោកបានបញ្ជាក់ថា៖ «ពាក់ព័ន្ធនឹងវិធានការរបស់ថៃ ដែលបានប្រកាសឲ្យពលករដែលមិនមានឯកសារត្រឹមត្រូវក្តី មិនមានវិសារក្តី សូមឲ្យមានការធ្វើដំណើរឆ្លងកាត់ និងធ្វើដំណើរត្រឡប់ទៅខ្មែរនេះ គឺពលករខ្លះ មិនបានទទួលដំណឹងទាំងនេះនោះទេ។ យើងដឹងស្រាប់ហើយ ចាប់តាំងពីផ្ទុះនេះមក គឺមានពលករជាច្រើន បានចល័តទី និងផ្លាស់ប្តូរកន្លែងស្នាក់នៅរួចទៅហើយ»។

លោកបានបន្ថែមទៀតថា៖ «ពេលខ្លះ ការប្រកាសរបស់រដ្ឋាភិបាលថៃបែបនេះ តែជាក់ស្តែង ពលរកខ្មែរយើង ដែលគ្មានឯកសារនេះ នៅក្នុងតំបន់ខ្លះអី ត្រូវបានប៉ូលីសថៃ ចាប់ផាកពិន័យ បើទោះមានសេចក្តីប្រកាសរបស់រដ្ឋាភិបាលថៃបែបនេះក៏ដោយ។ ដូច្នេះពលករ គាត់ភ័យថា បើពួកគាត់ ឆ្លងកូវីដ ហើយមិនមានឯកសារ តើនឹងទទួលបានការព្យាបាល ឬយ៉ាងណា?»។ លោក លឹម សុផុន ថ្លែងថា ក្នុងរយៈពេលចុងក្រោយនេះ គឺមានពលករខ្មែរជាច្រើនរួចទៅហើយ បានឆ្លងជំងឺកូវីដ ១៩ នៅក្នុងប្រទេសនេះ ដែលជាហេតុនាំឲ្យពលករខ្មែរដទៃទៀតមានការបារម្ភ និងភ័យខ្លាច ខណៈស្ថានភាពឆ្លងជំងឺកូវីដ ១៩ នៅប្រទេសថៃ បានផ្ទុះឡើងជាថ្មី ដោយក្នុងមួយថ្ងៃៗមានអ្នកឆ្លងជំងឺកូវីដ ១៩ ដល់ទៅជាង ៥ ០០០ នាក់ ចំណែកចំនួនអ្នកស្លាប់ក៏មានច្រើនផងដែរ។

អ្នកស្រី គៀង ម៉ៅ អាយុជាង ៤០ ឆ្នាំ ដែលកំពុងធ្វើការនៅការដ្ឋានសំណង់មួយកន្លែងនៅខេត្តសមុទ្រប្រាកាន និងមានកម្មករខ្មែរជាង ៣០០ នាក់ កំពុងធ្វើការទីនោះ បានប្រាប់ ភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី ២៩ មិថុនាថា អ្នកស្រី និងកម្មករដទៃទៀត មិនត្រូវបានឲ្យកម្មករចេញពីការដ្ឋាននោះទេ។ អ្នកស្រីបន្តថា ជាមួយនឹងវិធានការថ្មីនេះ គឺកម្មករខ្មែរភាគច្រើន បានចូលរួមអនុវត្តតាម ប៉ុន្តែក៏មានការព្រួយបារម្ភពីបញ្ហាសុខភាពផងដែរ ខណៈក្នុងពេលនេះកម្មករ គឺមិនទាន់ទទួលបានព័ត៌មានច្បាស់លាស់នោះទេ។ អ្នកស្រីបានរៀបរាប់ថា៖«ថៅកែគេមិនបានប្រាប់អ្វីច្រើននោះទេ គឺគេគ្រាន់តែឲ្យស្នាក់នៅហ្នឹងកន្លែង ហើយផុត ១ ខែហ្នឹង បានមានការងារធ្វើវិញ ហើយរឿងប្រាក់ខែ ឬប្រាក់ឧបត្ថម្ភអីនោះ មិនទាន់ទទួលបានដំណឹងអ្វីច្បាស់ទេ។ នៅពេលនេះ យើងមិនសូវអីទេ គ្រាន់តែតទៅមុខទៅបារម្ភដែរ ព្រោះមិនដឹងយ៉ាងណា កំពុងតែដេកគិតដែរ»។ អ្នកស្រី គៀង ម៉ៅ ថ្លែងថា នៅក្នុងខេត្តសមុទ្រប្រាកាន គឺមិនទាន់ទទួលបានព័ត៌មានថា មានពលករខ្មែរឆ្លងជំងឺកូវីដ ១៩ នេះនៅឡើយទេ ខណៈនៅខេត្តជិតៗនោះ គឺមានពលករខ្មែរ បានឆ្លងរួចទៅហើយ ដោយអ្នកស្រី រំពឹងថា ពលរកខ្មែរ នឹងទទួលបានការយកចិត្តទុកដាក់ នៅពេលឆ្លងជំងឺកូវីដ ១៩ នេះ៕

## ទាហានថៃ ចាប់ពលករខ្មែរ ២គោលដៅផ្សេងគ្នា សរុប១៤នាក់

https://cen-news.com/ Posted ByPen Srey Neat June 30, 2021

បន្ទាយមានជ័យ៖ ទោះបីជាមានការរឹតបន្តឹង តាមបន្ទាត់ព្រំដែនយ៉ាងណា ក៏នៅតែមានពលករខ្មែរ លួចឆ្លងដែនខុសច្បាប់ ក្រោយឃាត់ខ្លួននិយាយថា ពួកគេក្នុងម្នាក់ចំណាយប្រាក់ ឲ្យមេខ្យល់ចំនួន៧.០០០បាត ខណៈដែលទាហានថៃបានចាប់២គោលដៅផ្សេងគ្នា វេលាម៉ោង១០ និង១៩នាទីព្រឹក ថ្ងៃទី២៩ ខែមិថុនា ២០២១។ សមត្ថកិច្ចថៃតាមព្រំដែនប្រាប់ថា កម្លាំងនគបាលល្បាតព្រំដែនទី១២ និងសមត្ថកិច្ចទាហានក្រុមតាប្រាយ៉ា កងកម្លាំងបូផា សហការគ្នាចាប់ឃាត់ខ្លួនពលករខ្មែរ ចំនួន៥នាក់ ក្នុងនោះប្រុស៣នាក់ និងស្រី២នាក់ នៅបរិវេណភូមិទព័សៀម ឃុំតាប្រាយ៉ា ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ បន្ទាប់ពីឃាត់ខ្លួនសមត្ថកិច្ចនាំខ្លួនយកទៅសួរនាំបន្ថែម។ នៅពេលសួរនាំពលករទាំងនោះ បានប្រាប់ថា រកការងារធ្វើ ទើបបបួលគ្នា ធ្វើដំណើរចាកចេញ ពីខេត្តបន្ទាយមានជ័យ៕ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

# ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១

## សម្តេចស ខេង ណែនាំឱ្យខិតខំជំរុញការនុវត្តគោលនយោបាយ ភូមិឃុំសង្កាត់មានសុវត្ថិភាពទាំង៧ចំណុច

https://cen-news.com/ Posted ByPen Srey NeatJuly 1, 2021

កំពង់ឆ្នាំង ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានណែនាំឱ្យខិតខំជំរុញការនុវត្តគោលនយោបាយ ភូមិឃុំសង្កាត់មានសុវត្ថិភាពទាំង៧ចំណុច រួមមានផ្តល់សេវាសាធារណៈជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងប្រកបដោយការជឿទុកចិត្ត, គ្មានបទល្មើសលួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ, មានសណ្តាប់ធ្នាប់សាធារណៈល្អ ពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍, គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង, ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព, មានអនាម័យមានសោភណ្ឌភាពល្អ និងចុងក្រោយ គឺឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតប្រកបដោយប្រសិទ្ធភាព។

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី០១ ខែកក្កដា ឆ្នាំ២០២១ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងឯកឧត្តម ស៊ុន សុវណ្ណារិទ្ធិ ជាអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំងជំនួសឯកឧត្តម ឈរ ច័ន្ទឿន និងប្រកាសចូលកាន់មុខតំណែងលោក ណី ចារី ជាអភិបាលរងនៃគណនៈភិបាលខេត្តកំពង់ឆ្នាំង។ សម្តេចក្រឡាហោម ស ខេង ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា និងក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ បានសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះរដ្ឋបាលគ្រប់ថ្នាក់នៃខេត្តកំពង់ឆ្នាំង ក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្តកំពង់ឆ្នាំ មន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋក្នុងខេត្តកំពង់ឆ្នាំង ដែលបានរួមសហការគ្នាយ៉ាងសកម្មក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ព្រមទាំងសម្រេចបានសមិទ្ធផលជាច្រើន ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្នុងខេត្តកំពង់ឆ្នាំង។ សម្តេចបានបន្តថាការយកចិត្តទុកដាក់រួមគ្នាជាមួយមន្ទីរជំនាញនានាលើការលើកកម្ពស់គុណភាពសេវាសាធារណៈនានា អាជ្ញាធរខេត្តកំពង់ឆ្នាំងក៏បានខិតខំស្វែងយល់ និងដោះស្រាយបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋ ពិសេសបយកចិត្តទុកដាក់ចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងការបង្ការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩។ សម្តេចក៏បានថ្លែងអំណរគុណ និងកោតសរសើរជូនចំពោះសម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ព្រមទាំងសហការីទាំងអស់ និងក្រុមការងារគណបក្សប្រជាជនកម្ពុជា ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការសង្គម ប្រកបដោយការទទួលខុសត្រូវដើម្បីរួមចំណែកលើកស្ទួយជីវភាពប្រជាពលរដ្ឋ។

សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា ផ្អែកលើលក្ខណៈសម្បត្តិ សមត្ថភាព និងបទពិសោធន៍របស់ឯកឧត្តម ស៊ុន សុវណ្ណារិទ្ធិ ដែលជាមន្ត្រីបានទទួលការអប់រំខ្ពស់ពីសាលាភូមិន្ទរដ្ឋបាល និងមានបទពិសោធន៍ក្នុងការដឹកនាំ និងគ្រប់គ្រងមូលដ្ឋានក្នុងតំណែងជាអភិបាលរងខេត្តកំពង់ឆ្នាំងក្នុងរយៈពេលប្រមាណ៨ឆ្នាំមកនេះ រាជរដ្ឋាភិបាលបានទូលថ្វាយព្រះមហាក្សត្រតែងតាំងឯកឧត្តមជាអភិបាលខេត្តកំពង់ឆ្នាំងជំនួសឯកឧត្តម ឈួរ ច័ន្ទឿន និងបានសម្រេចផ្ទេរភារកិច្ចលោក ណី ចារី ដែលបញ្ចប់អាណត្តិជាអភិបាលរងខេត្តកណ្តាលឱ្យមកទទួលតំណែងជាអភិបាលរងខេត្តកំពង់ឆ្នាំង។ សម្តេចបានបន្ថែមថា រាល់ការសម្រេចចិត្តសុទ្ធតែផ្អែកលើទិដ្ឋភាពច្បាប់ជាធំ ពោលគឺមិនមែនជាការសម្រេចតាមការស្រមើស្រមៃ ឬនឹកឃើញចេះតែលើកដាក់នរណាម្នាក់ឱ្យធ្វើនោះទេ ពីព្រោះកិច្ចការនេះទាក់ទងនឹងជោគវាសនាប្រទេសជាតិ ជោគវាសនាប្រជាពលរដ្ឋ ដោយមិនអាចយកមនោស

ញ្ចេទនាណាមួយមកលាយឡំនឹងផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាពលរដ្ឋបានឡើយ ហើយថាប្រសិនបើធ្វើដូច្នេះមែន រាជរដ្ឋាភិបាលមិនមែនអាចគ្រប់ប្រទេសប្រកបដោយសេចក្ដីសុខ និងរីកចំរើនដូចសព្វថ្ងៃនេះទេ។

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានផ្ដល់អនុសាសន៍ឱ្យរដ្ឋបាលខេត្តបន្តថែរក្សា និងពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ដើម្បីបង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវពង្រឹងការគ្រប់គ្រងសភាពការណ៍តាមមូលដ្ឋាន ដើម្បីដាក់ចេញវិធានការទប់ស្កាត់ឱ្យបានទាន់ពេលវេលានូវសកម្មភាព ការផ្សព្វផ្សាយព័ត៌មានមិនពិត និងភាពចលាចល ពិសេសកម្មភាពប៉ុនប៉ងផ្ដួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។ សម្ដេចបានណែនាំឱ្យអាជ្ញាធរយកចិត្តទុកដាក់អប់រំប្រជាពលរដ្ឋឱ្យចូលរួមគោរពច្បាប់ ការពារផលប្រយោជន៍សាធារណៈ ផលប្រយោជន៍សហគមន៍ និងចៀសវាងការចូលរួមក្នុងសកម្មភាពផ្ទុយពីច្បាប់ដែលធ្វើឱ្យប៉ះពាល់សន្តិសភាព និងស្ថិរភាពនយោបាយ ព្រមទាំងយកចិត្តទុកដាក់ដោះស្រាយជម្លោះនៅមូលដ្ឋានឱ្យបានល្អ ដោយចៀសវាងឱ្យបាននូវការប្រើប្រាស់អំពើហិង្សាគ្រប់រូបភាព។

សម្ដេចបានទាញចំណាប់អារម្មណ៍ថានៅឆ្នាំក្រោយ គឺជាឆ្នាំនៃព្រឹត្តិការណ៍បោះឆ្នោត ដែលអ្នកនយោបាយផ្សេងៗអាចយកបញ្ហាប្រឈម និងទំនាស់នានាក្នុងមូលដ្ឋានធ្វើក្នុងបំណងទាញប្រជាប្រិយ៍ភាព ដូច្នេះអាជ្ញាធរសមត្ថកិច្ចទាំងអស់ ត្រូវតែយកចិត្តទុកដាក់ពីឥលូវទៅ ដើម្បីគ្រប់គ្រងសភាពការណ៍ ហើយដោះស្រាយបញ្ហាប្រជាពលរដ្ឋឱ្យបានល្អ ដោយមិនត្រូវមានទស្សនៈខុសឆ្គងថាបញ្ហាទាំងនោះ គឺដោយសារមានពួកប្រឆាំង ឬដោយសារបញ្ហានេះ បញ្ហានោះឡើយ ពោលគឺសំខាន់ត្រូវមើលខ្លួនឯង ថាតើមានបញ្ហាមែនដែរទេ មានប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ប្រជាពលរដ្ឋឬទេ ហើយបើមានត្រូវដោះស្រាយភ្លាម។

ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន សម្ដេចបានផ្ដល់ទស្សនទានក្នុងន័យដើមថា «ការជួញដូរ ការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បាននិងកំពុងបង្កឱ្យមានបញ្ហាប្រឈមជាច្រើនក្នុងសង្គមដែលត្រូវដោះស្រាយក្នុងរយៈពេលចំពោះមុខ និងរយៈពេលយូរអង្វែង ហេតុនេះត្រូវខិតខំពុះពារជម្នះប្រកបដោយឆន្ទៈនយោបាយ និងការប្ដេជ្ញាចិត្តឱ្យបានមុតមាំដើម្បីអនុវត្តវិធានការនានាក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ដោយចាត់ទុកយុទ្ធនាការនេះជាផ្នែកមួយនៃការលើកកម្ពស់យុត្តិធម៌សង្គម, ជាផ្នែកមួយនៃការប្រយុទ្ធប្រឆាំងនឹងបទល្មើសសម្អាតប្រាក់ និងការរីកសាយអាវុធមហាប្រល័យ, ជាផ្នែកមួយនៃការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម និងឧក្រិដ្ឋកម្មគ្រប់ប្រភេទ, ជាផ្នែកមួយនៃការកាត់ផ្ដាច់ទំនាក់ទំនងរបស់ក្រុមសង្គមងងឹតពីខាងក្រៅ និងមកខាងក្នុងប្រទេស និងទប់ស្កាត់ការកើតក្រុមសង្គមងងឹតក្នុងប្រទេស, ជាផ្នែកមួយនៃការលើកកម្ពស់សុខភាពនិងសុខមាលភាពប្រជាពលរដ្ឋដែលជាធនធានដ៏មានតម្លៃសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាពរយៈពេលយូរអង្វែងតទៅមុខទៀត ជាពិសេសយុវជន, ជាផ្នែកមួយនៃការធ្វើមានបរិយាកាសសុខសន្តិភាព ស្ថេរភាព និងសណ្ដាប់សាធារណៈ, ជាផ្នែកមួយនៃការបង្កើនភាពកក់ក្ដៅ និងភាពសុខដុមរមនានៅក្នុងក្រុមគ្រួសារ ប្រជាពលរដ្ឋក្នុងសង្គម និងជាផ្នែកមួយនៃការចូលរួមធនធានសង្គមដូចជាថវិកាជាតិ និងទ្រព្យសម្បត្តិប្រជាពលរដ្ឋ»។

សម្ដេចក្រឡាហោម ក៏បានណែនាំឱ្យរដ្ឋបាលខេត្តបន្តចូលរួមឱ្យបានសកម្ម និងប្រកបដោយប្រសិទ្ធភាពក្នុងការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងបានណែនាំឱ្យបន្តប្រឹងប្រែងក្នុងការងារផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អ តាមរយៈការយកចិត្តទុកដាក់កិច្ចការសំខាន់ៗ រួមមានបន្តជំរុញ និងលើកកម្ពស់ការគ្រប់គ្រងចាត់ចែង ការនុវត្តមុខងារនានាដែលបានប្រគល់ឱ្យ ពង្រឹងសេវាច្រកចេញចូលតែមួយ ការធ្វើវេទិកាសាធារណៈព្រមទាំងបានផ្ដល់ការណែនាំពាក់ព័ន្ធនឹងការដឹកនាំ និងការគ្រប់ការងារនៅក្នុងរដ្ឋបាលខេត្ត ពិសេសទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល និងកិច្ចសហការជាមួយក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន និងបានគូស

បញ្ជាក់អំពីកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិរយៈពេល១០ឆ្នាំ និងការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលស្រុក ព្រមការរៀបចំកម្មវិធីជាតិដំណាក់កាលទី២រយៈពេល១០ឆ្នាំបន្តទៀត ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## បុរស ៤ នាក់ នាំពលករទៅធ្វើការនៅថៃ ត្រូវតុលាការចោទប្រកាន់ និងបញ្ជូនទៅឃុំខ្លួន

https://www.postkhmer.com/national/ គឹម សារុំ | Publication date 30 June 2021 | 16:26 ICT

**បន្ទាយមានជ័យ:** បុរសចំនួន ១០ នាក់ ដែលនាំពលករទៅធ្វើការនៅថៃ ត្រូវបានចៅក្រមស៊ើបសួរ សម្រេចចោទប្រកាន់ពីបទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ហើយត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារនៅព្រឹកថ្ងៃទី ២៩ មិថុនា ៣ ថ្ងៃបន្ទាប់ពីចាប់ខ្លួន នៅក្រុងប៉ោយប៉ែត ខណៈបុរសជាពលករចំនួន ៥ នាក់ (ជនជាតិថៃម្នាក់) ត្រូវបានសមត្ថកិច្ចបញ្ជូនទៅមណ្ឌលចត្តាឡីស័ក។

លោក សំរិទ្ធ សុខុន ព្រះរាជអាជ្ញារង និងជាអ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យប្រាប់ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២៩ មិថុនាថា បុរសត្រូវចោទចំនួន ១០ នាក់ ត្រូវបានចៅក្រមស៊ើបសួរលោក ឃ្លោក ពិសិដ្ឋ សម្រេចចេញដីកាឃុំខ្លួន នៅពន្ធនាគារខេត្តបន្ទាយមានជ័យនៅថ្ងៃទី ២៩ មិថុនា។ ការឃុំខ្លួនជនត្រូវចោទទាំង ១០ នាក់នេះ គឺធ្វើឡើងបន្ទាប់ពីតំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យធ្វើការសាកសួរពេញ ១ថ្ងៃទី ២៨ មិថុនា។ លោក សុខុន ថ្លែងថា៖ «ជនត្រូវចោទទាំង ១០ នាក់ត្រូវបានតំណាងអយ្យការចោទពីបទការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនតាមមាត្រា ១១ នៃច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។ បទចោទតាមមាត្រា ១១ នៃច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ បើតុលាការរកឃើញថាពួកគេពិតជាមានទោសតាមបទចោទមែននោះត្រូវប្រឈមនឹងការផ្តន្ទាទោសជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។

ជុំវិញការឃាត់ខ្លួនមេខ្យល់នេះ នៅថ្ងៃទី ២៩ មិថុនា ភ្នំពេញ ប៉ុស្តិ៍ បានទាក់ទងលោកស្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនតាមទូរស័ព្ទដើម្បីសាកសួរព័ត៌មានបន្ថែម តែលោកស្រីប្រាប់ថា ជាប់ប្រជុំ។ ប៉ុន្តែលោកស្រី ឌី សុជាតិ ប្រាប់គេហទំព័ររបស់អគ្គស្នងការនគរបាលជាតិដែលបានចេញផ្សាយនៅថ្ងៃទី ២៨ មិថុនាថា ជនសង្ស័យទាំង ១០ នាក់ និងម៉ូតូ ៥ គ្រឿងត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនលេខ ៩១១ បានធ្វើការឃាត់ខ្លួនក្នុង ២ ករណីផ្សេងគ្នាតែនៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២១ ក្នុងថ្ងៃតែ ១។ ការឃាត់ខ្លួនមេខ្យល់ទាំង ១០ នាក់នេះ គឺបន្ទាប់ពីកម្លាំងនគរបាល វរសេនាតូច ការពារព្រំដែនលេខ ៩១១ ឈរជើងនៅក្រុងប៉ោយប៉ែត បានធ្វើការស្រាវជ្រាវរហូតឃាត់បានក្រុមជនសង្ស័យជាបន្តបន្ទាប់ក្នុងភូមិសាស្ត្រ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ បន្ទាប់មកនគរបាលវរសេនាតូច ការពារព្រំដែនលេខ ៩១១ បានប្រគល់ក្រុមជនសង្ស័យបន្តមកឱ្យការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

បើតាមលោកស្រី សុជាតិ បញ្ជាក់ថា ទន្ទឹមនឹងការឃាត់បានក្រុមមេខ្យល់ ១០ នាក់ហើយនោះ កម្លាំងសមត្ថកិច្ចក៏បានបន្ទទប់ស្កាត់បុរសជាពលករខ្មែរបានចំនួន ៤ នាក់ និងបុរសជនជាតិថៃម្នាក់ផង។ ពលករទាំង ៥ នាក់នេះគឺក្រុមជនសង្ស័យបម្រុងលួចនាំឆ្លងដែនចូលទៅប្រទេសថៃកាលពីថ្ងៃទី ២៨ មិថុនា។ ចំពោះបុរសជាពលករទាំង ៥ នាក់ (ជនជាតិថៃម្នាក់) ត្រូវបានសមត្ថកិច្ចឱ្យធ្វើកិច្ចសន្យា និងអប់រំ ហើយនឹងត្រូវអនុញ្ញាតឱ្យពួកគេវិលទៅផ្ទះវិញ ក្រោយពីពួកគេធ្វើចត្តាឡីស័ករួច។ រីឯបុរសជនជាតិថៃម្នាក់នឹងត្រូវប្រគល់ទៅឱ្យអាជ្ញាធរថៃ បន្ទាប់ពីបានធ្វើចត្តាឡីស័ក៕

## អង្គការសម្ព័ន្ធចាប់ដៃ៖ អំពើជួញដូរមនុស្សកើនឡើងទ្វេដងក្នុងអំឡុងពេលកូវីដ

https://kleykley.sabay.com.kh/ ម៉ោង 09:43 02/07/2021

អំពើជួញដូរមនុស្សកើនឡើងទ្វេដងក្នុងអំឡុងពេលកូវីដ១៩ ទោះបីជាប្រទេសកម្ពុជាបានបិទព្រំដែនរបស់ខ្លួន ដើម្បីការពារការឆ្លងរីករាលដាលនៃកូវីដ១៩ ក៏ដោយក៏ចំនួននៃអំពើជួញដូរមនុស្ស ជាពិសេសនារីវ័យក្មេងដែលមានអាយុចន្លោះពី ១៥-២៥ ឆ្នាំ មានការកើនឡើងទ្វេដងគួរអោយកត់សម្គាល់។ នារីរងគ្រោះទាំងនោះ ភាគច្រើនមកពីតាមបណ្តាទីជនបទនៃខេត្តមួយចំនួននៃប្រទេសកម្ពុជា ដោយមេខ្យល់បាននាំពួកគេ ធ្វើដំណើរឆ្លងដែនខុសច្បាប់ ទៅកាន់ប្រទេសជិតខាង។

ប្រធានកម្មយុត្តិធម៌កុមារ នៃអង្គការសម្ព័ន្ធចាប់ដៃ លោក ចាន់ សារ៉ុន បានថ្លែងនៅក្នុងបទសម្ភាសន៍ផ្ទាល់មុខជាមួយ A24 ថា ចំនួននារីវ័យក្មេង ដែលត្រូវបានគេជួញដូរក្រោមរូបភាពរៀបការទៅបរទេស បានកើនឡើងទ្វេដងនៅក្នុងត្រីមាសទី ១ ឆ្នាំ ២០២១ បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។ លោកបន្ថែមថាមេខ្យល់របស់នារីវ័យក្មេងទាំងនោះ សន្យាផ្តល់ការងារដល់ពួកគេ សន្យាថាពួកគេនឹងមានលុយកាក់ច្រើន និងសន្យានាំពួកគេអោយបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសអ្នកមាននៅឯបរទេស។ លោក ចាន់ សារ៉ុន បានចង្អុលបង្ហាញថា ដំបូងនារីវ័យក្មេងទាំងនោះត្រូវបានមេខ្យល់នាំ ឆ្លងកាត់ព្រំដែនកម្ពុជា - វៀតណាម ដោយខុសច្បាប់ទៅទីក្រុងហាណូយ ហើយបន្តពីទីនោះពួកគេត្រូវបានដឹកទៅកាន់ប្រទេសចិន។ នៅពេលពួកគេទៅដល់ប្រទេសចិន បុរសដែលរៀបការជាមួយនារីវ័យក្មេងនោះ ភាគច្រើនជាមនុស្សដែលមានអាយុច្រើនជាងនាងឆ្ងាយ ជាជនពិការ និងជាជនដែលក្រីក្រ។ បន្ទាប់ពីរៀបការ ពេលខ្លះនារីវ័យក្មេងទាំងនោះ ត្រូវបានគេចាក់សោឃុំនៅក្នុងបន្ទប់ និងរំលោភបំពានផ្លូវភេទពីក្រុមគ្រួសារខាងប្តី ខណៈដែលនារី រងគ្រោះផ្សេងទៀតត្រូវបានបង្ខំ ឱ្យធ្វើការនៅក្នុងរោងចក្រដើម្បីរកប្រាក់ផ្គត់ផ្គង់គ្រួសារខាងប្តីដែលជាជនជាតិចិន។

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៣នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៣នាក់ ស្រី ៧នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់ ( គ្មានរបាយការណ៍មក)។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៥នាក់ ស្រីចំនួន ៣នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៣នាក់ ស្រី ៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## សមត្ថកិច្ចមូលដ្ឋានត្រូវបង្កើនការគ្រប់គ្រងពលរដ្ឋមកពីថៃឱ្យមានប្រសិទ្ធភាពខ្ពស់

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១ កក្កដា ២០២១ដោយ KC Virak

ភ្នំពេញ៖ អគ្គស្នងការនគរបាលជាតិបានណែនាំទៅដល់កងកម្លាំងមន្ត្រីពាក់ព័ន្ធទាំងអស់ ត្រូវបង្កើនការគ្រប់គ្រងប្រជាពលរដ្ឋចំណូលស្រុកមកពីប្រទេសជិតខាង ពិសេសប្រទេសថៃ និងវៀតណាម ដើម្បីកាត់ផ្តាច់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បំប្លែងថ្មីចូលមកនៅក្នុងប្រទេសកម្ពុជា។

ការណែនាំ របស់ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ នេះធ្វើឡើងនៅក្នុងកិច្ចប្រជុំពីចម្ងាយ ស្តីពីការបូកសរុបសភាពការណ៍ និងលទ្ធផលកិច្ចប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ព្រមទាំងលទ្ធផលអនុវត្តផែនការសកម្មភាពឆមាសទី១ និងលើកទិសដៅអនុវត្តឆមាសទី២ ឆ្នាំ ២០២១។ ជាមួយគ្នានេះដែរ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានស្នើទៅដល់ កម្លាំងនគរបាលព្រំដែន ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាពទប់ស្កាត់មិនឱ្យបទល្មើសឆ្លងដែនចេញ-ចូលខុសច្បាប់ និងត្រូវសហការជាមួយគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្រ ដើម្បីគ្រប់គ្រងពលរដ្ឋដែលឆ្លងដែនចូលកម្ពុជាវិញឱ្យបានហ្មត់ចត់។ ទន្ទឹមនេះត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះសុខភាពរបស់កងកម្លាំងការពារព្រំដែន ដោយខិតខំឱ្យអស់ពីលទ្ធភាពក្នុងការអនុវត្តវិធានសុខាភិបាល និងការធ្វើតេស្តឆាប់រហ័ស (Rapid Test) ក្នុងករណីមានអាការៈសង្ស័យ។

នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន បានបន្តទៀតថា សមត្ថកិច្ចត្រូវធ្វើជាសេនាធិការជូនគណៈកម្មការប្រឆាំងជំងឺកូវីដ-១៩ នៅគ្រប់ថ្នាក់ ពិសេសនគរបាលប៉ុស្តិ៍រដ្ឋបាលត្រូវពង្រឹងការគ្រប់គ្រងប្រជាពលរដ្ឋក្នុងស្ថានភាពកូវីដ-១៩ ដោយអនុវត្តវិធានការរដ្ឋបាល និងផាកពិន័យយ៉ាងម៉ឺងម៉ាត់ចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងវិធានសុខាភិបាល ក៏ដូចជាបទកំណត់នានាជាធរមាន សំដៅកាត់ផ្តាច់ការឆ្លងរាតត្បាតជំងឺកូវីដ-១៩។ នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន ក៏បានណែនាំទៅដល់មន្ត្រីពាក់ព័ន្ធទាំងអស់ ត្រូវត្រៀមកម្លាំងអន្តរាគមន៍នៅគ្រប់ថ្នាក់ ពិសេសស្នងការដ្ឋាននគរបាលរាជធានី-ខេត្តត្រូវត្រៀមកម្លាំងជួយអធិការដ្ឋាន ថ្នាក់អធិការដ្ឋានត្រូវត្រៀមជួយដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលនៅពេលមានការចាំបាច់ផងដែរ។

ក្នុងការទប់ស្កាត់ជំងឺកូវីដ-១៩ បំប្លែងថ្មីនេះដែរ គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលហៅកាត់ថា (គ.ប.ក) បានដាក់ចេញនូវវិធានការមួយចំនួនដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ បំប្លែងខ្លួនថ្មីប្រភេទ Delta ចូលក្នុងសហគមន៍តាមរយៈអ្នកដំណើរឆ្លងដែនចូលមកកម្ពុជាតាមព្រំដែននានា ពិសេសពលករខ្មែរមកពីប្រទេសថៃ។ ក្នុងនោះអនុញ្ញាតឱ្យធ្វើតេស្តរហ័សទៅលើអ្នកដឹកជញ្ជូនទំនិញដែលឆ្លងកាត់ព្រំដែនរៀងរាល់៧២ម៉ោងម្តង និងធ្វើតេស្តរហ័សប្រចាំខែដល់កងកម្លាំងដែលឈរជើងនៅតាមមាត់ច្រកព្រំដែនផងដែរ៕ ៖ សំអឿន

## សង្គមស៊ីវិលស្នើឱ្យរកមេខ្លោងដែលនាំពលករចំណាកស្រុកខុសច្បាប់ ដើម្បីលុបបំបាត់ការជួញដូរមនុស្ស

https://vodkhmer.news/ លោក ណាត សុភាព ២៩ មិថុនា ២០២១ម៉ោង ១៦:៣១

មន្ត្រីសង្គមស៊ីវិលបានជំរុញទៅរដ្ឋាភិបាលជាថ្មីទៀត ឱ្យធ្វើការស្រាវជ្រាវ និងដឹកឫសគល់អ្នកពាក់ព័ន្ធករណីនាំពលករចំណាកស្រុកដោយខុសច្បាប់ ជាពិសេសមេខ្លោងធំៗ និងមន្ត្រីនៅតាមច្រកព្រំដែន ដែលគប់គិតគ្នាលើ

បញ្ហានេះ ដើម្បីឈានទៅលុបបំបាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលករខ្មែរបន្តទៀត។ ការជំរុញនេះធ្វើឡើងបន្ទាប់ពីស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ទទួលផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនមេខ្យល់ចំនួន១០នាក់ទៅសាលាដំបូងខេត្ត កាលពីថ្ងៃទី២៨ ខែមិថុនា ដើម្បីចាត់វិធានការបន្តតាមច្បាប់ ខណៈពលករចំនួន៥នាក់ត្រូវតម្រូវឱ្យធ្វើកិច្ចសន្យាអប់រំ រួចអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ។ ចំណែកឯជនជាតិថៃម្នាក់ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅវិទ្យាល័យនិមិត្ត មុននឹងមានចំណាត់ការបន្ត។

អ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ លោក សំរិទ្ធ សុខុន ប្រាប់ វីអូឌី នៅថ្ងៃអង្គារនេះថា មេខ្យល់ចំនួន១០នាក់ដែលបញ្ជូនមកតុលាការកាលពីម្សិលមិញនេះ ត្រូវបានអាជ្ញាធរឃាត់ខ្លួនកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១។ លោកបន្តទៀតថា ក្រោយពីបញ្ជូនមកតុលាការ នៅថ្ងៃទី២៩ ខែមិថុនានេះ ចៅក្រមស៊ើបសួរបានសម្រេចចោទប្រកាន់មេខ្យល់ចំនួន១០នាក់ដែលស៊ីឈ្នួលនាំពលករចំណាកស្រុកទៅប្រទេសថៃ ពីបទ «**នាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន**» និងឃុំខ្លួនពួកគេជាបណ្តោះអាសន្ននៅពន្ធនាគារខេត្ត។ លោកមានប្រសាសន៍ថា៖ «**ចៅក្រមស៊ើបគេសម្រេចចោទប្រកាន់រួចហើយ គេកំពុងរៀបចំបញ្ជូនទៅពន្ធនាគារ បញ្ជូនទៅឥលូវហ្នឹង គេសម្រេចឃុំខ្លួនហើយ**»។

មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា កាលពីពេលថ្មីៗនេះ ជាពិសេសក្រោយពីរដ្ឋាភិបាលបញ្ជាឱ្យមន្ត្រីក្រោមឱវាទធ្វើការស្រាវជ្រាវនិងចាប់មេខ្យល់ដែលនាំពលករចំណាកស្រុកទៅក្រៅប្រទេស ជាពិសេសប្រទេសថៃ នាអំឡុងពេលឆ្លងរាលដាលនៃជំងឺកូវីដ-១៩នេះ គឺមានមេខ្យល់ជាច្រើនត្រូវបានចាប់ខ្លួន។ តែយ៉ាងណា លោក ថេហូយ៉ា សង្កេតឃើញថា កន្លងមក អាជ្ញាធរចាប់បានតែមេខ្យល់តូចតាចតែប៉ុណ្ណោះ ខណៈអ្នកនៅពីក្រោយខ្នងមេខ្យល់តូចតាចទាំងនោះមិនត្រូវបានចាប់ខ្លួននៅឡើយ។ ករណីនេះ លោកជំរុញទៅស្ថាប័នពាក់ព័ន្ធត្រូវស្រាវជ្រាវរកមន្ត្រីខិលខូចដែលគប់គិតជាមួយមេខ្យល់នាំពលរដ្ឋឆ្លងដែនខុសច្បាប់ទៅក្រៅប្រទេស យកមកផ្តន្ទាទោស ទើបអាចទប់ស្កាត់បញ្ហានេះមានប្រសិទ្ធភាព។ លោកអំពាវនាវដូច្នេះថា៖ «**ការជួញដូរមិនមែនមានតែមេខ្យល់តូចតាចទេ វាអាចមានពាក់ព័ន្ធនឹងអ្នកមានអំណាច ជាពិសេសមន្ត្រីខាងព្រំដែន ជាពិសេសអ្នកពាក់ព័ន្ធផ្សេងៗ។ ហើយដើម្បីឱ្យវាមានប្រសិទ្ធភាព វាទាល់តែចាប់ត្រីធំ កុំចាប់ត្រីតូច ហើយចាត់វិធានការឱ្យមានប្រសិទ្ធភាព**»។ មន្ត្រីសង្គមស៊ីវិលរូបនេះបញ្ជាក់ថា ដើមចមដែលនាំឱ្យពលករនាំគ្នាចំណាកស្រុកទៅតាមមេខ្យល់ទាំងប្រថុយប្រថាននឹងគ្រោះថ្នាក់ ដោយសារពួកគេជួបវិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារ និងបញ្ហាលំបាករកការងារធ្វើនៅក្នុងស្រុកនិងប្រាក់ខែមិនបានច្រើន ជាដើម។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកស្រី ជូ ប៊ុនអេង មានប្រសាសន៍ថា ក្រសួងមិនលើកទឹកចិត្តដល់អាជ្ញាធរពាក់ព័ន្ធដែលគប់គិតជាមួយមេខ្យល់នាំពលករខ្មែរលួចឆ្លងដែនខុសច្បាប់ទៅធ្វើការនៅក្រៅប្រទេស ជាពិសេសប្រទេសថៃនោះទេ ព្រោះនាំឱ្យពលរដ្ឋខ្មែរជួបបញ្ហាប្រឈមនានា។ យ៉ាងនេះក្តី លោកស្រី ជូ ប៊ុនអេង អះអាងថា អាជ្ញាធរជំនាញកំពុងសហការគ្នាស្រាវជ្រាវរកអ្នកពាក់ព័ន្ធជាមួយមេខ្យល់ទាំងនោះ ដើម្បីចាត់វិធានការច្បាប់ផងដែរ ដោយមិនបណ្តែតបណ្តោយឱ្យរឿងនេះកើតឡើងបន្តទៀតនោះទេ។ លោកស្រីមានប្រសាសន៍ថា៖ «**បើនិយាយពីមន្ត្រីគប់គិត បើសិនជាសង្គមស៊ីវិលបានដឹងថាជានរណា សូមរាយការណ៍មក! យើងនឹងធ្វើការងារហ្នឹងជាមួយគ្នា ព្រោះយើងមិនបានគប់គិត ដើម្បីឱ្យរឿងហ្នឹងកើតឡើងដោយមិនបានដោះស្រាយទេ។ យើងអត់មានទុកឱ្យអ្នកដែលធ្វើការងារហ្នឹងចេះតែនៅបន្តទេ**»។

មាត្រា១១ នៃច្បាប់ស្តីពី «ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ» ចែងថា ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ក្នុងគោលដៅប្រគល់ឬនាំយកទៅក្រៅប្រទេសកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ឆ្នាំ ដល់១៥ឆ្នាំ។ បើការនាំយកជនរងគ្រោះជាអនីតិជន ដោយមានក្រុមចាត់តាំង ឬប្រព្រឹត្តដោយមន្ត្រីសាធារណៈដែលបំពានអំណាចរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ឆ្នាំ ទៅ២០ឆ្នាំ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង កាលពីថ្ងៃទី៩ ខែមិថុនា បានណែនាំជាថ្មីទៀតទៅអាជ្ញាធរជាប់ព្រំដែនឱ្យពង្រឹងវិធានការអនុវត្តច្បាប់បង្ក្រាបការនាំមនុស្សឆ្លងដែនខុសច្បាប់ ដើម្បីទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ប្រភេទថ្មីចូលកម្ពុជា។ ក្រោយមានការណែនាំនេះ អាជ្ញាធរតាមខេត្តមួយចំនួន ជាពិសេសខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានបង្ក្រាបមេខ្យល់និងកសាងសំណុំរឿងបញ្ជូនទៅតុលាការជាបន្តបន្ទាប់។

បើតាមមន្ត្រីជាន់ខ្ពស់នៃអង្គការសង់ត្រាល់ លោក ថេហ្វយ៉ា បានឱ្យដឹងថា អំឡុងពេលវិបត្តិកូវីដ-១៩ផ្ទុះឡើង មានពលករខ្មែរជាង២ ០០០នាក់ហើយត្រូវបានចាប់ខ្លួន ខណៈពួកគេកំពុងធ្វើដំណើរដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។ លោកថា ក្នុងការឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ពលករខ្មែរម្នាក់ៗត្រូវបង់ប្រាក់ចំនួន៣ ០០០បាត ឬស្មើជាង១០០ដុល្លារទៅឱ្យមេខ្យល់។

តាមរបាយការណ៍អង្គការសង់ត្រាល់ ឱ្យដឹងថា បច្ចុប្បន្ន ពលករខ្មែរដែលធ្វើការងារទាំងស្របច្បាប់និងមិនស្របច្បាប់នៅប្រទេសថៃ មានចំនួនជាង១លាន៨សែននាក់៕

## តំណាងពលករ ដាក់ញត្តិស្នើសុំគណៈរដ្ឋមន្ត្រី និងសភាថៃ ជួយដោះស្រាយវិបត្តិអត់អាហារ និងសេវាព្យាបាលកូវីដ១៩

https://www.rfa.org/khmer/news/ ដោយ ជាតិ ចំណាន 2021-06-30

តំណាងពលករខ្មែរប្រមាណ ២០នាក់ នាំគ្នាដាក់ញត្តិ និងថ្លែងសារ នៅមុខអគារគណៈរដ្ឋមន្ត្រីថៃ និងរដ្ឋសភាថៃ នៅទីក្រុងបាងកកនៅព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដើម្បីស្នើសុំអាជ្ញាធរប្រទេសនេះឱ្យជួយដោះស្រាយបញ្ហាពលករ ដែលកំពុងអត់អាហារ និងមិនទទួលបានសេវាព្យាបាលជំងឺកូវីដ១៩ (Covid-19) សមរម្យ។ អាជ្ញាធរថៃបានចេញមកទទួលញត្តិពីពលករ និងសន្យានាំរឿងនេះដាក់ជូនប្រធានស្ថាប័នរបស់ខ្លួន។ តំណាងពលករខ្មែរមួយក្រុមមានគ្នាប្រមាណ ២០នាក់ បាននាំគ្នាថ្លែងសារម្នាក់ម្តង នៅមុខអគារគណៈរដ្ឋមន្ត្រីថៃ និងរដ្ឋសភាថៃ នៅទីក្រុងបាងកកនៅព្រឹកថ្ងៃទី៣០ មិថុនា ទាមទារឲ្យអាជ្ញាធរថៃ ជួយដល់ពលករខ្មែរ ខណៈថៅកែមួយចំនួនអះអាងថាគ្មានលទ្ធភាពជួយពួកគេនោះទេ។

តំណាងពលរដ្ឋម្នាក់ លោកស្រី សេង ស្រីទូច ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី៣០ មិថុនាថា ការទាមទារនេះ ក្នុងគោលបំណងឲ្យអាជ្ញាធរថៃគិតគូរពីពលករខ្មែរ ព្រោះពួកគាត់កំពុងប្រឈមវិបត្តិធ្ងន់ធ្ងរ ទាំងគ្មានអាហារបរិភោគ និងមិនទទួលបានសេវាព្យាបាលជំងឺកូវីដ១៩ សមរម្យ ស្របពេលដែលស្ថានភាពជំងឺកូវីដ១៩ នៅប្រទេសថៃ កាន់តែរាលដាលខ្លាំងឡើង។ បន្ថែមពីនេះ រដ្ឋាភិបាលដាក់បម្រាមបិទខ្ទប់ការដ្ឋានសំណង់នៅទីក្រុងបាងកក និងខេត្តទាំង៥ ជុំវិញបណ្តាលឲ្យពលករជាច្រើននាក់អត់ការងារធ្វើ។ តំណាងពលកររូបនេះ បន្តថា ពលករខ្មែរភាគច្រើនជាប់នៅក្នុងកន្លែងបិទខ្ទប់ និងខ្លះទៀតកំពុងដេកព្យាបាលជំងឺកូ វីដ១៩ដោយខ្លួនឯងនៅតាមកន្លែងធ្វើការនិងបន្ទប់ជួលដោយមិនសូវទទួលបានការយកចិត្តទុកដាក់ពីរដ្ឋ និងថៅកែជនជាតិថៃនោះទេ។

ក្រៅពីនេះពួកគេទាមទារឲ្យអាជ្ញាធរជួយអន្តរាគមន៍បញ្ហាមួយចំនួនទៀតដូចជា ករណីជនឆបោកឆ្លៀតឱកាសក្នុងគ្រាអាសន្ននេះ បោកប្រាក់ពលករ ដើម្បីបន្តប័ណ្ណសុពលភាពការងារកម្មករឬហៅថា ប័ណ្ណស៊ីជម្ពូ។ ចំណែកកម្មករខ្លះទៀតអត់មានលទ្ធភាពធ្វើដំណើរត្រឡប់ទៅប្រទេសកម្ពុជាវិញ ជាដើម៖ «រកជំនួយឲ្យជួយពួកគាត់។ ជួយដោះស្រាយគាត់យ៉ាងម្តេចព្រោះគាត់អត់មានប្រាក់ធ្វើប័ណ្ណប្រកាន់សង្គមហ្នឹងគេ ព្រោះគេថាគេចែកតែអ្នកដែលមានប្រកាន់សង្គម។ អ្នកដែលអត់មានប្រកាន់សង្គម អ្នកដែលអត់មានឯកសារគ្រប់គ្រាន់ហ្នឹង គេអត់ចែកឲ្យទេ។ អ៊ីចឹងអ្នកដែលអត់មានឯកសារគ្រប់គ្រាន់ហ្នឹងគឺគាត់ពិបាក»។

ក្នុងការដាក់ញត្តិនេះ អាជ្ញាធរថៃមិនបានរារាំង រុញច្រាន វាយបង្ក្រាប ឬស្រែកជេរប្រមាថក្រុមអ្នកតវ៉ាឬក៏ចាប់ខ្លួនតំណាងពលករខ្មែរនោះទេ បើទោះជាពួកគេបាននាំគ្នាលើកបដាវាយស្គរ និងស្រែកទាមទារតាមឧបករណ៍បំពងសំឡេង

ស័ព្ទទាំងភាសាខ្មែរនិងភាសាថៃក្តី។ មន្ត្រីប្រចាំនៅគណៈរដ្ឋមន្ត្រីថៃ និងរដ្ឋសភាថៃ បានចេញមកទទួលញត្តិពីពលករ និងសន្យាដាក់ជូនប្រធានស្ថាប័នរបស់ពួកគេ។ តំណាងពលករទាំងនោះមិនបានស្វែងរកអន្តរាគមន៍ពីតំណាងស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃទេ ព្រោះពួកគេគ្មានជំនឿលើមន្ត្រីស្ថានទូត។ លោកស្រី សេង ស្រីទូច មិនជឿថាមន្ត្រីស្ថានទូតខ្មែរមិនដឹងថាពលករកំពុងជួបវិបត្តិទាំងអស់នេះទេ។ តំណាងពលករដដែល ក៏សោកស្ដាយចំពោះស្ថានទូត ដែលមិនបានជួយសម្រួលដល់ការធ្វើដំណើរពីកន្លែងធ្វើការត្រឡប់ទៅកម្ពុជាវិញ ដោយបណ្ដោយឲ្យកម្មកររកមធ្យោបាយធ្វើដំណើរដោយខ្លួនឯង។

អាស៊ីសេរីមិនអាចសុំការបញ្ជាក់ពីឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ លោក អ៊ុក សោភ័ណ្ឌ បានទេនៅថ្ងៃទី៣០ មិថុនា។ តែយ៉ាងណាហ្វេសប៊ុក (Facebook) របស់ស្ថានទូតបានបង្ហាញការចែកអំណោយដល់ពលករបានមួយចំនួនដែរ។

មន្ត្រីផ្នែកអន្តោប្រវេសន៍ប្រចាំប្រទេសថៃនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់អង្គការសង់ត្រាល់ (CENTRAL) លោក លឹង សុផុន ឲ្យដឹងថា ស្ថានភាពពលករនៅទីក្រុងបាងកក និងខេត្តទាំង៥ជុំវិញទីក្រុងពិតជាកំពុងជួបវិបត្តិធ្ងន់ធ្ងរ និងប្រឈមការឆ្លងជំងឺកូវីដ១៩ មែន ដោយសារការឆ្លងរាលដាលជំងឺកាចសាហាវនេះធ្ងន់ធ្ងរ។ លោកឲ្យដឹងថា ពលករខ្មែរជាច្រើននាក់កំពុងឆ្លងជំងឺកូវីដ១៩។ ក្នុងនោះពលករដែលមានប័ណ្ណការងារស្របច្បាប់ទទួលបានការយកចិត្តទុកដាក់ផ្នែកសុខាភិបាល តែពលករដែលមិនមានប័ណ្ណការងារមិនសូវទទួលបានការយកចិត្តទុកដាក់ទេ។ លោកបន្តថា ទន្ទឹមនឹងនេះ មានពលករខ្មែររាប់រយនាក់សម្រុកត្រឡប់ទៅកម្ពុជាវិញដែរក្នុងរយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ៖ «គេសន្យាថានឹងតវីសា និងធ្វើប័ណ្ណស៊ីជម្ពូឲ្យ។ តែមកដល់ពេលនេះ អត់ឃើញមានតវីសាអ្វីទេ ហើយអត់ទាន់មានធ្វើប័ណ្ណស៊ីជម្ពូផង ឥឡូវបញ្ឈប់ពួកគាត់។ បញ្ឈប់ដោយអត់មានប្រាប់មុន ឬក៏អត់មានទឹកប្រាក់សំណងអ្វី ដូចថាត្រូវតែបើកលុយឲ្យប៉ុណ្ណេះៗ ក៏អត់ទាន់ឃើញមានដែរ។ ពីរ បីថ្ងៃនេះ ឃើញបងប្អូនពលករយើងជ្រួលច្របល់មែនទែនរឿងហ្នឹងណា»។

ចាប់តាំងពីរដ្ឋាភិបាលថៃប្រកាសបិទខ្ទប់ការដ្ឋានសំណង់ និងរឹតបន្តឹងវិធានការទប់ស្កាត់ជំងឺកូវីដ១៩ នៅទីក្រុងបាងកក និងខេត្តទាំង ៥មក ពលករបានសម្រុកចេញទៅកម្ពុជាវិញប្រហែល ៣០០នាក់ ក្នុងមួយថ្ងៃ។

របាយការណ៍របស់អគ្គនាយកដ្ឋានអន្តោប្រវេសន្តបង្ហាញថា គិតចាប់ពីខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី១០ មិថុនា ឆ្នាំ២០២១ មានពលករត្រឡប់ពីថៃ ជាងបួនម៉ឺន (៤៤.០០០) នាក់។ ជាមួយគ្នានេះ មានពលករខ្មែរឆ្លងដែនខុសច្បាប់ប្រមាណ ៤.០០០នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនមកកម្ពុជាវិញ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលរដ្ឋខ្មែរមកពីប្រទេសថៃ១នាក់ នៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 7:48 pm 1 កក្កដា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប្រចាំ ស្ដីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និង មេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃព្រហស្បតិ៍ ៧ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទៅទទួលប្រជាពលរដ្ឋដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញត្រង់

ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូនចំនួន១នាក់ប្រុស ។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួចកម្លាំងបានប្រគល់បងប្អូនឱ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កបន្ត ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៧នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៧នាក់ ស្រី ៩នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៧នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២០នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់ ( គ្មានរបាយការណ៍មក)។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៧នាក់ ស្រី ៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១

## សម្តេចតេជោនៅតែបញ្ជាក់ថាទោះបីជាកម្ពុជាក្រ តែកម្ពុជាមិនទុកឱ្យប្រជាពលរដ្ឋរបស់ខ្លួនដែលវិលត្រឡប់ពីប្រទេសថៃ ខ្វះការយកចិត្តទុកដាក់ឡើយ

https://business.khmernote.com.kh/ July 2, 2021 Khmernote

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាឱ្យដឹងថា បើទោះបីជាកម្ពុជាក្រ តែកម្ពុជាមិនទុកឱ្យប្រជាពលរដ្ឋរបស់ខ្លួនដែលវិលត្រឡប់ពីប្រទេសថៃ ខ្វះការយកចិត្តទុកដាក់ឡើយ ដើម្បីធ្វើយ៉ាងណា បង្ការ ការពារ ទប់ស្កាត់ ការរាតត្បាតជំងឺឆ្លងកូវីដ១៩ប្រភេទថ្មី និងធានាបានសុវត្ថិភាពជូនប្រជាពលរដ្ឋ។ នេះបើយោងតាមការចុះផ្សាយរបស់ក្រសួងព័ត៌មាន។ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅតែអះអាងថា រាជរដ្ឋាភិបាលកម្ពុជាមិនមែនជារដ្ឋក្សៀយធនទេ រាជរដ្ឋាភិបាលកម្ពុជាបានសន្សំថវិកាប្រមាណ ៣ពាន់លានដុល្លារអាមេរិក ដើម្បីប្រើប្រាស់ក្នុងវិស័យសង្គម និងទប់ស្កាត់ការរីករាតត្បាតជំងឺកូវីដ១៩។

ថ្លែងក្នុងកិច្ចប្រជុំ និងថ្លែងសារពិសេសដោះស្រាយបញ្ហាជំងឺកូវីដ-១៩ ដែលកំពុងរីករាលដាលនៅក្នុងប្រទេសកម្ពុជា តាមប្រព័ន្ធវីដេអូ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ សម្តេចតេជោបានមានប្រសាសន៍ថា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ និងជំងឺកូវីដ១៩ បំប្លែងថ្មី នៅតាមខ្សែបន្ទាត់ព្រំដែន ពិសេសព្រំដែនកម្ពុជា ថៃ គឺត្រូវពង្រឹងវិធានការចត្តាឡីស័ក ត្រូវធ្វើចត្តាឡីស័កគ្រប់ថ្ងៃ ហើយការធ្វើ ចត្តាឡីស័កត្រូវធ្វើតេស្តរហ័ស ហើយបើមានការសង្ស័យត្រូវធ្វើតេស្តម៉ាស៊ីនធំ បន្ទាប់មក រថយន្តយោធានឹងដឹកជញ្ជូន ទៅកាន់មណ្ឌល ចត្តាឡីស័ក។ សម្តេចតេជោ បានណែនាំដល់ អនុគណៈកម្មការសាងសង់ និងជួសជុលត្រូវចូលរួមជាមួយរដ្ឋបាលខេត្តតាមព្រំដែន ដោយពិនិត្យមើល តើខ្វះខាតអ្វីទៀត ហើយបញ្ចេញថវិកាជាតិត្រូវធ្វើអ្វីបន្ថែម ដូចជាទិញគ្រែឬ ប្រដាប់ធ្វើចត្តាឡីស័កសម្រាប់ផ្គត់ផ្គង់ ដល់ពលករកម្ពុជា ដែលត្រឡប់មកពីប្រទេសថៃ វិញ។

សំឡេង៖ «ការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ពង្រឹងនិងផ្គត់ផ្គង់មណ្ឌលចត្តាឡីស័កឱ្យបានគ្រប់គ្រាន់ពិសេសនៅតាមច្រកព្រំដែនថៃ ។ ខេត្តនៅព្រំដែនថៃគឺជាខេត្តដែលមានពលករច្រើនអ៊ីចឹងត្រូវពិនិត្យ អនុគណៈកម្មការសាងសង់និងជួសជុលដែលមានឧត្តមសេនីយ ខេង សុមេធ ជាប្រធាន ដើរពិនិត្យមើលគ្រែខ្វះខាតត្រូវបំពាក់ ខែនេះចាប់ផ្តើមភ្លៀងធ្លាក់ហើយ ការពារបងប្អូនយើងឱ្យបាន ។ បើទោះបីជាកម្ពុជាក្រ តែកម្ពុជាមិនត្រូវទុកឱ្យប្រជាពលរដ្ឋរបស់ខ្លួនដែលវិលត្រឡប់ពីប្រទេសថៃ ដោយខ្វះការយកចិត្តទុកដាក់ ប្រដាប់ប្រដាប្រើប្រាស់ត្រូវផ្គត់ផ្គង់ឱ្យជាមុង ភួយ កន្ទេល សម្ភារ និងការហូបចុក៣ពេល មិនឱ្យខ្វះខាតឡើយ៕

## យោធាថៃ ប្រគល់ពលករខ្មែរ ឆ្លងដែនខុសច្បាប់ ១០ នាក់ មកឲ្យសមត្ថកិច្ចកម្ពុជា

https://www.rasmeinews.com/ 2 July, 20210

*ដោយៈ គ្រញូង / ប៉ៃលិនៈ នៅព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១នេះ យោធាឈុតខ្មៅថៃ បានប្រគល់ ពលករខ្មែរ ១០ នាក់ អោយមកប៉ូលិសព្រំដែនកម្ពុជា ក្រោយពេលពលករខ្មែរទាំងនោះ បានលបលួច ឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ។ ការប្រគល់ពលករខ្មែរ ទាំង១០នាក់នេះ បានធ្វើឡើង នៅក្បែរច្រកទ្វារព្រំដែនអន្តរជាតិបានផាក់កាត និងច្រកទ្វារព្រំដែនអន្តរជាតិ ព្រំ ។*

ភាគីថៃ បានអះអាងថាៈ ពលករទាំងនេះ បានឆ្លងដែន ត្រង់ចំណុចលូដាច់ ក្នុងឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ហើយចូលទៅក្នុងទឹកដីថៃ ត្រង់ចំណុចភូមិ៤ ឃុំខ្លងយ៉ៃ ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី។ ទាហានឈុតខ្មៅថៃ បានបញ្ជាក់ថាៈ មុននឹងប្រគល់ពួកគេ មកអោយសមត្ថកិច្ចកម្ពុជាវិញ ទាហានថៃ បានត្រួតពិនិត្យកម្តៅព្រមទាំងបានផ្តល់បាយកញ្ចប់ ឱ្យពួកគេបរិភោគ ដោយភាគីថៃ បានផ្តោតទៅ លើការពង្រឹង តាមខ្សែបន្ទាត់ព្រំដែនរវាងភាគីទាំងពីរ នៅក្នុងដំណាក់កាល នៃការទប់ស្កាត់ ការឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩ រួមគ្នា៕/V

## កម្ពុជាបន្តជាប់ក្នុងបញ្ជីឃ្លាំមើលការជួញដូរមនុស្សរបស់អាមេរិក៣ឆ្នាំជាប់គ្នា

https://khmer.voanews.com/ 02 កក្កដា 2021 អូន ឆេងប៉រ

ភ្នំពេញ៖ ទោះបីមានការខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ តែការមិនបំពេញបាននូវមូលដ្ឋានអប្បបរមារបស់រដ្ឋាភិបាលកម្ពុជា បាននាំឱ្យស្ថានភាពនៃការជួញដូរមនុស្សនៅក្នុងប្រទេសបន្តមានសភាពមិនល្អប្រសើរ។ នេះបើយោងតាមក្រសួងការបរទេសសហរដ្ឋអាមេរិក។ កាលពីថ្ងៃព្រហស្បតិ៍ក្រសួងការបរទេសអាមេរិកបានចេញផ្សាយការអង្កេត និងវាយតម្លៃប្រចាំឆ្នាំរបស់ខ្លួននូវ «របាយការណ៍ស្តីពីការជួញដូរមនុស្សលើសាកលលោកឆ្នាំ២០២១» ដោយបានចាត់ថ្នាក់ប្រទេសកម្ពុជា ក្នុងកម្រិត Tier 2 Watchlist គឺកម្រិតពីរស្ថិតក្នុងបញ្ជីតាមដាន។

របាយការណ៍បានបន្ទោសលើកង្វះការត្រួតពិនិត្យ និងចាប់តម្រូវឱ្យមានគណនេយ្យភាពលើរដ្ឋាភិបាល អំពើពុករលួយជាធរមានកង្វះធន្ធនៈនយោបាយក្នុងការស្រាវជ្រាវតាមដាន វែកមុខ និងផ្តន្ទាទោសឧក្រិដ្ឋជនជួញដូរ

មនុស្ស និងកង្វះប្រព័ន្ធបង្ការបទល្មើសនិងគាំពារជនរងគ្រោះដែលនាំឱ្យកម្ពុជាបន្តជាប់ក្នុងកម្រិតពីរស្ថិតក្នុងបញ្ជីតាមដាននេះបីឆ្នាំជាប់គ្នាចាប់ពីឆ្នាំ២០១៩មក។ ក្នុងផ្នែកដែលនិយាយពីស្ថានភាពប្រទេសនីមួយៗ មានការបែងចែកលើ៣ទិដ្ឋភាពធំៗក្នុងរបាយការណ៍នោះ អំពីស្ថានភាពការជួញដូរមនុស្សរួមមានការផ្តន្ទាទោសឧក្រិដ្ឋជន ការផ្តល់សេវាគាំពារដល់ជនរងគ្រោះ និងយន្តការបង្ការទប់ស្កាត់ការប្រព្រឹត្តបទល្មើស។ លើទិដ្ឋភាពបង្ក្រាបផ្តន្ទាទោសឧក្រិដ្ឋជនជួញដូរមនុស្ស របាយការណ៍ក្រសួងការបរទេសអាមេរិកដែលចេញផ្សាយប្រចាំឆ្នាំបានលើកឡើងថាកម្ពុជាមិនបានស៊ើបអង្កេតឱ្យអស់ពីលទ្ធភាពក្នុងការរែកមុខយកឧក្រិដ្ឋជនមកកាត់ទោស ជាពិសេសក្នុងករណីដែលពាក់ព័ន្ធនឹងអំពើពុករលួយរបស់អាជ្ញាធរនិងការលួចឱ្យដំណឹងដល់ជនល្មើសមុនពេលមានប្រតិបត្តិការបង្ក្រាប។ នៅលើទិដ្ឋភាពគាំពារជនរងគ្រោះក្រសួងការបរទេសអាមេរិកបានលើកឡើងថា ក្រសួងពាក់ព័ន្ធរបស់កម្ពុជាតែងតែទម្លាក់បន្ទុកនៃការផ្តល់ប្រឹក្សាគាំទ្រ និងស្តារនីតិសម្បទាដល់ជនរងគ្រោះទៅលើក្រុមអង្គការសង្គមស៊ីវិលដែលធ្វើការជាដៃគូទៅវិញ។

ការវាយតម្លៃក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ប្រទេសមហាអំណាចមួយនេះស្តីអំពីការជួញដូរមនុស្ស ចែកចេញជា៤កម្រិត។ កម្រិតមួយបានសេចក្តីថា រដ្ឋាភិបាលម្ចាស់ស្រុកបំពេញគ្រប់លក្ខខណ្ឌនៃនិយាមអប្បបរមាអំពីការជួញដូរមនុស្សដូចមានចែងក្នុងច្បាប់ស្តីពីការការពារជនរងគ្រោះដោយការជួញដូររបស់អាមេរិកតាក់តែងកាលពីឆ្នាំ២០០០ (TVPA)។ កម្រិតពីរ(Tier 2) បានសេចក្តីថា រដ្ឋាភិបាលម្ចាស់ប្រទេសមិនទាន់បំពេញគ្រប់និយាមអប្បបរមាដូចមានចែងក្នុងTVPA តែបានធ្វើកិច្ចជាច្រើនគួរឱ្យកត់សម្គាល់ ដើម្បីអនុលោមតាមនិយាមទាំងនោះ។ កម្រិតពីរស្ថិតក្នុងបញ្ជីតាមដាន (Tier 2 Watch List) បានសេចក្តីថា ទោះរដ្ឋាភិបាលម្ចាស់ប្រទេសបានធ្វើកិច្ចការជាច្រើនគួរឱ្យកត់សម្គាល់ តែមិនទាន់បានបំពេញគ្រប់និយាមអប្បបរមាដែលមានចែងក្នុងTVPA ហើយចំនួនជនរងគ្រោះនៅតែច្រើន ខណៈរដ្ឋាភិបាលមិនទាន់ខិតខំដល់កម្រិត និងមិនបង្ហាញភស្តុតាងជាតឹកតាងគ្រប់គ្រាន់ថាខ្លួនបានព្យាយាម។ កម្រិតបី (Tier 3) បានសេចក្តីថារដ្ឋាភិបាលម្ចាស់ប្រទេសមិនបានប្រឹងប្រែងដូចមានចែងនៅក្នុង TVPA ហើយមិនខិតខំធ្វើអ្វីជាដុំកំភួនដើម្បីកែលម្អ។

របាយការណ៍ក្រសួងការបរទេសអាមេរិកបានបន្តថា៖ «ដោយមូលហេតុថា រដ្ឋាភិបាលបានកៀគរធនធានគ្រប់គ្រាន់សម្រាប់តាក់តែងផែនការមួយ ផែនការនោះ បើសិនជាអនុវត្តបានជោគជ័យមែននឹងនាំឱ្យកិច្ចខិតខំប្រឹងប្រែងគួរឱ្យកត់សម្គាល់ឈានដល់ការអនុវត្តគ្រប់និយាមអប្បបរមា។ ការណ៍មានផែនការនេះបាននាំឱ្យកម្ពុជាទទួលបានការលើកលែង...ពីការទម្លាក់ចំណាត់ថ្នាក់ទៅកម្រិត៣»។ កាលពីឆ្នាំ២០១៩ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានដាក់ចេញផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៥ឆ្នាំ (២០១៩-២០២៣)។

អ្នកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានប្រាប់វីអូអេថារដ្ឋាភិបាលបានធ្វើកិច្ចខិតខំប្រឹងប្រែងមិនបង្អង់ដៃក្នុងការងារប្រឆាំងការកេងប្រវ័ញ្ចនិងជួញដូរមនុស្សទាំងក្នុង ទាំងក្រៅប្រទេសទោះជួបបញ្ហាកូវីដ១៩ និងគ្រោះទឹកជំនន់ នាឆ្នាំកន្លងមកយ៉ាងណាក្តី។ ឆ្លើយតបនឹងការចេញពិន្ទុនៅជាប់ក្នុងកម្រិតពីរក្នុងបញ្ជីតាមដានអ្នកស្រី ជូ ប៊ុនអេង បានលើកឡើងថា៖ «តែការងារប្រឆាំងការជួញដូរមនុស្សគឺយើងមិនទម្លាក់ដៃទេ ហើយសហរដ្ឋអាមេរិកក៏គាត់ដឹងដែរ ហើយរហូតដល់គាត់ឱ្យមានអ្នកធ្វើរបាយការណ៍ឯករាជ្យមកនៅចាំយកព័ត៌មានជាមួយ ផ្តល់យោបល់ ពិភាក្សាហើយឯកឧត្តមឯកអគ្គរដ្ឋទូតអាមេរិកហ្នឹងក៏លោកបានមកជួបពិភាក្សាច្រើនលើកច្រើនសា។ អ៊ីចឹងបើសួរខ្ញុំថាហេតុអ្វីបានជានៅតែ«លេខពីរក្នុងការឃ្លាំមើល» ខ្ញុំឆ្លើយអត់ចេញទេព្រោះវាពាក់ព័ន្ធទៅនឹងអ្នកវាយតម្លៃ វាជាពិន្ទុដែលនៅលើចុងប៊ិចរបស់គាត់ សួរគាត់បានដឹង»។ អ្នកស្រី ជូ ប៊ុនអេង ក៏បានលើកឡើងថា ការផ្តន្ទាទោសជនល្មើសបានធ្វើដោយមិនរើសមុខ រហូតដល់ករណីខ្លះមានថ្នាក់ឧត្តមសេនីយ៍ទៅទៀតហើយចំពោះការគាំពារជនរងគ្រោះវិញ

អ្នកស្រីថាអង្គការសង្គមស៊ីវិលមួយចំនួនក៏បានទទួលជំនួយជាហិរញ្ញប្បទានដើម្បីវត្តមានបន្តការងាររបស់ខ្លួនដោយសារតែសេវានេះដែលរដ្ឋយកជាដៃគូដែរ។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស(សង់ត្រាល់)លើកឡើងថារដ្ឋាភិបាលអាមេរិកគួរបន្តឃ្លាំមើលការអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិដែលកំពុងមានស្រាប់របស់កម្ពុជានោះ។ លោកប្រាប់វីអូអេថា៖ «ចំណាត់ថ្នាក់នេះហាក់ដូចជាចំណាត់ថ្នាក់មានការសម្របសម្រួល តែក៏ជាចំណាត់ថ្នាក់ដែលទុកឱកាសឱ្យកម្ពុជាពង្រឹងការអនុវត្តច្បាប់របស់ខ្លួនផងដែរ»។ លោកមឿន តុលា បន្តថា៖ «អំឡុងកូវីដ១៩នេះ ខ្ញុំមើលទៅឃើញស្ថានភាពនៃការជួញដូរកម្លាំងពលកម្មនិងជួញដូរមនុស្សគឺដូចជាអត់មានស្រក អត់មានថម ថយទេ។ ជាពិសេសការជួញដូរទៅចិនមានលក្ខណៈកាន់តែធ្ងន់ធ្ងរថែមទៀត ដែលពីមុនទៅតាមយន្តហោះ ឥឡូវមានការឆ្លងដែនផ្លូវគោកកាត់តាមវៀតណាមទៅចិន»។ អ្នកឃ្លាំមើលរូបនេះបានបន្តថា៖ «នៅពេលប្រទេសមួយចំនួន Lockdown (បិទខ្ទប់)អ៊ីចឹងទៅ អង្គការសង្គមស៊ីវិលប្រឈមការលំបាកក្នុងការធ្វើដំណើរអ៊ីចឹងជាឱកាសសម្រាប់ពួកជួញដូរក៏ដូចជាភាគីពាក់ព័ន្ធនានាដូចជិះសេះលែងដៃអ៊ីចឹង»។ លោកមឿន តុលាលើកទឹកចិត្តឱ្យមានការបង្កើនការបង្ក្រាបអំពើពុករលួយនិងបង្កើនកញ្ចប់ថវិកាសម្រាប់ការងារប្រឆាំងការជួញដូរមនុស្សដើម្បីបង្កើនប្រសិទ្ធភាពនៃការងារនេះ៕

## ៣ឆ្នាំជាប់ៗគ្នា៖កម្ពុជាត្រូវបានអាមេរិកដាក់ចំណាត់ថ្នាក់មិនល្អក្នុងបញ្ជីតាមដានការប្រឆាំងការជួញដូរមនុស្ស

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 03/07/2021 - 08:39 ដោយ៖អោ ស្រីពេជ្រ

ចាប់តាំងពីឆ្នាំ២០១៩មកកម្ពុជាបន្តជាប់ក្នុងបញ្ជីឃ្លាំមើលការជួញដូរមនុស្សរបស់សហរដ្ឋអាមេរិកក្នុងចំណាត់ថ្នាក់លេខ២ ក្នុងបញ្ជីតាមដាន។ របាយការណ៍ដែលចេញផ្សាយដោយក្រសួងការបរទេសសហរដ្ឋអាមេរិកនាថ្ងៃទី២កក្កដាម្សិលមិញនេះ បង្ហាញថា នៅក្នុងបញ្ហាជួញដូរមនុស្សនៅកម្ពុជាក្នុងឆ្នាំ២០២១នេះ កម្ពុជានៅតែមិនបានគោរពបានពេញលេញតាមបទដ្ឋានអប្បបរមា ក្នុងការលុបបំបាត់ការជួញដូរមនុស្សនោះឡើយ។ មានការប្រឹងប្រែងពិតមែន ក៏ប៉ុន្តែរដ្ឋាភិបាលកម្ពុជានៅតែមិនបានចាត់វិធានការដល់កម្រិតស្តង់ដារអប្បបរមាក្នុងការកម្ចាត់ការជួញដូរមនុស្សទេ។ នេះបើយោងតាមរបាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិក «ស្តីពីការជួញដូរមនុស្សលើសាកលលោកឆ្នាំ២០២១»។ របាយការណ៍ចុងក្រោយដែលក្រសួងការបរទេសទើបនឹងចេញផ្សាយនេះបង្ហាញថា រដ្ឋាភិបាលកម្ពុជាគ្មានគណនេយ្យភាព គ្មានឆន្ទៈនយោបាយក្នុងការស្រាវជ្រាវតាមដាន រកមុខ និងផ្តន្ទាទោសឧក្រិដ្ឋជនជួញដូរមនុស្សនោះទេ រួមនឹងកង្វះប្រព័ន្ធបង្ការបទល្មើសជាដើម។ លើសពីនេះ រដ្ឋាភិបាលហាក់ទម្លាក់កិច្ចគាំពារជនរងគ្រោះរំលោភបំពានដោយការជួញដូរ ទៅលើក្រុមអង្គការសង្គមស៊ីវិលដែលជាដៃគូទៅវិញ។ សកម្មភាពនេះហើយដែលធ្វើអោយកម្ពុជាបន្តជាប់ក្នុងកម្រិតពីរ «Tier 2 Watchlist» ស្ថិតក្នុងបញ្ជីតាមដានបីឆ្នាំជាប់ៗគ្នា។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី៣មិថុនានេះ បានថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិ RFI ថា កន្លងមក រដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងមោះមុត ក្នុងកិច្ចការប្រយុទ្ធនឹងការជួញដូរមនុស្ស មិនថាក្នុងឬក្រៅប្រទេស។ ជាពិសេស បើទោះបីជាកម្ពុជាស្ថិតនៅក្នុងបរិបទកូវីដ១៩នេះក្តី។ បើតាមមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលរូបនេះ គិតត្រឹមពេលនេះ រដ្ឋាភិបាលបានចាត់ការលើការជួញដូរមនុស្សក្នុងរូបភាពទេសន្តោប្រវេសន៍សរុបជាង ១៥០០០ករណីហើយ។ លោកស្រី ជូ ប៊ុនអេង អះអាងថា រដ្ឋាភិបាលបានផ្តន្ទាទោសជនល្មើសដោយមិនរើសមុខ ក្នុងនោះមានទាំងមន្ត្រីជាន់ខ្ពស់ក្នុងជួរកម្លាំងប្រដាប់អាវុធទៀតផង ដែលត្រូវបានបញ្ជូនទៅកាន់តុលាការច្រើនជាងឆ្នាំមុនៗទៅ

ទៀត។ គួរជម្រាបថា ក្នុងរយៈពេល៦ខែដើមឆ្នាំ២០២១ ការបង្ក្រាបការជួញដូរមនុស្សនៅកម្ពុជាមានការកើនឡើងជាង១០០ករណី ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៩ ដែលមានត្រឹមតែជិត១០០ករណីប៉ុណ្ណោះ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៧នាក់ ស្រី ២៨នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៣នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១២នាក់ ស្រី ៦នាក់ កុមារា ១នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣១នាក់ ស្រី ១៣នាក់ កុមារា ០០នាក់ កុមារី ២នាក់ ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៧នាក់ ស្រី ២៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអរសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## របាយការណ៍អាមេរិក៖ វិបត្តិកូវីដបង្កើតបរិយាកាសល្អឥតខ្ចោះសម្រាប់ក្រុមជួញដូរមនុស្ស

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 02/07/2021 - 13:09

ជំងឺកូវីដបានសម្លាប់មនុស្សជិត ៤លាននាក់ក្នុងពិភពលោក។ ជាមួយគ្នានោះ វាបានធ្វើឲ្យមនុស្សរាប់រយលាននាក់ ធ្លាក់ខ្លួនក្នុងភាពក្រីក្រ។ ការណ៍ដែលប្រជាជនធ្លាក់ខ្លួនក្រីក្រ និងមានជីវភាពកាន់តែអត្តខាត់ គឺជាឱកាសល្អ សម្រាប់ក្រុមជួញដូរមនុស្ស។ របាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងការបរទេសអាមេរិក ដែលចេញផ្សាយ កាលពីថ្ងៃព្រហស្បតិ៍ម្សិលមិញ បានបង្ហាញថា ជំងឺកូវីដបានបង្កើតបរិយាកាសអំណោយផល ធ្វើឲ្យការជួញដូរមនុស្សកើនឡើង ជាពិសេស នៅពេលរដ្ឋាភិបាលជាច្រើនបានបង្វែរថវិកា និងការប្រឹងប្រែងទាំងអស់សម្រាប់តែការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ។ តាមរបាយការណ៍របស់ក្រសួងការបរទេសអាមេរិក ដែលមានឈ្មោះថា ការជួញដូរមនុស្សនៅក្នុងកាលៈទេសៈកូវីដ រដ្ឋាភិបាលជាច្រើនបង្វែរ ចំណាប់អារម្មណ៍ និងធនធានសម្រាប់ តែការប្រយុទ្ធប្រឆាំង ជំងឺកូវីដ ដោយលែងសូវ យកចិត្តទុកដាក់លើកម្មវិធីប្រយុទ្ធប្រឆាំងការជួញដូរ។ ក្រុមជួញដូរមនុស្ស បានឆក់ឱកាសនេះដើម្បី អូសទាញ ប្រជាជន ដែលមានជីវភាពអត្តខាត់ ដោយសារវិបត្តិកូវីដ ឲ្យធ្លាក់ចូលក្នុងអន្ទាក់របស់ខ្លួន។

នៅក្នុងឱកាសចេញផ្សាយរបាយការណ៍ ប្រចាំឆ្នាំ ២០២១ កាលពីថ្ងៃព្រហស្បតិ៍ម្សិលមិញ រដ្ឋមន្ត្រី ការបរទេសអាមេរិក លោកអង់តូនី ប្លីងកិន បាននិយាយថា មានមនុស្សប្រមាណ ២៥លាននាក់ ក្នុងពិភពលោកដែលធ្លាក់ខ្លួនរងគ្រោះដោយសារការជួញដូរមនុស្ស។ តាមរដ្ឋមន្ត្រីការបរទេសអាមេរិក ជនរងគ្រោះមួយចំនួនត្រូវគេលក់ទៅក្នុងបណ្ដាញជំនួញផ្លូវភេទ ចំណែកមួយចំនួនផ្សេងទៀត ត្រូវគេចាប់បង្ខំឲ្យធ្វើការ នៅតាមរោងចក្រ នៅចំការ ឬ

រើសបញ្ចូលក្នុងក្រុមប្រដាប់អាវុធ។ របាយការណ៍ របស់ក្រសួងការបរទេសបានលើកឧទាហរណ៍មួយចំនួនដូចជា នៅ ប្រទេសឥណ្ឌា ឬណេប៉ាល់ ក្មេងស្រីរបស់គ្រួសារក្រីក្រ ត្រូវឈប់រៀន ដើម្បីរៀបការទាំងក្នុងវ័យក្មេង ជាថ្នូរនឹង លុយចំណងដៃ ឬ ត្រូវធ្វើការដោយបង្ខំ ដើម្បីបានប្រាក់ផ្គត់ផ្គង់គ្រួសារ។ នៅអាមេរិក អង់គ្លេស ឬនៅអ៊ីយ៉ាហ្គេ ម្ចាស់ផ្ទះបានបង្ខំឲ្យអ្នកជួល ជាមនុស្សស្រី មានទំនាក់ទំនងផ្លូវភេទជាមួយខ្លួន ជាថ្នូរនឹងប្រាក់បង់ជួលថ្លៃផ្ទះ។ ចំណែកនៅ ហៃទី ឬនៅប្រទេសម៉ាលី ឆ្លៀតពេលដែលក្រុមការងារសន្តិសុខ បន្ទរដៃ នៅក្នុងកាលៈទេសៈ កូវីដ ក្រុម ជនអន្ធពាលបានចាប់បង្ខំមនុស្សស្រី ក្នុង ជំរំជនភៀសខ្លួន ឲ្យបម្រើសេវាផ្លូវភេទ។

នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ ២០២១ ក្រសួងការបរទេសអាមេរិកបានទម្លាក់ចំណាត់ថ្នាក់ ប្រទេសមួយ ចំនួន និងដំឡើងចំណាត់ថ្នាក់សម្រាប់ប្រទេសមួយចំនួនផ្សេងទៀត ដែលបានប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងការ ជួញដូរមនុស្ស។ ប្រទេស១៧ ដែលនៅក្នុងនោះ មានម៉ាឡេស៊ី ភូមា ចិន គុយបា អាល់ហ្សេរី និងរុស្ស៊ី ជាដើម ត្រូវ បានអាមេរិកទម្លាក់ទៅក្នុងចំណាត់ថ្នាក់លេខ៣ ក្នុងមូលហេតុថា រដ្ឋាភិបាលរបស់ប្រទេសទាំងនោះ មិនបានឆ្លើយ តបនឹងលក្ខខណ្ឌជាអប្បបរមា ប្រឹងប្រែងមិនគ្រប់គ្រាន់ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។ ប្រទេសដែលស្ថិត ក្នុងចំណាត់ថ្នាក់ទី៣ នឹងអាចប្រឈមនឹងការដាក់ទណ្ឌកម្ម ឬការដកជំនួយពីរដ្ឋបាលអាមេរិកាំង៕

## ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

### កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលរដ្ឋខ្មែរ ២នាក់ ត្រឡប់មកពីប្រទេសថៃនៅចំណុចឃុំសន្តិភាព ស្រុកសំពៅលូន

http://cambodiapolice.com/policekh/ 4:42 pm 3 កក្កដា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការ នគរបាលខេត្តបាត់ដំបងជាប្រចាំ ស្ដីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋ ឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរ សេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ នៅថ្ងៃសៅរ៍ ៩រោច ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាល ប៉ុស្តិ៍ព្រំដែនកូនភ្នំ ដឹកនាំដោយលោកអនុសេនីយ៍ទោ ខៀវ-រ៉ាត់ នាយប៉ុស្តិ៍ ចំណុះវរសេនាតូចនគរបាលការពារព្រំ ដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្ត ប៉ុស្តិ៍គ្រប់គ្រង និងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ ចំណុចនៃភូមិសាស្រ្តភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូនចំនួន២នាក់,ស្រី១នាក់ ក្នុងនោះក្មេងប្រុស១នាក់ ។ បន្ទាប់ពីសាកសួរ,កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនឱយទៅក្រុមគ្រូពេទ្យ ដើម្បីទទួល យកទៅកាន់មណ្ឌលចត្តាឡីស័កបន្ត ៕

### អាជ្ញាធរខេត្តបន្ទាយមានជ័យបន្តរឹតបន្តឹងការត្រួតពិនិត្យព្រំដែន តែករណីលួចឆ្លងដែន នៅតែមាន

https://www.rasmeinews.com/ 3 July, 2021

**ដោយ ៖ ប.ជ័យ / បន្ទាយមានជ័យ៖** *មន្ត្រីអាជ្ញាធរមានសមត្ថកិច្ច ក៏ដូចគ្រួសារពលរដ្ឋ បានអោយដឹងកាល ពីថ្ងៃទី៣ខែកក្កដាថា ទោះបីកម្លាំងសរុបបាននឹងកំពុងបន្ត រឹតសន្តិសុខតាមបណ្តោយព្រំដែនកម្ពុជាថៃយ៉ាងណាក៏ នៅតែមានពលករនិងមេខ្យល់ ជូនពលករឆ្លងដែនជាហូរហែដដែល ប៉ុន្តែសមត្ថកិច្ចក៏បានចាត់តាំងកម្លាំងបង្ការ និង ទប់ស្កាត់ជាបន្តបន្ទាប់។*

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ ទទួលផែនការងារប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជនបានឲ្យដឹងថា មេខ្យល់ចំនួន ១០នាក់ដែលពាក់ព័ន្ធនឹងករណីនាំមនុស្សឆ្លងដែនទៅប្រទេសថៃ មិនស្របច្បាប់ត្រូវបានឃាត់ខ្លួន ក្រោយពេលកម្លាំងនគរបាលវរសេនាតូចការពារ ព្រំដែនលេខ ៩១១ បានធ្វើការបង្ក្រាបចំនួន២ករណីដោយឡែកពីគ្នា ។ លោកស្រីបានបន្តថា មួយរយៈចុងក្រោយនេះ កងកម្លាំងនគរបាល យោធា អាវុធហត្ថ អាជ្ញាធរដែនដីក្នុងខេត្តនេះបានចាប់ខ្លួននិងកសាងសំណុំរឿងបញ្ជូននូវមេខ្យល់រាប់សិបនាក់ជាបន្តបន្ទាប់ទៅតុលាការដើម្បីត្រៀមកាត់ទោស ។ ក្នុងនោះ ក៏បានប្រមូលពលករ ដែលលួចឆ្លងដែនខ្លួនឯងនិងដែលលួចឆ្លងដែនដោយមានមេខ្យល់ជូន ទៅអប់រំ ធ្វើចត្តាឡីស័កនិងបញ្ជូនត្រឡប់ទៅលំនៅឋានវិញជាបន្តបន្ទាប់ ៕/PC

## មេរោគបំប្លែងថ្មីDelta រកឃើញលើពលករខ្មែរចំនួន៤នាក់វិលពីប្រទេសថៃ

http://nokorwatnews.com/ 03/07/2021

ខេត្តបន្ទាយមានជ័យ៖ ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យបានប្រាប់អ្នកសារព័ត៌មានក្នុងស្រុកកាលពីរសៀលថ្ងៃទី២ ខែកក្កដាថា នៅខេត្តបន្ទាយមានជ័យគ្រូពេទ្យជួរមុខនៅមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេចឪ កណ្តាលក្រុងសិរីសោភ័ណ បានរកឃើញមេរោគកូវីដ-១៩ បំប្លែងថ្មីដែលតា (Delta) ឥណ្ឌាលើពលករខ្មែរវិលពីប្រទេសថៃ៤នាក់បន្ថែមទៀត។ បើតាមលោកវេជ្ជបណ្ឌិត ឡេ ច័ន្ទសង្វាត ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ បានបញ្ជាក់ថា មកទល់ពេលនេះស្ថានភាពនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងខេត្តបន្ទាយមានជ័យបានកើតមានរាយប៉ាយពាសពេញទាំងនៅក្រុងប៉ោយប៉ែត ក្រុងសិរីសោភ័ណ និងតាមស្រុកចំនួន៧ទៀត។

ចំណែកលោក ណង វុទ្ធី នាយករងសាលាខេត្តបន្ទាយមានជ័យបានឱ្យដឹងកាលពីថ្ងៃទី២ ខែកក្កដា ដែរថា៖ មេរោគកូវីដ-១៩ មានលើពលករខ្មែរវិលពីប្រទេសថៃ ដូចថ្ងៃនេះពេលព្រឹករកឃើញវិជ្ជមាន ៣នាក់ ដល់ល្ងាចវិជ្ជមានកូវីដ-១៩មានម្នាក់ទៀត ក្នុងនោះថែមកុមារតូចៗតាមម្តាយ៣នាក់ទៀតផង សរុប២៥នាក់ ក្នុងនោះ មានមេរោគឆ្លងរហ័សថ្មី(delta)ដែលតាចំនួន៣នាក់ផងដែរ ។ លោកបានបន្តថា អ្នកវិជ្ជមានទាំងនោះ ត្រូវបានបញ្ជូនពីមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេចឪ ទៅព្យាបាលបន្តនៅមណ្ឌលព្យបាលកងរ៉ា ក្នុងសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ។ លោកនិយាយថា ហេតុនេះបើមិនមានការចាំបាច់ សូមបងប្អូននៅផ្ទះជួបជុំគ្រួសារក្នុងផ្ទះល្អជាង ហើយថែរក្សាគម្លាតនៅទីប្រជុំជន លាងដៃនិងអាល់កុលជាប្រចាំដើម្បីកាត់បន្ថយនៃការរីករាលដាលជំងឺកាចសាហាវមួយនេះ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧១នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៧១នាក់ ស្រី ៣៧នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៥នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២៤នាក់ ស្រី ៩នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៨នាក់ ស្រី ១៩នាក់ កុមារា ០០នាក់ កុមារី ២នាក់ ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៩នាក់ ស្រីចំនួន ៤នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៨១នាក់ ស្រី ៣៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## តើកម្ពុជាគួរមានវិធានការបន្ថែមអ្វីខ្លះ ដើម្បីឲ្យស្ថានភាពការជួញដូរមនុស្ស ល្អប្រសើរជាងមុន?

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 04/07/2021 - 07:49 ដោយ៖អោ ស្រីពេជ្រ

ស្ថានភាពនៃការជួញដូរមនុស្សនៅកម្ពុជា ត្រូវបានគេសម្គាល់ឃើញជាទូទៅថា នៅតែជាបញ្ហាដុះស្នឹមក្នុងសង្គមខ្មែរ ដែលមិនទាន់អាចដោះស្រាយបាននៅឡើយ។ ក្នុងបរិបទរាលដាលជំងឺកូវីដ១៩នេះ ជនទុច្ចរិតជាច្រើនបានឈ្លៀតឱកាសបង្កើនល្បឿនសកម្មភាពជួញដូរមនុស្ស មិនថាក្នុង និងក្រៅប្រទេស ខណៈពេលដែលរដ្ឋាភិបាលកំពុងជាប់ដៃទប់ស្កាត់ការឆ្លងជំងឺរាតត្បាតសកល។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សអះអាងថា ខ្លួនបានប្រឹងប្រែងទប់ស្កាត់អស់ពីសមត្ថភាពហើយ។ តែចំពោះក្រុមអង្គការសង្គមស៊ីវិលធ្វើការក្នុងរឿងនេះវិញយល់ឃើញថា ការអនុវត្តនៅមានកម្រិត។ និងថា រដ្ឋាភិបាលគួរតែពង្រឹងការអនុវត្តវិធានការទប់ស្កាត់ករណីជួញដូរមនុស្សដែលមានស្រាប់នោះបន្ថែមទៀត។

## ចុះឆែកឆេរការដ្ឋានសំណង់មួយ ចាប់បានមេការថៃនាំពលករមានកូមា ខ្មែរមកធ្វើការខុសច្បាប់

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ៤ កក្កដា ២០២១ដោយ Dy Bunnara

ប្រទេសថៃ ៖ អ្នកគ្រប់គ្រងការងារសាងសង់ម្នាក់ដែលជាជនជាតិថៃ និងពលករដែលជាកម្មករចំនួន ២១ នាក់ ក្នុងនោះមានជនជាតិភូមា ១ នាក់ និងខ្មែរចំនួន ២០ នាក់ ត្រូវបានអាជ្ញាធរថៃ ក្នុងខេត្តស្រះកែវ ឃាត់ខ្លួនដើម្បីបញ្ជូនទៅតុលាការ ពាក់ព័ន្ធករណីចូលធ្វើការនៅក្នុងប្រទេសថៃគ្មានច្បាប់អនុញ្ញាត។

ការឃាត់ខ្លួននេះបានធ្វើឡើងកាលពីរសៀលថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០២១ ត្រង់ចំណុចទីតាំងសាងសង់មួយកន្លែង ក្នុងឃុំស្រះកែវ ស្រុកមឿង ខេត្តស្រះកែវ ដោយក្នុងនោះមានអ្នកគ្រប់គ្រងម្នាក់ ឈ្មោះ ភូមិរិន្ទ ស៊ិនសិរី មកពីខេត្តឆៈឈើងសៅ រីឯពលករទាំង ២១ នាក់ គឺមានខ្មែរ ២០ នាក់ និង ជនជាតិភូមា ១ នាក់ ។ ចំពោះអ្នកគ្រប់គ្រងបានសារភាពទទួលស្គាល់កំហុស ដែលបាននាំពលករទាំងអស់ ដែលរស់នៅមិនស្របច្បាប់ឲ្យចូលទៅធ្វើការនៅក្នុងការដ្ឋានសាងសង់របស់ខ្លួន ដោយឡែកពលករខ្មែរម្នាក់ឈ្មោះ គឿ អាយុ ២៣ ឆ្នាំ បាននិយាយថា ខ្លួនរួមទាំងមិត្តភ័ក្រមួយចំនួន បានចូលមកធ្វើការនៅទីនេះ តាំងពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២០ មកម្ល៉េះ ដោយមិនហ៊ានចេញដើរទៅក្រៅខេត្ត ឬឆ្ងាយៗឡើយ ព្រោះដោយសារតែពួកខ្លួនរស់នៅដោយគ្មានច្បាប់អនុញ្ញាត។

បច្ចុប្បន្នទាំងពលករ២១នាក់ ក៏ដូចជាអ្នកគ្រប់គ្រងម្នាក់ ត្រូវបានអាជ្ញាធរ និងសមត្ថកិច្ច បញ្ជូនទៅអង្គភាពជំនាញហើយ ដើម្បីចាត់ការតាមនីតិវិធី ៕ អត្ថបទ៖ សោ និយមរ័ត្ន

# កូវីដ១៩ក្នុងប្រទេសថៃ បន្តរុញច្រានជីវភាពពលករខ្មែរកាន់តែលំបាក

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 04/07/2021 ដោយ៖ សឿង ភារៈ

ការផ្ទុះរាលដាលកូវីដ១៩នៅក្នុងប្រទេសថៃ ហាក់មិនទាន់មានសញ្ញាថមថយ ខណៈពលករខ្មែរខ្លះ ត្រូវបង្ខំចិត្តត្រឡប់មកស្រុកខ្មែរវិញ។ ប៉ុន្តែពលករខ្មែរខ្លះទៀត គ្មានជម្រើសអ្វីក្រៅពីស្នាក់នៅបន្ត បើទោះបីស្ថានភាពជីវភាពរបស់ពួកគេកាន់តែលំបាកជាងឆ្នាំ២០២០ ដែលជាឆ្នាំដំបូងនៃការផ្ទុះឡើងកូវីដ១៩នៅក្នុងប្រទេសថៃ។ នៅក្នុងនាទីបទយកការណ៍ថ្ងៃនេះ សឿង ភារៈ បានសម្ភាសពលករខ្មែរមួយចំនួន ដែលកំពុងស្នាក់នៅក្នុងប្រទេសថៃនាពេលនេះ។

# មន្ត្រីរដ្ឋាភិបាល ចាត់ទុករបាយការណ៍ស្ដីពី ការជួញដូរមនុស្សរបស់អាមេរិក ជាទស្សនៈ និងជាសិទ្ធិអ្នកឱ្យពិន្ទុ

https://www.postkhmer.com/ រី សុចាន់ | Publication date 05 July 2021 | 18:27 ICT

**ភ្នំពេញ៖** មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃឆ្លើយតប និងច្រានចោលរបាយការណ៍របស់សហរដ្ឋអាមេរិក ដែលថា រដ្ឋាភិបាលកម្ពុជាមិនបានបំពេញតាមស្តង់ដាអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្ស។ មន្ត្រីចាត់ទុកការលើកឡើងនេះ ជាទស្សនៈ និងជាសិទ្ធិរបស់អ្នកផ្ដល់ពិន្ទុ ប៉ុន្តែរដ្ឋាភិបាលមិនបានបន្ធូរដៃក្នុងការងារបង្ក្រាបនោះទេ។ សហរដ្ឋអាមេរិកកាលពីថ្ងៃទី២ ខែកក្កដាបានចេញរបាយការណ៍ប្រចាំឆ្នាំ២០២១ ស្ដីពីការជួញដូរមនុស្សនៅកម្ពុជា ដោយបានលើកឡើងថា៖«រដ្ឋាភិបាលកម្ពុជាមិនបានបំពេញគ្រប់គ្រាន់តាមសង្ដ់ដាអប្បបរមាក្នុងការលុបបំបាត់ការជួញដូរមនុស្សប៉ុន្តែបានខិតខំប្រឹងប្រែងធ្វើ»។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រាប់ភ្នំពេញនៅថ្ងៃទី៥ ខែកក្កដា ថា៖«អ្វីដែលបានលើកឡើងហ្នឹងគឺជាទស្សនៈរបស់គាត់ ជាការមើលឃើញរបស់គាត់ជាអ្នកវាយតម្លៃហ្នឹង ប៉ុន្តែចំពោះយើងដែលជាអ្នកធ្វើគឺខំប្រឹងប្រែងណាស់»។ លោកស្រីថ្លែងថា៖«វាជាសិទ្ធិរបស់អ្នកផ្ដល់ពិន្ទុ ចំណែកពួកយើងខ្ញុំ មិនធ្លាក់ដៃទេ។ យើងតែងតែគិតថា អ្វីដែលយើងធ្វើទៅតាមលទ្ធភាពជាក់ស្ដែងរបស់យើង ហើយយើងនឹងមិនបណ្ដែតបណ្ដោយឱ្យអំពើជួញដូរមនុស្សហ្នឹងកើតមានដោយយើងមិនបានធ្វើការបង្ក្រាបទេ»។ លោកស្រី ជូ ប៊ុនអេង បន្តថា អ្វីដែលរដ្ឋាភិបាលធ្វើគឺមិនមែនធ្វើតែម្នាក់ឯងនោះទេ គឺបានសហការជាមួយអង្គការដៃគូជាតិ អន្តរជាតិនិងអង្គការសហប្រជាជាតិ(UN)ដែលបានធ្វើការជាមួយគ្នា។ លោកស្រីថ្លែងថា ទោះបីជំងឺកូវីដ១៩រាតត្បាត ថែមទាំងមានពលករចំណាកស្រុកត្រឡប់មកកម្ពុជាជិត ២០០ ០០០នាក់ក្នុងពេលតែមួយក្ដី ក៏រដ្ឋាភិបាលបានទប់ស្កាត់មិនឱ្យនាំមនុស្សចេញទៅក្រៅប្រទេសដែលជាផ្នែកនៃការជួញដូរមនុស្ស និងបានបង្ក្រាបជាបន្តបន្ទាប់ សូម្បីអ្នកដែលមានឋានៈខ្ពស់ក្នុងជួរកងកម្លាំងក៏នៅតែត្រូវបានបង្ក្រាបដែរ។

លោកស្រីជូ ប៊ុនអេង ថ្លែងថា៖«យើងខំប្រឹងប្រឹងធ្វើគ្រប់មុខសញ្ញាទាំងអស់ ដោយសារយើងអត់បានបោះបង់ចោលនូវការងារស្នួលរបស់យើងទេ។ យើងនៅតែធ្វើ ហើយការងារប្រឆាំងកូវីដហ្នឹង គឺយើងចាត់ទុកជាការងារអំវែកមួយទៀតដែលយើងខំប្រឹងធ្វើទាំងអស់គ្នា»។ លោកស្រីបញ្ជាក់ថា៖«អ៊ីចឹងដល់ពេលថាមិនបំពេញតាមស្តង់ដា ឬមួយក៏តាមអីហ្នឹង ខ្ញុំគិតថា វាត្រឹមត្រូវហើយ ពីព្រោះមិនដឹងស្តង់ដាគាត់ហ្នឹងគាត់ចង់ឱ្យយ៉ាងម៉េចទេ។ ពីព្រោះអ្វីដែលយើងធ្វើ គឺធ្វើទី១ទៅតាមគោលការណ៍របស់យើងតាមផែនការក៏ដូចជាទៅតាមសមត្ថភាពឬលទ្ធភាពដែលយើងបានដាក់ចេញ»។ លោកស្រីរដ្ឋលេខាធិការ បន្តថា សូម្បីប្រមុខរាជរដ្ឋាភិបាលនៅពេលរាល់មានកិច្ចប្រជុំ ឬកិច្ចពិភាក្សាជាលក្ខណៈអន្តរជាតិក្នុងតំបន់ក៏ដោយ ក៏មិនដែលបំភ្លេចនូវអំពើជួញដូរមនុស្សនោះទេ ព្រោះវា

ជាអាទិភាពដែលរាជរដ្ឋាភិបាលត្រូវតែខំប្រឹងប្រយុទ្ធប្រឆាំង មិនឱ្យមានការរំលោភបំពានលើសិទ្ធិមនុស្សឬសេចក្តីថ្លៃថ្នូររបស់មនុស្សតាមរយៈការជួញដូរមនុស្ស។ បើតាមលោកស្រីជូប៊ិន អេង អាជ្ញាធរបានបង្ក្រាបការជួញដូរមនុស្សនៅក្នុងត្រីមាសដើមឆ្នាំនេះបាន៥៨ករណី ខណៈឆ្នាំមុនអាជ្ញាធរបានបង្ក្រាប២៧ករណី។

របាយការណ៍លើកឡើងថា ការខិតខំប្រឹងប្រែងទាំងនេះរួមមានការកែលម្អការប្រមូលទិន្នន័យនិងការត្រួតពិនិត្យការចោទប្រកាន់និងការផ្តន្ទាទោសអ្នកជួញដូរក៏ដូចជាទិន្នន័យអត្តសញ្ញាណជនរងគ្រោះនៅទូទាំងប្រទេស។ ការបន្តការស៊ើបអង្កេតការបន្តចោទប្រកាន់ និងការបន្តផ្តន្ទាទោសអ្នកជួញដូរ និងការបន្តអនុវត្តផែនការសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ របាយការណ៍បន្តថា ក៏ប៉ុន្តែរដ្ឋាភិបាលមិនបានបង្ហាញឱ្យឃើញនូវការបង្កើនកិច្ចខិតខំប្រឹងប្រែងថែមទៀត ហើយអំពើពុករលួយនៅតែបន្តរាំងដល់ការអនុវត្តច្បាប់ ការអនុវត្តនីតិវិធីព្រហ្មទណ្ឌ និងការផ្តល់សេវាការពារជនរងគ្រោះ។ របាយការណ៍បន្តថា រដ្ឋាភិបាលមិនបានផ្តល់ការការពារគ្រប់គ្រាន់ដល់ជនរងគ្រោះក្នុងនិងក្រៅប្រទេសទេ តែបែរជាពឹងផ្អែកខ្លាំងទៅលើម្ចាស់ជំនួយបរទេសនិងអង្គការក្រៅរដ្ឋាភិបាលដើម្បីផ្តល់ការថែទាំជនរងគ្រោះ។ អំពើពុករលួយនិងកង្វះឆន្ទៈនយោបាយនឹងបន្តរាំងដល់ការនាំខ្លួនអ្នកជួញដូរមនុស្សឱ្យទទួលខុសត្រូវ។

របាយការណ៍លើកឡើងថា ដោយសារវិធានការត្រួតពិនិត្យ និងគណនេយ្យភាពរបស់រដ្ឋាភិបាលមិនគ្រប់គ្រាន់ អាជ្ញាធរមិនបានស៊ើបអង្កេតការរាយការណ៍ដែលភាគច្រើនអាចជឿទុកចិត្តបានអំពីការឃុបឃិតគ្នា។ ជាពិសេសជាមួយម្ចាស់អាជីវកម្មដែលជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស ដែលមានបុរសស្ត្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេសនៅក្នុងកន្លែងកម្សាន្តនិងឡផ្ទះ។ បើតាមរបាយការណ៍ អាជ្ញាធរមិនបានចេញសេចក្តីណែនាំជាផ្លូវការដែលអនុញ្ញាតឱ្យប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ក្នុងប្រតិបត្តិការប្រឆាំងការជួញដូរ។ នេះគឺជាកត្តាដែលបន្តរាំងដល់សមត្ថភាពមន្ត្រីក្នុងការនាំខ្លួនអ្នកជួញដូរផ្លូវភេទឱ្យទទួលខុសត្រូវពេញលេញ៕

# ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១

## ត្រឹម២ថ្ងៃប៉ុណ្ណោះ ពលករវិលមកពីថៃចូលស្រុកវិញជាង៥០០នាក់ រកឃើញជាង១០០នាក់ឆ្លងកូវីដ

https://kohsantepheapdaily.com.kh/ Oddar Meanchey០៥ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៦:១៥

ខេត្តឧត្តរមានជ័យ ៖ គិតត្រឹមតែរយៈពេលតែ២ថ្ងៃប៉ុណ្ណោះ មានពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃមកស្រុកកំណើតវិញ ដោយចូលតាមច្រកទ្វារអន្តរជាតិអូរស្មាច់ ចាប់ពីថ្ងៃទី៤ និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១នេះ មានមនុស្សប្រុសស្រីប្រមាណជាង៥០០នាក់ ហើយត្រូវបានក្រុមគ្រូពេទ្យរកឃើញមនុស្សប្រុសស្រីមានវិជ្ជមានកូវីដ ១៩ ជាង១០០នាក់ទៅហើយ។

បើតាមលោក ឃ្លាំង ហួត ប្រធានសុខាភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ពលករខ្មែរស្វែងរកការងារធ្វើនៅឯប្រទេសថៃ ដែលវិលត្រឡប់មកស្រុកកំណើតវិញជាង៥០០នាក់ ដោយចូលមកតាមច្រកទ្វារអន្តរជាតិអូរស្មាច់ និងត្រូវបានក្រុមគ្រូពេទ្យធ្វើការវាស់កំដៅ និងយកសំណាក គិតត្រឹមតែរយៈពេលចាប់តាំងពីថ្ងៃទី៤ និងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១នេះ ត្រូវបានគ្រូពេទ្យប្រចាំការមាត់ច្រក រកឃើញមានអ្នកដែលជាប់វិជ្ជមានកូវីដ ១៩ ជាង១០០នាក់។ លោកប្រធានសុខាភិបាលខេត្តបានបញ្ជាក់ថា គិតត្រឹមថ្ងៃទី៥ ខែកក្កដានេះ អ្នកដែលកំពុងធ្វើចត្តាឡីស័កចំនួន២២៣៨នាក់ អ្នកដែលមានវិជ្ជមានកូវីដ១៩ បានកើនឡើងដល់ទៅចំនួន៩២៦នាក់ហើយ ដោយឆ្លងនៅក្នុងសហគមន៍ចំនួន៩៦នាក់ និងពលករដែលវិលត្រឡប់ពីប្រទេសថៃចំនួន៨៣០នាក់ និងអ្នកកំពុងសម្រាកព្យាបាលសព្វថ្ងៃមានចំនួន៧៥៨នាក់ ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦២នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦២នាក់ ស្រី ២៧នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៥នាក់ ស្រី ៨នាក់ កុមារា ២នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៤នាក់ ស្រី ១០នាក់ កុមារា ០០នាក់ កុមារី ០០នាក់ ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១៣នាក់ ស្រីចំនួន ៥នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៦នាក់ ស្រីចំនួន ២នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦២នាក់ ស្រី ២៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## តុលាការកំពូលជម្រះលើបណ្តឹងសារទុក្ខរបស់ស្ត្រី ជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធនារីខ្មែរ១៦នាក់ ពីកម្ពុជា ទៅធ្វើការខុសច្បាប់ នៅក្នុងប្រទេស ម៉ាឡេស៊ី

https://cen-news.com/ Posted ByPen Srey NeatJuly 5, 2021

ភ្នំពេញ ៖ តុលាការកំពូលកាលពីព្រឹក ថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០២១នេះ បានជំនុំជម្រះលើបណ្តឹងសារទុក្ខរបស់ស្ត្រីជនជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធនារីខ្មែរ១៦នាក់ ពីកម្ពុជា ទៅធ្វើការដោយ ខុសច្បាប់ នៅក្នុងប្រទេស ម៉ាឡេស៊ី ប្រព្រឹត្តកាលពីអំឡុងឆ្នាំ ២០១៥ និង ២០១៦។ សវនាការនេះបានធ្វើឡើងក្រោមការដឹកនាំរបស់លោកចៅក្រម ឃឹម ប៉ុណ្ណ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូលនឹងមានលោក ជុំ សាបាន ជាតំណាងមហាអយ្យការ។

លោកចៅក្រម ឃឹម ប៉ុណ្ណ បានថ្លែងថា នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ មានឈ្មោះ អ៊ុំ រ៉ាឌីន ហៅ មាំ ហៅ ម៉ា ហៅ ដោលី ភេទស្រី អាយុ ២៦ ឆ្នាំ ខ្មែរឥស្លាម រស់នៅ ក្នុងសង្កាត់ឬស្សីកែវ រាជធានីភ្នំពេញ។ លោកចៅក្រមបានបញ្ជាក់ថា ជនជាប់ចោទ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៨ កាត់ទោសដាក់ពន្ធនាគារ កំណត់ ៨ ឆ្នាំ ពីបទ៖ « នាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន» តាមបញ្ញត្តិមាត្រ១១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស នឹងអំពើអាជីវកម្មផ្លូវភេទ។ តែនាងបានប្ដឹងជំទាស់នឹងសាលក្រមខាងលើទៅកាន់សាលាឧទ្ធរណ៍ ។ សាលាឧទ្ធរណ៍ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ បានសម្រេចតម្កល់ទោសរបស់នាងដដែល។ នាងបន្តប្ដឹងសារទុក្ខសាលដីកា របស់សាលាឧទ្ធរណ៍ ទៅកាន់តុលាការកំពូល។ លោកចៅក្រមបានបន្ថែមថា ជនជាប់ចោទ ឈ្មោះ អ៊ុំ រ៉ាឌីន ត្រូវបានចាប់ឃុំខ្លួន កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧ តាមបណ្តឹង

របស់នារីរងគ្រោះ ចំនួន ១៦នាក់ (ជនជនរងគ្រោះ) ដែលបានប្តឹងនាងមក កាន់សមត្ថកិច្ចនគរបាលជំនាញថា៖ ជនជាប់ចោទ បានឆបោក និង ជួញដូរពួកគេ ទៅធ្វើការជាអ្នកបម្រើនៅតាមផ្ទះ ដោយធ្វើដំណើរតាមច្រកប៉ោយប៉ែត ព្រំដែនកម្ពុជា ថៃ កាលពីឆ្នាំ ២០១៦។ តែពេលដល់ប្រទេសម៉ាឡេស៊ី ពួកគេត្រូវបានលក់ឲ្យ ទៅធ្វើការហាងម៉ាស្សា បម្រើផ្លូវទៅវិញ។

នាពេលសវនាការជនជាប់ចោទឈ្មោះ អ៊ុំ រ៉ាឌីន បានឆ្លើយសារភាព នឹងទទួលស្គាល់កំហុសរបស់នាង។ នាងបាននិយាយថា រហូតមកទល់ពេលនេះ នាងបានឃុំខ្លួន នៅក្នុងពន្ធនាគារ ពន្ធនាគារព្រៃស ( ម២) រយះពេល ០៤ ឆ្នាំហើយ។ នាងបានដឹងពីកំហុស បានកែខ្លួន ជាមនុស្សថ្មី និង សន្យាថា នឹងមិនប្រព្រឹត្តអំពើ អ្វី ដែលខុសឆ្នាំទៀតឡើយ។ នាងបានសំណូមពរ ដល់តុលាការកំពូល មេត្តា ជួយបន្ធូរបន្ថយទោស ដល់នាង ដើម្បីនាង ឆាប់បានវិលត្រឡប់មកជួបជុំនឹងកូនតូចៗ ០២នាក់ ដែលសព្វថ្ងៃ ពួកគេ រស់នៅជាមួយម្តាយ បង្កើតរបស់នាង នៅឯស្រុកកំណើត។ សំណុំរឿងនេះតុលាការកំពូល បានលើកពេលប្រកាសសន្ដីការនៅថ្ងៃទី១២ខែកក្កដា ខាងមុខនេះ៕រក្សាសិទ្ធិដោយ៖ ចន្ទា ភា

## ខេត្តឧត្តរមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ ៨៥នាក់ទៀត ក្នុងនោះពលករមកពីថៃ៧៥នាក់ ខណៈជាសះស្បើយ១៥នាក់

http://freshnewsasia.com/ 2021-07-05 08:29pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន៨៥ករណីបន្ថែមទៀត និងជាសះស្បើយ១៥នាក់ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១នេះ តាមរយៈការធ្វើតេស្តរហ័ស (Rapid Test)។ បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺដែលរកឃើញថ្មីទាំង៨៥នាក់ខាងលើនេះ គឺមានអ្នកជំងឺចំនួន៧៥នាក់ ជាពលករមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់។ សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យរកឃើញជំងឺកូវីដ១៩ ចំនួន១០០៨ករណី ក្នុងនោះ ករណីនាំចូលពីបរទេសចំនួន៨៩៥ករណី និងករណីឆ្លងក្នុងសហគមន៍២០កុម្ភៈ ចំនួន១១៣ករណី បានព្យាបាលជាសះស្បើយចំនួន១៧៧នាក់ កំពុងសម្រាកព្យាបាលចំនួន៨២៨នាក់ និងស្លាប់បាត់បង់ជីវិត៣នាក់ផងដែរ៕

## សង្គមស៊ីវិលស្នើឲ្យអាជ្ញាធរខ្មែរ-ថៃ ប្រញាប់អន្តរាគមន៍ផ្តល់ជំនួយបន្ទាន់ដល់ពលករដែលកំពុងខ្វះខាតជីវភាពនិងត្រូវការសេវាព្យាបាលជំងឺ

https://www.rfa.org/khmer/ ដោយ ខែ សុណង 2021-07-04

សង្គមស៊ីវិលធ្វើការលើកស្ទួយពលករចំណាកស្រុក ស្នើឲ្យអាជ្ញាធរខ្មែរ ថៃ ប្រញាប់អន្តរាគមន៍ផ្តល់ជំនួយបន្ទាន់ដល់ពលករ ដែលកំពុងខ្វះខាតជីវភាព និងត្រូវការសេវាព្យាបាលជំងឺ។ មន្ត្រីផ្នែកបកប្រែភាសាថៃ នៃអង្គការមូលនិធិបណ្តាញលើកកម្ពស់គុណភាពជីវិតពលករនៅប្រទេសថៃលោក ទិត្យ ផល្លា មានប្រសាសន៍ថា លោកចង់ឲ្យរដ្ឋាភិបាលខ្មែរ ឬស្ថានទូតខ្មែរប្រចាំប្រទេសថៃ ជួយផ្តល់សេវាកម្មដល់ពលករឲ្យបានទាន់ពេលវេលា នៅពេលដែលរដ្ឋាភិបាលគេបានប្រកាសបិទខ្ទប់ជាច្រើនតំបន់ ដោយសារតែការផ្ទុះខ្លាំងជំងឺកូវីដ-១៩ ក្នុងប្រទេសថៃ៖ «នៅពេលដែលរដ្ឋាភិបាលខ្មែរប្រកាសបានបិទខ្ទប់តាមការដ្ឋានសំណង់ឬរោងចក្រនានា គឺពលករទាំងអស់ហ្នឹងគាត់លំបាកមែនទែន ព្រោះថា គេហាមមិនឲ្យចេញចូលទាំងអស់ យើងចង់ទៅវិញរបស់របរហូបចុកខាងក្រៅក៏មិនអាចទៅទិញបានដែរ ព្រោះគេមានទាំងទាហាន ទាំងប៉ូលិស នៅយាមតាមច្រកការដ្ឋានសំណង់ហ្នឹង ពួកគាត់មិនអាចចេញខាងក្រៅបានទេ។ មួយផ្នែកទៀតចំពោះបងប្អូនដែលឆ្លងជំងឺគឺពួកគាត់ទទួលមិនបានសេវាឲ្យទាន់ពេលវេលាទេ ដោយ

សារប្រទេសថៃ កំពុងមានការរាតត្បាតជំងឺនេះខ្លាំងក្លាដែរ អ៊ីចឹងហើយការផ្តល់សេវាកម្មមិនថា ចំពោះប្រជាជនថៃ ឬពលករចំណាកស្រុកទេ គឺមិនបានដិតដល់ទេ។ ជួនកាលបងប្អូនយើងខ្លះ ទៅឆ្លងមួយអាទិត្យហើយ គឺមិនទាន់មានឡានពេទ្យមកយកពួកគាត់ទៅព្យាបាលនៅពេទ្យដែរបាទ!»។

លោកថា រីឯចំនួនពលករខ្មែរដែលឆ្លងវិញ លោកមិនបានដឹងថា មានចំនួនប៉ុន្មានឲ្យពិតប្រាកដនោះទេ ពីព្រោះអាជ្ញាធរថៃមិនបានបូកសរុបចំនួនអ្នកឆ្លងដោយឡែកទេ គឺគេបានបញ្ចូលក្នុងស្ថិតិរួមតែមួយ។ លោក ទិត្យ ផល្លា កត់សម្គាល់ថា ពលករដែលឆ្លងខ្លាំង គឺអ្នកធ្វើការនិងស្នាក់នៅក្នុងការដ្ឋានសំណង់ ពលករតាមរោងចក្រ អ្នកធ្វើការកាត់ដេរ និងធ្វើការតាមទីផ្សារក៏បានឆ្លងខ្លាំងដែរ។ លោកថា តំបន់ដែលផ្ទុះឆ្លងខ្លាំងមាននៅទីក្រុងបាងកក និងខេត្តចំនួន១០ និងខេត្តភាគខាងត្បូងនៃប្រទេសថៃ ចំនួន ៤ ខេត្តទៀត។ លោកថា អាជ្ញាធរថៃបានដាក់ទីក្រុងបាងកក ខេត្តសាមុតសាខន ខេត្តសាមុតប្រាកាន ខេត្តប៉ាថុមថានី និងខេត្តណាខនបាថុម ជាតំបន់ក្រហម ដែលតំបន់ទាំងនេះ គឺសម្បូរដោយពលករខ្មែរធ្វើការនិងរស់នៅ។ ទន្ទឹមនឹងគ្នានេះ នៅតាមក្រុមហ៊ុន និងរោងចក្រមួយចំនួនបានចាប់ផ្តើមបិទប្រកាស និងសន្យាយកវ៉ាក់សាំងចាក់ឲ្យពលករបណ្តើរៗដែរ។ លោក ទិត្យ ផល្លា បញ្ជាក់ថា កាលពីថ្ងៃទី២ ខែកក្កដា គ្រូពេទ្យថៃ បានចុះទៅចាក់វ៉ាក់សាំងដល់ពលករខ្មែរផ្នែកនេសាទ នៅខេត្តប្រជួប គិរីខាន់ (Prachuap Khiri Khan) បានចំនួន៣រយនាក់ (៣០០)៕

## ពលករខ្មែរនៅថៃមិនទាន់ទទួលបានអាហារនិងសេវាព្យាបាលជំងឺកូវីដ១៩ សមរម្យនៅឡើយទេ

https://www.rfa.org/khmer/news/ ដោយ សន ចាន់រដ្ឋា 2021-07-03

តំណាងពលករខ្មែរប្រមាណ ២០នាក់ នាំគ្នាដាក់ញត្តិ និងថ្លែងសារ នៅមុខអគារគណៈរដ្ឋមន្ត្រីថៃ និងរដ្ឋសភាថៃ នៅទីក្រុងបាងកកនៅព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដើម្បីស្នើសុំអាជ្ញាធរប្រទេសនេះឱ្យជួយដោះស្រាយបញ្ហាពលករ ដែលកំពុងអត់អាហារ និងមិនទទួលបានសេវាព្យាបាលជំងឺកូវីដ១៩ (Covid-19) សមរម្យ។ ពលករមួយចំនួន ដែលកំពុងរងការបិទខ្ទប់នៅក្នុងការដ្ឋានសំណង់ក្នុងប្រទេសថៃមិនទាន់ទទួលបានការផ្គត់ផ្គង់អាហារ និងសេវាព្យាបាលជំងឺកូវីដ១៩(Covid-19) បានសមរម្យនៅឡើយទេ បើទោះជារដ្ឋាភិបាលប្រកាសថា ស្ថានភាព និងអាជ្ញាធរថៃកំពុងជួយពួកគាត់ក៏ដោយ។ អ្នកឃ្លាំមើលសិទ្ធិពលករជំរុញឲ្យរដ្ឋាភិបាលពន្លឿននីតិវិធី និងសកម្មភាពជួយកម្មករជាបន្ទាន់។ ជិតមួយសប្តាហ៍ហើយពលករមួយចំនួននៅតែប្រឈមបញ្ហាខ្វះខាតអាហារ និងមិនទទួលបានសេវាព្យាបាលជំងឺកូវីដ១៩ បានសមរម្យនៅឡើយទេ តាមមន្ទីរពេទ្យក្នុងប្រទេសថៃ។

ពលករម្នាក់ធ្វើការសំណង់នៅជាយទីក្រុងបាងកកលោក ណុប លីន ឲ្យដឹងថា ប៉ូលិសថៃបានហ៊ុមព័ទ្ធបិទខ្ទប់ និងយាមកាមនៅការដ្ឋានសំណង់ដែលលោកធ្វើការជិតមួយសប្តាហ៍ហើយ។ លោកបន្តថា អាជ្ញាធរថៃបានផ្គត់ផ្គង់អាហារហូបចុកខ្លះដល់កម្មករ និងអនុញ្ញាតឲ្យពួកលោកដើររើសខ្យងនិងបេះត្រកួននៅខាងក្រោយការដ្ឋានសំណង់បាន។ ប៉ុន្តែលោកថា សម្រាប់ពលករដែលគ្មានការងារធ្វើ ហើយមិនរងការបិទខ្ទប់វិញ ពួកគាត់មិនទទួលបានការផ្គត់ផ្គង់អាហារពីរដ្ឋាភិបាលថៃនោះទេ។ អ្នកខ្លះត្រូវដើររើសខ្យង បេះត្រកួន និងដើរសុំបាយវត្តហូបដោយខ្លួនឯង។ ចំណែកស្ថានភាពពលករឆ្លងជំងឺកូវីដ១៩វិញ លោក ណុប លីន ឱ្យដឹងថា ពួកគាត់នៅតែមិនទទួលបានសេវាព្យាបាលទាន់ពេលវេលាដដែល ដោយពួកគាត់ត្រូវដេកនៅបន្ទប់ជួលឬនៅកន្លែងធ្វើការជិតមួយសប្តាហ៍ទើបមានឡានពេទ្យមកដឹកយកទៅព្យាបាលដោយសារបញ្ហាខ្វះគ្រែ៖ «ខ្ញុំទៅចាប់ខ្យងព្រឹកមិញហ្នឹងទៅជួបគេដែរ ហើយសួរគ្នាថៅកែបងឯងគេឲ្យអ្វីហូបអត់? ជួបខ្មែរយើងដូចគ្នាហ្នឹងសួរថា ថៅកែគេឲ្យអ្វីហូបអត់? គាត់ថាគ្មានបានទេបងអើយ។ អ្នកខ្លះថៅកែគេរ៉ាប់ប្រឈម (ជានារ៉ាប់រង) អ្នកខ្លះ ថៅកែគេអត់រ៉ាប់ប្រឈម»។ ពលករខ្មែរបានជួបការលំបាកខ្លាំងចាប់តាំងពីអាជ្ញាធរថៃបានបិទខ្ទប់ការដ្ឋានសំណង់ និងពង្រឹងវិធានការតឹងរ៉ឹងមួយចំនួននៅទី

ក្រុងបាងកក និងខេត្តទាំង៥ដែលនៅជុំវិញនោះដើម្បីទប់ស្កាត់ការរាលដាលជំងឺកូវីដ១៩។ កាលពីថ្ងៃទី៣០ មិថុនា តំណាងពលករប្រមាណ២០នាក់ បាននាំគ្នាតវ៉ានិងដាក់ញត្តិទាមទារឲ្យរដ្ឋាភិបាលថៃ និងរដ្ឋសភាថៃយកចិត្តទុកដាក់ជួយផ្គត់ផ្គង់អាហារ និងផ្តល់សេវាព្យាបាលដល់ពលករខ្មែរឲ្យបានសមរម្យ។

ទាក់ទងនឹងករណីនេះដែរ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងកាលពីថ្ងៃទី១ កក្កដាថា អាជ្ញាធរថៃនឹងមិនដាក់ទោសទណ្ឌចំពោះពលករមិនស្របច្បាប់នោះទេ ប៉ុន្តែថែមទាំងផ្តល់ការចុះឈ្មោះឲ្យពលករទាំងនោះក្លាយជាស្របច្បាប់វិញ។ លោកជំរុញឲ្យក្រសួងពាក់ព័ន្ធជួយស្ថានទូតខ្មែរនៅប្រទេសថៃ ដើម្បីផ្សព្វផ្សាយឲ្យពលករបានដឹងនិងពន្យល់កម្មករកុំឲ្យធ្វើដំណើរវិលត្រលប់មកកម្ពុជាវិញ៖ «អ្នកដែលមានការងារធ្វើស្របច្បាប់អត់មានការភ័យខ្លាចទេ។ ប៉ុន្តែអ្នកដែលអត់មានការទៅមិនស្របច្បាប់ ធ្វើការមិនស្របច្បាប់ ទាំងថៅកែទាំងកម្មករសុទ្ធតែភ័យ។ ប៉ុន្តែខាងភាគីថៃគេបានបញ្ជាក់ហើយថា នៅពេលដែលគេរកឃើញ គេមិនដាក់ទោសទណ្ឌទេ។ ផ្ទុយទៅវិញ គេចុះឈ្មោះឲ្យធ្វើការស្របច្បាប់»។

អាស៊ីសេរីមិនអាចសុំការបញ្ជាក់បន្ថែមពីឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ លោក អ៊ុក សោភ័ណ្ឌ និងអ្នកនាំពាក្យក្រសួងការបរទេសលោក កុយ គួង បានទេ នៅថ្ងៃទី៣ កក្កដា។ ទោះយ៉ាងណាស្ថានទូតកម្ពុជាប្រចាំប្រទេសថៃបានបង្ហោះសារលើហ្វេសប៊ុក (Facebook)ថា ពលករសំណង់ដែលរងការបិទខ្ទប់នឹងទទួលបានការជួយពីអាជ្ញាធរថៃដោយអ្នកធ្វើការក្នុងប្រព័ន្ធធានារ៉ាប់រងសង្គម នឹងទទួលបានប្រាក់៥០%នៃប្រាក់ឈ្នួល។ ឯអ្នកធ្វើការក្រៅប្រព័ន្ធធានារ៉ាប់រងសង្គមនោះ ពលករត្រូវសុំការឧបត្ថម្ភពីថៅកែដោយផ្ទាល់។ ស្ថានទូតបង្ហាញទៀតថា ការផ្គត់ផ្គង់អាហារក៏ត្រូវស្នើសុំនិយោជកទទួលបន្ទុកផ្គត់ផ្គង់មួយថ្ងៃ ៣ពេលដែរ។ ឯការពិនិត្យជំងឺវិញគ្រូពេទ្យនឹងចុះពិនិត្យដល់ក្នុងការដ្ឋានហើយក្នុងករណីមានវិជ្ជមាននឹងនាំទៅព្យាបាលជាដើម។ ទោះជាយ៉ាងណាស្ថានភាពជាក់ស្តែងវិញមិនមែនងាយស្រួលបែបនេះទេ ព្រោះថៅកែភាគច្រើនមិនបានអើពើពីសុខទុក្ខពលករឡើយ ដោយអះអាងថា មានលទ្ធភាពជួយដែរ។

មន្ត្រីផ្នែកអន្តោប្រវេសន៍ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា អង្គការសង់ត្រាល់ (CENTRAL) ប្រចាំប្រទេសថៃលោក លឹង សុផុន មើលឃើញថា វិធានការរបស់អាជ្ញាធរខ្មែរនិងថៃដែលសន្យាជួយពលករនោះមានភាពយឺតយ៉ាវណាស់។ លោកឲ្យដឹងថា ពលករកាន់តែច្រើនឡើងជួបបញ្ហាកាន់តែលំបាកពីមួយថ្ងៃទៅមួយថ្ងៃដោយសារគ្មានការងារធ្វើនិងគ្មានអាហារបរិភោគ។ លោកអះអាងពលករទាំងនោះភាគច្រើនទទួលបានប្រាក់កម្រៃប្រចាំថ្ងៃហើយពួកគេធ្វើការសំណង់ ឬមុខរបរក្រៅប្រព័ន្ធមួយថ្ងៃសម្រាប់ហូបតែមួយថ្ងៃប៉ុណ្ណោះមិនមានប្រាក់ឈ្នួលប្រចាំខែ ឬចំណូលផ្សេងទេ។ អ្នកឃ្លាំមើលសិទ្ធិពលករនៅប្រទេសថៃរូបនេះជំរុញឲ្យអាជ្ញាធរខ្មែរ និងថៃពន្លឿនសកម្មភាពជួយពលករឱ្យបានលឿន៖ «សូមឲ្យពន្លឿនវិធានការហ្នឹងឲ្យបានលឿនជាងហ្នឹងណា ដើម្បីជួយពួកគាត់។ កុំឲ្យគាត់មានបញ្ហាប្រឈម។ នៅពេលដែលពួកគាត់ប្រឈមខ្វះអាហារហ្នឹងអាចធ្វើឲ្យពួកគាត់ហ្នឹងមានការភ័យខ្លាចពីជំងឺ ហើយអាចលួចរត់ពីកន្លែងដែលគាត់ស្នាក់នៅពីកន្លែងដែលគាត់ធ្វើចត្តាឡីស័កទៅកន្លែងផ្សេងណា។ ធម្មតាទេ ដឹងស្រាប់ហើយមិនថា គេមិនថាខ្ញុំ តែខ្វះខាតហើយ រកអាហារហើយ ឬរត់ចេញពីកន្លែងហ្នឹងណា»។

របាយការណ៍របស់អង្គការសង់ត្រាល់បង្ហាញថា ពលករខ្មែរធ្វើការក្នុងប្រទេសថៃ មានជិតពីរលាន (២.០០០.០០០)នាក់។ ពួកគាត់ភាគច្រើនជាពលករផ្នែកសំណង់រោងចក្រ និងក្នុងវិស័យកសិកម្ម។ ពួកគាត់រងផលប៉ះពាល់ធ្ងន់ធ្ងរចុងក្រោយនេះគឺចាប់តាំងពីចុងខែមិថុនា មកដោយសាររដ្ឋាភិបាលថៃបិទខ្ទប់ការដ្ឋានសំណង់និងរឹតបន្តឹងវិធានការទប់ស្កាត់ជំងឺកូវីដ១៩ នៅទីក្រុងបាងកក និងខេត្តទាំង៥។ ពលករខ្លះនាំគ្នាធ្វើដំណើរទាំងប្រថុយនឹងឆ្លងជំងឺកូវីដ-១៩ ដើម្បីត្រឡប់មកកម្ពុជាវិញដោយសារការខ្វះខាតធ្ងន់ធ្ងរដោយក្នុងមួយថ្ងៃមានប្រមាណបីរយ(៣០០)នាក់៕

## ពលករខ្មែរ៤៦គ្រួសារនៅថៃ ជួបការលំបាកដោយសារបិទខ្ទប់ការដ្ឋានសំណង់ទទួលអំណោយពីទូតខ្មែរ

https://dap-news.com/national/ BySKK106 Posted on July 5, 2021

**ភ្នំពេញ ៖** ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះចែកអំណោយជាគ្រឿងឧបភោគបរិភោគមាន អង្ករ មី ត្រីខ ទឹកសុទ្ធ បន្លែ សាច់មាន់-ជ្រូក ដល់ពលករខ្មែរដែលកំពុងជួបការលំបាកខ្លាំងបំផុត ដោយសារការរាតត្បាតជំងឺកូវីដ១៩ ចំនួន ២ ទីតាំងនៅក្នុងទីក្រុងបាងកក នៅព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១ ។ ការចុះចែកអំណោយដល់ពលករសំណង់ចំនួន៤៦គ្រួសារដែលត្រូវបានបិទខ្ទប់ការដ្ឋានសំណង់នៅបរិវេណសហគមន៍វត្តម៉ាក់កៈសាន់ ខណ្ឌផៈយ៉ាថៃ ទីក្រុងបាងកក ៕

## ទូតខ្មែរនៅថៃ ចុះចែកអំណោយ ដល់ពលករខ្មែរ ៧០គ្រួសារ ដែលកំពុងជួបការលំបាកខ្លាំង

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១

(ភ្នំពេញ)៖ នៅព្រឹកថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ សហការជាមួយមូលនិធិ LPN ចុះចែកអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារប្រើប្រាស់រួមមាន អង្ករ មី ត្រីខ ប្រេងឆា ត្រីងៀត អំបិល ប្រហុក និងម៉ាស ដល់បងប្អូនពលករខ្មែរចំនួន ៧០គ្រួសារ ធ្វើការនៅខេត្តឆាក់ឈើងសៅ ដែលកំពុងជួបការលំបាកខ្លាំងបំផុត ដោយសារការរាតត្បាតជំងឺកូវីដ១៩ រលកទី៣នៅក្នុងប្រទេសថៃ៕

# ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១

## អាជ្ញាធរនៃខេត្តជាប់ព្រំដែនកម្ពុជា-ថៃ រៀបចំឱ្យពលករមកពីថៃធ្វើចត្តាឡីស័កនៅតាមព្រំដែន

https://www.postkhmer.com/ ឡាយ សាមាន | Publication date 06 July 2021 | 09:29 ICT

**ភ្នំពេញ:** អាជ្ញាធរនៃបណ្ដាខេត្តមួយចំនួនជាប់ព្រំដែនកម្ពុជា-ថៃ បានរឹតបន្តឹងការធ្វើចត្តាឡីស័កជាថ្មី ដោយបន្ថែមមណ្ឌលចត្តាឡីស័កសម្រាប់ពលករត្រឡប់មកពីប្រទេសថៃ បន្ទាប់ពីមានបញ្ជាពីលោក ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ លោក ហ៊ុន សែន កាលពីថ្ងៃទី ១ ខែកក្កដា បានដាក់បទបញ្ជាដល់ខេត្តជាប់ព្រំដែនត្រូវពង្រឹងការធ្វើចត្តាឡីស័ក និងមិនអនុញ្ញាតឱ្យពលករដែលត្រឡប់មកពីប្រទេសថៃទៅធ្វើចត្តាឡីស័កនៅទីឆ្ងាយឡើយ។ លោកនាយករដ្ឋមន្ត្រីថ្លែងថា៖ «អ្វីដែលជាកង្វល់ធំសម្រាប់យើង គឺព្រំដែនកម្ពុជាដែលបញ្ហាសំខាន់មិនមែនជនជាតិថៃចូលមកកម្ពុជានោះទេ គឺកម្មករកម្ពុជាយើងដែលទៅធ្វើការនៅប្រទេសថៃ ត្រឡប់ចូលមកកម្ពុជាព្រោះអត់ការងារធ្វើ»។ លោកបន្តថា៖ «ដែលមុននេះយើងឱ្យធ្វើចត្តាឡីស័កនៅទល់ដែន ប៉ុន្តែក្រោយមកយើងឱ្យធ្វើការវាស់កម្ដៅ ក្រោយពិនិត្យរួចហើយដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅខាងក្នុង។ ប៉ុន្តែរយៈពេលចុងក្រោយនេះ.... ពលករត្រូវធ្វើចត្តាឡីស័កនៅតាមព្រំដែនទាំងអស់ នេះគឺជាចំណុចដែលត្រូវការយកចិត្តទុកដាក់ខ្ពស់ជាមួយព្រំដែនថៃ ដែលត្រូវពង្រឹងឡើងវិញនៅកន្លែងធ្វើចត្តាឡីស័ក»។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យកាលពីថ្ងៃទី ៤ កក្កដានេះ បានដឹកនាំក្រុមការងាររៀបចំបន្ថែមមណ្ឌលចត្តាឡីស័ក ៣ កន្លែងទៀត នៅសាលាបឋមសិក្សាអូរអំបិល សាលាបឋមសិក្សាភ្នំបាក់ ក្រុងសិរីសោភ័ណ និងមណ្ឌលចត្តាឡីស័កនៅវិទ្យាល័យ ហ៊ុន សែន មង្គលបុរី ស្រុកមង្គលបុរី។ លោកថ្លែងថា ក្នុងនាមគណៈកម្មការខេត្តប្រយុទ្ធនឹងជំងឺកូវីដនឹងបន្តខិតខំដោះស្រាយ ទប់ស្កាត់ និងគ្រប់គ្រងបងប្អូនត្រឡប់មកពីថៃ និងអ្នកពាក់ព័ន្ធដើម្បីដាក់ធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ហ្មត់ចត់ជាប់ជានិច្ច។

លោក សេក សុខុម ប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យប្រាប់ភ្នំពេញប៉ុស្តិ៍ថា សម្រាប់ខេត្តរបស់លោក បានត្រៀមលក្ខណៈរួចជាស្រេចរៀបចំកន្លែងធ្វើចត្តាឡីស័កសម្រាប់ពលករមកពីថៃ។ លោកថា៖ «ខេត្តបន្ទាយមានជ័យយើងមានច្រកចេញចូល ៣ កន្លែងជាមួយថៃ គឺច្រកម៉ាឡៃ ច្រកអន្តរជាតិប៉ោយប៉ែត និងច្រកអូរ៣ជាន់។ ប៉ុន្តែច្រកអូរ៣ជាន់ ជាច្រកទ្វេភាគីកម្ពុជា-ថៃ យើងអនុញ្ញាតឱ្យពលករចូលមកតាមច្រកនេះ ដើម្បីងាយស្រួលគ្រប់គ្រង ហើយយើងមានមណ្ឌលចត្តាឡីស័ក ១ ចម្ងាយប្រហែល ៣០០ ម៉ែត្រពីព្រំដែន ដែលតម្រូវឱ្យពលករត្រូវធ្វើចត្តាឡីស័ក»។ លោកឱ្យដឹងដែរថា កន្លងមកពលករមកពីថៃតាមខេត្តបន្ទាយមានជ័យ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅទីតាំងរៀងៗខ្លួនដែលនៅឆ្ងាយ ប៉ុន្តែក្រោយពីទទួលបានអនុសាសន៍ពីប្រមុខថ្នាក់ដឹកនាំ ក្រុមការងារថ្នាក់ខេត្តសម្រេចឱ្យពលករធ្វើចត្តាឡីស័កនៅក្នុងមូលដ្ឋានវិញ។ លោកថា៖ «ដោយសារ កន្លងមកពលករមកពីថៃឆ្លងកាត់បន្ទាយមានជ័យ បើពលករនៅសៀមរាប យើងបញ្ជូនទៅសៀមរាប បើនៅកំពង់ចាមយើងដឹកទៅធ្វើចត្តាឡីស័កនៅកំពង់ចាម តែដោយសារកូវីដ១៩ ផ្ទុះខ្លាំង លោកនាយករដ្ឋមន្ត្រីបានណែនាំឱ្យធ្វើចត្តាឡីស័កនៅតាមព្រំដែនសិន»។

លោក សេក សំអុល នាយករដ្ឋបាលខេត្តកោះកុងបានថ្លែងថា ក្រុមការងារជំនាញខេត្តកំពុងសិក្សាពីលទ្ធភាពក្នុងការសង់មណ្ឌលចត្តាឡីស័កនៅតាមបន្ទាត់ព្រំដែននៅច្រកអន្តរជាតិចាំយាម សម្រាប់ធ្វើចត្តាឡីស័កពលករដែលមកពីថៃ ដើម្បីការពង្រឹងវិធានការតាមព្រំដែន។ លោកថា៖ «យើងកំពុងពិនិត្យមើលលទ្ធភាពថាតើអាចសង់មណ្ឌលចត្តាឡីស័ក នៅតាមបន្ទាត់ព្រំដែនបានដែរទេ ព្រោះស្ថានភាពភូមិសាស្ត្រវាមិនអំណោយផលព្រោះមានភ្នំច្រើននិងចំណាយច្រើន»។ លោកបន្តថា បច្ចុប្បន្នខេត្តបានរៀបចំមជ្ឈមណ្ឌល Q2 នៅសាលាខេត្តចាស់សម្រាប់ទទួលពលករមកពីក្រៅប្រទេសជាពិសេសពីប្រទេសថៃ ហើយពលករណាក៏ដោយឱ្យតែឆ្លងចូលកម្ពុជា ត្រូវតែឱ្យធ្វើចត្តាឡីស័ក ១៤ ថ្ងៃសិន និងបន្តពិនិត្យកម្តៅ»។ លោក សំអុល ឱ្យដឹងដែរថា បើគិតពីខែមេសា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០២១ ពលករដែលត្រឡប់មកពីប្រទេសថៃមានចំនួន ១ ៣៩៤ នាក់ ក្នុងចំណោមពលករទាំងនោះ រកឃើញវិជ្ជមានតែម្នាក់ប៉ុណ្ណោះ។

លោក សួស សុភ័ក្រ្ត ប្រធានមន្ទីរព័ត៌មានខេត្តបាត់ដំបងបានថ្លែងថា ដើម្បីពង្រឹងវិធានការតាមព្រំដែន និងវិធានការឆ្លងសហគមន៍ឱ្យមានប្រសិទ្ធភាព រដ្ឋបាលខេត្តគ្រោងបន្ថែមគ្រែសម្រាប់ព្យាបាល និងធ្វើចត្តាឡីស័កឱ្យបាន ៦ ពាន់គ្រែ។ លោកថា៖ «អភិបាលខេត្តលោកបានខិតខំពង្រីកបន្ទប់ និងគ្រែទាំងនៅតាមព្រំដែន និងនៅក្រុងបាត់ដំបងយ៉ាងហោចណាស់ឱ្យបាន ៦ ពាន់គ្រែ។ បច្ចុប្បន្ននៅបាត់ដំបងមានច្រកព្រំដែនចំនួន ៣ ហើយយើងមានមណ្ឌលចត្តាឡីស័ក ៣ ដែរ ប៉ុន្តែទាំង ៣ ទីតាំងមានតែ ៨០០ គ្រែទេ អ៊ីចឹងថ្នាក់ដឹកនាំខេត្តគ្រោងពង្រីកដល់ ១ ៦០០ គ្រែ សម្រាប់ពលករធ្វើចត្តាឡីស័ក»។ លោកថ្លែងថា គិតពីថ្ងៃ «ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ» នៃការរីករាលដាលជំងឺកូវីដ ១៩ ពលករកម្ពុជាដែលត្រឡប់មកពីប្រទេសថៃវិញតាមច្រកខេត្តបាត់ដំបងមានជិត ៣ ម៉ឺននាក់៕

## តុលាការរាជធានីភ្នំពេញ ផ្តន្ទាទោសប្តីប្រពន្ធវៀតណាម ២ នាក់ ដាក់គុក ៥ ឆ្នាំ ពាក់ព័ន្ធនឹងការបើកហាងខារ៉ាអូខេ តែ លួចបង្កប់សេវាកម្មសិច

https://cen-news.com/ Posted ByPen Srey NeatJuly 6, 2021

ភ្នំពេញ ៖ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី៦ ខែ កក្កដា ២០២១នេះ បានប្រកាសសាលក្រមផ្តន្ទាទោសជនជាប់ចោទ២នាក់ ដែលត្រូវជាប្តីប្រពន្ធនឹងគ្នាដោយដាក់គុក កំណត់០៥ ឆ្នាំ ក្នុងម្នាក់ៗ តែការអនុវត្តន៍ទោស នៅក្នុងពន្ធនសគារ មានរយៈពេលត្រឹមតែតែ ២ ឆ្នាំប៉ុណ្ណោះ។ ទោសនៅសេសសល់ត្រូវព្យួរទាំងអស់ជាប់ពាក់ព័ន្ធនឹងការបើកហាងខារ៉ាអូខេ តែ លួចបង្កប់សេវាកម្មសិច ឬ រ៉ែសិច ដោយគ្មានការអនុញ្ញាត។

លោ ធាម ច័ន្ទពិសិដ្ឋ ជាចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ បានថ្លែងក្នុងសវនាការប្រកាសាលក្រមថា ជនជាប់ចោទវៀតណាមទាំង២នាក់នេះ មានឈ្មោះ ង្វៀង បានចៀន ភេទប្រុស និង ឈ្មោះ ហ្វាម ធី

មិនធូ ភេទស្រី។ ជនជាប់ចោទទាំង០២នាក់ ត្រូវបានជាប់ចោទ ពីបទ" សញ្ចារកម្មមានស្ថានទម្ងន់" នៃ ច្បាប់ស្តីពីការបង្រ្កាបអំពីជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ។ ពួកគេត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៥ ខែមីនាឆ្នាំ ២០២០ នៅចំណុចផ្ទះជួលបើកហាងខារ៉ាអូខេរបស់ពួកគេ នៅក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ៕ រក្សាសិទ្ធិដោយ ចន្ទា ភា

## ពលរដ្ឋខ្មែរ មកពីថៃ ៤១នាក់ ត្រូវបានរកឃើញវិជ្ជមានជំងឺកូវីដ-១៩ ក្នុងនោះ ៤នាក់ ជាមេរោគបំប្លែងថ្មី Delta

https://kohsantepheapdaily.com.kh/ Siem Reap០៦ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២០:២៣

ខេត្តសៀមរាបៈ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១ មានបងប្អូនប្រជាពលរដ្ឋខ្មែរ ដែលបានត្រឡប់មកពីប្រទេសថៃ ចំនួន ៤១នាក់ ត្រូវបានរដ្ឋបាលខេត្តសៀមរាប ប្រកាសរកឃើញមានវិជ្ជមានជំងឺកូវីដ-១៩ ដែលជាតួលេខខ្ពស់ជាងគេ មិនធ្លាប់មានប្រចាំថ្ងៃកន្លងមក។ ដូច្នេះគិតត្រឹមយប់ថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ២០២១ មានពលរដ្ឋខ្មែរ ចំនួន ២៣៣នាក់ ក្នុងចំណោមពលរដ្ឋខ្មែរ មកពីប្រទេសថៃចំនួន ២៨.៤២៥នាក់ មានវិជ្ជមានជំងឺកូវីដ-១៩។ ក្នុងនោះ បានព្យាបាលឲ្យជាសះស្បើយចំនួន ១០២នាក់ និងកំពុងសម្រាកព្យាបាល ចំនួន ១៣១នាក់។

គួររំលឹកថា ក្នុងចំណោមពលរដ្ឋខ្មែរ មកពីប្រទេសថៃចំនួន ២៣៣នាក់ ដែលមានវិជ្ជមាន ជំងឺកូវីដ-១៩ នោះ មានបងប្អូនពលករខ្មែរ ចំនួន ០៤នាក់ ត្រូវបានរកឃើញវីរុសកូវីដ-១៩ បំប្លែងថ្មី ប្រភេទ21A/B-1-617.2 (Delta) ជាប្រភេទវីរុស ដែលវាមានសមត្ថភាពចម្លងលឿនរហ័ស និងកាចសាហាវជាងមុន ធ្វើឲ្យអ្នកជំងឺស្លាប់លឿន ប្រសិនបើអ្នកជំងឺនោះ កើតរោគសញ្ញាសួតធ្ងន់ធ្ងរ ហើយពេទ្យជួយមិនបានទាន់ពេលវេលា។ ក្នុងនោះ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ មានចំនួន ០២នាក់ និងនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ មានចំនួន ០២នាក់ បានស្លាប់។

សូមរម្លឹកថា កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២១ រដ្ឋបាលខេត្តសៀមរាប បានប្រកាសពីការរកឃើញអ្នកវិជ្ជមានជំងឺកូវីដ-១៩ ថ្មី ចំនួន ១៤៤នាក់ ជាសះស្បើយ ចំនួន ២៥នាក់ និងស្លាប់ម្នាក់។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ នៅខេត្តសៀមរាប ក៏បានប្រកាសពីការរកឃើញអ្នកឆ្លងកូវីដ១៩ ចំនួន ចំនួន ៨០នាក់។ មកទល់ល្ងាចថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ នៅខេត្តសៀមរាប មានអ្នកវិជ្ជមានជំងឺកូវីដ-១៩ ចំនួន១៧៣៤នាក់ បានព្យាបាលជាសះស្បើយ ចំនួន ៦០៥នាក់ ស្លាប់ ១៨នាក់ និង១១១១នាក់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប មណ្ឌលចត្តាឡីស័កគរុកោសល្យ និងវិក្រឹតការខេត្ត និងវិទ្យាល័យដំដែក៕ ច័ន្ទ រស្មី

## កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ មកពីប្រទេសថៃ ចំនួន ៣នាក់

http://cambodiapolice.com/policekh/ 6:41 pm 6 កក្កដា 2021

**បាត់ដំបង៖** នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន៣នាក់, ស្រីចំនួន១នាក់ ។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័ក អនុវិទ្យាល័យកូនភ្នំ៣២ ស្រុក សំពៅលូន៕

## ១ថ្ងៃពលករខ្មែរត្រឡប់ពីថៃចូលកម្ពុជាវិញតាមច្រកអូរបីជាន់មាន៨៨នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដ១០នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey០៧ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៦:៥០

បន្ទាយមានជ័យ ៖ ១ថ្ងៃពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលកម្ពុជាវិញ តាមច្រកអូរបីជាន់មានចំនួន ៨៨នាក់ រកឃើញអ្នកវិជ្ជមានកូវីដ១៩ចំនួន១០នាក់ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ស្ថិតឃុំអូរបីជាន់ ស្រុកអូរជ្រៅ ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅបានប្រាប់ថា ៖ រហូតដល់ល្ងាចថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ នេះ ប្រជាពលរដ្ឋខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកម្ពុជាវិញ ដែលក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ស្រុកអូរជ្រៅ ទទួលមាន៨៨នាក់ ស្រី៣៤នាក់ ហើយត្រូវយកសំណាកធ្វើតេស្តរហ័សលទ្ធផលវិជ្ជមានកូវីដ១៩ មានចំនួន១០នាក់ ស្រី៤នាក់ ។ លោកបានបញ្ជាក់ថា ៖ ពលករខ្មែរដែលរកឃើញវិជ្ជមានកូវីដ១៩ចំនួន១០នាក់ ជាប្រជាពលរដ្ឋរស់នៅស្រុកមង្គលបូរីចំនួន២នាក់ ស្រុកព្រះនេត្រព្រះ ចំនួន១នាក់ ស្រុកម៉ាឡៃចំនួន១នាក់ ស្រុកស្វាយចេក ចំនួន២នាក់ ស្រុកអូរជ្រៅចំនួន៤នាក់ ខេត្តបន្ទាយមានជ័យដែលត្រឡប់ពីធ្វើការងារប្រទេសថៃមានខេត្តមិនបូរីចំនួន៥នាក់ ផាថុមថានីចំនួន៤នាក់ បាងកកចំនួន១នាក់ ។ លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា ៖ ចំពោះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ក្រោយក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់យកសំណាកធ្វើតេស្ត ហើយចេញលទ្ធផលអ្នកវិជ្ជមានកូវីដ១៩ ត្រូវបានបញ្ជូនទៅមណ្ឌលកងវ៉ា ដើម្បីព្យាបាលអ្នកអវិជ្ជមានកូវីដ១៩ ត្រូវបានបញ្ជូនទៅមណ្ឌលវិទ្យាល័យសម្តេចឪ ក្រុងសិរីសោភ័ណដើម្បីធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ ៕

## ខេត្តឧត្តរមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ ចំនួន៩៦នាក់ ក្នុងនោះពលករមកពីថៃ ៩០នាក់ ខណៈជាសះស្បើយ៣៦នាក់

http://freshnewsasia.com/ 2021-07-07 08:00pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន៩៦ករណីបន្ថែមទៀត និងជាសះស្បើយ ៣៦នាក់ នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១នេះ តាមរយៈការធ្វើតេស្តរហ័ស (Rapid Test)។ បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺដែលរកឃើញថ្មីទាំង៩៦នាក់ខាងលើនេះ គឺមានអ្នកជំងឺចំនួន៩០នាក់ ជាពលករមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យរកឃើញជំងឺកូវីដ១៩ ចំនួន ១,១៩២ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ១,០៦៣ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន១២៨ករណី បានព្យាបាលជាសះស្បើយចំនួន ២៣៧នាក់ កំពុងសម្រាកព្យាបាលចំនួន ៩៥០នាក់ និងស្លាប់បាត់បង់ជីវិត ៣នាក់ផងដែរ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការទទួលពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសចំនួន៤នាក់ បញ្ជូនទៅមណ្ឌលចត្តាឡីស័ក

http://cambodiapolice.com/policekh/ 5:18 pm 7 កក្កដា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និង មេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារ៉ុជ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ នៅថ្ងៃពុធ ១៣រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយកម្លាំងយោធាចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្រ្តប៉ុស្តិ៍គ្រប់គ្រង និងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ មក ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ សរុបចំនួន ៤នាក់(ស្រី២នាក់) ក្នុងនោះក្មេងស្រី១នាក់ នៅចំណុច២ទីតាំងផ្សេងគ្នា គឺចំណុចនៃភូមិសាស្រ្តភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ៣នាក់ និងចំណុចនៃភូមិសាស្រ្តភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន១នាក់ ។ បន្ទាប់ពីសាកសួរ ធ្វើកំណត់ហេតុ និងអប់រំណែនាំរួច កម្លាំងបានប្រគល់ពួកគាត់ឲ្យ ក្រុមគ្រូពេទ្យ ដើម្បីបញ្ជូនបន្តទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ស្រុក សំពៅលូន ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ១២នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១២នាក់ ស្រី ៥នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៥នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ១នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍) ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៤នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១២នាក់ ស្រី ៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១

## ថៃបិទកន្លែងធ្វើការខារទប់ស្កាត់កូវីដ ពលរដ្ឋខ្មែរនាំគ្នាមកស្រុកវិញជិត១០០នាក់ រកឃើញ១៦នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey០៨ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១០:១០

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរគ្មានការងារធ្វើ ក៏បាននាំគ្នាត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ តាមច្រកអូរបីជាន់ ដោយ១ថ្ងៃជិត១០០នាក់ ហើយក៏បានរកឃើញមានវិជ្ជមានកូវីដ១៩ ចំនួន១៦នាក់ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ នេះ។ បើតាមលោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ បានប្រាប់ថា នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១នេះ មណ្ឌលសំចតច្រកអូរបីជាន់ស្រុកអូរជ្រៅ បានទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ មានចំនួន៨៤នាក់ ក្នុងនោះស្រី៣៤នាក់ និងធ្វើការពិនិត្យសុខភាព ដោយយកសំណាកទៅធ្វើតេស្ត Rapid test ជាលទ្ធផល គឺរកឃើញមានវិជ្ជមានកូវីដ១៩ ចំនួន១៦នាក់ ក្នុងនោះស្រី៤នាក់។ លោកបានបញ្ជាក់ថា នៅពេលទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញនោះ អ្នកអវិជ្ជមានកូវីដ១៩ ក៏ត្រូវបានបញ្ជូនទៅមណ្ឌលវិទ្យាល័យសម្តេចឪ ដើម្បីធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃសិន ចំណែកអ្នករកឃើញវិជ្ជមានកូវីដ១៩ ក៏ត្រូវបានបញ្ជូនទៅមណ្ឌលព្យាបាលកងវ៉ា ក្រុងសិរីសោភ័ណ ដើម្បីសម្រាកព្យាបាលផងដែរ។

បើតាមសំដីពលករខ្មែរដែលត្រឡប់ពីថៃនោះបានប្រាប់ថា មូលហេតុដែលពួកគាត់ត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញនេះ ព្រោះតែអាជ្ញាធរថៃ បានបិទកន្លែងធ្វើការងារនៅប្រទេសថៃ ដើម្បីបង្ការទប់ស្កាត់កូវីដ១៩ នៅពេលកំពុងតែឆ្លងរីករាលដាលក្នុងប្រទេសថៃ ដូច្នេះធ្វើពលករខ្មែរគ្មានការងារធ្វើ ទើបសម្រេចចិត្តនាំគ្នាវិលត្រឡប់មកប្រទេសកម្ពុជាវិញតែម្តង៕

## អាជ្ញាធរក្រុងប៉ោយប៉ែតរឹតបន្តឹងការឃ្លាំមើលលើការវិលត្រឡប់របស់ពលករចំណាកស្រុក

https://www.khmertimeskh.com/ ខ្មែរថាមស៍ 08/07/2021

ស្របពេលដែលករណីឆ្លងនៅតែបន្តកើនឡើងនៅខេត្តបន្ទាយមានជ័យយ៉ាងឆាប់រហ័ស រួមទាំងករណីនាំចូលជាច្រើនទៀតនោះ ប៉ោយប៉ែតដែលជាក្រុងមួយរបស់ខេត្តបន្ទាយមានជ័យ បានចាប់ផ្តើមបង្កើនការឃ្លាំមើលរបស់ខ្លួនលើពលករកម្ពុជាដែលត្រឡប់មកពីប្រទេស ថៃ។

បើយោងតាមអភិបាលក្រុងប៉ោយប៉ែតលោកគាត ហ៊ុលបានឲ្យដឹងថា ចំនួនជនភៀសខ្លួនពីប្រទេសថៃមានការកើនឡើងជារៀងរាល់ថ្ងៃ ដែលនាំឲ្យមានការកើនឡើងនូវករណីនាំចូល។ លោកបានបញ្ជាក់បន្ថែមទៀតថា មន្ត្រីព្រំដែនបានបង្កើនការប្រុងប្រយ័ត្នក្នុងការត្រួតពិនិត្យសុខភាពពលរដ្ឋ ស្របតាមស្តង់ដាររបស់ក្រសួងសុខាភិបាល ដើម្បីកាត់បន្ថយការកើនឡើងនូវករណីនាំចូល និងការរីករាលដាលដល់សហគមន៍។ ទន្ទឹមនឹងនេះ លោកបានជំរុញឱ្យប្រជាពលរដ្ឋទាំងអស់ និងពលករចំណាកស្រុកដែលវិលត្រឡប់មកកម្ពុជាវិញ ត្រូវចូលរួមអនុវត្តវិធានការរបស់ក្រសួងសុខាភិបាលទាំងអស់គ្នា៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៣នាក់

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ

ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៣នាក់ ស្រី ១១នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១១នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១០នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍ ) ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៧នាក់ ស្រីចំនួន ២នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៣នាក់ ស្រី ១១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## អភិបាលខេត្តបាត់ដំបងបង្កើនការត្រួតពិនិត្យលើពលករវិល ត្រឡប់ពីថៃដើម្បីការពារការនាំ ចូលនូវវីរុសកូវីដ១៩

https://information.gov.kh/ ចេញផ្សាយថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០២១ វិទ្យុជាតិកម្ពុជា៖ ដោយ ធីណា ឌីណេ

បាត់ដំបង៖ អភិបាលខេត្តបាត់ដំបង បានបង្កើនការត្រួតពិនិត្យលើពលករវិលត្រឡប់ពីប្រទេសថៃ ឱ្យកាន់តែម៉ត់ចត់បន្ថែមទៀត ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ ខណៈកាលពីពេលកន្លងទៅ បានរកឃើញប្រភេទវីរុសបំប្លែងថ្មី B.I.617 ទៅលើពលករកម្ពុជាដែលទើបត្រឡប់មកពីប្រទេសថៃ។

ឯកឧត្តម ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំ បងមានប្រសាសន៍ឱ្យដឹងថា ក្នុងរយៈពេលចុងក្រោយនេះ ចំនួនពលករខ្មែរឆ្លងដែនមកពីប្រទេសថៃ ចូលមកស្រុកកំណើតវិញ មានការកើនឡើង ដូចនេះអាជ្ញាធរខេត្តបានរៀបចំនូវទីតាំងធ្វើតេស្តរហ័សរកមេរោគកូវីដ-១៩ មាននៅច្រកទ្វារព្រំដែនអន្តរជាតិដូង ច្រកតំបន់អូរអន្លក់ ច្រកតំបន់អូរជ្រៃ និងច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ទៅលើអ្នកបើកបររថយន្ត និងពលករទើបត្រឡប់មកពីប្រទេសថៃ ។ ឯកឧត្តមបន្តថា បន្ទាប់ពីបានរៀបចំទីតាំងសម្រាប់ធ្វើតេស្តរហ័សនៅតាមបន្ទាត់ព្រំដែន ទៅលើពលករទើបត្រឡប់មកពីប្រទេសថៃ និងអ្នកបើកបររថយន្ត ត្រូវបានរកឃើញមានវិជ្ជមានកូវីដ-១៩ ជាបន្តបន្ទាប់។

ដើម្បីចូលរួមទប់ស្កាត់នូវការនាំចូលពីប្រទេសជិតខាង និងបង្ការការចម្លងជំងឺកូវីដ-១៩ ឱ្យកាន់តែមានប្រសិទ្ធភាព ឯកឧត្តមអភិបាលខេត្ត បានចាត់ឱ្យមន្ត្រីជំនាញនៅតាមច្រកព្រំដែនកម្ពុជា-ថៃ ត្រូវបង្កើនការយកចិត្តទុកដាក់ត្រួតពិនិត្យសុខភាពពលករវិលត្រឡប់ពីថៃឱ្យបានម៉ត់ចត់ជាទីបំផុត។ ឯកឧត្តមក៏បានស្នើឱ្យប្រជាពលរដ្ឋដែលវិលត្រឡប់ពីក្រៅប្រទេស ត្រូវចូលរួមសហការជាមួយអាជ្ញាធរនៅតាមច្រកព្រំដែន និងអនុវត្តន៍តាមការណែនាំរបស់មន្ត្រីសុខាភិបាល ដើម្បីកាត់ផ្តាច់នូវការចម្លងរីករាលដាលជំងឺ កូវីដ-១៩ ចូលក្នុងសហគមន៍មូលដ្ឋាន។

ឯកឧត្តមអភិបាលខេត្ត ក៏បានស្នើឱ្យអាជ្ញាធរមូលដ្ឋាន និងមន្ត្រីដែលពាក់ពន្ធ័ទាំងអស់ត្រូវចូលរួមផ្សព្វផ្សាយអំពីវិធានការការពារ ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ របស់រាជរដ្ឋាភិបាល គណៈកម្មការប្រយុទ្ធប្រឆាំងនឹង

ជំងឺកូវីដ១៩ថ្នាក់ជាតិ និងគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ថ្នាក់ខេត្ត ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបន្ថែមទៀត ដើម្បីធានាសុខសុវត្ថិភាពក្រុមគ្រួសារ និងសង្គមជាតិទាំងអស់គ្នា។

យោងតាមរបាយការណ៍រដ្ឋបាលខេត្តបាត់ដំបងបានបង្ហាញថា កាលពីថ្ងៃទី៧ ខែកក្កដា មានពលករត្រឡប់មកពីប្រទេសថៃ ចូលតាមច្រកនានាជាប់ព្រំប្រទល់ខេត្តបាត់ ដំបងចំនួន៣៧នាក់ និងរហូតមកដល់ពេលនេះ អាជ្ញាធរខេត្តបានកំណត់មុខសញ្ញាពាក់ព័ន្ធក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ បានចំនួនសរុប៤៥២១នាក់ លទ្ធផលវិជ្ជមាន៨៦៥នាក់។ ចាប់ពីមានការឆ្លងជំងឺកូវីដ១៩ នៅក្នុងប្រទេសកម្ពុជាខេត្តបាត់ដំបងមានអ្នកឆ្លងចំនួន១៣៤០នាក់ត្រូវបានព្យាបាលជាសះស្បើយចំនួន៦៤៣នាក់ស្លាប់ចំនួន៩នាក់ និងកំពុងសម្រាកព្យាបាលចំនួន៦៨៨នាក់៕

## ឧត្តរមានជ័យមានករណីស្លាប់១នាក់ រកឃើញថ្មី១២៧ ករណី ក្នុងនោះ ១២៣ករណី ជាពលករមកពីថៃ

https://www.khmertimeskh.com/ កែវ រចនា / Khmer Times Khmer 09/04/2021

រដ្ឋបាលខេត្តឧត្តរមានជ័យ នៅនៅថ្ងៃទី៨ ខែកក្កដា បានស្រាវជ្រាវឃើញអ្នកជំងឺកូវីដ១៩ ថ្មីបន្ថែមទៀតសរុបមាន១២៧ករណី ក្នុងនោះ១២៣ ជាករណីនាំចូលពីប្រទេសថៃ ដែលជាពលករទើបវិលត្រឡប់មកស្រុកវិញ។ បន្ថែមពីនេះ ក៏មានករណីស្លាប់១នាក់ដែរ។ គិតត្រឹមថ្ងៃ៨ ខែកក្កដ ខេត្តឧត្តរមានជ័យ រកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ សរុប ១,៣១៨ករណី ក្នុងនោះ ១,១៨៥ ជាករណីនាំចូលពីប្រទេសថៃ ស្លាប់៤នាក់ ជាសះស្បើយ ២៩០នាក់ និង១,០២៣នាក់ទៀត កំពុងព្យាបាល។ អាជ្ញាធរខេត្ត សុំឱ្យប្រជាពលរដ្ឋ គោរពនូវវិធានការការពារខ្លួនឱ្យបានខ្ជាប់ខ្ជួន ពិសេសអនុវត្តវិធីការពារខ្លួន ដោយមិនត្រូវធ្វេសប្រហែសឡើយ ដោយត្រូវអនុវត្តវិធានការ ៣ការពារ ៣កុំជាប់ជានិច្ច៕

## តាមការរាយការណ៍ ស្ត្រីនេប៉ាល់ត្រូវបាននាំមកលក់នៅកម្ពុជា

https://www.khmertimeskh.com/ 09/07/2021

ស្ត្រីជនជាតិនេប៉ាល់ម្នាក់ដែលអះអាងថា ខ្លួនត្រូវបានគេជួញដូរនៅប្រទេសកម្ពុជា បានដាក់ពាក្យបណ្តឹងទៅការិយាល័យជួញដូរមនុស្ស ដើម្បីទាមទារឱ្យមានសកម្មភាពប្រឆាំងនឹងក្រុមជួញដូរ។ ប៉ូលីសបាននិយាយថា ក្រុមជួញដូរមនុស្សមួយក្រុម រួមទាំងម្នាក់ឈ្មោះ Kisan Rai ផង មកពី Dhankuta ត្រូវបានចោទប្រកាន់ពីបទនាំស្ត្រីរូបនេះមកកាន់ប្រទេសកម្ពុជា ដែលនៅទីនោះនាងត្រូវបានរាយការណ៍ថា ត្រូវបានលក់ ក្រោមលេសនៃការផ្តល់ការងារផ្នែកសំណង់ដល់នាង និងទទួលបានប្រាក់ចំនួន ១០០,០០០ Rs ក្នុងមួយខែ។ ស្ត្រីរូបនេះត្រូវបានទាក់ទងតាមរយៈបណ្តាញទំនាក់ទំនងសង្គម Facebook មុនពេលនាងក្លាយជាជនរងគ្រោះ។ ឥឡូវនេះ ឈ្មោះ Rai ត្រូវបានចាប់ខ្លួនតាមរបាយការណ៍បណ្តឹងរបស់ជនរងគ្រោះ។

ប៉ូលីសបាននិយាយថា ជនរងគ្រោះបានប្រគល់ប្រាក់ចំនួន Rs ៤៥០,០០០ ទៅឱ្យឈ្មោះ Rai ដើម្បីនាំនាងមកប្រទេសកម្ពុជា។ Rai បាននាំស្ត្រីនោះធ្វើដំណើរតាមផ្លូវ Kathmandu-Kakadvitta ក្នុងប្រទេសនេប៉ាល់ និងផ្លូវ Assam-Nagaland-Manipur ក្នុងប្រទេសឥណ្ឌា និងធ្វើដំណើរឆ្លងកាត់ប្រទេសថៃ មុនមកដល់ប្រទេសកម្ពុជា។ យោងតាមរបាយការណ៍ប៉ូលីសដែលផ្តល់ដោយជនរងគ្រោះបានលើកឡើងថា នៅក្នុងប្រទេសកម្ពុជា ជនរងគ្រោះត្រូវបានជួញដូរក្រោមលេសថា នាងត្រូវចម្អិនអាហារ និងរត់តុ។ អគ្គស្នងការប៉ូលីស Anurag Kumar Dwivedi បាននិយាយថា ការស៊ើបអង្កេតកំពុងដំណើរការ។ *Khabarhub*

## ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

## សម្តេចតេជោ ហ៊ុន សែន ប្រកាសថា ពលករមកពីថៃ ៥០០នាក់ មានជិត ២០០នាក់ ឆ្លងកូវីដ តែ Delta មិនទាន់ឆ្លងចូលសហគមន៍នៅឡើយទេ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១

(ភ្នំពេញ)៖ ក្នុងខ្លីបជាសំឡេង ដែលទំនងជាសម្តេចតេជោ ហ៊ុន សែន ថ្លែងក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី តាមប្រព័ន្ធវិដេអូ Zoom នៅព្រឹកថ្ងៃសុក្រ ទី៩ ខែកក្កដានេះ សម្តេចតេជោ ហ៊ុន សែន បានប្រកាសថា ពលករខ្មែរ មកពីថៃ ៥០០នាក់ មានជាង ២០០នាក់ រកឃើញឆ្លងកូវីដ។ ក្នុងនោះ មេរោគបំប្លែងខ្លួនថ្មី Delta មិនទាន់ឆ្លងរាលដាលចូលសហគមន៍ទេ។ ដូច្នេះ យើងត្រូវខិតខំបន្តទប់ស្កាត់ឱ្យបានជោគជ័យ។

សម្តេចតេជោ ហ៊ុន សែន លើកឡើងថា «អាល់ហ្វា វាបានចូលមកហើយ ដែលកំពុងឆ្លងរាល់ថ្ងៃ។ ប៉ុន្តែបើដែលតា ឆ្លងចូលក្នុងសហគមន៍ទៀត មហន្តរាយពិតជាកើតមាននៅក្នុងប្រទេសរបស់យើង។ លើកនេះ ខុសពីលើកមុន! ពលករមកពីថៃ លើកមុន ១០០០នាក់ កូវីដ មានត្រឹមតែ ២០-៣០នាក់។ ប៉ុន្តែឥឡូវមក ៣០០នាក់ កូវីដឡើងជាង ១០០នាក់។ ៥០០នាក់ កូវីដឡើងជិត ២០០នាក់ ហើយប្រមូលផ្តុំទៅលើខេត្តបន្ទាយមានជ័យ និងឧត្តរមានជ័យ។ ឯការរុករកឃើញ Delta គឺនៅក្នុងការនាំចូលទាំងអស់ មិនទាន់មានការឆ្លងចូលនៅសហគមន៍ទេ។ អីចឹង ត្រូវខិតខំទប់ស្កាត់»៕

## សម្តេចតេជោ ណែនាំឲ្យរដ្ឋបាលខេត្ត នៅតាមព្រំដែន ត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាព ការធ្វើចត្តាឡីស័ក ចំពោះពលករនិង ប្រជាពលរដ្ឋដែលឆ្លងដែន

https://cen-news.com/ Posted ByPen Srey NeatJuly 9, 2021

ភ្នំពេញ ៖ សម្តេចតេជោ ហ៊ុន សែន បានណែនាំឲ្យ រដ្ឋបាលខេត្តនៅតាមព្រំដែន និងអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាព ការធ្វើចត្តាឡីស័កចំពោះពលករ និង ប្រជាពលរដ្ឋដែលឆ្លងដែន ចូលព្រះរាជាណាចក្រកម្ពុជា ឱ្យបានម៉ត់ចត់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ បំប្លែងថ្មី DELTA ដ៏កាចសាហាវកុំឱ្យចូលមកក្នុងសហគមន៍។

គណៈរដ្ឋមន្ត្រី បានចេញសេចក្តីប្រកាសព័ត៌មាន ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃសុក្រ ១៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង៨និង២០នាទីព្រឹក ទីស្តីការគណៈរដ្ឋមន្ត្រីបានសហការជាមួយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមរយៈប្រព័ន្ធអនឡាញ (Zoom) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

២-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពី ការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។

៣-បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពី ស្ថាប័ននីតិប្បញ្ញត្តិ លើ «សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើ វិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពីការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់»។ ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក សម័យប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

១-សេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាដែលបានតាក់តែងឡើងថ្មីនេះ គឺដើម្បីជំនួសច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាចាស់ ដែលបានចូលជាធរមានតាំងពី ឆ្នាំ១៩៩៤ និង ឆ្នាំ២០០៣ ក្នុងគោលបំណងធ្វើឱ្យមានភាពទាក់ទាញនិងប្រសើរ

ជាងមុននការវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយឈរលើមូលដ្ឋានឯករាជ្យម្ចាស់ការ ស្ថានភាពជាក់ស្តែងរបស់ វិនិយោគិននិងសេដ្ឋកិច្ច ដែលនឹងបង្កើតក្របខ័ណ្ឌគតិយុត្តដែលមានភាពបើកចំហ មានតម្លាភាព អាចប៉ាន់ប្រមាណទុកជាមុន ក៏ដូចជាពង្រឹងភាពទាក់ទាញនិងសមត្ថភាពបំពេញបន្ថែម ជាពិសេសបានគិតគូរអំពីការផ្តល់ការលើកទឹកចិត្តដល់វិស័យអាទិភាព កម្រិតបច្ចេកវិទ្យានិងបច្ចេកទេស ការបង្កើតការងារ ការបណ្តុះបណ្តាលជំនាញ ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍនិងនវានុវត្តន៍ និង សហគ្រាសធុនតូចនិងមធ្យម។ លើសពីនេះ សេចក្តីព្រាងច្បាប់នេះក៏បានកែសម្រួលនិងធ្វើឱ្យ ប្រសើរឡើងនូវនីតិវិធីរដ្ឋបាលពាក់ព័ន្ធទៅនឹងយន្តការស្ថាប័ន និងនីតិវិធីនៃការស្នើសុំការចុះបញ្ជី គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ. )។

ជាមួយគ្នានេះដែរ ដើម្បីបង្កើនភាពប្រកួតប្រជែងនិងភាពទាក់ទាញរបស់កម្ពុជាពីសំណាក់ វិនិយោគិន សេចក្តីព្រាងច្បាប់នេះបានបំព្រួញពេលវេលាក្នុងការចេញវិញ្ញាបនបត្រចុះបញ្ជីពី៣១ថ្ងៃ ទៅ២០ថ្ងៃ ហើយការបំពេញពាក្យសុំចុះបញ្ជីអាចធ្វើទៅបានតាមរយៈការដាក់ឱ្យប្រើប្រាស់ថ្នាល បច្ចេកវិទ្យាព័ត៌មាន។ បន្ថែមលើនេះផងដែរ សេចក្តីព្រាងច្បាប់នេះក៏បានដាក់ចេញនូវការពង្រឹង យន្តការតាមដាននិងត្រួតពិនិត្យរបស់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ តាមរយៈការចុះត្រួតពិនិត្យ ក្នុងពេលតែមួយនឹងរួមគ្នា ព្រមទាំងកំណត់នូវរបបលើកទឹកចិត្តចំពោះគម្រោង គ.ល.គ. ទាំងផ្នែកពន្ធ នឹងមិនមែនពន្ធ ដើម្បីទាក់ទាញលំហូរវិនិយោគមកកាន់វិស័យដែលកម្ពុជាត្រូវការជាចាំបាច់ក្នុង បរិបទនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង។ ដើម្បីផ្តល់ភាពកក់ក្តៅដល់វិនិយោគិន សេចក្តីព្រាងច្បាប់នេះបានដាក់បញ្ចូលនូវកាតព្វកិច្ចជា អន្តរជាតិមួយចំនួនរបស់កម្ពុជា ដើម្បីបង្ហាញដល់វិនិយោគិនទាំងអស់នូវការប្តេជ្ញារបស់រាជរដ្ឋាភិបាល កម្ពុជាក្នុងការការពារវិនិយោគ និងផ្តល់ការធានាដោយអនុលោមតាមច្បាប់អន្តរជាតិនូវប្រព្រឹត្តកម្ម ដែលមិនរើសអើង ព្រមទាំងផ្តល់សេវាថែទាំវិនិយោគផងដែរ។ សេចក្តីព្រាងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា មាន១២ពួក និង៤២មាត្រា។

២-សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារដលតូវ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ច្បាប់ស្តីពីការងារ គឺជាក្របខ័ណ្ឌគតិយុត្តដ៏សំខាន់ក្នុងការលើកកម្ពស់សិទ្ធិការងារនិងភាព សុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ស្របពេលដែលកម្ពុជាចាប់ផ្តើមអភិវឌ្ឍវិស័យការងារដោយ ផ្សារភ្ជាប់ជាមួយពាណិជ្ជកម្មអន្តរជាតិ តាមរយៈការរីកចម្រើនការវិនិយោគនៃវិស័យឯកជន ជាពិសេស ការវិនិយោគលើវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងផលិតផលស្បែកជើង។ ច្បាប់ស្តីពី ការងារត្រូវបានធ្វើវិសោធនកម្មចំនួន២លើករួចមកហើយ ដែលក្នុងនោះនៅឆ្នាំ២០០៧ វិសោធនកម្ម ពាក់ព័ន្ធនឹងអត្រាប្រាក់ឈ្នួលបន្ថែមម៉ោង និងការងារពេលយប់ និងនៅឆ្នាំ២០១៨ វិសោធនកម្មពាក់ព័ន្ធ នឹងប្រាក់បំណាច់អតីតភាពការងារ។

តាមរយៈការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ និងការអនុវត្តច្បាប់ស្តីពីការងារក្នុងរយៈពេល ២ទសវត្សចុងក្រោយនេះ ពិតជាបាននិងកំពុងរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រ ចតុកោណនិងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបានផ្តល់ជំនឿទុកចិត្តបស សាធារណជនជាតិនិងអន្តរជាតិមកលើព្រះរាជាណាចក្រកម្ពុជាក្នុងការគោរពសិទ្ធិការងារ និងបាន ។ ធ្វើឱ្យលំហូរនៃការវិនិយោគវិស័យឯកជនមានការកើនឡើងជាបន្តបន្ទាប់ ដែលការងារនេះបាននាំអ្នកទៅ នូវការអភិវឌ្ឍវិស័យសង្គម-សេដ្ឋកិច្ចបច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជា។ ក្នុងបរិបទសកលភាវូបនីយកម្មនិងសមាហរណកម្មសេដ្ឋកិច្ច កម្ពុជាពិតជាមិនអាចចៀសផុតពី ឥទ្ធិពលនៃបដិវត្តន៍ឧស្សាហកម្មទី៤ ដែលបាននិងកំពុងជះឥទ្ធិពលយ៉ាងខ្លាំងលើសង្គមនិងសេដ្ឋកិច្ច ជាពិសេសការផ្លាស់ប្តូរបច្ចេកវិទ្យានៃប្រព័ន្ធផលិតកម្មក្នុងវិស័យឧស្សាហកម្មមួយចំនួនធំ។ ដើម្បី ឆ្លើយតបទៅនឹងបរិបទនេះ ការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ជាលើកទី៣នេះ មានគោលបំណង ពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជាក្នុងបរិបទនៃការវិវត្តវិស័

យសង្គម-សេដ្ឋកិច្ចក្នុងតំបន់និង សកលលោក សំដៅសម្រេចឱ្យបាននូវឋានៈជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅ ឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

តាមស្មារតីគិតគូរដល់ផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិត សម្តេចតេជោនាយករដ្ឋមន្ត្រី បានសម្រេចដ៏ខ្ពង់ខ្ពស់រក្សាទុកអត្រាប្រាក់ឈ្នួលការងារពេលយប់ឱ្យនៅចំនួន១៣០%ដដែល។ សេចក្តីព្រាងច្បាប់នេះមានពីរមាត្រា ដោយមាត្រាមួយចែងអំពីការធ្វើវិសោធនកម្ម មាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ និងមាត្រាពីរចែងអំពីការអនុវត្តច្បាប់នេះជាការប្រញាប់។

៣-បញ្ហាផ្សេងៗ៖

៣.១. អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តបញ្ជូន «សេចក្តីព្រាងច្បាប់ស្តីពីការអនុម័ត យល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពីការត្រៀមបម្រុងអង្ករ សង្គ្រោះបន្ទាន់» ទៅសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

៣.២. សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានមានប្រសាសន៍ថា៖

-រាជរដ្ឋាភិបាលនឹងបន្តទិញវ៉ាក់សាំងកូវីដ-១៩ និងសម្រេចបន្តការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ កម្ពុជាឱ្យបានតាមផែនការកំណត់ ព្រមទាំងពិចារណាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋដូសទី៣និង ក្រោមអាយុ១៨ឆ្នាំ។ គ្រប់ក្រសួងស្ថាប័ន ត្រូវយកចិត្តទុកដាក់ក្នុងការប្រើប្រាស់ឧបករណ៍តេស្តរហ័សដោយ សន្សំសំចៃ និងប្រើថវិកាសន្សំដើម្បីទិញឧបករណ៍តស្តរហ័សសម្រាប់ប្រើប្រាស់នៅក្នុងសាមី ក្រសួងស្ថាប័ន។

រដ្ឋបាលខេត្តនៅតាមព្រំដែន និងអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័កត្រូវយកចិត្តទុកដាក់ពង្រឹងសមត្ថភាពការធ្វើចត្តាឡីស័កចំពោះពលករនិង ប្រជាពលរដ្ឋដែលឆ្លងដែនចូលព្រះរាជាណាចក្រកម្ពុជាឱ្យបានម៉ត់ចត់ ដើម្បីទប់ស្កាត់ការឆ្លងរាលដាល នៃជំងឺកូវីដ-១៩ បំប្លែងថ្មី DELTA ដ៏កាចសាហាវកុំឱ្យចូលមកក្នុងសហគមន៍។

គ្រប់ក្រសួងស្ថាប័នត្រូវអនុវត្តការងារតាមប្រព័ន្ធអនឡាញ ដើម្បីធានារក្សាប្រក្រតីភាពការងារ និងចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូដ-១៩។ រក្សាសិទ្ធិដោយ៖បញ្ញាស័ក្តិ

## ខេត្តឧត្តរមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ ចំនួន១២០នាក់ ក្នុងនោះ២៦នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និង៨៤នាក់ផ្សេងទៀត ជាពលករមកពីថៃ

http://freshnewsasia.com/ 2021-07-09 07:52pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន១២០ករណីបន្ថែមទៀត និងជាសះស្បើយ ចំនួន៣នាក់ នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១នេះ តាមរយៈការធ្វើតេស្តរហ័ស (Rapid Test)។ បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១នេះ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង ១២០នាក់ ក្នុងនោះអ្នកជំងឺចំនួន ២៦នាក់ ជាពលករដែលកំពុងធ្វើចត្តាឡីស័ក និង៨៤នាក់ទៀត ជាពលករមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងចំនួន១០នាក់ទៀត ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យ បានរកឃើញជំងឺកូវីដ១៩ ចំនួន១៤៣៧ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ១២៩៤ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ

ចំនួន១៤៣ករណី បានព្យាបាលជាសះស្បើយចំនួន ២៩៣នាក់ កំពុងសម្រាកព្យាបាលចំនួន១១៤០នាក់ និងស្លាប់បាត់បង់ជីវិត ៤នាក់ផងដែរ៕

## ខេត្តឧត្តរមានជ័យរកឃើញពលករវិជ្ជមានកូវីដ១៩ចន្លោះពី៥០-៧០នាក់ជាប្រចាំ ខណៈខេត្តកំពុងប្រឈមនឹងការខ្វះទីតាំងព្យាបាល

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 09/07/2021 - 13:31

*ក្រោយពីមានការផ្ទុះរាលដាលជាថ្មីនៃជំងឺកូវីដ-១៩ នៅប្រទេសថៃ ខេត្តឧត្តរមានជ័យតាមច្រកព្រំដែនអូរស្មាច់បាន និងកំពុងទទួលពលករខ្មែរចូលមកវិញជាប្រចាំថ្ងៃ ចន្លោះពី២០០ ទៅ៣០០នាក់។ បើតាមលោកឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យ ប្រាប់វិទ្យុបារាំងអន្តរជាតិឲ្យដឹងនៅល្ងាចថ្ងៃសុក្រនេះថា ក្នុងចំណោមពលករ២០០ ទៅ៣០០នាក់ ជាប្រចាំថ្ងៃនោះ រកឃើញមានអ្នកវិជ្ជមានកូវីដ-១៩ប្រមាណពី ៥០ ទៅ ៧០នាក់។ ប្រឈមនឹងការត្រលប់មកវិញនៃពលករជាកំហុក លោកបានឲ្យដឹងថា ខេត្តកំពុងប្រឈមនឹងការខ្វះទីតាំងសម្រាប់ធ្វើចត្តាឡីស័ក និងសម្រាកព្យាបាល។*

លោក ឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យបានបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិថា ជាតួលេខគិតត្រឹមថ្ងៃទី៤កក្កដា មានពលករខ្មែរចំនួន២២៣៤នាក់កំពុងធ្វើចត្តាឡីស័ក និងសម្រាកព្យាបាលជំងឺកូវីដ-១៩ នៅទីតាំងមណ្ឌលទាំង២៣នៅក្នុងខេត្តឧត្តរមានជ័យ។ ពួកគេត្រលប់ចូលមកកម្ពុជាតាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ ដោយមានការត្រួតពិនិត្យ និងយកសំណាកជាប្រចាំពីសំណាក់មន្ត្រីជំនាញនៅច្រកព្រំដែន។ ក្នុងចំណោមនោះ ជាប្រចាំថ្ងៃមានពលករយ៉ាងហោចណាស់ពី៥០ទៅ៧០នាក់រកឃើញថាមានវិជ្ជមានកូវីដ-១៩ តាមរយៈការធ្វើតេស្តរហ័ស។ ក៏ប៉ុន្តែលោកអភិបាលរង បានបញ្ជាក់ថា ពុំអាចដឹងបានទេថាពួកគាត់ទាំងនោះមានវិជ្ជមានជំងឺកូវីដ-១៩ប្រភេទបំប្លែងខ្លួន«ដែលតា» ឬយ៉ាងណា ព្រោះរាល់សំណាកទាំងអស់ត្រូវដឹកជញ្ជូនយកមកពិនិត្យនៅឯវិទ្យាស្ថានប៉ាស្ទ័រភ្នំពេញ។ ទោះជាយ៉ាងនេះក្តីលោកថា អាជ្ញាធរខេត្តបានរៀបចំវិធានការយ៉ាងម៉ត់ចត់ ក្នុងន័យបង្ការហានិភ័យណាមួយកើតឡើង។

កាលពីថ្ងៃទី២៥ មិថុនាកន្លងទៅ ក្រសួងសុខាភិបាលបានចេញនូវសេចក្តីសម្រេចឲ្យខេត្តទាំងអស់នៅតាមតំបន់ព្រំដែនរឹតបន្តឹងការធ្វើចត្តាឡីស័ក និងទទួលអ្នកដំណើរទាំងអស់ឲ្យធ្វើចត្តាឡីស័ក និងសម្រាកព្យាបាលនៅខេត្តទាំងនោះតែម្តង ដោយមិនឲ្យដឹកជញ្ជូនទៅខេត្តសាមី ដោយសារតែការឃើញជំងឺកូវីដ-១៩បំប្លែងខ្លួនថ្មីប្រភេទ«ដែលតា»។

យ៉ាងណាក៏ដោយ ដោយសារតែចំនួនពលករខ្មែរត្រលប់ចូលមកកម្ពុជាមានចំនួនច្រើនគួរឲ្យកត់សម្គាល់ពីមួយថ្ងៃទៅមួយថ្ងៃ អភិបាលរងខេត្តឧត្តរមានជ័យ លោកឌី រ៉ាដូ បានឲ្យដឹងទៀតថា ទីតាំងសម្រាកធ្វើចត្តាឡីស័ក និងព្យាបាលទាំង២៣ នៅក្នុងខេត្តកំពុងប្រឈមនឹងសភាពខ្វះខាត។ ស្ថានការណ៍នេះត្រូវបានលោកបញ្ជាក់ថា រដ្ឋបាលខេត្តកំពុងពិចារណាយកខេត្តជាប់នឹងខេត្តឧត្តរមានជ័យ ធ្វើជាទីតាំងសម្រាកចត្តាឡីស័កនិងព្យាបាលរាល់ពលករដែលចូលមកវិញ។ ជាគោលដៅក្រោយការពិភាក្សា រដ្ឋបាលខេត្តឧត្តរមានជ័យ នឹងអាចយកខេត្តសៀមរាបសម្រាប់ដាក់សម្រាកនិងព្យាបាលបន្ថែម ព្រោះងាយស្រួលក្នុងការចល័តពលករ។

គួរបញ្ជាក់ថា គិតចាប់តាំងពីមានការផ្ទុះរាលដាលនៃជំងឺកូវីដ-១៩នៅសាមុតប្រាកានអំឡុងខែធ្នូឆ្នាំ២០២០ មក ជាតុល្យការមានពលករខ្មែរត្រលប់ចូលមកកម្ពុជាវិញតាមច្រកព្រំដែនអូរស្មាច់ចំនួន៨២៨២៥នាក់៕

## ខេត្តបន្ទាយមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដចំនួន១២០នាក់ ក្នុងនោះ១១០នាក់ ជាពលករមកពីថៃ និងជាសះស្បើយ៣នាក់

http://freshnewsasia.com/ 2021-07-09 09:02pm

**(បន្ទាយមានជ័យ)៖** រដ្ឋបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១នេះ បានបង្ហាញអត្តសញ្ញាណអ្នកវិជ្ជមានកូវីដ១៩ ចំនួន១២៥នាក់ តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) និងមានករណីជាសះស្បើយចំនួន០៣នាក់។ តាមរយៈសេចក្តីប្រកាសព័ត៌មានដែលបណ្តាញព័ត៌មាន Fresh News ទទួលបានរដ្ឋបាលខេត្តបន្ទាយមានជ័យ ក៏បានបង្ហាញពីអត្តសញ្ញាណ និងកន្លែងធ្វើការរបស់អ្នកកើតជំងឺកូវីដ១៩ ទាំង១២០នាក់ផងដែរ។ រដ្ឋបាលខេត្តបន្ទាយមានជ័យ សូមជម្រាបជូនប្រជាពលរដ្ឋ ដែលបានពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយអ្នកវិជ្ជមានខាងលើ សូមរួសរាន់ធ្វើចត្តាឡីស័កតាមផ្ទះ ក្នុងក្រុមគ្រួសាររៀងៗ ខ្លួនឱ្យបានគ្រប់១៤ថ្ងៃ ដោយមិនត្រូវពាក់ព័ន្ធ និងប៉ះពាល់ជាមួយអ្នកដទៃជាដាច់ខាត ក្នុងករណីមិនអនុវត្តកាតព្វកិច្ចចត្តាឡីស័ក រដ្ឋបាលខេត្តនឹងចាត់វិធានការផ្លូវច្បាប់ ចំពោះបុគ្គលទាំងឡាយណាដែលល្មើសនឹងវិធានសុខាភិបាលនេះ។

សូមបញ្ជាក់ថា មកទល់ពេលនេះខេត្តឧត្តរមានជ័យមានអ្នកជំងឺកូវីដ១៩ចំនួន ១,៤៣៧នាក់ បានព្យាបាលជាសះស្បើយចំនួន ២៩៣នាក់ កំពុងសម្រាកព្យាបាលចំនួន ១,១៤០នាក់ និងមានអ្នកស្លាប់ចំនួន ០៤នាក់៕

## ការធ្វើតេស្តជនទេសន្តរប្រវេសន៍ជាង ១៣ ០០០ នាក់ រកឃើញអ្នកកើតជំងឺរបេង ២០០ នាក់

https://www.postkhmer.com/national/ វ៉ន ដារ៉ា | Publication date 09 July 2021 | 10:22 ICT

**ភ្នំពេញៈ** ចាប់ពីខែមករាឆ្នាំមុនមកដល់ខែមិថុនា ឆ្នាំ២០២១នេះ អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានធ្វើតេស្តជនទេសន្តរប្រវេសន៍ជាង ១៣០០០ នាក់ រករោគឃើញអ្នកមានជំងឺរបេងប្រមាណ ២០០ នាក់ ហើយបានបញ្ជូនទៅព្យាបាលនៅមណ្ឌលសុខភាព ខណៈមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិនឱ្យដឹងថា ចាប់តាំងពីឆ្នាំ ២០១១ រហូតដល់បច្ចុប្បន្ន អ្នកឆ្លងជំងឺរបេងមានការធ្លាក់ចុះច្រើន។

លោកស្រី ឌុំ ច័ន្ទធីតា មន្ត្រីគម្រោងថ្នាក់ជាតិទទួលបន្ទុកផ្នែកសុខភាពទេសន្តរប្រវេសន៍នៃអង្គការ IOM ប្រាប់ភ្នំពេញ-ប៉ុស្ដិ៍កាលពីម្សិលមិញថា លទ្ធផលខាងលើបានរកឃើញ តាមរយៈកិច្ចសហការជាមួយក្រសួងសុខាភិបាល និងអាជ្ញាធរខេត្តបន្ទាយមានជ័យក្នុងការអនុវត្តគោលនយោបាយ សុខភាពទេសន្តរប្រវេសន៍នៅខេត្តបន្ទាយមានជ័យឱ្យកាន់តែប្រសើរឡើង។ លោកស្រីបញ្ជាក់ថា៖ «អង្គការ IOM បានធ្វើតេស្តជនទេសន្តរប្រវេសន៍ជាង ១៣ ០០០ នាក់ ដើម្បីរកមើលរោគសញ្ញាជំងឺរបេងក្នុងចំណោមនេះ ជនទេសន្តរប្រវេសន៍ប្រមាណ ២០០ នាក់ មានជំងឺរបេង និងត្រូវបានបញ្ជូនទៅទទួលការព្យាបាលក្នុងនោះក៏មានអ្នកជំងឺមួយចំនួន បានព្យាបាលជាសះស្បើយរួចហើយដែរ»។ ទិន្នន័យនេះគឺជាទិន្នន័យសរុបដែលយើងបានធ្វើតាំងពីការចាប់ផ្ដើមអនុវត្តគម្រោងកាលពីខែមករា ឆ្នាំ ២០២០ រហូតដល់ខែមិថុនា ឆ្នាំនេះ។ កាលពីការអនុវត្តគម្រោងនេះជំហានដំបូង អង្គការ IOM បានអនុវត្តចំពោះជនទេសន្តរប្រវេសន៍ដែលត្រឡប់មកពីប្រទេសថៃតាមច្រកព្រំដែនដោយផ្ទាល់ភ្លាមៗតែម្តង។ ប៉ុន្តែដោយសារស្ថានភាពនៃការរីករាលដាលជំងឺកូវីដ ១៩ ការអនុវត្តនេះបានផ្លាស់ប្តូរនៅអំឡុងខែកញ្ញាឆ្នាំមុន ដោយក្រុមការងាររបស់អង្គការបានចុះទៅធ្វើតេស្តរកមេរោគរបេងដល់ពលករនៅមូលដ្ឋាន នៅក្នុងសហគមន៍តែម្តង គឺលែងធ្វើនៅមាត់ច្រកព្រំដែនទៀតហើយ។ លោកស្រី ឌុំ ច័ន្ទធីតា បានឱ្យដឹងទៀតថា បច្ចុប្បន្នគម្រោងនេះកំពុងអនុវត្តនៅក្នុងស្រុកប្រតិបត្តិចំនួន ៣ គឺក្រុងប៉ោយប៉ែត ស្រុកមង្គលបុរី និងស្រុកម៉ាឡៃ ខណៈអង្គការ IOM នឹងពង្រីកគម្រោងនេះទៅតាមបណ្តាស្រុកផ្សេងទៀតឱ្យបានទូទាំងខេត្តបន្ទាយមានជ័យ។

លោក ហួត ចាន់យូដា នាយកមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន នៃក្រសួងសុខាភិបាលប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា ក្រុមការងាររបស់ក្រសួងសុខាភិបាលកំពុងបន្តអនុវត្តការងារ ស្វែងរកមេរោគរបេង និង

ព្យាបាលជំងឺរបេងដល់ពលរដ្ឋដដែល មិនមានការអាក់ខានឡើយ។ ចំណែកការសហការជាមួយអង្គការ IOM គឺនៅតែបន្តសហការនៅក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ លើពលករចំណាកស្រុកមកពីប្រទេសថៃ។ លោកថ្លែងថា៖ «ការងារប្រយុទ្ធប្រឆាំងនឹងមេរោគរបេង ជំងឺរបេងនេះ គឺយើងនៅបន្តដំណើរការទៅមុខជានិច្ច ទោះបីជាជំងឺកូវីដ ១៩ បានកំពុងវាយលុកក៏ដោយ។ ការងារនេះគឺតម្រូវឱ្យយើងមានកិច្ចសហការគ្នាបន្តទៀតរវាងអាជ្ញាធរ និងអង្គការសង្គមស៊ីវិលដៃគូដែលពាក់ព័ន្ធទាំងអស់»។ លោកឱ្យដឹងថា ក្នុងឆ្នាំ ២០២០ ក្រុមគ្រូពេទ្យជំនាញបានរកឃើញអ្នកជំងឺរបេងចំនួន ២៩ ១៣៦ ករណី ក្នុងនោះបានព្យាបាលជាសះស្បើយចំនួន ៩៤ ភាគរយ។ ចំណែកអត្រាស្លាប់ ដោយសារជំងឺរបេងចាប់តាំងពីឆ្នាំ ២០១១ រហូតមកដល់ឆ្នាំ ២០១៩ គឺមានការធ្លាក់ចុះជាង ៥០ ភាគរយ។ កាលពីឆ្នាំ ២០១៩ មានអ្នកស្លាប់ដោយសាររបេងចំនួន ១៧ ករណីក្នុងចំណោមប្រជាពលរដ្ឋទូទាំងប្រទេសជាង ១០ លាននាក់។ ចំណែកទិន្នន័យស្លាប់ឆ្នាំ ២០២១ មិនទាន់មានការបូកសរុបនៅឡើយទេ។ ប៉ុន្តែលោក ហួត ចាន់យូដា អះអាងថា រយៈពេល ៦ ខែឆ្នាំ ២០២១ នេះ បើប្រៀបធៀបជាមួយឆ្នាំ ២០២០ គឺមានការធ្លាក់ចុះ។ លោកបន្តថា ដោយសារការរីករាលដាលជំងឺកូវីដ១៩ សកម្មភាពប្រយុទ្ធប្រឆាំងនឹងមេរោគរបេងមួយចំនួនត្រូវបានអាក់ខាន។ ប៉ុន្តែការផ្តល់សេវាព្យាបាល និងការស្រាវជ្រាវរកមេរោគរបេង គឺនៅតែបន្តធ្វើដដែល។

លោកស្រី ឌុំ ច័ន្ទធីតា បានលើកឡើងថា ជំងឺរបេងគឺជាជំងឺឆ្លង។ ជំងឺនេះអាចមានគ្រោះថ្នាក់ដល់អាយុជីវិតប្រសិនបើអ្នកជំងឺមិនទៅទទួលការព្យាបាល។ ដូច្នេះអ្វីដែលអង្គការ IOM ព្យាយាមរកមេរោគរបេងនេះ គឺដើម្បីកំណត់រកមុខសញ្ញារកមេរោគរបេងឱ្យទាន់ពេលវេលា ការពារកុំឱ្យជនដែលមានផ្ទុកមេរោគរបេង ចម្លងទៅដល់សមាជិកគ្រួសាររបស់ពួកគេ ឬអ្នកផ្សេងទៀត។ លោកស្រីបន្តថា មេរោគបេងនេះ គឺងាយឆ្លងដូចមេរោគកូវីដ ១៩ ដែរ ហើយដើម្បីធ្វើការទប់ស្កាត់ គឺត្រូវកាត់បន្ថយការចម្លងទៅកាន់អ្នកដទៃ នៅពេលដែលរកឃើញអ្នកដែលមានរោគសញ្ញាភ្លាមៗ។ ពីព្រោះបើសិនអ្នកផ្ទុកមេរោគរបេងទៅព្យាបាលទាន់ពេល គឺមិនអាចប្រឈមនឹងការស្លាប់ទេ។ ប៉ុន្តែលោកស្រីបញ្ជាក់ថា ការព្យាបាលជំងឺនេះ គឺត្រូវការពេលវេលាយូរ រហូតដល់ ៦ ខែដោយអ្នកជំងឺត្រូវអនុវត្តទៅតាមវិជ្ជបញ្ជារបស់គ្រូពេទ្យជំនាញឱ្យបានត្រឹមត្រូវ។ លោកស្រី ឌុំ ច័ន្ទធីតា បញ្ជាក់ថា៖ «អង្គការ IOM មានក្រុមការងារទំនាក់ទំនងជាមួយមណ្ឌលសុខភាព នៅមូលដ្ឋានដោយផ្ទាល់ ដើម្បីតាមដានដល់អ្នកជំងឺរបេង ដែលត្រូវព្យាបាលដើម្បីប្រាកដថា ពួកគេនឹងអនុវត្តបានត្រឹមត្រូវតាមការណែនាំរបស់គ្រូពេទ្យ និងទទួលយកថ្នាំទៅព្យាបាលទៀងទាត់»៕

## ស្ត្រីខ្មែរម្នាក់ ប្រឹងរត់គេចពីបុរសតៃកុងឡាន ដែលប្រុងចាំនាង នៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ១០ កក្កដា ២០២១ដោយ Sorn Phanith

ស្ត្រីខ្មែរម្នាក់ខំប្រឹងរត់គេចចេញពីបិសាចតណ្ហា ទាំងខ្លួនកំពុងចោមពុង ដោយការរត់នេះគឺនៅលើទីសាធារណៈ រហូតធ្វើឲ្យមហាជនមួយចំនួនគិតថា នាងគឺជាមនុស្សវិកលចរិតថែមទៀតផង ព្រោះភាសាថៃក៏នាងមិនចេះមួយម៉ាត់។ យោងតាមការផ្សាយរបស់បណ្តាញព័ត៌មានក្នុងប្រទេសថៃបានបញ្ជាក់ថា ហេតុការណ៍បានកើតឡើងកាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១ ត្រង់ចំណុចភូមិ១៦ ឃុំសារ៉ាដែង ស្រុកបាងណាំព្រៀវ ខេត្តឆៈឈើងសៅ ប្រទេសថៃ។ ព័ត៌មានបានសង្កត់ធ្ងន់ថា នៅពេលនោះគេសង្កេតឃើញមាននារីម្នាក់ ដែលនៅលើរាងកាយមានតែសំពត់ចោមពុង គ្មានអាវ គ្មានស្បែកជើង បានរត់សុំឲ្យពលរដ្ឋនៅក្នុងតំបន់នោះជួយ ប៉ុន្តែអ្វីគ្មានបានការដោយសារតែនាងនិយាយទៅកាន់អ្នកដទៃគ្មានអ្នកណាស្តាប់បានមួយម៉ាត់ ដោយគេគិតថានាង គឺជាមនុស្សសតិមិនគ្រប់ ឬក៏ជាមនុស្សវិកលចរិត។

ដោយមិនអស់ចិត្តនឹងកាយវិការរបស់នាងទើបមានអ្នកភូមិម្នាក់ បានស្រែកហៅពលករខ្មែរដែលធ្វើការនៅក្បែរនោះមកស្តាប់ ទើបដឹងថានាង គឺជានារីខ្មែរដែលខំចំណាយប្រាក់អស់ចំនួន ៦.២០០ បាត ដើម្បីឲ្យមេខ្យល់នាំ

នាងទៅរកស្វាមី ដែលកំពុងធ្វើការនៅក្នុងស្រុកណាឌី ខេត្តប្រាជីនបូរី។ ការចំណាយប្រាក់ទាំងនេះ គឺនាងត្រូវបាន គេនាំឆ្លងតាមច្រករបៀងចូលទៅកាន់ស្រុកអារញ្ញប្រាថេត ទើបមានរថយន្តនីសាន់មួយគ្រឿងចាំដឹកបន្ត ដោយមាន គ្នាសរុបជាង២០នាក់ ហើយនាងមានឈ្មោះ ផៃ សុភា អាយុ៣២ឆ្នាំ។

នាងបានរៀបរាប់ថា នៅពេលដែលរថយន្តទម្លាក់ពលករតាមផ្លូវអស់ គឺសល់តែនាងម្នាក់គត់ទើបតែកុងរថ យន្តបាននិយាយជាភាសាខ្មែរថា ពីធ:ឈើងសៅទៅដល់ខេត្តប្រាជីនបុរី គឺមានចម្ងាយឆ្ងាយណាស់ទៅមិនដល់ទេ ដូច្នេះនាងត្រូវសម្រាកនៅផ្ទះសំណាក់មួយយប់សិនហើយ គឺនៅពេលនោះហើយ ខណៈដែលនាងកំពុងចោមពុង បម្រុងងូតទឹកស្រាប់តែអ្នកបើករថយន្តចង់ចូលទៅចាប់នាងរំលោភ ទើបនាងខំប្រឹងរត់ចេញឲ្យគេជួយតែម្តង។ ក្រោយពេលកើតហេតុពលរដ្ឋថៃ បានប្តឹងទៅក្រុមតម្រួតរួចហើយដើម្បីតាមប្រមាញ់យកអ្នកបើករថយន្តនោះមក ផ្តន្ទាទោស ព្រោះគេបានស្គាល់ស្លាកលេខរួចហើយ ដោយឡែកស្ត្រីខ្មែរក៏ត្រូវបានអ្នកភូមិជួយទាក់ទងតាមទូរសព្ទ ប្រាប់អស់ហើយ ដោយបច្ចុប្បន្នបញ្ហាដែលសំខាន់ជាងគេដែលពលរដ្ឋថៃបារម្ភ គឺនាងបានឆ្លងចូលទឹកដីថៃគ្មាន ច្បាប់អនុញ្ញាតនិងមិនទាន់បានពិនិត្យកម្តៅនិងធ្វើតេស្តរកមេរោគកូវីដ-១៩នៅឡើយ៕**អត្ថបទ៖ សោ និយមវ័ត្ន**

# ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

## ស្នងការខេត្តឧត្តរមានជ័យបញ្ជាក់ថា ការឆ្លងដែនខុសច្បាប់ចូលកម្ពុជា ត្រូវបានទប់ស្កាត់ទាំងស្រុង

https://news.btv.com.kh/ 07/11/2021 01:07 PM

ឧត្តរមានជ័យ៖ លោកឧត្តមសេនីយ៍ទោ ហួត សុធី ស្នងការនគរបាលខេត្តឧត្តរមានជ័យបានបញ្ជាក់ថា ការ ឆ្លងដែនខុសច្បាប់របស់ពលករមកពីប្រទេសថៃ ត្រូវបានទប់ស្កាត់ទាំងស្រុងក្រោយពីមានការបង្ក្រាប និងអនុវត្តតាម ផ្លូវច្បាប់ជាបន្តបន្ទាប់។ ថ្លែងក្នុងសម្ភាសន៍ជាមួយ BTV កាលពីថ្មីៗនេះ លោកឧត្តមសេនីយ៍ទោ ហួត សុធី ស្នងការ នគរបាលខេត្តឧត្តរមានជ័យបានឱ្យដឹងថា ពាក់ព័ន្ធនឹងកិច្ចការទប់ស្កាត់បញ្ហាឆ្លងរាតត្បាតជាសកលនូវជំងឺកូវីដ១៩ កងកម្លាំងនគរបាលខេត្តឧត្តរមានជ័យដោយអនុវត្តតាមបទបញ្ជា របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ជុំវិញ ការរៀបចំផែនការអនុវត្តឱ្យបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពបំផុត កងកម្លាំងនគរបាលខេត្តឧត្តរមានជ័យ ត្រូវបាន ចូលរួមយ៉ាងសកម្មក្នុងគោលដៅ ជានានូវការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ របស់បងប្អូនពលករមកពីប្រទេសថៃ ខណៈស្ថានភាពនៃការឆ្លងរាលដាលជំងឺកូវីដ១៩ ក្នុងប្រទេសថៃបន្តកើនឡើងជារៀងរាល់ថ្ងៃ។

លោកឧត្តមសេនីយ៍ទោ ហួត សុធី បានបញ្ជាក់ថា កាលពីថ្មីៗនេះនគរបាលខេត្តឧត្តរមានជ័យ បានអនុវត្ត ទៅតាមផ្លូវច្បាប់ចំពោះករណីឆ្លងដែនខុសច្បាប់ ក៏ដូចជាមេខ្យល់មួយចំនួន ស្របពេលនគរបាលវរៈការពារព្រំដែន គោក ត្រូវបានដាក់ពង្រាយតាមច្រកនានា ពិសេសច្រកល្បៀងជាដើម ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់។ ពាក់ ព័ន្ធនឹងការឆ្លងដែនរបស់ពលករមកពីប្រទេសថៃចូលតាមខេត្តឧត្តរមានជ័យ លោកឧត្តមសេនីយ៍ទោ ហួត សុធី បន្ត ថា ក្នុងពេលបច្ចុប្បន្នពលករបានប្រើប្រាស់មធ្យោបាយ នៃការធ្វើដំណើរចូលមកកម្ពុជាតាមច្រកព្រំដែនអន្តរជាតិអូរ ស្មាច់ ខណៈកងកម្លាំងនគរបាលចម្រុះបានសហការ ជាមួយកងកម្លាំងទាហានចុះល្បាតតាមបណ្តាគោលដៅទាំង ២៩ ២៤ម៉ោងលើ ២៤ម៉ោង។

ដោយឡែកពាក់ព័ន្ធ នឹងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដក្នុងសហគមន៍ លោកឧត្តមសេនីយ៍ទោ ហួត សុធី បានលើកឡើងថា កងកម្លាំងនគរបាលទាំងអស់បានខិតខំអនុវត្តទៅតាមបទបញ្ជា របស់សម្តេចតេជោនាយក រដ្ឋមន្ត្រី និងនាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ជុំវិញការទប់ស្កាត់បញ្ហាជំងឺកូវី ដ១៩ តាមរយៈការណែនាំជាប្រចាំ ហើយជាពិសេសគឺការអនុវត្តពាក់ និង៣ការពារ។ បន្ថែមលើសពីនេះ លោក

ឧត្តមសេនីយ៍ទោ ហួត សុធី បានឱ្យទៀតថា ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ក្នុងសហគមន៍ កង កម្លាំងនគរបាលបានចូលរួមការពារទីតាំងធ្វើចត្តាឡីស័ក និងមណ្ឌលព្យាបាលកូវីដ១៩ គ្រប់ទីតាំងនៃស្រុក-ក្រុង ចំនួន ៥ ផងដែរ៕ អត្ថបទ៖ សេក ឧត្តម

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ ខេត្តសៀមរាប សរុបចំនួន ១៦នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៦នាក់ ស្រី ៩នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១០នាក់ ស្រី ៥នាក់ កុមារា ១នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍ ) ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៦នាក់ ស្រី ៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋមលើសុខភាព និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតាដោយតម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ ខេត្តសៀមរាប សរុបចំនួន ២៥នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៥នាក់ ស្រី ១០នាក់ ក្នុងនោះកុមារា ១នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារា ១នាក់ កុមារី ១នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍) ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ១៤នាក់ ស្រីចំនួន ៤នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៥នាក់ ស្រី ១០នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋមលើសុខភាព និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតាដោយតម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ។ សូមបញ្ជាក់ជូនថាៈ ថ្ងៃនេះ ក្រុមការងារបានបញ្ជូនពលករ ដែលបញ្ចប់ធ្វើចត្តាឡីស័ក និងអ្នកព្យាបាលជាសះស្បើយមកពីបណ្តាខេត្តតាមព្រំដែន មានចំនួន៧៣នាក់ ស្រី៣០នាក់ ៕ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ជនជាតិវៀតណាម៣នាក់ និងអ្នករត់ម៉ូតូឌុប២នាក់មានបំណងលួចឆ្លងដែន ត្រូវកម្លាំងចម្រុះឃាត់ខ្លួន

http://nokorwatnews.com/ 10/07/2021

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៩១១ សហការជាមួយកម្លាំងយោធាបានធ្វើការឃាត់ខ្លួនជនជាតិវៀតណាម៣នាក់ និងអ្នករត់ម៉ូតូឌុបចំនួនពីរនាក់ នៅវេលាម៉ោង០៦ និង១៥នាទីព្រឹក ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២១ នៅចំណុចគោលដៅត្រួតពិនិត្យមុខប៉ុស្តិ៍សិលាខ្មែរស្ថិតនៅក្នុងភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ។ ក្នុងប្រត្តិបត្តិការឃាត់ខ្លួនជនជាតិវៀតណាមខាងលើ និងអ្នកម៉ូតូឌុបចំនួន២នាក់នោះ សមត្ថកិច្ចដកហូតវត្ថុតាងម៉ូតូចំនួន២គ្រឿង ដែលជាមធ្យោបាយដឹកជញ្ជូនជនជាតិវៀតណាមដែលមានបំណងឆ្លងដែនពីប្រទេថៃមកកម្ពុជា ។

សមត្ថកិច្ចបញ្ជាក់ថា មុននឹងទៅឃាត់ខ្លួនសួរនាំអ្នកគួរឲ្យសង្ស័យទាំងនេះគឺកម្លាំងសមត្ថកិច្ចឃើញអ្នករត់ម៉ូតូឌុប២នាក់ បានឌុបជនជាតិវៀតណាមតាមផ្លូវបម្រុងឆ្ពោះចូលក្រុងប៉ោយប៉ែត ដើម្បីបន្តដំណើរទៅប្រទេសវៀតណាម ក៏ត្រូវសមត្ថកិច្ចឈរជើងតាមគោលដៅហៅសួរនាំតែម្តង។ ក្រោយពីសមត្ថកិច្ចសួរនាំរួចរាល់ កម្លាំងនគរបាលការពាព្រំដែនគោកលេខ៩១១ រួមកងកម្លាំងយោធាដឹងថា ជនជាតិវៀតណាមទាំងនេះឆ្លងដែនចូលកម្ពុជាខុសច្បាប់ក៏បានធ្វើការឃាត់ខ្លួនហើយប្រគល់ពួកគេជូនកម្លាំងប៉ុស្តិ៍រដ្ឋបាល ដើម្បីស្រាវជ្រាវ សួរនាំរកអ្នកពាក់ព័ន្ធបន្ត៕

## ផ្ទុះខ្លាំង ក្នុងខេត្តមួយនេះ រកឃើញពលករមកពីប្រទេសថៃ ជាង ២០០នាក់ វិជ្ជមានកូវីដ១៩

https://news.sabay.com.kh/ 12/07/2021

ពលករជាច្រើននាក់មកពីប្រទេសថៃ ដែលចូលមកខេត្តឧត្តរមានជ័យ រកឃើញមានវិជ្ជមានកូវីដ១៩ ។ នេះបើតាមទិន្នន័យដែលទទួលបានពីរដ្ឋបាលខេត្ត នៅថ្ងៃទី ១១ កក្កដា ឆ្នាំ ២០២១នេះ។ នាថ្ងៃទី ១១ កក្កដា ឆ្នាំ ២០២១ ខេត្តឧត្តរមានជ័យ បានរកឃើញករណីឆ្លងថ្មី ចំនួន ២៤០ នាក់ ដែលក្នុងនោះ ពលករ ២៣៩ នាក់ ដែលមកប្រទេសថៃ មានវិជ្ជមានកូវីដ១៩ និង ១ នាក់ ជាករណីឆ្លងក្នុងសហគមន៍។ គិតត្រឹមថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២១នេះ ខេត្តឧត្តរមានជ័យ រកឃើញអ្នកវិជ្ជមានជំងឺកូវីដ១៩ ចំនួន១.៨២៥ ករណី ក្នុងនោះករណីនាំចូលពីក្រៅប្រទេសចំនួន ១៦៧៧ករណី និងករណីឆ្លងក្នុងសហគមន៍ ២០កុម្ភៈ ចំនួន ១៤៨ ករណី និងបានព្យាបាលជាសះស្បើយចំនួន ៣៧១ នាក់ កំពុងសម្រាកព្យាបាលចំនួន ១៤៥០ នាក់ និងស្លាប់ចំនួន ០៤នាក់ ៕

## តុលាការខេត្តស្រះកែវ ចេញដីកាចាប់ខ្លួនមេខ្យល់ខ្មែរម្នាក់ នាំពលករឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ១១ កក្កដា ២០២១ ដោយ deth leng

តុលាការខេត្តស្រះកែវ បានចេញដីកាចាប់ខ្លួន មេខ្យល់ខ្មែរម្នាក់ ស្នាក់នៅ ក្នុងបន្ទប់ជួលលេខ២៨ ផ្លូវសុព្រៅខ្លង ខណ្ឌបាងផាន់ ទីក្រុងបាងកក ដោយបានចោទប្រកាន់ថា ករណីនាំពលករខ្មែរឱ្យចូលទៅក្នុងទឹកដីថៃដោយមិនស្របច្បាប់។ បុរសជនសង្ស័យ មានឈ្មោះ វ៉ន បុំរ៉ុង អាយុ ៤៤ ឆ្នាំ បានឃុបឃិតជាមួយមេខ្យល់ថៃ ៣ នាក់ទៀត ដែលតម្រួតថៃចាប់បាន កាលពីថ្ងៃទី ២៥ ខែមីនា ជាមួយពលករខ្មែរ ២៦ នាក់។ ពួកគេបាននាំពលករខ្មែរ ២៦ នាក់ ចូលទឹកដីថៃ ជាថ្នូរនឹងប្រាក់ ១០០០ ទៅ ១៥០០ បាត៕

## បុរសម្នាក់សង្ស័យនាំពលករខ្មែរឆ្លងដែនខុសច្បាប់ដំណាក់កាលរីករាលដាលជំងឺកូវីដ-១៩ សមត្ថកិច្ចថៃឃាត់ខ្លួន

http://nokorwatnews.com/ 11/07/2021

ក្រុងប៉ោយប៉ែត៖ បុរសម្នាក់ជនជាតិខ្មែរសង្ស័យនាំពលករឆ្លងដែនខុសច្បាប់នៅដំណាក់កាលរីករាលដាលជំងឺកូវីដ-១៩ កាលពីល្ងាចថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២១នេះ ត្រូវកម្លាំងនគបាលអន្តោប្រវេសន៍ថៃ បាននាំដីការបស់សាលាដំបូងខេត្តស្រះកែវ លេខ១-146/2564 ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២១ ចូលទៅចាប់ខ្លួន។ សមត្ថកិច្ចចាប់ខ្លួនបុរសនោះមានឈ្មោះ វ៉ន ប្រុង ហៅ(ជាងវ៉េង) អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ខណៈកំពង់ស្នាក់នៅក្នុងបន្ទប់ជួលលេខ២៨ ក្រុងបាងកក ។

សេចក្តីរាយការពីព័ត៌មានថៃប្រាប់ថា បុរសរូបនេះត្រូវសមត្ថកិច្ចចោទពីបទឃុបឃិតគ្នាជួយលាក់បាំង ឬជួយឧបត្ថមបុគ្គលអន្តោប្រវេសន៍ លួចចូលប្រទេសថៃដោយមិនបានអនុញ្ញាត។ ការចាប់ខ្លួនខាងលើ ជាលទ្ធផលផ្តើមចេញកាលពីថ្ងៃទី២៥ មិថុនា កន្លងមក អង្គភាពចំពោះកិច្ចស្រុកតាព្រះយ៉ា មើលការខុសត្រូវព្រំដែនថៃ-កម្ពុជាច្រកព្រំដែនស្រះកែវ បានចាប់ឃុំខ្លួនជនជាតិថៃ៣នាក់ ដែលជាមេខ្យល់នាំពលករខ្មែរសរុបទាំងអស់២៦នាក់ ដែលដើរចូលមកតាមច្រករបៀង ដើម្បីលួចចូលមកប្រទេសថៃ ត្រង់បរិវេណស្រុកតាព្រះយ៉ា ដោយមានគោលដៅឆ្ពោះទៅទីក្រុងបាងកក។ ក្រោយពីការព្យាយាមបំបែកសំណុំរឿងខណៈកើតហេតុ រកឃើញទិន្នន័យថា បុរសឈ្មោះ ជាង វ៉េង គឺជាមនុស្សម្នាក់ដែលចូលរួមក្នុងបណ្តាញ ដែលមានឈ្មោះ ជា ជាមេក្លោង និងនៅពេលចាប់ខ្លួនបុរសម្នាក់នេះរត់គេចខ្លួនបាន។

ដោយឈ្មោះ ជា បានប្រគល់ភារកិច្ចឲ្យជាង វ៉េង បើករថយន្តដឹកទំនិញ រួមជាមួយបក្ខពួកមួយចំនួនជាដៃគូមិនតិចជាង៣-៤គ្រឿង ពីក្រុងបាងកក មកទទួលពលករដែលលួចឆ្លងដែនពីនៅក្នុងស្រុកតាព្រះយ៉ា ខេត្តស្រះកែវ តាមចំណុចដែលបានណាត់ទុក៉តែនៅថ្ងៃកើតហេតុ សមត្ថកិច្ចថៃអាចចាប់ឃុំខ្លួនមេខ្យល់ជនជាតិថៃ និងពលករ

ខ្មែរទាំងអស់បានមុន ទើបធ្វើឲ្យបុរសរូបនេះរត់គេចពីព្រំដែនត្រឡប់មកក្រុងបាងកកវិញ ដោយឡែកថ្លៃឈ្នួលក្នុងការនាំពលករបុរសខាងលើបានលុយក្នុងពលករម្នាក់ពី១,០០០បាត-១,៥០០បាត ក្នុងការដឹកពលករចូលក្រុងបាងកកក្នុងមួយជើងៗ នឹងនេះជាមូលហេតុសំខាន់ដែលធ្វើឲ្យពលករខ្មែរទាំងនេះ ចេះតែហូរចូលក្នុងប្រទេសថៃបាន ៕

## តុលាការកំពូលតម្កល់ទោសស្ត្រីម្នាក់ ដាក់៨ឆ្នាំ ជាប់ពាក់ព័ន្ធ នឹងការរត់ពន្ធនារីខ្មែរ១៦នាក់ ពីកម្ពុជា ទៅធ្វើការខុសច្បាប់ នៅក្នុងប្រទេស ម៉ាឡេស៊ី

https://cen-news.com/ Posted ByPen Srey NeatJuly 12, 2021

ភ្នំពេញ ៖ តុលាការកំពូលកាលពីព្រឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ ២០២១នេះ បានបើកសវនាការ ប្រកាសសាលដីកាលើបណ្តឹងសារទុក្ខ របស់ស្ត្រីជនជាប់ចោទម្នាក់ជាប់ពាក់ព័ន្ធ នឹងការរត់ពន្ធនារីខ្មែរ១៦នាក់ ពីកម្ពុជា ទៅធ្វើការដោយ ខុសច្បាប់ នៅក្នុងប្រទេសម៉ាឡេស៊ី ប្រព្រឹត្តកាលពី អំឡុងឆ្នាំ ២០១៥ និង ២០១៦។ តុលាការកំពូលបានសម្រេច តម្កល់សាលដីការបស់សាលាឧទ្ធរណ៍ រក្សាទុកជាបានការដដែល និងតម្កល់ទោស ស្ត្រីជាប់ចោទ ដាក់គុកកំណត់ ០៨ ឆ្នាំដដែល និង ប្រកាសបិទផ្លូវតវ៉ា។

លោកចៅក្រម ឃឹម ប៉ុណ្ណ ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃ តុលាការកំពូលបានថ្លែងថា នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ មានឈ្មោះ អ៊ុ រ៉ាឌីន ហៅ មាំ ហៅ ម៉ា ហៅ ដោលី ភេទស្រី អាយុ ២៦ ឆ្នាំ ខ្មែរឥស្លាម រស់នៅ ក្នុងសង្កាត់ឬស្សីកែវ រាជធានីភ្នំពេញ។ លោកចៅក្រមបានបញ្ជាក់ថា ជនជាប់ចោទ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៨ កាត់ទោសដាក់ពន្ធនាគារ កំណត់ ៨ ឆ្នាំ ពីបទ៖ « នាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន» តាមបញ្ញត្តិ មាត្រ១១ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ តែនាងបានប្តឹងជំទាស់នឹងសាលក្រមខាងលើទៅកាន់សាលាឧទ្ធរណ៍ ។ សាលាឧទ្ធរណ៍ នៅថ្ងៃទី២២ ខែ តុលា ឆ្នាំ២០២០ បានសម្រេចតម្កល់ទោសរបស់នាងដដែល។ នាងបន្តប្តឹងសារទុក្ខសាលដីកា របស់សាលាឧទ្ធរណ៍ ទៅកាន់តុលាការកំពូល។

យោងតាមរបាយការណ៍ របស់នគរបាលបាលប្រឆាំងការជួញដូរមនុស្ស នៃ ក្រសួងមហាផ្ទៃ បានឲ្យដឹងថា ជនជាប់ចោទ ឈ្មោះ អ៊ុ រ៉ាឌីន ត្រូវបានចាប់ឃុំខ្លួន កាលពីថ្ងៃទី១ ខែ កញ្ញា ឆ្នាំ ២០១៧ តាមបណ្តឹងរបស់នារីរងគ្រោះ ចំនួន ១៦នាក់ (ជនជនរងគ្រោះ) ដែលបានប្តឹងនាងមក កាន់សមត្ថកិច្ចនគរបាលជំនាញថា៖ ជនជាប់ចោទ បានឆបោក និង ជួញដូរ ពួកគេទៅធ្វើការជាអ្នកបម្រើនៅតាមផ្ទះ ដោយធ្វើដំណើរតាម ច្រកប៉ោយប៉ែត ព្រំដែន កម្ពុជា ថៃ កាលពីឆ្នាំ ២០១៦។ តែពេលដល់ប្រទេសម៉ាឡេស៊ី ពួកគេត្រូវបានលក់ឲ្យ ទៅធ្វើការហាងម៉ាស្សា បម្រើផ្លូវទៅវិញ៕ រក្សាសិទ្ធិដោយ៖ ចន្ទា ភា

# ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

## ពលករ១៣នាក់ដែលត្រឡប់មកពីប្រទេសថៃ ត្រូវកម្លាំងការពារព្រំដែនបញ្ជូនទៅចត្តាឡីស័ក

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១២ កក្កដា ២០២១ ដោយ Sorn Phanith

ពលករខ្មែរចំនួន១៣នាក់ ត្រូវបានកម្លាំងរៈការពារព្រំដែន ទៅទទួលដល់មាត់អូរព្រំដែនដើម្បីប្រគល់ឲ្យក្រុមគ្រូពេទ្យយកទៅពិនិត្យ បន្ទាប់ពីភាគីថៃបានប្រគល់មកឲ្យកម្ពុជា។ ការងារនេះបានធ្វើឡើង កាលពីថ្ងៃទី១១ ខែ

កក្កដា ឆ្នាំ២០២១នេះ នៅក្នុងទឹកដី ស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយកងកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមកិច្ចសហការពីកងកម្លាំងយោធាផ្នែកសឹករង និងកម្លាំងវរសេនាតូចលេខ៥៣៣ បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ពីប្រទេសថៃ ចំនួន ១៣នាក់ ស្រី ០៦នាក់ និងក្មេង ០១នាក់ នៅត្រង់ចំណុចភូមិពោធិជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ក្រៅពីបានទទួលរួចមក កម្លាំងបានប្រគល់ជូនក្រុមគ្រូពេទ្យដើម្បីយកទៅកាន់មណ្ឌលចត្តាឡីស័កនៃអនុវិទ្យាល័យកូនភ្នំ៣២ ស្រុកសំពៅលូន៕ **សោ និយមរ័ត្ន**

## ពលករខ្មែរមកពីថៃតាមច្រកអូរបីជាន់រយៈពេល២ថ្ងៃជាង២០០នាក់ និងរកឃើញវិជ្ជមានកូវីដ៧១នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ១២ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៣:៤៣

បន្ទាយមានជ័យ ៖ ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃរយៈពេល២ថ្ងៃ ជាង២០០នាក់ រកឃើញវិជ្ជមានកូវីដ១៩ មានចំនួន៧១នាក់ តាមច្រកអូរបីជាន់ស្រុកអូរជ្រៅ ។ លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ ដែលត្រូវទទួលតំណែងថ្មីជាអភិបាលរងខេត្តបន្ទាយមានជ័យថ្មីបានប្រាប់ថា ៖ រយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី១០ ដល់ ១១ ខែកក្កដា ឆ្នាំ២០២១ មានពលករខ្មែរដែលត្រឡប់ពីប្រទេសថៃតាមច្រកអូរបីជាន់ស្រុកអូរជ្រៅ មានចំនួន២៣១នាក់ ស្រី៩៧នាក់ ក្នុងនោះរកឃើញអ្នកវិជ្ជមានកូវីដ១៩ មានចំនួន៧១នាក់ ស្រី២៧នាក់ ។ លោកបានបញ្ជាក់ថា៖ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២១មានពលករខ្មែរដែលត្រឡប់ពីប្រទេសថៃដែលត្រូវបានក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ទទួលមានចំនួន១២៤នាក់ ស្រី៥៣នាក់ រកឃើញវិជ្ជមានកូវីដ១៩មានចំនួន៣៤នាក់ ស្រី១៣នាក់ ក្នុងនោះមានប្រជាពលរដ្ឋ ខេត្តបន្ទាយមានជ័យចំនួន២៣នាក់ ខេត្តពោធិ៍សាត់ចំនួន៣នាក់ ខេត្តកំពង់ធំចំនួន៥នាក់ ខេត្តកំពង់ឆ្នាំងចំនួន៣នាក់ ។

ថ្ងៃទី១០ ខែកក្កដានេះ មានចំនួន១០៧នាក់ ស្រី៤៤នាក់ រកឃើញអ្នកវិជ្ជមានកូវីដ១៩ មានចំនួន៣៧នាក់ ស្រី១៤នាក់ ក្មេង៣នាក់ ក្នុងនោះមានប្រជាពលរដ្ឋខេត្តបន្ទាយមានជ័យ មានចំនួន៣២នាក់ ខេត្តបាត់ដំបងចំនួន៣នាក់ ខេត្តតាកែវចំនួន១នាក់ ខេត្តត្បូងឃ្មុំចំនួន១នាក់ ។ លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា៖ចំពោះពលករខ្មែរដែលត្រូវដែលក្រុមការងារទទួលរយៈពេល២ថ្ងៃចំនួន២៣១នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដ១៩ចំនួន៧១នាក់ ត្រូវបានបញ្ជូនទៅដាក់មណ្ឌលកងរ៉ា ក្រុងសិរីសោភ័ណដើម្បីព្យាបាល ចំណែកពលករដែលអវិជ្ជមានកូវីដ១៩ត្រូវបានយកទៅដាក់មណ្ឌលវិទ្យាល័យសម្តេចឳ ដើម្បីធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ៕

## ឃាត់ខ្លួនជនជាតិថៃ២នាក់ លួចឆ្លងដែនចូលមកកម្ពុជា បម្រុងរកការងារធ្វើ នៅក្រុងប៉ោយប៉ែត

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១២ កក្កដា ២០២១ដោយ sopheak khoun

(បន្ទាយមានជ័យ)៖ ជនជាតិថៃប្រុស-ស្រី២នាក់ លួចឆ្លងដែនចូលមកប្រទេសកម្ពុជា ដោយជិះម៉ូតូឌុបបម្រុងចូលមករកការងារធ្វើ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ត្រូវកម្លាំងប៉ុស្តិ៍១ក្រុម ដឹកនាំដោយលោកវរៈសេនីយ៍ត្រី ប៉ាក់ សារ៉ាត់ នាយប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាចុះល្បាតតាមព្រំដែនឃាត់ខ្លួន ជាមួយវត្ថុតាងម៉ូតូចំនួន១គ្រឿង។ ចំណែកម្ចាស់ម៉ូតូឌុប ឃើញសភាពការណ៍មិនស្រួល បានរត់គេចខ្លួនបាត់។ ហេតុការណ៍ឃាត់ខ្លួនជនជាតិថៃខាងលើនេះ គឺនៅវេលាម៉ោង១០ព្រឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២១ម្សិលមិញ នៅចំណុចត្រួតពិនិត្យទប់ស្កាត់ប្រជាពលរដ្ឋ លួចឆ្លងដែនខុសច្បាប់មុខប៉ុស្តិ៍ ស្ថិតនៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លោកវរៈសេនីយ៍ត្រី ប៉ាក់ សារ៉ាត់ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ជនជាតិថៃដែលកម្លាំងចម្រុះឃាត់ខ្លួនបាននោះ ទី១.ឈ្មោះ ណាធី ហុងវៀងចាន់ ភេទប្រុស អាយុ២៧ឆ្នាំ។ ទី២. ឈ្មោះ ចុងវ៉ាន់ វ៉ាន់ណាវ៉ាត់ ភេទស្រី អាយុ

១៨ឆ្នាំ រស់នៅខេត្តស្រះកែវ។ លោក វរៈសេនីយ៍ត្រី ប៉ាក់ សារ៉ាត់ បានបញ្ជាក់ទៀតថា តាមការសាកសួររបស់សមត្ថកិច្ច បានឲ្យដឹងថា គោលបំណងជនជាតិថៃទាំង២នាក់ លួចឆ្លងដែនដោយខុសច្បាប់ ចូលមកប្រទេសកម្ពុជា ដើម្បីទៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ រកការងារធ្វើ។ ក្រោយពីសួរនាំរួចរាល់ ដោយទទួលតាមបទបញ្ជា ពីលោកមេបញ្ជាការយោធាជួរមុខ គឺជនជាតិថៃទាំង២នាក់នេះ បានធ្វើការប្រគល់ជូនក្រុមការងារចម្រុះ ស្នាក់ការត្រួតពិនិត្យសុខភាពច្រកអូរបីជាន់ និងចាត់ការទៅតាមនិតិវិធីច្បាប់៕ (ដោយ)៖ វ៉ាន់ ណាង

## ពលករខ្មែរជាង ១ពាន់នាក់ ចប់អាណត្តិការងារនៅកូរ៉េ ត្រូវត្រឡប់មកកម្ពុជាវិញ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

(ភ្នំពេញ)៖ មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ បានជូនដំណឹងនៅថ្ងៃទី១២ ខែកក្កដានេះ សម្រាប់ដល់បងប្អូនពលករខ្មែរដែលទើបនឹងចប់អាណត្តិ អំពីអត្ថប្រយោជន៍នៃការទទួលបានប្រាក់ធានារ៉ាប់រងបាន (សាំសុងហ្វាជេរ) នៅពេលដែលបងប្អូនត្រឡប់មកស្រុកវិញ។ នេះបើតាមការចុះផ្សាយរបស់គេហទំព័រ Korea in Cambodia។ ប្រភពដដែលបានឲ្យដឹងថា តាមរយៈការចែករំលែកពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ដែលជាតំណាងផ្លូវការរបស់ស្ថាប័នគ្រប់គ្រងពលករធ្វើការនៅក្នុងប្រទេសកូរ៉េខាងត្បូង ដែលមានទីតាំងប្រចាំការនៅកម្ពុជានោះ បានបង្ហោះចែករំលែកជាការជូនដំណឹងដល់បងប្អូនពលករខ្មែរ ដែលបានចប់អាណត្តិការងារនៅកូរ៉េដល់ទៅ ១១១៨នាក់ឯណោះ ដែលបងប្អូនទាំងអស់អាចមកដកប្រាក់ធានារ៉ាប់រងបាន (សាំសុងហ្វាជេរ) បាននៅពេលមកដល់ស្រុកខ្មែរវិញ។

ប្រាក់ធានារ៉ាប់រងបាន (សាំសុងហ្វាជេរ) នេះជាអត្ថប្រយោជន៍ដែលបងប្អូនពលករខ្មែរគ្រប់រូបសុទ្ធតែអាចទទួលបាន នៅពេលដែលត្រឡប់មកស្រុកខ្មែរវិញ នៅពេលចប់អាណត្តិការងារនៅកូរ៉េ។ ដូចនេះ បងប្អូនពលករដែលចប់អាណត្តិ អាចអញ្ជើញទៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅភ្នំពេញ ដើម្បីស្នើសុំដកប្រាក់ធានារ៉ាប់រងបាន (សាំសុងហ្វាជេរ)នេះបាន។ ក្នុងនោះដែរ នីតិវិធីដើម្បីធ្វើការដាក់ស្នើសុំដកប្រាក់ធានារ៉ាប់រងរបស់បងប្អូន គឺមិនមានការលំបាកអ្វីនោះទេ គឺបងប្អូនគ្រាន់តែត្រូវភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន រូបថតមួយសន្លឹក សៀវភៅធនាគារដែលមានឈ្មោះដូចនឹងលិខិតឆ្លងដែនតែប៉ុណ្ណោះ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងមកកាន់ទូរស័ព្ទលេខ: 023 997 844 / 023 997 855 ឬអាចចូលទៅមើលទំព័រហ្វេសប៊ុក HRD Korea in Cambodia បន្ថែមបានផងដែរ៕

## កូវីដ-១៩ នាំចូលមកកម្ពុជាមានច្រើនជាង ២,១០០ ករណីត្រឹម១១ ថ្ងៃដើមខែកក្កដា

https://kohsantepheapdaily.com.kh/ Phnom Penh១២ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៨:៤៨

រាជធានីភ្នំពេញ ៖ ត្រឹមរយៈពេល ១១ ថ្ងៃ ដើមខែកក្កដា ឆ្នាំ២០២១ កម្ពុជាបានរកឃើញមានករណីនាំចូលកូវីដ-១៩ សរុប ២១៩៣ នាក់ ដែលភាគច្រើនគឺជាពលករខ្មែរមកពីប្រទេសថៃ ។ ដែលការរកឃើញច្រើននេះផងដែរ ដោយសារតែមានការរឹតបន្តឹងយ៉ាងខ្លាំងក្លាក្នុងការធ្វើតេស្តរាល់ពលករត្រឡប់ចូលមកកម្ពុជាវិញ ។

យោងតាមប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលចេញផ្សាយរៀងរាល់ថ្ងៃ បានបង្ហាញឱ្យឃើញថា រយៈពេល ១១ ថ្ងៃនៃខែកក្កដានេះ កម្ពុជាមានករណីវិជ្ជមានកូវីដ-១៩ សរុប ១០,៤៨៦ នាក់ ក្នុងនោះចំនួន ២,១៩៣ ជាករណីនាំចូលកម្ពុជា ដែលភាគច្រើនជាពលករខ្មែរវិលត្រឡប់មកពីប្រទេសថៃ ក្រោយពីប្រទេសជិតខាងកម្ពុជាមួយនេះបានប្រកាសបិទប្រទេសដោយសារតែការវាយលុយរបស់វីរុសបំប្លែងថ្មីដែលតា ។

ថ្លែងប្រាប់សារព័ត៌មានកោះសន្តិភាព លោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការនិងជាអ្នកនាំពាក្យក្រសួងសុខាភិបាលបានមានប្រសាសន៍ថា ពលករខ្មែរត្រឡប់មកពីថៃមានចំនួនច្រើន នាំឱ្យរកឃើញករណីនាំចូល

កូវីដ មកកម្ពុជាកាន់តែកើនឡើងផងដែរ ។ លោកជំទាវវេជ្ជបណ្ឌិតបានបញ្ជាក់ថា ការរឹតបន្តឹងតាមច្រកព្រំដែនគោក ទឹក និងអាកាស គឺជាការដាក់ចេញនូវវិធានការមួយដើម្បីទប់ស្កាត់ការចូលមកនូវវីរុស១៩ មកក្នុងប្រទេសកម្ពុជា ។ លោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន មានប្រសាសន៍បញ្ជាក់ថា «កាលដែលយើងរកឃើញច្រើន ដោយសារតែកំណើននៃពលករគាត់វិលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា បើយើងប្រៀបធៀបជាមួយនឹងដំណាក់កាលមុនៗ ។ កាលពីប៉ុន្មានខែមុន មានពលករមកដែរ តែក្នុងកម្រិតមួយទាប ។ ប៉ុន្តែនៅពេលដែលព្រះរាជាណាចក្រថៃ គាត់ប្រកាសការបិទប្រទេស ដល់អ៊ីចឹងពលករយើងធ្វើដំណើរត្រឡប់មក (កម្ពុជា) មានកំណើនច្រើន ។ ហើយធម្មតាកាលណាកំណើនច្រើន ការរុករក គឺឃើញច្រើនហើយក្អួយ វាជៀសមិនរួចទេ ។ មកតិច មើលឃើញតិច មកច្រើន មើលឃើញច្រើន » ។

លោកជំទាវអ្នកនាំពាក្យក្រសួងសុខាភិបាលបានបន្តថា «ដូចខ្ញុំបានជម្រាបជូនអញ្ចឹង ការឆ្លងនូវវីរុសកូវីដ-១៩ ហ្នឹង វាតាមការចល័តរបស់បុគ្គល ពេលគាត់ចល័តមក មេរោគអាចនឹងមកជាមួយគាត់ហើយ អ៊ីចឹងកាលណាយើងរឹតបន្តឹង យើងធ្វើតេស្តទៅយើងឃើញច្រើន អ៊ីចឹងនេះគឺជាចំណុចល្អមួយ ដែលយើងរកឃើញបានទាន់ពេលវេលា ។ ឥឡូវយើងគិតទៅវិញ បើសិនជាសម្តេច លោកមិនរឹតបន្តឹង ហើយយើងរកឃើញមិនទាន់ ហើយអ្នកនឹងគាត់មាន ហើយគាត់ចូលមកកម្ពុជា ហើយអាហ្នឹង វាជាការនាំចូលវីរុសមកកម្ពុជាឬអត់ ? វានឹងនាំចូលមក ក្អួយ ។ ដូច្នេះការរឹតបន្តឹងនិងការធ្វើតេស្តហ្ន៎ស គឺជាចំណុចល្អណាស់ ដែលសម្តេច លោកបានដាក់ចេញនូវ យុទ្ធសាស្ត្រមួយ គឺការត្រួតពិនិត្យដ៏ម៉ត់ចត់ជាទីបំផុតនូវអ្នកដំណើរ ដែលចូលមកក្នុងព្រះរាជណាចក្រកម្ពុជា ទាំងផ្លូវអាកាស ទាំងផ្លូវទឹកនិងផ្លូវគោក » ៕

## លោក ឌី រ៉ាដូះក្នុងចំណោមពលករខ្មែរជាង៤ពាន់នាក់ដែលវិលមកពីថៃគឺមានជាង ១ពាន់នាក់ឆ្លងកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 12/07/2021 - 13:38 ដោយ៖អ៊ឹង ប៊ុនថន

ពលករខ្មែរដែលទៅធ្វើការនៅប្រទេសថៃ បានបន្តនាំគ្នាសម្រុកវិលចូលប្រទេសកម្ពុជាវិញរាប់រយនាក់ក្នុងមួយថ្ងៃៗ។ គ្រាន់តែតាមច្រកព្រំដែនអូរស្មាច់មួយគឺមានពលករជាង៤ពាន់នាក់បានឆ្លងកាត់។ នេះបើតាមអ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យ។ លោក ឌី រ៉ាដូ បញ្ជាក់ថា មានពលករខ្មែរប្រមាណ៣ពាន់នាក់កំពុងធ្វើចត្តាឡីស័កនៅខេត្តជាប់ព្រំដែនថៃនេះ ខណៈដែលពលករខ្មែរជាង១ពាន់៦រយនាក់ទៀតត្រូវបានរកឃើញថាវិជ្ជមានកូវីដ១៩។ បើតាមអ្នកនាំពាក្យដដែលសន្ទុះពលករខ្មែរដែលវិលមកពីប្រទេថៃវិញនឹងមិនថមថយឡើយ នៅគ្រាដែលប្រទេសថៃកំពុងផ្ទុះឡើងកូវីដ១៩ប្រភេទថ្មី។

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៣នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត,

ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៣នាក់ ស្រី ៦នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍ ) ។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ២នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៣នាក់ ស្រី ៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋមលើសុខភាព និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតាដោយតម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ។ សូមបញ្ជាក់ជូនថាៈ ថ្ងៃនេះ ក្រុមការងារបានបញ្ជូនពលករ ដែលបញ្ចប់ធ្វើចត្តាឡីស័ក និងអ្នកព្យាបាលជាសះស្បើយមកពីបណ្ដាខេត្តតាមព្រំដែន មានចំនួន ១០០នាក់ ស្រី ៤៧នាក់ ៕ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

### សម្ដេច ស ខេង សំណូមពរដាក់បញ្ចូលផែនការសកម្មភាពបង្ការ ទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅក្នុងផែនការប្រតិ បត្តិប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន

https://www.kampucheathmey.com/ ថ្ងៃពុធ ១៤ កក្កដា ២០២១ដោយ sopheak khoun

សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានសំណូមពរដល់ក្រសួង-ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គួរតែដាក់បញ្ចូលផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំនៅក្នុងអង្គភាពរបស់ខ្លួន។ ការសំណូមពរនេះ គ្រាដែលសម្ដេចក្រឡាហោម ស ខេង បានអញ្ជើញជាអធិបតីភាព ក្នុងពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ «ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញ» ធ្វើឡើងតាមកម្មវិធីអនឡាញ (ZOOM) នាព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១នេះ។

សម្ដេចរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានប្រសាសន៍ថា ការដាក់បញ្ចូលផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំ គឺជាកិច្ចការដ៏សំខាន់ ដែលនឹងបញ្ជាក់អំពីការគាំទ្រ និងចូលរួមរបស់ក្រសួង-ស្ថាប័នរបស់រដ្ឋ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់។ សម្ដេចក្រឡាហោម ស ខេង បានថ្លែងយ៉ាងដូច្នេះថា «គ្រប់ក្រសួង-ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ គប្បីយកចិត្តទុកដាក់បញ្ចូលផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញឆ្នាំ២០២១-២០២៥ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពសាម៉ី....បាទនេះ គឺជាកិច្ចការសំខាន់ណាស់ ដែលបញ្ជាក់អំពីការគាំទ្រ និងការចូលរួមគ្រប់ក្រសួង-ស្ថាប័ន មិនមែនតែក្រសួងសង្គមកិច្ច ឬមិនមែនតែក្រសួងមហាផ្ទៃ ឬក៏មិនមែនតែអគ្គស្នងការដ្ឋាននគរបាលជាតិនោះ គឺគ្រប់ក្រសួង-ស្ថាប័នទាំងអស់ របស់រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវតែបញ្ចូលនូវផែនការ ការពារកុមារក្នុងការប្រយុទ្ធ

ប្រឆាំង ការកេងប្រវ័ញ្ចផ្លូវភេទ តាមប្រព័ន្ធអនឡាញនេះ»។ ជាមួយគ្នានេះសម្តេចក្រឡាហោម ស ខេង ក៏បានស្នើដល់នាយកដ្ឋាន និងការិយាល័យជំនាញ ដែលមានសមត្ថកិច្ចអន្តរាគមន៍ និងដោះស្រាយករណីបទល្មើសបច្ចេកវិទ្យា ត្រូវបន្តអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ដោយអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិដែលមានជាធរមាន ជាពិសេសផ្តោតការយកចិត្តទុកដាក់ ជាអាទិភាពលើការដោះស្រាយករណីកុមារ ឲ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ទោះបីជាកុមារស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារដែលជាអនាគតរបស់ប្រទេសជាតិ។

បើតាមអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានឲ្យដឹងថា នៅកម្ពុជាតាមរយៈការរាយការណ៍ពីសាធារណៈជនមកកាន់សមត្ថកិច្ច និងបណ្តាញរាយការណ៍តាមអ៊ីនធើណិត (Internet Hotline) ជាមធ្យម មានចំនួនរាយការណ៍ជាង១៥០ករណី ក្នុងមួយឆ្នាំៗ ដែលជាករណីសង្ស័យ ទាក់ទងនឹងការលួងលោមកុមារតាមអនឡាញ ការផលិត និងចែកចាយរូបភាពសម្ភារៈអាសអាភាសកុមារ និងការគំរាមខាងផ្លូវភេទជាដើម។ ដើម្បីឆ្លើយតបនឹងបញ្ហានេះ ប្រទេសកម្ពុជា បាននឹងកំពុងយកចិត្តទុកដាក់ និងរួមកម្លាំងគ្នា ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាព៕ (ដោយ)៖ ឃួន សុភ័ក្រ

## សម្តេចក្រឡាហោម ស ខេង លើកឡើង ១៣ចំណុច ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១

(ភ្នំពេញ)៖ ក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «ផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ» រយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥ នាព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានលើកឡើងនូវអនុសាសន៍ ១៣ចំណុច។ ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាននៅក្នុងកិច្ចប្រជុំតាមប្រព័ន្ធវិដេអូ សម្តេចក្រឡាហោម ស ខេង បានលើកឡើង១៣ ចណុច រួមមាន៖

១-គ្រប់ក្រសួងស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ច គប្បីយកចិត្តទុកដាក់បញ្ចូលផែនការសកម្មភាព ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១ ដល់ឆ្នាំ ២០២៥ ទៅក្នុងផែនការសកម្មភាពប្រតិបត្តិរបស់អង្គភាពសាមី។

២-នាយកដ្ឋាន និងការិយាល័យជំនាញ ដែលមានសមត្ថកិច្ច ក្នុងការធ្វើអន្តរាគមន៍ និងដោះស្រាយបទល្មើសបច្ចេកវិទ្យា ត្រូវបន្តអនុវត្តឲ្យមានប្រសិទ្ធភាព អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ ដែលមានជាធរមាន ជាពិសេសផ្តោតលើការយកចិត្តទុកដាក់ ជាអាទិភាពលើការដោះស្រាយករណីកុមារ ឲ្យទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ទោះបីកុមារស្ថិតក្នុងស្ថានភាពណាក៏ដោយ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដែលជាអនាគតរបស់ប្រទេសជាតិយើង។

៣-សិក្សាឡើងវិញនូវភាពខ្វះចន្លោះនៃបទប្បញ្ញត្តិ ដែលមានជាធរមានលើបទល្មើសឧក្រិដ្ឋប្រឆាំងបច្ចេកវិទ្យាលើកុមារ ដោយស្មារតី និងឆន្ទៈទទួលខុសត្រូវខ្ពស់ ជាពិសេសក្នុងករណី មិនមានចែងនៅក្នុងច្បាប់ សូមអនុវត្តដោយឈរលើគោលការណ៍នៃការសម្រេច ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស និងសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

៤-ក្រុមប្រឹក្សាជាតិ ដើម្បីកុមារ គប្បីបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រើប្រាស់យន្តការ ដែលមានស្រាប់ លើកកម្ពស់ការអនុវត្តសំដៅធ្វើឲ្យសម្រេចនូវយុទ្ធសាស្ត្រទាំង ៩ ដែលមានចែងក្នុងផែនការនេះ។ លើសពីនេះទៀត ត្រូវពង្រឹងប្រព័ន្ធតាមដាន វាយតម្លៃ ជាពិសេសបង្កើតប្រព័ន្ធ

ទិន្នន័យកុមារនៅទូទាំងប្រទេស ហើយត្រូវបំពេញតួនាទី ជាសេនាធិការ ជូនរាជរដ្ឋាភិបាល កំណត់ច្រកចេញចូលតែមួយ គ្រប់ការងារ ដែលផ្តោតលើកុមារ។

៥-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គប្បីបន្តការគ្រប់គ្រងឲ្យបានហ្មត់ចត់នូវក្រុមហ៊ុនផ្តល់សេវាអ៊ិនធឺណេត ក្នុងការកំណត់នូវស្តង់ដារ ដែលអាចបង្កើត Data និងរក្សាកំណត់ត្រាទិន្នន័យបង្កើតគោលនយោបាយការពារកុមារ ដែលអាចឆ្លើយតបបានឆាប់រហ័ស និងការទទួលខុសត្រូវចំពោះមាតិការូបភាព និងសម្ភារៈអាសអាភាស ដែលរក្សាទុកនៅក្រុមហ៊ុន។

៦-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គប្បីបន្តការលើកកម្ពស់សេវាសង្គម ពិសេសការផ្តល់ប្រឹក្សាយោបល់ ការស្តារនីតិសម្បទា និងសមាហរណកម្មចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ នៅក្នុងបច្ចេកវិទ្យាព័ត៌មាន ដោយផ្តល់អាទិភាពជាចម្បងលើកុមារី កុមារជនជាតិដើមភាគតិច និងកុមារមានពិការភាព។

៧-គ្រប់ក្រសួងស្ថាប័ន អាជ្ញាធរ និងសមត្ថកិច្ចគ្រប់វិស័យ ទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិ និងអង្គការដៃគូ គប្បីជំរុញ លើកកម្ពស់ការយល់ដឹងអំពីព័ត៌មានសង្គមដល់មាតាបិតា និងអ្នកដែលមានទំនាក់ទំនងជាមួយកុមារ អំពីការប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណេត បញ្ហាគ្រោះថ្នាក់ ដែលកើតមានចំពោះកុមារតាមប្រព័ន្ធអ៊ិនធឺណេត និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ពីរបៀបបង្ការ ជៀសវាងពីទំនាក់ទំនងជាមួយជនខិលខូច នៅក្នុងប្រព័ន្ធអ៊ិនធឺណេតនេះ ដើម្បីពង្រឹងការអនុវត្តប្រព័ន្ធរាយការណ៍ទាន់ហេតុការណ៍ និងយន្តការឆ្លើយតបឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ចំពោះករណីរំលោភបំពានកុមារ តាមប្រព័ន្ធអ៊ិនធឺណេត។

៩-ពង្រឹងបណ្តាញប្រឆាំងបទល្មើសបច្ចេកវិទ្យា និងសមត្ថភាពអនុវត្តនៅថ្នាក់ក្រោមជាតិជារួម សហការជាមួយដៃគូជាតិ និងអន្តរជាតិ ក្នុងការបង្ការ ទប់ស្កាត់ និងឆ្លើយតបករណីរូបភាព និងសម្ភារៈអាសអាភាសកុមារឲ្យបានទាន់ពេលវេលា។

១០-ពិនិត្យលទ្ធភាព ក្នុងការវិនិយោគ លើធនធានមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច តាមបណ្តាញឃុំសង្កាត់ ដើម្បីបង្វិតសេវាសង្គមកិច្ច គាំពារកុមារឲ្យដល់សហគមន៍ ជាពិសេសយកចិត្តទុកដាក់ ចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ កុមារដែលត្រូវបានគេបោះបង់ កុមារដែលទទួលរងនូវអំពើហិង្សានិងការកេងប្រវ័ញ្ចគ្រប់រូបភាព។

១១-ពង្រឹងការបញ្ជ្រាបចូលបញ្ហានៃការរំលោភ បំពានកុមារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអនឡាញទៅក្នុងវេទិកាសាធារណៈនៃគោលនយោបាយភូមិឃុំមានសុវត្ថិភាព ដើម្បីឲ្យមាតាបិតា អាណាព្យាបាល អាជ្ញាធរមានសមត្ថកិច្ច បានយល់ជ្រួតជ្រាប និងបង្កើនកិច្ចការពារក្នុងគ្រួសារ និងសហគមន៍។

១២-ជំរុញ និងលើកទឹកចិត្តឲ្យក្រុមហ៊ុនឯកជន ដែលផ្តល់សេវាអ៊ិនធឺណេត ណែនាំឲ្យអ្នកប្រើប្រាស់ឧបករណ៍ ចែកចាយអ៊ិនធឺណេត ដែលមានសុវត្ថិភាពចំពោះកុមារ។ ក្នុងនោះដែរ លើកទឹកចិត្តឲ្យពិនិត្យលទ្ធភាពដាក់ឧបករណ៍ ដើម្បីគ្រប់គ្រង និងផ្តល់សញ្ញាហាមឃាត់ និងប្រើប្រាស់វេបសាយអាសអាភាសកុមារ។

១៣-តាមដានភាពប្រែប្រួលប្រសើរឡើងនៃការយល់ដឹងរបស់សហគមន៍ក្នុងកិច្ចការពារកុមារពីភាពរងគ្រោះដោយការរំលោភបំពាន តាមប្រព័ន្ធអនឡាញ៕

## ផែនការសកម្មភាពដើម្បីទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី១៤ ខែកក្កដា

https://www.rfa.org/khmer/news/ ដោយ សេក បណ្ឌិត 2021-07-13

មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃសង្ឃឹមថា សកម្មភាពជួញដូរផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នឹងអាចកាត់បន្ថយបានច្រើន ក្រោយការប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនូវផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយ

តបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅថ្ងៃទី១៤ ខែកក្កដានេះ ខណៈអ្នកជំនាញបារម្ភអំពីការកើនឡើងខ្លាំងក្នុងអំឡុងផ្ទុះជំងឺកូវីដ-១៩។

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអ្នកស្រី ជូ ប៊ុនអេង មានប្រសាសន៍ប្រាប់អាស៊ីសេរីថា ក្នុងរយៈពេលនៃការផ្ទុះជំងឺរាតត្បាតកូវីដ-១៩មក សកម្មភាពកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវបានរកឃើញថា មានការកើនឡើងជាលំដាប់មិនថានៅក្នុងប្រទេសកម្ពុជា ឬនៅជុំវិញពិភពលោកនោះទេ។ អ្នកស្រីបន្តថា សម័យវិទ្យាសាស្ត្រទំនើប នៃការប្រើប្រាស់ប្រព័ន្ធអនឡាញនេះ ជនល្មើសប្រើគ្រប់រូបភាព ដើម្បីកេងប្រវ័ញ្ចផ្លូវភេទលើកុមារ៖ « នៅពេលរងគ្រោះហើយបានយើងដឹងថា គេទាក់ទងគ្នាតាមអនឡាញ ទាក់ទងគ្នាតាមទូរស័ព្ទ ជួនកាលមិនដឹងថាមុខអ្នកនិយាយយ៉ាងម៉េចផង។ សូម្បីរូបភាពប្រើប្រាស់ គេក្រឡៃទៀត ដែលនេះគឺជាភាពរងគ្រោះ។ ជួនកាលដឹងខ្លួនហើយ ទម្រាំរកមុខអ្នកប្រព្រឹត្តបទល្មើសឃើញ ត្រូវប្រើពេលព្រោះពួកគេប្រើរូបភាពនិងឈ្មោះក្លែងក្លាយ»។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃរូបនេះឲ្យដឹងថា ទម្រង់នៃការជួញដូរផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត រួមមាន ការកាន់កាប់ ការបង្ហោះ និងការផលិតរូបភាពអាសអាភាសរបស់កុមារ ការកេងប្រវ័ញ្ចផ្លូវភេទ តាមរយៈការរៀបអាពាហ៍ពិពាហ៍ និងការគំរាមកំហែងតាមទម្រង់ជាច្រើនទៀត ដែលធ្វើឱ្យកុមារទទួលរងគ្រោះ ហើយប៉ះពាល់ដល់សតិអារម្មណ៍ និងការអភិវឌ្ឍរបស់ពួកគេ។

កម្មវិធីប្រកាសឱ្យប្រើប្រាស់ផែនការនេះត្រូវបានរៀបចំដោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយ ក្រសួងមហាផ្ទៃ និងជាមួយអង្គការអន្តរជាតិមួយចំនួនទៀត រួមមាន អង្គការមូលនិធិកុមារ (ChildFund) អង្គការយូនីសេហ្វ (UNICEF) អង្គការសកម្មភាពដើម្បីកុមារ (APLE) និងអង្គភាពការពារកុមារ (CPU) ជាដើម៕

## ផែនការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញលើកុមារ ត្រូវដាក់ឱ្យប្រើថ្ងៃស្អែក

https://m.postkhmer.com/national/ ឡុង គីមម៉ារីតា 13 July 2021 | 10:05 ICT

**ភ្នំពេញៈ** ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញនឹងត្រូវប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ១៤ ខែកក្កដាស្អែក ខណៈអ្នកជំនាញបារម្ភអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញមានការកើនឡើងខ្លាំងក្នុងអំឡុងផ្ទុះជំងឺកូវីដ ១៩។

ទំព័រហ្វេសប៊ុកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងក្រសួងសង្គមកិច្ចអតីតយុទ្ធជន បានឱ្យដឹងថា ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ «ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ» ដែលនឹងប្រព្រឹត្តទៅតាមកម្មវិធីអនឡាញ (ZOOM) នៅថ្ងៃទី ១៤ ខែកក្កដា នឹងត្រូវធ្វើឡើងក្រោមអធិបតីភាពលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងមានមន្ត្រីពីស្ថាប័នពាក់ព័ន្ធជាច្រើនចូលរួម។ កម្មវិធីប្រកាសឱ្យប្រើប្រាស់ផែនការនេះ ត្រូវបានរៀបចំដោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយសហការជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងក្រសួងមហាផ្ទៃក្រោមការឧបត្ថម្ភថវិកាពីអង្គការ Terre des Homme Netherlands អង្គការភ្លែនអន្តរជាតិ អង្គការ ChildFund អង្គការ UNICEF អង្គការ APLE អង្គការ CPU និងអង្គការចាប់ដៃ។

លោកស្រី ញៀប សុភាព អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានប្រាប់ភ្នំពេញ-ប៉ុស្តិ៍នៅថ្ងៃទី ១១ កក្កដា ថាក្នុងរយៈពេលនៃការផ្ទុះជំងឺរាតត្បាត អំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវបានរកឃើញថាបានកើនឡើងជាលំដាប់មិនថាបរិបទក្នុងប្រទេសកម្ពុជាឬពិភពលោកនោះទេ។

តាមការស្រាវជ្រាវថ្មីបានបង្ហាញថា ក្នុងរៀងរាល់ ៥ នាទីម្តង អំពើជួញដូររូបអាសអាភាសរបស់កុមារលើប្រព័ន្ធអ៊ីនធឺណិតត្រូវបានកើតឡើងក្នុងបរិបទជាសកល ខណៈកម្ពុជាក៏មានសម្ទុះខ្លាំង តាមរយៈការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធអនឡាញរបស់កុមារក្នុងពេលបច្ចុប្បន្ន។

លោកស្រីបានបញ្ជាក់ថា៖ «កុមារដែលត្រូវគេជួញដូរ គឺពិបាក ព្រោះគាត់លាក់ទុកនៅក្នុងខ្លួន និងគាត់មានផលពិបាក ហើយមិនដឹងប្រាប់អ្នកណាដែលទុកចិត្ត ហើយនៅពេលប្រាប់អាណាព្យាបាលក៏អាចនឹងទទួលបានការស្តីបន្ទោសត្រឡប់មកវិញ ព្រោះពួកគាត់មិនទាន់យល់ ហើយមិនជឿថា មានអំពើរំលោភតាមប្រព័ន្ធអ៊ីនធឺណិត»។ ប៉ុន្តែយ៉ាងណា លោកស្រី ញ៉ោប សុភាព បានអះអាងថា អំពើរំលោភតាមប្រព័ន្ធអ៊ីនធឺណិត គឺមានដល់ទៅ ៦ ទម្រង់ ដូចជាការកាន់កាប់រូបភាពអាសអាភាសរបស់កុមារ បង្ហោះរូបភាពអាសអាភាសរបស់កុមារ ការផលិតរូបភាពអាសអាភាសកុមារ ការបង្ហោះរូបភាពអាសអាភាសផ្សេងៗ និងការគំរាមកំហែងតាមទម្រង់ជាច្រើនទៀត ដែលធ្វើឱ្យកុមារទទួលរងគ្រោះ ហើយប៉ះពាល់ដល់ការអភិវឌ្ឍពួកគាត់ និងឈានដល់ការបាត់បង់ស្មារតីជាដើម។ លោកស្រីបានបញ្ជាក់បន្ថែមថា៖ «ការផ្ទុះជំងឺរាតត្បាត បានធ្វើឱ្យកុមារ ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតច្រើន ជាពិសេសសម្រាប់ការសិក្សា។ ដូច្នេះ យើងជំរុញដល់ឪពុកម្តាយកុំឱ្យទុកកូនចោល ឱ្យគាត់ប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតដោយមិនមានសុវត្ថិភាព»។

សូមជម្រាបថា ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ជាលើកដំបូងកាលពីឆ្នាំ ២០១៩ ហើយដើម្បីឆ្លើយតបនឹងបរិបទថ្មី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក៏បានធ្វើបច្ចុប្បន្នភាពក្នុងការដាក់ឱ្យអនុវត្តជាថ្មីទៀត ដើម្បីកៀរគរភាគីពាក់ព័ន្ធជាពិសេសស្ថាប័នអ្នកអនុវត្តច្បាប់ទូទាំងប្រទេសឱ្យបង្កើនសកម្មភាពបង្ការ ទប់ស្កាត់ និងឆ្លើយតបឱ្យកាន់តែមានប្រសិទ្ធភាព៕

## កម្ពុជា៖ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញមានជាង ១៥០ករណីក្នុង១ឆ្នាំៗ

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 14/07/2021 - 08:38

នៅកម្ពុជា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមអនឡាញមានជាង១៥០ករណីក្នុង១ឆ្នាំៗ។ នេះបើតាមការរាយការណ៍ពីសាធារណៈជនមកកាន់សមត្ថកិច្ច និងបណ្តាញរាយការណ៍តាមអ៊ីនធើណិត (Internet Hotline)។ តាមរយៈការសិក្សាស្រាវជ្រាវ និងការធ្វើអង្កេតលើកុមារកម្ពុជាឆ្នាំ២០២០ មានកុមារកម្ពុជាប្រមាណ៦០% ពួកគេបានរាយការណ៍ថា ធ្លាប់ជួបប្រទះហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ ដូចជាការលួងលោមក្នុងគោលបំណងផ្លូវភេទ និងការបង្ខំឱ្យផ្ញើរូបអាក្រាតជាដើម។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរួមរវាងក្រុមការងារអន្តរក្រសួង និងអង្គការសង្គមស៊ីវិលធ្វើការពាក់ព័ន្ធនឹងកុមារចេញផ្សាយនៅថ្ងៃទី១៤កក្កដានេះ។

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ កំពុងក្លាយជាក្តីព្រួយបារម្ភសម្រាប់ពិភពលោកទាំងមូលនិយាយជារួម និងនិយាយឡែកសម្រាប់ប្រទេសកម្ពុជាជាពិសេសកុមារដែលជួបប្រទះបញ្ហានេះរួចទៅហើយ។ នៅចំពោះមុខក្តីព្រួយបារម្ភនេះ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ នៅថ្ងៃទី១៤កក្កដានេះ តាមរយៈកម្មវិធីអនឡាញ ZOOM ដោយមានការចូលរួមពីអង្គទូត និងអង្គការអន្តរជាតិមួយចំនួន។ ផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញនេះ រួមមាន ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយ និងអភិបាលកិច្ច លើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ លើកកម្ពស់វិធានការបង្ការទប់ស្កាត់ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវ

តាមប្រព័ន្ធអនឡាញ។ ក៏មានដែរការពង្រឹងសុវត្ថិភាពសហគមន៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ រួមនឹងការពង្រឹងលក្ខន្តិកៈសម្រាប់ការផ្តល់សេវាអ៊ីនធឺណិត និងបង្កើនការផ្សព្វផ្សាយ និងការយល់ដឹងត្រឹមត្រូវអំពីបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានកត់សម្គាល់ថា ស្របពេលវិបត្តិកូវីដ-១៩ កំពុងរាតត្បាតទូទាំងពិភពលោក ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រឹតតែមានសារៈសំខាន់ ក្នុងការប្រាស្រ័យទាក់ទង និងដោះស្រាយគ្រប់បញ្ហា រួមទាំងការសិក្សាអប់រំរបស់កុមារ និងយុវជន យុវនារី ទាំងនៅទីក្រុង ទាំងជនបទ។ ទោះបីជាបច្ចេកវិទ្យាព័ត៌មានរីកចម្រើនក៏មានផ្នែកអវិជ្ជមានមួយចំនួន ពាក់ព័ន្ធនឹងការប្រើប្រាស់ខុសគោលដៅពីក្រុមឧក្រិដ្ឋជនឆ្លៀតឱកាសទាញយកផលប្រយោជន៍ដោយខុសច្បាប់ ដូចជាៈការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងរាលដាល និងបង្កហានិភ័យខ្ពស់ដល់កុមារនៅលើពិភពលោក រួមទាំងកម្ពុជាផងដែរ។

លោកស្រី ហ្សូអ៊ី ឌីម៉ែលឡូ អ្នកគ្រប់គ្រងគម្រោងប្រចាំកម្ពុជារបស់អង្គការដែនដីមនុស្សហូឡង់ ថ្លែងថា ផែនការសកម្មភាពជាតិដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅក្នុងប្រទេសកម្ពុជា គឺជាជំហានទៅមុខដែលអស្ចារ្យ ក្នុងការបង្កើតនូវការប្រើប្រាស់អ៊ីនធឺណិតប្រកដោយសុវត្ថិភាពសម្រាប់កុមារ។ បើតាមលោកស្រី ភាពស្មុគស្មាញនៃការរំលោភបំពានតាមប្រព័ន្ធអ៊ីនធឺណិត និងការគិតគូរពីបញ្ហាប្រឈមកើតចេញពីបច្ចេកវិទ្យាថ្មីៗនេះ គឺទាមទារឱ្យមានការឆ្លើយតបច្បាស់លាស់មួយ។

គួររំឭកជូនថា ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញនៅក្នុងពិភពលោក កើនឡើងដល់ជាង ២១,៧ លានករណី ក្នុងនោះជនល្មើសភាគច្រើនជាមនុស្សដែលកុមារមិនស្គាល់។ ចំណែក៧៦% នៃកុមាររងគ្រោះពីរូបភាពរំលោភបំពានផ្លូវភេទមានអាយុពី ៣ ទៅ ១៣ឆ្នាំ ក្នុងនោះ១% ជាកុមារមានអាយុពី ០ ទៅ ២ឆ្នាំ និង ៩៣% ជាក្មេងស្រី។ នេះបើតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិសម្រាប់កុមារបាត់ខ្លួន និងត្រូវបានកេងប្រវ័ញ្ច (NCMEC) របស់សហរដ្ឋអាមេរិក ឆ្នាំ២០២០ និងរបាយការណ៍របស់សមាគមន៍បណ្តាញរាយការណ៍បន្ទាន់អន្តរជាតិ (INHOPE) ឆ្នាំ២០២០៕

## កងទ័ពល្បាតទាំងយប់ទាំងថ្ងៃ តាមព្រំដែនកម្ពុជា-ថៃ ដើម្បីទប់ស្កាត់កូវីដបម្លែងថ្មី ឆ្លងចូលតាមរយៈពលករខ្មែរ

https://kohsantepheapdaily.com.kh/ ១៣ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២០:៥៩

ខេត្តបាត់ដំបង ៖ សភាពការណ៍ប្រទេសថៃ កំពុងវាយលុកខ្លាំង ដោយវីរុសកូវីដបម្លែងថ្មី ប្រភេទ Delta ហើយនៅខេត្តមួយចំនួនជាប់ព្រំដែនប្រទេសកម្ពុជា មានពលករចំណាកស្រុក អាចនឹងវិលត្រលប់មកចូលមកខ្មែរវិញ ដូច្នេះកងកម្លាំងកងពលតូចថ្មើរជើងលេខ៥៣ បន្តល្បាតទាំងយប់ទាំងថ្ងៃ ទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងឃាត់ខ្លួនឲ្យបាន ដើម្បីបញ្ជូនទៅធ្វើចត្តាឡីស័ក ។

បើយោងតាមប្រភពពីឧត្តមសេនីយ៍ត្រី កែវ សេងលន មេបញ្ជាការកងពលតូចថ្មើរជើងលេខ៥៣ បានចេញបញ្ជាតឹងរឹង ដល់មេបញ្ជាការវរសេនាតូចទិសស្រុកកំរៀង ទិសស្រុកភ្នំព្រឹក និងទិសស្រុកសំពៅលូន ដែលគ្រប់គ្រងកម្លាំងតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងការសហការទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់ នាំយកជំងឺកូវីដ-១៩ ចូលក្នុងប្រទេស ត្រូវអនុវត្តហ្មត់ចត់ នូវបទបញ្ជា ដែលបានដាក់ចេញ និងស៊ើបអង្កេតកំណត់មុខសញ្ញាមេខ្យល់ឲ្យបានច្បាស់ ដើម្បីចាប់ខ្លួនបញ្ជូនទៅឲ្យសមត្ថកិច្ចចាត់វិធានការតាមផ្លូវច្បាប់ ។ លោកមេបញ្ជាការ បានអំពាវនាវដល់ពលករ ដែលនឹងត្រូវត្រឡប់មកប្រទេសវិញ ត្រូវធ្វើដំណើរត្រង់មកតាមច្រកទ្វារចូលពិនិត្យតេស្តសំណាក ចូរកុំជឿពាក្យបោកប្រាស់របស់ពួកមេខ្យល់ថា កងកម្លាំងចាប់ធ្វើបាបឲ្យសោះ នេះគ្រាន់តែជាល្បិចកិច្ចកលរបស់ពួកមេខ្យល់ ដើម្បីលាភសក្ការៈផ្ទាល់ខ្លួន ហើយនាំបងប្អូនគេចពង្វៀងពីការធ្វើចត្តាឡីស័កតែប៉ុណ្ណោះ ។ ការ

គេចវេសពីការធ្វើចត្តាឡីស័ក មិនត្រឹមតែគ្រោះថ្នាក់ដល់ក្រុមគ្រួសារប៉ុណ្ណោះទេ ថែមទាំងមហន្តរាយធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូលទៀតផង ៕

## លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ានិត ចុះពិនិត្យទីតាំងធ្វើចត្តាឡីស័ក សម្រាប់ដាក់បងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃវិញ

http://nokorwatnews.com/ 13/07/2021

ខេត្តឧត្តរមានជ័យ៖ លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ានិត ចុះពិនិត្យទីតាំងធ្វើចត្តាឡីស័កបន្ថែមទៀតអោយបានលឿនទាន់សភាពការណ៍ សម្រាប់ដាក់បងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃវិញ ដែលលោកបានមមាញឹក និងកិច្ចការនេះ ប្រកបដោយភាពទទួលខុសត្រូវលើបញ្ហានេះយ៉ាងខ្លាំងក្លាបំផុតដើម្បីការពារការរាតត្បាតនៃជំងឺកូវីដ-១៩ ដែលកំពុងឃាយឃីយ៉ាងធ្ងន់ធ្ងរមកលើប្រជាពលរដ្ឋកម្ពុជាយើងនោះ។

សូមជម្រាបជូនថា, នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ នាយឧត្តមសេនីយ៍ ខេង សុមេធ អគ្គស្នងការរងនគរបាលជាតិ និងជាប្រធានអនុគណៈកម្មការសាងសង់ និងជួសជុល ព្រមទាំង លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ានិត អគ្គនាយកស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ និងជាប្រធានអនុគណៈគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក លោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តមានជ័យបានអញ្ជើញចុះពិនិត្យទីតាំងជាក់ស្តែងដើម្បីរៀបចំកន្លែងធ្វើចត្តាឡីស័កបន្ថែមទៀតអោយបានលឿនទាន់សភាពការណ៍ សម្រាប់ដាក់បងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃវិញ។

សូមបញ្ជាក់ថា, ដោយការយកចិត្តទុកដាក់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុនសែន , បើតាមតួលេខ កម្ពុជាកំពុងឈរលំដាប់ទី២ បន្ទាប់ពី សឹង្ហបូរី បើគិតនៅក្នុងតំបន់អាស៊ាន ,ដោយគិតមកទល់នឹងពេលនេះ កម្ពុជាសម្រេចបាននូវការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋរបស់ខ្លួនបានប្រមាណជិត ៥លាននាក់រួចហើយ ដែលស្មើនឹងប្រមាណ ៤៩.៩៧%ធៀបនឹងគោលដៅចំនួន ១០ លាននាក់។ ប្រការនេះបានធ្វើឱ្យប្រទេស និងមជ្ឈដ្ឋានមួយចំនួនបានបើកភ្នែកធំៗ ព្រោះត្បិតនឹកស្មានមិនដល់ថា កម្ពុជាដែលជាប្រទេសតូច និងធនធានមានកម្រិត អាចមានលទ្ធភាពបើកយុទ្ធនាការចាក់វ៉ាក់សាំងជូនអ្នកផ្តល់សេវាជួរមុខ មន្ត្រីរាជការ និងក្រុមជនអាទិភាពព្រមទាំងប្រជាពលរដ្ឋរបស់ខ្លួន ដូចបណ្តាប្រទេសជឿនលឿននានាដែរសោះ៕

# ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

## សម្តេចក្រឡាហោម ៖ ក្រុមឧក្រិដ្ឋជន បង្កើតឱ្យមានការកេងប្រវ័ញ្ច និងឧក្រិដ្ឋកម្មគ្រប់រូបភាព រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ

https://cen-news.com/ Posted ByPen Srey NeatJuly 14, 2021

ភ្នំពេញ ៖ នាព្រឹកថ្ងៃពុធ ទី១៤ ខែកក្កដា ឆ្នាំ២០២១នេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អញ្ជើញជាអធិបតីក្នុងពិធី «ផ្សព្វផ្សាយផែនការសកម្មភាព ដើម្បីបង្ការទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឆ្នាំ២០២១-២០២៥» តាមប្រព័ន្ធអនឡាញ។ ពិធីផ្សព្វផ្សាយនេះ មានការអញ្ជើញចូលរួមពីឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ, ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី ក្រសួងស្ថាប័នពាក់ព័ន្ធ, ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូតប្រចាំនៅកម្ពុជា, អនុប្រធាន សមាជិក សមាជិកា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ, ឯកឧត្តម អគ្គស្នងការដ្ឋាននគរបាលជាតិ, អភិបាលនៃគណ:អភិបាល រាជធានី ខេត្ត, តំណាងក្រសួងស្ថាប័ននិងអង្គការដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ។

អញ្ជើញមានប្រសាសន៍នាឱកាសនោះ សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា ជាការពិត ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជាបញ្ហាសកល ហើយពិភពលោកកំពុងតែយកចិត្តទុកដាក់ និងរួមគ្នា ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការរំលោភបំពានក្នុងបរិបទប្រព័ន្ធបច្ចេក វិទ្យាព័ត៌មាន ដែលក្នុងនោះ កម្ពុជាជាប្រទេសដែលបោះជំហានទៅមុខ ក្នុងការចូលរួមចំណែកសំដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវការលើកកម្ពស់កិច្ចការពារកុមារ និងឧត្តមប្រយោជន៍របស់កុមារ ទាំងកម្ពុជា ក៏ដូចជាពិភពលោកផងដែរ។ សម្តេច មានប្រសាសន៍បន្តថាបន្ទាប់ពី កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ព្រមទាំងលើពិធីសារបន្ថែម ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះ ប្រដាប់អាវុធ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២រួចមក រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទដ្ឋានទាំងនោះ ដោយខិតខំដាក់បញ្ចូលខ្លឹមសារពាក់ព័ន្ធទៅក្នុងច្បាប់ គោលនយោបាយ ផែនការនានា សំដៅពង្រឹងកិច្ចការពារកុមារពីភាពរងគ្រោះទាំងឡាយឲ្យកាន់តែល្អប្រសើរ។

សម្តេចបានបង្ហាញការកត់សម្គាល់ថា ស្របពេលនឹងវិបត្តិកូវីដ-១៩ កំពុងរាតត្បាតទូទាំងពិភពលោក ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រឹតតែមានសារសំខាន់ ក្នុងការប្រាស្រ័យទាក់ទង និងដោះស្រាយគ្រប់បញ្ហា រួមទាំងការសិក្សាអប់រំរបស់កុមារ និងយុវជន យុវនារី ទាំងនៅទីក្រុង ទាំងជនបទ ប៉ុន្តែក៏កើតមានជ្រុងអវិជ្ជមានតាមរយៈការប្រើប្រាស់ខុសគោលដៅ និងដោយមានការជ្រៀតចូលពីក្រុមឧក្រិដ្ឋជន ឆ្លៀតឱកាសទាញយកផលប្រយោជន៍ដោយខុសច្បាប់ និងប្រាសចាកពីគន្លងសីលធម៌ និងការអភិវឌ្ឍន៍ ដោយបង្កើតឱ្យមានការកេងប្រវ័ញ្ចនិងឧក្រិដ្ឋកម្មគ្រប់រូបភាព រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងរាលដាល និងបង្កហានិភ័យខ្ពស់ដល់កុមារនៅលើពិភពលោក រួមទាំងកម្ពុជា។ ដោយមើលឃើញនូវបញ្ហាប្រឈមនិងផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរបែបនេះ សម្តេចឧបនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ថា កម្ពុជា បានសម្រេចចូលជារដ្ឋភាគីហត្ថលេខីនៃសេចក្តីថ្លែងការណ៍សកម្មភាពសកល កាលពីឆ្នាំ២០១៥, ចូលជាសមាជិកនៃប្រទេសភាពជាដៃគូសកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារនៅឆ្នាំ២០១៩, អនុម័តលើសេចក្តីថ្លែងការណ៍អាស៊ានជំរុញការប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ និងបានរៀបចំផែនការសកម្មភាពទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដើម្បីជាមូលដ្ឋានបង្អែក និងជំរុញការចូលរួមពីក្រសួង ស្ថាប័ន អាជ្ញាធរ និងអង្គភាពពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាលរួមគ្នាទប់ស្កាត់អំពើហិង្សា និងអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឲ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត។

ដោយផ្អែកលើវឌ្ឍនភាពការងារដូចបានបានបញ្ជាក់មកនេះ សម្តេចក្រឡាហោម បានសម្តែងនូវការកោតសរសើរ ចំពោះការដឹកនាំរបស់ឯកឧត្តមរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏ដូចជាអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលបានបំពេញតួនាទីយ៉ាងល្អប្រសើរ ក្នុងការសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរួមគ្នាប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ព្រមទាំងបទដ្ឋានគតិយុតិជាតិ និងអន្តរជាតិជាច្រើនដែលមានជាធរមាន និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន គ្រួសារ និងសហគមន៍ រួមទាំងកុមារទាំងឡាយដែលបានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងធនធានប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការរួមចំណែកលើកកម្ពស់សិទ្ធិកុមារ ដើម្បីកុមារទទួលបាននូវសិទ្ធិពេញលេញដូចមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ។

ដើម្បីរួមគ្នាជំរុញ និងលើកកម្ពស់កិច្ចខិតខំប្រឹងប្រែង ក្នុងកិច្ចការពារកុមារ តាមប្រព័ន្ធអនឡាញនេះ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី បានក្រើនរំលឹក គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ សូមយកចិត្តទុកដាក់បញ្ចូល ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពសាមុី។ នាយកដ្ឋាន និងការិយាល័យ ជំនាញដែលមានសមត្ថកិច្ចក្នុងការធ្វើអន្តរាគមន៍ និងដោះស្រាយករណីបទល្មើសបច្ចេកវិទ្យា ត្រូវបន្តការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិដែលមានជាធរមាន ជាពិសេស ផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើការដោះស្រាយករណីកុមារ ឲ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ទោះបីកុមារស្ថិតក្នុងស្ថានភាពណាក៏ដោយ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ដែលជាអនាគតប្រទេសជាតិ។

សម្តេចមានប្រសាសន៍ណែនាំឱ្យសិក្សាឡើងវិញ នូវភាពខ្វះចន្លោះនៃបទបញ្ញត្តិ ដែលមានជាធរមានលើបទល្មើសឧក្រិដ្ឋកម្មបច្ចេក វិទ្យាលើកុមារ ដោយស្មារតី និងឆន្ទៈទទួលខុសត្រូវខ្ពស់ ជាពិសេសក្នុងករណីមិនមានចែងនៅក្នុងច្បាប់ សូមអនុវត្តដោយឈរលើគោលការណ៍នៃការសម្រេច ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស និងសិទ្ធិកុមារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន និងមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គប្បីបន្តសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងក្រោមជាតិ ដោយប្រើប្រាស់យន្តការដែលមានស្រាប់ លើកកម្ពស់ការអនុវត្ត សំដៅធ្វើឲ្យសម្រេចនូវយុទ្ធសាស្ត្រទាំង៦ដែលមាននៅក្នុងផែនការនេះ។ លើសពីនេះទៀត ត្រូវពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ ជាពិសេស បង្កើតប្រព័ន្ធទិន្នន័យកុមារទូទាំងប្រទេស ហើយត្រូវបំពេញតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាល។

សម្តេចក៏បានអំពាវនាវឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ គប្បីបន្តការគ្រប់គ្រងឱ្យបានហ្មត់ចត់ នូវក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណិត ក្នុងការកំណត់នូវស្តង់ដាដែលអាច បង្កើត ចែកផ្សាយ និងរក្សាកំណត់ត្រាទិន្នន័យ ជាពិសេស បង្កើតគោលនយោបាយការពារកុមារ ដែលអាចឆ្លើយតបឆាប់រហ័ស និងការទទួលខុសត្រូវចំពោះមាតិការូបភាពនិងសម្ភារអាសអាភាសដែលរក្សាទុកនៅក្រុមហ៊ុន ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គប្បីបន្តការលើកកម្ពស់សេវាសង្គម ជាពិសេស ការផ្តល់ប្រឹក្សាយោបល់ ការស្តារនីតិសម្បទា និងសមាហរណកម្មចំពោះកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងបទល្មើសបច្ចេកវិទ្យាពត៌មាន ដោយផ្តល់អាទិភាពជាចម្បងដល់កុមារី កុមារជាជនជាតិដើមភាគតិច និងកុមារមានពិការភាព។

ជាមួយគ្នានេះ សម្តេចបានទទូចឱ្យគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរ និងសមត្ថកិច្ចគ្រប់ផ្នែក ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនិងអង្គការដៃគូ គប្បីជំរុញ លើកកម្ពស់ការយល់ដឹងអំពីព័ត៌មានសង្គមដល់មាតាបិតា និងអ្នកដែលមានទំនាក់ទំនងជាមួយកុមារអំពីការប្រើប្រាស់ប្រព័ន្ធអ៊ីនធើណិត បញ្ហាគ្រោះថ្នាក់ដែលកើតមានចំពោះកុមារតាមប្រព័ន្ធអ៊ីនធើណិត និងផ្សព្វផ្សាយដល់អ្នកប្រើប្រាស់ពីរបៀបបង្ការ ជៀសវាងពីទំនាក់ទំនងជាមួយជនខិលខូចនៅក្នុងប្រព័ន្ធអ៊ីនធើណិត និងពង្រឹងការអនុវត្តប្រព័ន្ធរាយការណ៍ទាន់ហេតុការណ៍ (Internet Hotline) និងយន្តការឆ្លើយតប ឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ចំពោះករណីរំលោភបំពានកុមារតាមប្រព័ន្ធអ៊ីនធើណិត ព្រមទាំងពង្រឹងបណ្តាញប្រឆាំងបទល្មើសបច្ចេកវិទ្យា និងសមត្ថភាពអនុវត្តនៅថ្នាក់ក្រោមជាតិ ដោយរួមសហការជាមួយដៃគូពាក់ព័ន្ធ ជាតិ និង អន្តរជាតិ ក្នុងការបង្ការ ទប់ស្កាត់ និងឆ្លើយតបករណីរូបភាព និងសម្ភារអាសអាភាសកុមារឱ្យទាន់ពេលវេលា។

សម្តេចក៏បានផ្តល់អនុសាសន៍ឱ្យពិនិត្យលទ្ធភាពក្នុងការវិនិយោគ លើធនធានមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច តាមបណ្តាឃុំ-សង្កាត់ ដើម្បីបង្ហិតសេវាសង្គមកិច្ច គាំពារកុមារឲ្យដល់សហគមន៍ ជាពិសេសយកចិត្តទុកដាក់ចំពោះកុមាររងគ្រោះ និងងាយរងគ្រោះ កុមារត្រូវបានគេបោះបង់ កុមារដែលទទួលរងអំពើហិង្សា និងការកេងប្រវ័ញ្ច

គ្រប់រូបភាព និងពង្រឹងការបញ្ជ្រាបចូលបញ្ហា នៃការរំលោភបំពានកុមារគ្រប់រូបភាព ជាពិសេស តាមប្រព័ន្ធអនឡាញ ទៅក្នុងវេទិកាសាធារណៈ នៃគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ដើម្បីឲ្យមាតា បិតា អាណាព្យាបាល អាជ្ញាធរ សមត្ថកិច្ច បានយល់ជ្រួតជ្រាប និងបង្កើនកិច្ចការពារកុមារក្នុងគ្រួសារ និងសហគមន៍ ជំរុញ និងលើកទឹកចិត្តឱ្យក្រុមហ៊ុនឯកជនដែលផ្តល់សេវាអ៊ីនធើណិត ណែនាំអ្នកប្រើប្រាស់ឧបករណ៍ចែកចាយអ៊ីនធើណិត ដែលមានសុវត្ថិភាពចំពោះកុមារ និងតាមដានភាពប្រែប្រួលប្រសើរឡើងនៃការយល់ដឹងរបស់សហគមន៍ ក្នុងកិច្ចការពារកុមារពីភាពរងគ្រោះ ដោយការរំលោភបំពានតាមប្រព័ន្ធអនឡាញ ។ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## សម្តេច ស ខេង ឲ្យក្រសួងស្ថាប័ន អាជ្ញាធរយកចិត្តទុកដាក់បង្ការ ទប់ស្កាត់ ការកេងប្រវ័ញ្ចផ្លូវភេទកុមារ

https://dap-news.com/national/ ByTR110 Posted on July 14, 2021

**ភ្នំពេញ ៖ ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិ ប្រឆាំងអំពើជួញដូរមនុស្សផង និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃផង សម្តេច ស ខេង បានដាក់បទបញ្ជាឲ្យគ្រប់ក្រសួងស្ថាប័ន អាជ្ញាធរ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវយកចិត្តទុកដាក់លើផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥។**

ក្នុងពិធីប្រកាសដាក់ប្រើប្រាស់ជាផ្លូវការ «ផែនការសកម្មភាពដើម្បី បង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារ នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ សម្តេច ស ខេង បានក្រើនរំលឹកដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងស្ថាប័នមានសមត្ថកិច្ចទាំងអស់ រួមគ្នាបន្តពង្រឹងការអនុវត្ត បទដ្ឋានច្បាប់ដែលមានជាធរមាន ដើម្បីប្រសិទ្ធភាពក្នុងកំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ប្រកបដោយសង្គតិភាពក្នុងការបង្ការ ទប់ស្កាត់ អន្តរគមន៍ និងការឆ្លើយតបលើករណីកុមារ។ សម្តេចមានប្រសាសន៍ថា «គ្រប់ក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ សូមយកចិត្តទុកដាក់ បញ្ចូលផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ ទៅក្នុងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់អង្គភាពសាម៉ី»។

សម្តេចបន្តថា នាយកដ្ឋាន និងការិយាល័យ ជំនាញដែលមានសមត្ថកិច្ចក្នុងការធ្វើអន្តរាគមន៍ និងដោះស្រាយករណីបទ ល្មើសបច្ចេកវិទ្យា ត្រូវបន្តការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ អនុលោមតាមច្បាប់ជាតិ និងអន្តរជាតិដែលមានជាធរមាន ជាពិសេស ផ្តោតការយកចិត្តទុកដាក់ជាអាទិភាពលើការដោះស្រាយករណីកុមារ ឲ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ទោះបីកុមារស្ថិតក្នុងស្ថានភាពណាក៏ដោយ ដើម្បីជាឧត្តមប្រយោជន៍របស់កុមារដែលជាអនាគតប្រទេសជាតិ ។ សម្តេច ស ខេង ក៏បានណែនាំដល់អ្នកពាក់ព័ន្ធទាំងអស់ ត្រូវពង្រឹងការបញ្ជ្រាបចូលបញ្ហា នៃការរំលោភបំពានកុមារគ្រប់រូបភាព ជាពិសេស តាមប្រព័ន្ធអនឡាញ ទៅក្នុងវេទិកាសាធារណៈ នៃគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព ដើម្បីឲ្យមាតា បិតា អាណាព្យាបាល អាជ្ញាធរ សមត្ថកិច្ច បានយល់ជ្រួតជ្រាប និងបង្កើនកិច្ចការពារកុមារក្នុងគ្រួសារ និងសហគមន៍ ៕

## កម្ពុជា បោះជំហានទៅមុខ ក្នុងការលើកកម្ពស់កិច្ចការពារកុមារ ទាំងកម្ពុជា និងពិភពលោក

https://dap-news.com/national/ ByKD102 Posted on July 14, 2021

ភ្នំពេញ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការ ជាតិប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងថា កម្ពុជា ជាប្រទេសបោះជំហានទៅមុខ ក្នុងការរួមចំណែកធ្វើឲ្យប្រសើរឡើង នូវការលើកកម្ពស់កិច្ចការពារកុមារ ទាំងកម្ពុជា និងពិភពលោក ផងដែរ។

ក្នុងពិធីប្រកាសដាក់ប្រើប្រាស់ជាផ្លូវការ «ផែនការសកម្មភាពដើម្បី បង្ការ ទប់ស្កាត់ និងឆ្លើយតប ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥ នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ តាមប្រព័ន្ធវីដេអូ សម្តេច ស ខេង មានប្រសាសន៍ថា «ជាការពិត ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ជាបញ្ហាសកល ហើយពិភពលោកកំពុងតែយកចិត្តទុកដាក់ និងរួមគ្នា ដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការរំលោភបំពានក្នុងបរិបទប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលក្នុងនោះ កម្ពុជា ជាប្រទេសដែលបោះជំហានទៅមុខ ក្នុងការចូលរួមចំណែក សំដៅធ្វើឲ្យកាន់តែប្រសើរឡើង នូវការលើកកម្ពស់កិច្ចការពារកុមារ និងឧត្តមប្រយោជន៍របស់កុមារ ទាំងកម្ពុជា ក៏ដូចជាពិភពលោក ផងដែរ»។

សម្តេច ក៏បានរំលឹកថា ក្រោយពីកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នាថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងលើពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ព្រមទាំងលើពិធីសារបន្ថែម ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះ ប្រដាប់អាវុធ នាថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២រួចមក រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវបទដ្ឋានទាំងនោះ ដោយខិតខំដាក់បញ្ចូល ខ្លឹមសារពាក់ព័ន្ធទៅក្នុងច្បាប់ គោលនយោបាយ ផែនការនានា សំដៅពង្រឹងកិច្ចការពារកុមារពីភាព វង្វេងគ្រោះទាំងឡាយឲ្យកាន់តែល្អប្រសើរ។ សម្តេច បន្តថា ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា សេដ្ឋកិច្ច និងសង្គមជាតិ ត្រូវបានជំរុញស្តារ និងអភិវឌ្ឍន៍បន្ថែមទៀត រហូតធ្វើឲ្យសម្រេចកំណើនសេដ្ឋកិច្ច គួរឲ្យកត់សម្គាល់ក្នុងពីរទសវត្សរ៍ចុងក្រោយនេះ ហើយត្រូវបានប្រទេសនានាក្នុងតំបន់ និងលើពិភពលោកទទួលស្គាល់ នូវការប្រែប្រួលឈានឡើង យ៉ាងឆាប់រហ័សរបស់កម្ពុជា បានបង្កើតនូវឱកាសជាច្រើនថែមទៀត ក្នុងការកសាងនិងអភិវឌ្ឍន៍ប្រទេសជាតិ៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៣នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៣នាក់ ស្រី ១១នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១១នាក់ ស្រី ៥នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៦នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍)។

៥-ប្រកដួង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារា ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ប្រកព្រំ÷ ចំនួន ៥នាក់ ស្រីចំនួន ២នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៣នាក់ ស្រី ១១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋមលើសុខភាព និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតាដោយតម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ។ សូមបញ្ជាក់ជូនថាៈ ថ្ងៃនេះ ក្រុមការងារបានបញ្ជូនពលករ ដែលបញ្ចប់ធ្វើចត្តាឡីស័ក និងអ្នកព្យាបាលជាសះស្បើយមកពីបណ្ដាខេត្តតាមព្រំដែន មានចំនួន ២នាក់ ស្រី ១នាក់ ៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយៈ ធូ កុសល

## ពលករខ្មែរចំណាកស្រុកប្រមាណ២000នាក់ បានចាកចេញពីប្រទេសថៃ

https://www.khmertimeskh.com/ Khmer July 15, 2021

ដោយសារកន្លែងធ្វើការជាច្រើនត្រូវបានបិទ ពលករចំណាកស្រុកកម្ពុជាប្រមាណជាង ២,០០០នាក់ ត្រូវបានរាយការណ៍ថា ត្រលប់មកប្រទេសកំណើតវិញដោយឆ្លងកាត់ខេត្តសូរិន តាមច្រកជាំស្រងាំ។ ពលករចំណាកស្រុកជាច្រើនបានសំរេចចិត្តត្រលប់មកប្រទេសកំណើតវិញ បន្ទាប់ពីលោក ប្រាយុទ្ធ ចាន់ អូចា នាយករដ្ឋមន្ត្រីថៃ បានប្រកាសអោយបិទកន្លែងធ្វើការជាច្រើននៅទូទាំងទីក្រុងបាងកក ដើម្បីគ្រប់គ្រងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងទីក្រុង ខេត្តនៅជុំវិញ និងខេត្តនៅភាគខាងត្បូងចំនួន៤ទៀត កាលពីថ្ងៃទី២៨ ខែមិថុនា។ កាលពីថ្ងៃសៅរ៍ ការរឹតត្បិតធ្វើដំណើរឆ្លងកាត់ខេត្តក៏ត្រូវបានដាក់ចេញ សម្រាប់ទីក្រុងបាងកក នុនថាបុរី ណាខនផាធុម ផាធុមថានី សាមុទ្រប្រកាន និងសាមុទ្រប្រាខន។ វិធានការណ៍រឹតត្បិត បានធ្វើអោយពលករចំណាកស្រុកប្រមាណ ១០០ ទៅ ១៥០នាក់ គ្មានការងារធ្វើ។ ចំពោះពលករដែលរស់នៅក្រៅតំបន់រឹតត្បិត ពួកគេបានត្រលប់មកប្រទេសកំណើតរបស់ពួកគេវិញ។

កាលពីថ្ងៃអាទិត្យ យោងតាមមន្ទីសុខាភិបាលខេត្តឧត្តមានជ័យ ៖ ចាប់តាំពីកន្លែងធ្វើការជាច្រើនត្រូវបានបិទ ពលករចំណាកស្រុកកម្ពុជាប្រមាណ២០០០នាក់ ត្រូវបានរាយការណ៍ថាត្រលប់មកស្រុកកំណើតវិញដោយឆ្លងកាត់ច្រកត្រួតពិនិត្យព្រំដែនជាំស្រងាំ។ ក្នុងចំណោមចំនួនពលរករទាំងនេះពលករចំនួន២៣៩នាក់ត្រូវបានរកឃើញថាមានជំងឺកូវីត-១៩។

ដោយសារការរីករាលដាលគ្រោះថ្នាក់នៃវីរុស មន្ត្រីអន្តោប្រវេសន៍នៅខេត្តសូរិនបានរឹតបន្តឹងវិធានការណ៍ប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយផ្តល់ទីតាំងដាក់លាក់សម្រាប់ពលករចំណាកស្រុកកម្ពុជា ដើម្បីត្រួតពិនិត្យរកវីរុស ព្រមទាំងបាញ់ថ្នាំសម្លាប់មេរោគនៅលើរបស់របរធ្វើដំណើររបស់ពួកគេ។ មន្ត្រីអន្តោប្រវេសន៍បានតំរូវអោយអ្នកគ្រប់គ្រងនាំយកពលកររបស់ខ្លួនទៅតាំងដែលបានកំណត់ទុក ដើម្បីបំបែកពួកគេកុំអោយនៅជិតអ្នកដទៃ។ ពលករមិនត្រូវបានអនុញ្ញាតអោយចាកចេញពីកន្លែងដែលបានកំណត់ទុកនោះទេ ពួកគេត្រូវបានជូនអោយឡើងជិះឡានដើម្បីឆ្លងកាត់ព្រំដែន។ នៅថ្ងៃពុធ មានករណីថ្មីចំនួន៣៣៩ ត្រូវបារកឃើញក្នុងខេត្តទាក់ធីនសៅ ដែលធ្វើអោយករណីសរុបកើនឡើងដល់ ៤,៤១២ ករណី៕ *Bangkok post*

## ពលករចំណាកស្រុកកម្ពុជានៅប្រទេសថៃបានទទួលការអនុញ្ញាតអោយស្នាក់នៅបន្ត

https://www.khmertimeskh.com/ Khmer July 15, 2021

គណៈរដ្ឋមន្ត្រីថៃបានអនុម័តសំណើរអនុញ្ញាតអោយពលករចំណាកស្រុក៤ក្រុម មកពីកម្ពុជា ឡាវ និងភូមា ស្នាក់នៅ និងធ្វើការស្របច្បាប់ រហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំក្រោយ ដើម្បីអនុញ្ញាតអោយពួកគេអាចដោះស្រាយឯកសារពាក់ព័ន្ធនឹងការធ្វើការស្របច្បាប់ តំរូវដោយច្បាប់ ដែលធ្លាប់បានដាក់ចេញពីមុន។

លោក Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារបាននិយាយថា ការសម្រេចចិត្តនេះត្រូវបានសម្រេចក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី កាលពីថ្ងៃអង្គារ។ រដ្ឋាភិបាលធ្លាប់បានដោះស្រាយ និងអនុញ្ញាតពលករចំណាកស្រុកប្រទេសទាំងនេះស្នាក់នៅ និងធ្វើការបណ្តោះអាសន្ននៅក្នុងប្រទេស តាមរយៈសេចក្តីសម្រេចចំនួនបី មុននឹងមានសេចក្តីសម្រេចចិត្តរបស់គណៈរដ្ឋមន្ត្រីនេះទៅទៀត សេចក្តីសម្រេចទាំងបីនេះមាន សេចក្តីសម្រេចធ្វើនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ សេចក្តីសម្រេចធ្វើនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ និងសេចក្តីសម្រេចញធ្វើនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០។

មានពលករចំណាកស្រុកជាច្រើន ដែលមានប័ណ្ណការងារផុតកំណត់ ដោយសារពួកគេមិនអាចស្វែករកអ្នកអោយការងារថ្មីក្នុរយៈពេល៣០ថ្ងៃ ដែលតំរូវដោយច្បាប់ បន្ទាប់ពីពួកគេឈប់ ឬក៏បាត់បង់ការងារដែលធ្លាប់មាន។ ប៉ុន្តែ លិខិតអនុញ្ញាតស្នាក់នៅបន្តរបស់ពួកគេនឹងត្រូវផុតកំណត់ឆាប់ៗ ដោយសារជំងឺរាតត្បាតកូវីដ-១៩។ ពលករចំណាកស្រុកទាំងនេះប្រឈមនឹងការក្លាយទៅជាពលករខុសច្បាប់ប្រសិនបើគ្មានអន្តរាគមន៍ណាមួយជួយទេនោះ។ ជាលទ្ធផល នៅថ្ងៃទី២៦ ខែមករា រដ្ឋាភិបាលបានសំរេចបន្តផ្តល់ការអនុញ្ញាតផ្សេងទៀតដល់ពួកគេ ដែលអាចអោយអ្នកចំណាកស្រុក ស្នាក់នៅរហូតពីថ្ងៃទី៣១ ខែកក្កដា ដល់ ថ្ងៃទី៦ ខែកញ្ញា ដោយយោងតាមកាលបរិច្ឆេទផុតកំណត់ក្នុងប័ណ្ណអនុញ្ញាតអោយធ្វើការរបស់ពួកគេ។

ដោយសារជំងឺរាតត្បាតនៅមិនទាន់មានភាពស្រាកស្រាន្ត ពលករនៅតែប្រឈមនឹងការបាត់បង់ភាពធ្វើការងារស្របច្បាប់នៅក្នុងប្រទេសថៃ។ ដូច្នេះហើយ លោក Suchart បានបន្ថែមថា រដ្ឋាភិបាលបានសំរេចអនុញ្ញាតពលករចំណាកស្រុកប្រទេសទាំងនេះអាចស្នាក់នៅរហូតដល់ថ្ងៃទី២៧ ខែកក្កដា ឆ្នាំក្រោយ ដើម្បីផ្តល់ទល្ធភាពអោយពួកគេមានឱកាសចាត់ចែងឯកសារធ្វើការស្របច្បាប់ និងចុះឈ្មោះទទួលប័ណ្ណការងារ។

Pairoj Chotikasatien អគ្គនាយកនៃនាយកដ្ឋានការងារ បានគូសបញ្ជាក់ថា៖ លើសពីនេះពលករចំណាកស្រុកមកពីប្រទេសទាំងនេះ ដែលបាត់បង់ការងារដោយសារសេដ្ឋកិច្ចចុះខ្សោយបណ្តាលមកពីវិធានការណ៍រឹតត្បឹតការពារជំងឺកូវីដ-១៩ ពួកគេនឹងត្រូវបានផ្តល់រយៈពេលចំនួន៦០ថ្ងៃថែមទៀត ដើម្បីអាចរកការងារថ្មី និងចុះឈ្មោះជាមួយអាជ្ញាធរខាងផ្នែកការងារ។

លោក Suchart បាននិយាយថា រដ្ឋាភិបាលកំពុងតែព្យាយាមជួយសម្រួលពលករទាំងនេះ ដើម្បីជានាអោយពួកគេបាននូវសុវត្ថិភាព សុខភាពល្អ ដែលមានសារៈសំខាន់ក្នុងការធានាបាននូវសុខភាពសាធារណៈជាទូទៅក្នុងប្រទេសថៃ។

## សមត្ថកិច្ចនាំពលករជិត១០នាក់ទៅមណ្ឌលធ្វើចត្តាឡីស័ក

https://cambodiaflashnews.com/ by Mr Ratanak July 15, 2021

បាត់ដំបង៖ ពលករខ្មែរជិត១០នាក់បាននាំគ្នាចាកចេញពីប្រទេសថៃតាមច្រករបៀងស្រុកសំពៅលូន ត្រូវសមត្ថកិច្ចនាំយកមកធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ។ មន្ត្រីបានឲ្យដឹងនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២១នេះថា កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ កម្លាំងប៉ុស្តិ៍នគរបាលព្រំដែន សហការជាមួយកម្លាំងចម្រុះជាច្រើនទៀត កាលពីថ្ងៃទី១៤ ខែកក្កដា បាននាំខ្លួនពលករខ្មែរប្រុសស្រីសរុបចំនួន ៨នាក់ ដែលបានចូលមកទឹកដីស្រុកសំពៅលូន កាត់តាមផ្លូវច្រករបៀងដែលព្យាយាមមិនចូលធ្វើចត្តាឡីស័កតាមការណែនាំរបស់រាជរដ្ឋាភិបាល។ ពលករទាំងអស់ខាងលើ បន្ទាប់ពីកម្លាំងប្រចាំគោលដៅសាកសួររួច និងបានណែនាំអប់រំឲ្យចូលរួមធ្វើ

ជាពលរដ្ឋល្អ អនុវត្តការធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល និងចូលរួមជាមួយក្រុមគ្រូពេទ្យ ធ្វើចត្តាឡីស័ក ១៤ថ្ងៃ៕ ដោយៈព្រះអង្គខ្មៅ

## បង្កំខ្លួនក្នុងរថយន្តសង្គ្រោះដឹកអ្នកជំងឺកូវីដ តម្រួតថៃចាប់បានពលករខ្មែរជាង១០នាក់

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៥ កក្កដា ២០២១ដោយ Sokhom Khon

ពកលកខ្មែរប្រមាណជាង១០នាក់ រួមជាមួយរថយន្តចំនួន២គ្រឿង ក្នុងនោះ១គ្រឿង ជារថយន្តសង្គ្រោះបន្ទាន់ ត្រូវបានក្រុមតម្រួតប្រចាំខេត្តច័ន្ទបុរី ស្ទាក់ចាប់បាន បន្ទាប់ពីមានការសង្ស័យថា នៅក្នុងរថយន្តសង្គ្រោះបន្ទាន់នោះ មិនមែនជាអ្នកជំងឺកូវីដ-១៩ ។ ការឃាត់រថយន្តទាំង២គ្រឿងនេះ បានធ្វើឡើងកាលពីល្ងាចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ត្រង់ចំណុចភូមិ៤ឃុំទេពនិមិត្រ ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី ប្រទេសថៃ ដែលរថយន្តទាំង២គ្រឿងនេះ គឺទី១ ជាប្រភេទរថយន្តសង្គ្រោះបន្ទាន់ ដោយអ្នកបើកបរមានស្លៀកពាក់ឯកសណ្ឋានជាគ្រូពេទ្យដើរយកសំណាក ព្រមទាំងបានបើកភ្លើងស៊ីរ៉ែនតាមផ្លូវរហូត។ ដោយឡែក១គ្រឿងទៀត គឺជារថយន្តនីសាន់ ដឹកសម្ភារៈតាមក្រោយ។ បន្ទាប់ពីមានការសង្ស័យសមត្ថកិច្ចថៃបានឃាត់ដើម្បីសុំត្រួតពិនិត្យ ជាលទ្ធផលនៅក្នុងរថយន្តសង្គ្រោះបន្ទាន់គេឃើញមានពលករខ្មែរសរុបចំនួន១៤នាក់ មនុស្សធំ៩នាក់ និងក្មេង៥នាក់ ដោយអ្នកបើកបររថយន្តទាំង២គ្រឿង គឺជាជនជាតិថៃចំនួន៣នាក់ ។

ជនជាតិថៃទាំងនោះបានសារភាពថា ពួកគេស៊ីឈ្នួលដឹកចេញពីខេត្ត ណុនថៈបុរី ឆ្ពោះទៅកាន់ខេត្តច័ន្ទបុរី ក្នុងតម្លៃសរុប ២៥,០០០ បាត ដើម្បីអោយពួកគាត់ឆ្លងដែនតាមច្រកបានឡែន ចូលទៅកាន់ប្រទេសកម្ពុជាវិញ ប៉ុន្តែដោយសារតែខេត្ត ណុនថៈបុរី គឺជាតំបន់ក្រហម ទើបសមត្ថកិច្ចថៃ ចាត់អោយក្រុមគ្រូពេទ្យចុះពិនិត្យសំណាកទៅលើពលករទាំង១៤នាក់ ជាលទ្ធផលមាន៥នាក់ មានវិជ្ជមានកូវីដ-១៩ ហើយបច្ចុប្បន្ន នេះត្រូវបានដាក់អោយក្រុមគ្រូពេទ្យព្យាបាល និងឃុំខ្លួនដើម្បីធ្វើចត្តាឡីស័ក ដោយឡែកជនជាតិថៃទាំង ៣នាក់ ត្រូវបានបញ្ជូនទៅតុលាការ ៕ អត្ថបទ ៖ សោ និយមរ័ត្ន

## លោក ហ៊ុន ម៉ាណែត ចុះមើលទីតាំងមួយក្នុងខេត្តឧត្តរមានជ័យ រៀបចំជាមណ្ឌលព្យាបាលជំងឺកូវីដកម្រិតស្រាល និងកម្រិតធ្ងន់ សម្រាប់ពលករមកពីថៃ

http://freshnewsasia.com/ 2021-07-15 06:03pm

(ឧត្តរមានជ័យ)៖ លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១នេះ បានដឹកនាំក្រុមការងារ អមដំណើរដោយលោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ ចុះពិនិត្យមើលទីតាំងមួយចំនួនក្នុងខេត្ត ដើម្បីរៀបចំជាមណ្ឌលព្យាបាលជំងឺកូវីដ-១៩កម្រិតស្រាល និងមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩កម្រិតធ្ងន់ សម្រាប់ពលករដែលវិលត្រឡប់ មកពីប្រទេសថៃ។ ការចុះពិនិត្យរៀបចំមណ្ឌលជាព្យាបាលជំងឺកូវីដ-១៩កម្រិតស្រាល និងមន្ទីរពេទ្យព្យាបាលជំងឺកូវីដ-១៩ កម្រិតធ្ងន់សម្រាប់ប្រជាពលរដ្ឋដែលជាពលករវិលត្រឡប់មកពីប្រទេសថៃនាពេលនេះ គឺដោយសារមួយរយៈកន្លងមកនេះ អាជ្ញាធរខេត្តឧត្តរមានជ័យ បានរកឃើញពលករដែលមកពីប្រទេសថៃមានផ្ទុកជំងឺកូវីដ-១៩ ជាច្រើននាក់គួរឲ្យព្រួយបារម្ភ ម្យ៉ាងទៀតទីតាំងមួយចំនួនក៏មានការពេញផងដែរ។

លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត បានថ្លែងនូវការកោតសរសើរដល់អាជ្ញធរខេត្តឧត្តរមានជ័យ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងមន្ត្រីសុខាភិបាលខេត្ត ដែលមួយរយៈនេះបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត អនុវត្តន៍នូវបទបញ្ជារបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទប់

ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ ពិសេសលើការគ្រប់គ្រងមើលថែ ពលករដែលវិលត្រឡប់មកពីប្រទេសថៃបានយ៉ាងល្អ។

សូមបញ្ជាក់ថា នៅខេត្តឧត្តរមានជ័យ គិតត្រឹមថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ បានរកឃើញជំងឺកូវីដ-១៩ ចំនួន២.២២២នាក់ ក្នុងនោះករណីនាំចូលពីក្រៅប្រទេស ចំនួន២.០៦០នាក់ ករណីឆ្លងក្នុងសហគមន៍ ចំនួន ១៦២នាក់ បានព្យាបាលជាសះស្បើយ ចំនួន៤៨៩នាក់ និងកំពុងសម្រាកព្យាបាល ចំនួន១.៧២៩នាក់ និងស្លាប់ចំនួន៤នាក់ផងដែរ៕

## ពលករចំណាកស្រុកគ្មានឯកសារនៅប្រទេសថៃប្រឈមនឹងការខេគ្រោះដោយជំងឺកូវីដ-១៩

https://www.khmertimeskh.com/ Khmer July 15, 2021យិន សឿម / ខ្មែរថាមស៍

យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងការងារថៃ បានឲ្យដឹងថា ពលករចំណាកស្រុកខ្មែរជាច្រើននាក់ដែលស្ថិតនៅប្រទេសថៃកំពុងរងចាំទទួលការចាក់វ៉ាក់សាំងការពារកូវីដ-១៩។ ក្រសួងបានប្រកាសនៅថ្ងៃទី ២៦ ខែមិថុនាថា រាល់ពលករចំណាកស្រុកមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលធ្វើការនៅប្រទេសថៃឥឡូវនេះត្រូវតែមានឯកសារការងារស្របច្បាប់ ដើម្បីទទួលបានវ៉ាក់សាំងការពារកូវីដ-១៩។

លោក ប៊ុន សីហា ប្រធានសហជីពកម្មករតំណាងពលករចំណាកស្រុកកម្ពុជានៅថៃបាននិយាយថា៖ «ខ្ញុំបានឮអំពីការប្រកាសនេះពីរដ្ឋាភិបាលថៃកាលពី ២ សប្តាហ៍មុន»។

យោងតាមសេចក្តីប្រកាសរបស់ក្រសួងការងារថៃ សេចក្តីសម្រេចនេះត្រូវបានអនុវត្តចំពោះកម្មករចំណាកស្រុកទាំងអស់ដែលធ្វើការនៅរោងចក្រក្នុងខេត្ត Pathum Thani ខេត្ត Nonthaburi និងខេត្ត Samut Prakan។ ពលករចំណាកស្រុកទាំងអស់ដែលស្ថិតនៅតំបន់ទាំងនេះត្រូវតែមានលិខិតអនុញ្ញាតការងារជាផ្លូវការ ដើម្បីទទួលបានការចាក់វ៉ាក់សាំងការពារកូវីដ-១៩។ សេចក្តីប្រកាសបានឲ្យដឹងថាក្រុមសង្កេតការចល័តឃើញថាមានតែពលករចំណាកស្រុកចំនួន ៣០.០០០ នាក់ប៉ុណ្ណោះដែលបានបង្ហាញប័ណ្ណការងារស្របច្បាប់ ដើម្បីទទួលបានការចាក់វ៉ាក់សាំងកូវីដ-១៩ នៅមន្ទីរពេទ្យ។ ក្រុមការងារបានចុះទៅពិនិត្យនៅរោងចក្រ និងការដ្ឋានសាងសង់ ដើម្បីយកសំណាក ហើយបានរកឃើញថា រោងចក្រមួយចំនួនមានកម្មករដែលបានឆ្លងជំងឺកូវីដ-១៩ នៅកន្លែងធ្វើការ។ អ្នកដែលបានធ្វើតេស្តវិជ្ជកូវីដ-១៩ ត្រូវបានបញ្ជូនទៅសម្រាកព្យាបាល។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារបានប្រាប់កាសែតខ្មែរថាមស៍កាលពីម្សិលមិញថាលោកមិនទាន់បានដឹងអំពីសេចក្តីប្រកាសនេះពីប្រទេសថៃនៅឡើយទេ។ លោកនិយាយថា រដ្ឋាភិបាលថៃនឹងបញ្ជូនលិខិតការទូតផ្លូវការទៅក្រសួងថាវ៉ាក់សាំងនេះត្រូវបានផ្តល់ឲ្យតែពលករស្របច្បាប់ប៉ុណ្ណោះ។

លោក លួង សុភណ្ឌ បុគ្គលិកនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស ( សង់ត្រាល់ ) បាននិយាយថាវាជាការព្រួយបារម្ភមួយដែលថាពលករកម្ពុជាជាច្រើនមិនទាន់ទទួលបានវ៉ាក់សាំងកូវីដ-១៩។ លោកបន្តថា៖ «រដ្ឋាភិបាលថៃគួរតែផ្តល់វ៉ាក់សាំងកូវីដ-១៩ ដល់ពលករទាំងអស់ ទោះបីពួកគេមានឯកសារការងារស្របច្បាប់ឬមិនមានក៏ដោយ ពីព្រោះពិតជាសំខាន់ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេស»៕

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៥នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៣៥នាក់ ស្រី ១៤នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

1-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៣នាក់ ស្រី ៥នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

3-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២១នាក់ ស្រី ៩នាក់ កុមារា ២នាក់ កុមារី ១នាក់។

4-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់( គ្មានរបាយការណ៍ ) ។

5-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

6-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៣៥នាក់ ស្រី ១៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋមលើសុខភាព និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតាដោយតម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ។ សូមបញ្ជាក់ជូនថា: ថ្ងៃនេះ ក្រុមការងារបានបញ្ជូនពលករ ដែលបញ្ចប់ធ្វើចត្តាឡីស័ក និងអ្នកព្យាបាលជាសះស្បើយមកពីបណ្ដាខេត្តតាមព្រំដែន មានចំនួន ៤នាក់ ស្រី ០០នាក់ ៕ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ខេត្តសៀមរាបនឹងក្លាយជាខ្សែត្រៀមទី២ បន្ទាប់ពីខេត្តឧត្តរមានជ័យ គ្មានកន្លែងគ្រប់គ្រាន់ក្នុងការទទួលប្រជាពលរដ្ឋចំណាកស្រុកពីក្រៅប្រទេស !

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាប៖ លោកវេជ្ជបណ្ឌិត ប៉ែន ផលគុណ ប្រធានមន្ទីរពេទ្យបង្អែកខេត្តសៀមរាប មានប្រសាសន៍ឲ្យដឹងកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ម្សិលមិញនេះថា រាជរដ្ឋាភិបាលសម្រេចយកខេត្តសៀមរាប ជាខេត្តសម្រាប់ទទួលប្រជាពលរដ្ឋខ្មែរចំណាកស្រុកមកពីក្រៅប្រទេស បន្ទាប់ពីខេត្តឧត្តរមានជ័យខ្វះខាតកន្លែង មិនអាចទទួលដាក់ប្រជាពលរដ្ឋខ្មែរចំណាកស្រុកបន្តទៀតបាន ។ លោកវេជ្ជបណ្ឌិត បន្តថា ដោយមានការភ័យខ្លាចចំពោះការរកឃើញវីរុសបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta ) មានការឆ្លងទៅលើប្រជាពលរដ្ឋខ្មែរ ដែលចំណាកស្រុកពីក្រៅប្រទេស ដែលមេរោគនេះ មានសភាពកាចសាហាវជាងមេរោគកូវីដ-១៩ធម្មតា។ រហូតមកដល់ពេលនេះ ប្រទេសកម្ពុជារកឃើញមេរោគប្រភេទថ្មីនេះចំនួន ២៧ករណី នៅទូទាំងប្រទេស ទើបប្រមុខរាជរដ្ឋាភិបាល កំណត់ឲ្យប្រជាពលរដ្ឋខ្មែរចំណាកស្រុកមកពីក្រៅប្រទេសត្រូវដាក់ធ្វើចត្តាឡីស័ក និងព្យាបាល នៅតាមបណ្ដាខេត្តជាប់ព្រំដែនថៃដូចជា÷ ខេត្តឧត្តរមានជ័យ, ខេត្តបន្ទាយមានជ័យ, ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។ ដោយឡែកខេត្តឧត្តរមានជ័យដែលជាខេត្តជាប់ព្រំប្រទល់ ប៉ុន្តែដាក់ស្តែងពេលនេះ ប្រជាពលរដ្ឋចំណាកស្រុកមកកាន់តែមានចំនួនច្រើន លើសពី

បន្ទុក ទើបសម្រេចយកខេត្តសៀមរាប ជាខ្សែត្រៀមទី២ បន្ទាប់ពីខេត្តឧត្តរមានជ័យ ក្នុងការទទួលប្រជាពលរដ្ឋខ្មែរចំណាកស្រុកទាំងអស់ ទោះមិនមែនមានស្រុកកំណើតនៅខេត្តសៀមរាបក៏ដោយ ។

គួររំឭកថា កាលពីពេលថ្មីនេះ រដ្ឋបាលខេត្តសៀមរាប បានចេញលិខិតផ្លូវការមួយ ដោយផ្អែកតាមសភាពការណ៍ នៃការរីករាលដាលជំងឺកូវីដ-១៩ បំប្លែងខ្លួនថ្មីប្រភេទឌែលតា និងដើម្បីបង្ការ ទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ បំប្លែងខ្លួនថ្មីប្រភេទឌែលតានេះ រដ្ឋបាលខេត្ត បានធ្វើការណែនាំដល់គណៈអភិបាលក្រុង ស្រុក បង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការពង្រឹងវិធានការចត្តាឡីស័ក នៅតាមមណ្ឌលឲ្យបានម៉ឺងម៉ាត់ ស្របតាមគោលការណ៍របស់ក្រសួងសុខាភិបាល ជាពិសេសចំពោះប្រជាពលរដ្ឋធ្វើចំណាកស្រុក ដែលត្រឡប់ទៅមូលដ្ឋានរស់នៅវិញ ត្រូវធ្វើការត្រួតពិនិត្យឲ្យបានម៉ត់ចត់។ ក្នុងករណីដែលប្រជាពលរដ្ឋពុំបានឆ្លងកាត់ការធ្វើចត្តាឡីស័ក នៅតាមព្រំដែនទេ ត្រូវពង្រឹងការអនុវត្តវិធានការទាំងផ្នែករដ្ឋបាល ផ្នែកសុខាភិបាល សំដៅបង្ការគ្រប់គ្រង និងកាត់ផ្តាច់នូវខ្សែរយៈចម្លង នៃមេរោគកូវីដ-១៩ ប្រភេទថ្មីនេះ នៅតាមមូលដ្ឋាន ដែលត្រូវបានរកឃើញអ្នកដែលបានឆ្លងជំងឺនេះ ។

សូមបញ្ជាក់ថា ក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ គិតមកទល់ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១នេះ ខេត្តសៀមរាប មានអ្នកវិជ្ជមានជំងឺកូវីដ-១៩ សរុបចំនួន ២,៧១១នាក់, បានព្យាបាលជាសះស្បើយចំនួន១,០៦០នាក់, ស្លាប់ចំនួន ២៦នាក់ និងចំនួន ១,៦២៥នាក់, កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តសៀមរាប, មណ្ឌលចត្តាឡីស័កគរុកោសល្យ និងវិក្រឹតការខេត្ត, វិទ្យាល័យអង្គរ និងវិទ្យាល័យជំដែក ខណៈខេត្តសៀមរាប បានរកឃើញមេរោគបំប្លែងខ្លួនថ្មី ប្រភេទឌែលតានេះចំនួន ៤ករណីផងដែរ៕ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

# ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

## ប្រើប្រាស់ថវិកាជាង ៣,៨ លានដុល្លារអាមេរិក ដើម្បីឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ

https://kohsantepheapdaily.com.kh/ Phnom Penh ១៤ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៤:២៤

រាជធានីភ្នំពេញ ៖ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ សម្រាប់វិស័យកិច្ចការពារកុមារ អ្នកធ្វើការពាក់ព័ន្ធ ជាពិសេសសម្រាប់កុមារ និងយុវជនគ្រប់រូប នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនឹងទទួលបានការការពារសុវត្ថិភាពកាន់តែប្រសើរ នៅពេលកំពុងប្រើប្រាស់បច្ចេកវិទ្យាទំនើប នាយុគ្គសម័យឌីជីថលនេះ ។

នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០២១ នេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) ក្រោមកិច្ចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) និងក្រសួងមហាផ្ទៃ នឹងរៀបចំ ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ ឆ្នាំ២០២១-២០២៥" តាមរយៈកម្មវិធីអនឡាញ ZOOM ដែលចំនួនថវិកាប៉ាន់ស្មាន សម្រាប់អនុវត្តផែនការសកម្មភាពនេះ គឺប្រមាណជាង ៣,៨ លានដុល្លារអាមេរិក សម្រាប់រយៈពេលជាង ៥ ឆ្នាំ ដែលគ្របដណ្តប់ទៅលើវិស័យយុទ្ធសាស្ត្រទាំង ៦ ។ ថវិកាចំនួន ៣៦ ភាគរយ គឺជាថវិកាផ្តល់ដោយរាជរដ្ឋាភិបាល និងថវិកា ៦៤ ភាគរយទៀត គឺជាការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍នានា ។

សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍ថា ៖ «ស្របពេលនឹងវិបត្តិកូវីដ-១៩ កំពុងរាតត្បាតទូទាំងពិភពលោក ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រឹតតែមានសារសំខាន់ ក្នុងការប្រាស្រ័យទាក់ទង និងដោះស្រាយគ្រប់បញ្ហា រួមទាំងការសិក្សាអប់រំរបស់កុមារ និងយុវជន យុវនារី

ទាំងនៅទីក្រុង ទាំងជនបទ ដែលធ្វើឱ្យវិស័យបច្ចេកវិទ្យាព័ត៌មាននេះ រឹតតែទទួលបាននូវការពេញនិយមសម្រាប់ទំនាក់ទំនង និងអភិវឌ្ឍន៍គ្រប់វិស័យ ។ ទោះបីជាយ៉ាងនេះក្តី ការរីកចម្រើនផ្នែកបច្ចេកវិទ្យាព័ត៌មាន ក៏មានជ្រុងអវិជ្ជមានមួយចំនួន ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ខុសគោលដៅ និងដោយមានការជ្រៀតចូលពីក្រុមឧក្រិដ្ឋជនឆ្លៀតឱកាសទាញយកផលប្រយោជន៍ដោយខុសច្បាប់ និងប្រាសចាកពីគន្លងសីលធម៌ និងការអភិវឌ្ឍន៍ ដោយបង្កើតឱ្យមានការកេងប្រវ័ញ្ច និងឧក្រិដ្ឋកម្មគ្រប់រូបភាព រួមទាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលជាទម្រង់ថ្មីមួយកំពុងរាលដាល និងបង្កហានិភ័យខ្ពស់ដល់កុមារនៅលើពិភពលោក រួមទាំងកម្ពុជាផងដែរ» ។

គួរបញ្ជាក់ផងដែរថា ផែនការសកម្មភាពនេះ គឺជាការចូលរួមចំណែកដ៏ធំ បង្ហាញអំពីឆន្ទៈ និងកិច្ចខិតខំប្រឹងប្រែង ជាពិសេសការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការការពារកុមារពីគ្រោះថ្នាក់ និងការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ ។ ផែនការនេះបានកំណត់នូវគោលដៅយុទ្ធសាស្ត្រសំខាន់ៗ រួមមាន ៖

១). ពង្រឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយ និងអភិបាលកិច្ច។

២). លើកកម្ពស់យុត្តិធម៌ព្រហ្មទណ្ឌ។

៣). លើកកម្ពស់វិធានការបង្ការ ទប់ស្កាត់ និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើកេងប្រវ័ញ្ចផ្លូវតាមប្រព័ន្ធអនឡាញ។

៤). ពង្រឹងសុវត្ថិភាពសហគមន៍ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ។

៥). ពង្រឹងលក្ខន្តិកៈសម្រាប់ការផ្តល់សេវាអ៊ីនធឺណិត។

៦). បង្កើនការផ្សព្វផ្សាយ និងការយល់ដឹងត្រឹមត្រូវអំពីបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ។

ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញមានសារៈសំខាន់ក្នុងការបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលសំដៅ ៖

-ការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ រួមទាំងការពារផលប្រយោជន៍របស់ជនរងគ្រោះ សហគមន៍ និងសង្គម។

-បង្កើននូវការអប់រំ ទប់ស្កាត់ និងកាត់បន្ថយនូវភាពអសកម្ម ឆ្លើយតបទៅនឹងវិធានការនានា ដែល រាជរដ្ឋាភិបាល រួមជាមួយគ្រួសារ សហគមន៍ ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងការអភិវឌ្ឍអនីតិជនឲ្យក្លាយជាពលរដ្ឋល្អ និងជាអ្នកបន្តវេនរបស់ប្រទេសជាតិ។

-បង្កើនកិច្ចសហការរវាងក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការនីតិប្រតិបត្តិ និងតុលាការ ក្នុងការដោះស្រាយបញ្ហាអនីតិជនឲ្យស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ។

-បំពេញកាតព្វកិច្ចជាប្រទេសសមាជិកនៃអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជាជាមួយស្ថាប័នអន្តរជាតិផ្សេងៗ ក្នុងការការពារសិទ្ធិកុមារ ។

ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានបន្ថែមទៀតថា ៖ « ពិធីប្រកាសជាផ្លូវការនាពេលនេះ រៀបចំឡើងក្នុងគោលបំណងដើម្បីជំរុញ លើកកម្ពស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសតួអង្គ យុត្តិធម៌ព្រហ្មទណ្ឌ អ្នកអនុវត្តន៍ច្បាប់ និងអង្គការដៃគូពាក់ព័ន្ធ ទទួលយកផែនការសកម្មភាពមកអនុវត្ត ដោយផ្សារភ្ជាប់និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័នសាមី» ៕

## ខេត្តឧត្តរមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ ១៨៤នាក់ ក្នុងនោះ៩០នាក់ ជាពលករទើបមកពីថៃ និងជាសះស្បើយ៨នាក់

http://freshnewsasia.com/ 2021-07-16 08:40pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន១៨៤ករណី បន្ថែមទៀត តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) និងព្យាបាលជាសះស្បើយចំនួន៨នាក់ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១នេះ។ បើតាមសេចក្តីប្រកាសព័ត៌មាន របស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១នេះ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង ១៨៤នាក់ ក្នុងនោះអ្នកជំងឺចំនួន៩១នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និង៩០នាក់ទៀត ជាពលករទើបមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងចំនួន២នាក់ទៀត ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យ បានរកឃើញជំងឺកូវីដ១៩ ចំនួន២.៥០៣ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន២.៣៣៩ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន១៦៤ករណី បានព្យាបាលជាសះស្បើយចំនួន ៤៩៨នាក់ កំពុងសម្រាកព្យាបាលចំនួន១.៩៩៩នាក់ និងស្លាប់បាត់បង់ជីវិត ៦នាក់ផងដែរ៕

## កម្ពុជាពុំធ្លាប់ជាប់ឈ្មោះក្នុងបញ្ជីប្រទេសអនុវត្តការកាត់ប្រដាប់ភេទស្ត្រី

https://www.rasmeinews.com/ 16 July, 2021

*ដោយៈមុនីរ័ត្ន/ភ្នំពេញៈ ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅហ្សឺណែវ បានបញ្ជាក់ថា ជារដ្ឋភាគីនៃអនុសញ្ញាស្តីពី "ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រីភេទ" (CEDAW) កម្ពុជាប្តេជ្ញាលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី និងក្មេងស្រី តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌគាំពារសង្គមជាច្រើន ក៏ដូចជាការផ្តល់ជូនសេវាសុខភាពផ្លូវភេទ និងបន្តពូជនៅតាមកន្លែងជាច្រើន ដល់ស្ត្រី។ ការបញ្ជាក់នេះ បានធ្វើឡើងនៅក្នុងកិច្ចសន្ទនាអន្តរកម្មរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សសម័យប្រជុំលើកទី៤៧ កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១។*

ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ទៀតថា កម្ពុជាពុំធ្លាប់ជាប់ឈ្មោះក្នុងបញ្ជីប្រទេសអនុវត្តការកាត់ប្រដាប់ភេទស្ត្រី(Female Genital Mutilation)នោះទេ។ ការលើកកម្ពស់សមភាពយេនឌ័រក្នុងប្រទេសក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ។ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) កម្ពុជាផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់ការលុបបំបាត់រាល់អំពើហិង្សាលើស្ត្រីនិងកុមារី រួមទាំងការរំលោភសេពសន្ថវៈ។ ក្របខ័ណ្ឌច្បាប់និងគោលនយោបាយជាច្រើនដែលផ្តោតលើអភិក្រមគាំទ្រជនរងគ្រោះ រួមមានការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់និងមន្ត្រីមូលដ្ឋាន ក៏ដូចជាជំនួយផ្នែកច្បាប់នានា ត្រូវបានដាក់ចេញ និងផ្តល់ជូនក្នុងគោលដៅការពារនិងឆ្លើយតបឱ្យមានប្រសិទ្ធភាពចំពោះ បទឧក្រិដ្ឋនេះ។

ប្រភពដដែលបានបន្តថា ក្នុងនាមជារដ្ឋភាគីនៃពិធីសារ Palermo ឆ្នាំ ២០០៧ កម្ពុជាបន្តប្រកាន់យកនូវវិធីសាស្រ្តគ្រប់ជ្រុងជ្រោយ ដើម្បីលុបបំបាត់ការជួញដូរមនុស្ស ដោយបញ្ចូលស្មារតីនិងគោលការណ៍នៃពិធីសារនេះ ទៅក្នុងវិសោធនកម្មច្បាប់ជាតិ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ៕ សរន

## នគរបាល ប៉ុស្តិ៍បឹងសាគួ សហការជាមួយកម្លាំងចម្រុះ ឃាត់ពលរដ្ឋខ្មែរ០៣នាក់ឆ្លងដែនមកពីប្រទេសថៃដោយខុសច្បាប់

http://www.fridaydailynews.com/ Sat,17 July 2021 (Time 12:36 PM)ដោយ ៖ លោក រ៉េម សារី

បន្ទាយមានជ័យ ÷ នៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង២១ : ១៥ នាទីយប់ កម្លាំងប៉ុស្តិ៍បឹងសាគួ ដឹកនាំដោយលោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍ បាន សហការជាមួយកម្លាំងចម្រុះ ឃាត់បានប្រជាពលរដ្ឋខ្មែរ

ចំនួន03នាក់(ប្រុស)លួចឆ្លងដែនពីថៃមកខ្មែរ នៅចំណុចខាងមុខ BigC ភូមិក្បាលស្ពាន1 សង្កាត់/ក្រុង ប៉ោយប៉ែត ខេត្ត ប/ជ។ តាមប្រភពពីសមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋខ្មែរទាំង៣នាក់មានឈ្មោះដូចខាងក្រោម :

១ : បឿន សុម៉េង ភេទប្រុសអាយុ ២៣ ឆ្នាំ រស់នៅភូមិ ប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ មានកម្តៅ ៣៦.៩ អង្សា។

២ : អៃ វី្វ ភេទ ប្រុស អាយុ ២០ ឆ្នាំ រស់នៅភូមិ ប្រជាធម្មកើត សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។មានកម្តៅ ៣៦.៤ អង្សា។

៣ : ហូ តុលា ភេទ ប្រុស អាយុ ២១ ឆ្នាំ រស់នៅភូមិ អូរឬស្សីក្រោម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។មានកម្តៅ ៣៦.៤ អង្សា។

បន្ទាប់ពីឃាត់ខ្លួន និង សួរនាំរួចនគរបាលប៉ុស្តិ៍បឹងសាគូ នៃវរសេនាតូចការពារព្រំដែនគោក៩១១ បានបញ្ជូនពលរដ្ឋខ្មែរដែលឆ្លងដែនពីប្រទេសថៃចូលកម្ពុជាដោយខុសច្បាប់ ទៅយកសំណាក និង ធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យនិមិត្ត ៕

## ខេត្តឧត្តរមានជ័យ បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ ១៩៩នាក់ ក្នុងនោះ១១២នាក់ ជាពលករទើបមកពីថៃ ខណៈជាសះស្បើយ១៧នាក់

http://freshnewsasia.com/ 2021-07-17 09:39pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន១៩៩ករណីបន្ថែមទៀត តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) និងព្យាបាលជាសះស្បើយចំនួន១៧នាក់ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១នេះ។ បើតាមសេចក្តីប្រកាសព័ត៌មាន របស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅយប់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១នេះ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង ១៩៩នាក់ ក្នុងនោះអ្នកជំងឺចំនួន៧៥នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និង១១២នាក់ទៀត ជាពលករទើបមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ ចំណែកចំនួន១២នាក់ទៀត រកឃើញក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១នេះ ខេត្តឧត្តរមានជ័យ បានរកឃើញជំងឺកូវីដ១៩ ចំនួន២,៧០២ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន២,៥២៦ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន១៧៦ករណី បានព្យាបាលជាសះស្បើយចំនួន ៥១៥នាក់ កំពុងសម្រាកព្យាបាលចំនួន២,១៨១នាក់ និងស្លាប់បាត់បង់ជីវិត ៦នាក់ផងដែរ៕

## កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ចុះសហការទទួលពលរដ្ឋត្រឡប់ពីប្រទេស២នាក់ បញ្ជូនទៅមណ្ឌលចត្តាឡីស័ក

http://cambodiapolice.com/policekh/ 8:30 pm 17 កក្កដា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ ជាក់ស្តែងនៅថ្ងៃសៅរ៍ ៨កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ លោកវរសេនីយ៍ឯក ពៅ ថារ៉ុជ ស្នងការរង ទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ សហការជាមួយ

កម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រង និងបានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១នាក់ប្រុស និងត្រង់ចំណុចនៃភូមិសាស្ត្រភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន១នាក់ប្រុស សរុបចំនួន២នាក់។ បន្ទាប់ពីសាកសួរ,កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនទាំងអស់ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័ក អនុវិទ្យាល័យកូនភ្នំ៣២ ស្រុកសំពៅលូន៕

## ខេត្តសៀមរាបរៀបចំទីតាំង៤ក្នុងក្រុង និងស្រុកមួយចំនួន ទទួលពលករពីខេត្តឧត្តរមានជ័យ

https://thmeythmey.com/ 17, Jul 2021 , 11:00 pm ដោយ: អុីសា រ៉ហានី ( Isa Rohany )

សៀមរាប៖ រាជរដ្ឋាភិបាល បានសម្រេចយកខេត្តសៀមរាប ជាខ្សែត្រៀមទី២ ដើម្បីទទួលពលករវិលត្រឡប់ពីប្រទេសថៃតាមព្រំដែនខេត្តឧត្តរមានជ័យ ខណៈបច្ចុប្បន្នខេត្តនេះខ្វះកន្លែងដាក់ប្រជាពលរដ្ឋទាំងនោះ។

នាយករដ្ឋបាលខេត្តសៀមរាប លោក សុខ ថុល បានឱ្យដឹងថា មកដល់ពេលនេះអាជ្ញាធរបានរៀបចំទីតាំងចំនួន៤ ក្នុងក្រុងសៀមរាប សម្រាប់ដាក់ពលករទើបវិលត្រឡប់មកពីប្រទេសថៃ ទោះបីមិនមែនជាពលរដ្ឋក្នុងខេត្តសៀមរាបក៏ដោយ។ លោកបញ្ជាក់ថា ទីតាំងទាំងនោះរួមមាន វិទ្យាល័យវត្តស្វាយ វិទ្យាល័យអង្គរ វិទ្យាល័យ ១០មករា និងវិទ្យាល័យសម្តេចឪ។ លោកបន្ថែមថា ក្រៅពីក្នុងក្រុង អាជ្ញាធរក៏បានរៀបចំកន្លែងដាក់ពលករតាមស្រុកចំនួន៥ទៀត មានស្រុកប្រាសាទបាគង (វិទ្យាល័យស្វាយធំ) ស្រុកអង្គរជុំ ស្រុកស្រីស្នំ ស្រុកពួក និងស្រុកក្រឡាញ់។ លោក សុខ ថុល បន្ថែមទៀតថា ត្រឹមថ្ងៃទី១៥ កក្កដា ខេត្តសៀមរាបទទួលពលករមកពីថៃតាមច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យជាង២ពាន់រួចហើយ ដែលបានដាក់ធ្វើចត្តាឡីស័ក និងព្យាបាលតាមស្រុកជុំវិញ។

អភិបាលរង និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តឧត្តរមានជ័យ លោក ឌី រ៉ាដូ មានប្រសាសន៍ថា គិតត្រឹមថ្ងៃទី១៦កក្កដា ខេត្តនេះមានអ្នកជំងឺកូវីដ១៩សរុប២,៣១៩នាក់ ក្នុងនោះគ្រាន់តែពលករមានចំនួនជាង២,១០០នាក់។ លោកបន្ថែមថា ក្នុងចំណោមនោះភាគច្រើនជាពលរដ្ឋនៅតាមបណ្តាខេត្តនានា ហើយក៏មានមួយចំនួនជាពលរដ្ឋខេត្តឧត្តរមានជ័យដែរ។ អ្នកនាំពាក្យរូបនេះបន្តថា សន្ទុស្សន៍នៃការសម្រុកចូលស្រុកវិញរបស់ពលករខ្មែរតាមច្រកព្រំដែនអូរស្មាច់ នៅតែមានចំនួនច្រើន ដែលក្នុងមួយថ្ងៃមានចន្លោះពី៣០០ទៅ៤០០នាក់ ហើយក្នុងចំណោមនោះជាមធ្យមរកឃើញវិជ្ជមានជំងឺកូវីដ១៩ ៧០នាក់។ តាមអ្នកនាំពាក្យដដែល មកដល់ពេលនេះខេត្តឧត្តរមានជ័យមានកន្លែងធ្វើចត្តាឡីស័ក និងព្យាបាលអ្នកជំងឺកូវីដ១៩ សរុបជាង ២០ទីតាំង ហើយគ្រោងនឹងពង្រីកបន្ថែមទៀត។

តាមការបញ្ជាក់ពីលោក ឌី រ៉ាដូ បច្ចុប្បន្នរាជរដ្ឋាភិបាលបានចេញគោលការណ៍ថ្មី បន្ទាប់ពីរកឃើញវីរុសបំលែងខ្លួនថ្មី ប្រភេទដែលតា ដែលភាគច្រើនរកឃើញលើពលករមកពីប្រទេសថៃ ដូច្នេះតម្រូវឱ្យធ្វើចត្តាឡីស័ក និងព្យាបាលនៅខេត្តជាប់ព្រំដែន ហើយបន្ថែមរយៈពេលចត្តាឡីស័ករហូត ២១ថ្ងៃ៕

## សមត្ថកិច្ចថៃឃាត់ខ្លួនពលករខ្មែរ៥នាក់និងមេខ្យល់ជនជាតិថៃម្នាក់

http://nokorwatnews.com/ 16/07/2021

ក្រុងប៉ោយប៉ែត៖ ទោះបីជាបិតនៅក្នុងដំណាក់កាលកូវីដ-១៩កំពុងរីករាលដាលក៏ដោយ ក៏ទាហានថៃនៅតែបន្តឃាត់ខ្លួនពលករខ្មែរ៥នាក់ និងមេខ្យល់ជាជនជាតិថៃម្នាក់ដែលនាំគ្នាលួចឆ្លងដែនខុសច្បាប់កាលពីវេលាម៉ោង១២៖៤០នាទី ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១។

សមត្ថកិច្ចជួរមុខឱ្យដឹងថា នគបាលខ្លងលឹក ស្រុកអារញ្ញ ខេត្តស្រះកែវ សហការជាមួយកម្លាំងទាហានប្រាណទី១២០៥ អាជ្ញាធរឃុំប៉ារ៉ៃ,អាជ្ញាធរស្រុកអារញ្ញ បានចាប់ឃុំខ្លួនពលករខ្មែរ ព្រមទាំងមេខ្យល់ម្នាក់ សរុប៦នាក់ នៅបរិវេណផ្លូវភូមិកូណាំគ្លៀង ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ និងបាននាំខ្លួនទៅសួរនាំបន្ថែម។ សមត្ថកិច្ចដដែលប្រាប់បន្ថែមថា អ្នកដែលត្រូវចាប់ឃុំខ្លួនទាំង៦នាក់ខាងលើ រួមមានឈ្មោះសិទ្ធិឆ័យ កិងណាយ អាយុ២០ឆ្នាំ ជនជាតិថៃ ជាមេខ្យល់, ឈ្មោះខាត់ ថេត ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះទើត សាក់លឿន ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះអែម ចាន់លី ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ, ឈ្មោះរ៉ាន រ៉ែន ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះឃាត ណាក់ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ រួមទាំងវត្ថុតាងរថយន្តភីកអាប់ ម៉ាកអុីស៊ុយហ្ស៊ុយឌីម៉េក ពណ៌ស ពាក់ស្លាកលេខកง-8443ណៈខន នាយក។ ដោយឡែកពលករខ្មែរទាំង៥នាក់ត្រូវសមត្ថកិច្ចថៃចោទពីបទ ជាបុគ្គលអន្តោប្រវេសន៍ចូលមកនិងស្នាក់នៅក្នុងរាជាណាចក្រថៃដោយមិនបានទទួលការអនុញ្ញាត។ ក្រោយពីអនុវត្តតាមវិធានការសុខាភិបាល សមត្ថកិច្ចថៃបាននាំខ្លួនជនសង្ស័យទាំងនេះបញ្ជូនទៅឲ្យជំនាញខ្លងលឹក ដើម្បីចាត់ការតាមច្បាប់បន្ត៕

## ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១

### នគរបាលការពារព្រំដែនខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនពលរដ្ឋខ្មែរ៣នាក់ លួចឆ្លងដែនពីថៃ

http://freshnewsasia.com/ 2021-07-18 05:17pm

**(បន្ទាយមានជ័យ)៖** កម្លាំងនគរបាលការពារព្រំដែនគោកបឹងសាគូ នៃវរសេនាតូចលេខ៩១១ បានឃាត់ខ្លួនពលរដ្ឋខ្មែរ៣នាក់ ពេលពួកគេព្យាយាមលួចឆ្លងដែនពីថៃចូលមកប្រទេសកម្ពុជា នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ នៅត្រង់ចំណុចមួយក្នុងភូមិសាមគ្គីមានជ័យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោកបឹងសាគូ បានឱ្យដឹងថា ប្រជាពលរដ្ឋខ្មែរទាំងបីនាក់នេះ មានឈ្មោះ ឡឹក ត្រា ភេទប្រុស អាយុ៤១ឆ្នាំ, ឈ្មោះ ហោ ណា ភេទស្រី អាយុ៤១ឆ្នាំ និងឈ្មោះ ត្រា ជី ភេទស្រី អាយុ ១៧ឆ្នាំ ដែលអ្នកទាំងបីនាក់នេះរស់នៅភូមិប៉ោយប៉ែត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ជាមួយគ្នា។ ក្រោយឃាត់ខ្លួន កម្លាំងនគរបាលប៉ុស្តិ៍បឹងសាគូ ក៏បានបញ្ជូនពួកគាត់ទៅមណ្ឌលចត្តាឡីស័កវិទ្យាល័យនិមិត្ត ដើម្បីធ្វើចត្តាឡីស័កបង្ការការរីករាលដាលជំងឺកូវីដ១៩។ លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ ក៏បានអំពាវនាវដល់ប្រជាពលរដ្ឋ ចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល និងអនុវត្តតាមអនុសាសន៍ «៣ការពារ ៣កុំ» ជាពិសេសពេលត្រឡប់មកពីប្រទេសថៃ ត្រូវចូលរួមសហការផ្តល់ការធ្វើចត្តាឡីស័ក៕

### អធិការដ្ឋាននគរបាលស្រុកជាំក្សាន្តឃាត់មនុស្ស១២នាក់ឆ្លងដែនចូលប្រទេសថៃ

https://www.rasmeinews.com/ 18 July, 2021

**ដោយៈបាយ័ន/សៀមរាបៈ** *នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១នេះ មនុស្សចំនួន១៣នាក់ បានឆ្លងដែនខុសច្បាប់តាមច្រកដំណាក់ជ្រៃទៅកេអនុផលព្រៃឈើក្នុងទឹកដីថៃ ជាប់ឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ត្រូវបានកំលាំងអធិការស្រុកជាំក្សាន្តចាប់បាន១២នាក់ ដោយឡែកជនម្នាក់ទៀតបានបាត់ខ្លួន។* ការឃាត់ខ្លួនជនខាងលើ គឺបន្ទាប់ពីពួកគេ ត្រូវខាងផ្នែកបរិស្ថានឈុតខៀវថៃចាប់បានម្នាក់ និង១២នាក់ទៀតបានរត់រួចកាលពីថ្ងៃទី១៧ កក្កដានៅចំណុចហាប់ខ្សាច់ក្នុងទឹកដីថៃ៕/R

## បញ្ជូនពលករឆ្លងដែនខុសច្បាប់៤នាក់ទៅមណ្ឌលចត្តាឡីស័ក

https://www.rasmeinews.com/ 20 July, 2021

**ដោយៈគ្រញូង/បាត់ដំបងៈ** *ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នៅព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បានបញ្ជូនមេពលកឆ្លងដែនខុសច្បាប់៤នាក់ (ស្រីម្នាក់) ទៅមណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ស្រុកសំពៅលូន ក្រោយពេលឃាត់ខ្លួននៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅ លូន ខេត្តបាត់ដំបង ។*

លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរងនគរបាលខេត្តទទួលការងារ វរសេនាតូច នគរបាល ការពារ ព្រំដែនគោកលេខ ៨១៧ បានបញ្ជាក់ថា បន្ទាប់ពីសាកសួរ ធ្វើកំណត់ហេតុ និងអប់រំណែនាំរួច កម្លាំងបានប្រគល់បងប្អូនទាំងអស់ ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់ មណ្ឌលចត្តាឡីស័ក៕

## ស្ត្រីពលករខ្មែរម្នាក់ ត្រឡប់ពីថៃ ចូលមណ្ឌលចត្តាឡីស័ក កម្រិត២ នៅវិទ្យាល័យភ្នំស្រុក ២ថ្ងៃ ស្លាប់ ដោយកូវីដ១៩

https://kohsantepheapdaily.com.kh/ Banteay Meanchey ១៩ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២០:៣៨

បន្ទាយមានជ័យ៖ ស្ត្រីពលករខ្មែរម្នាក់ ត្រឡប់ពីប្រទេសថៃ ចូលមណ្ឌលចត្តាឡីស័កកម្រិត២ វិទ្យាល័យភ្នំស្រុក រយៈពេល ២ថ្ងៃ បានស្លាប់ ដោយវិជ្ជមានកូវីដ១៩ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១។

ក្រុមការងារមណ្ឌលចត្តាឡីស័កវិទ្យាល័យភ្នំស្រុក បានប្រាប់ថា ស្ត្រី ដែលស្លាប់ដោយវិជ្ជមានកូវីដ.១៩ មានឈ្មោះ សុត គន្ធា អាយុ ៣៥ឆ្នាំ រស់នៅភូមិស្វាយចេក ឃុំស្វាយចេក ស្រុកស្វាយចេក។ ក្រុមការងារ បានបញ្ជាក់ថា ស្ត្រីរងគ្រោះ ដែលស្លាប់ ដោយវិជ្ជមានកូវីដ ត្រូវបានក្រុមការងារ ទទួលមកដាក់នៅមណ្ឌលចត្តាឡីស័ក កម្រិត២ វិទ្យាល័យភ្នំស្រុក កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ហើយបានស្លាប់ នៅវេលាម៉ោង ៦ និង៤៥នាទី ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២១។ ក្រុមការងារ បានយកសំណាក ក៏រកឃើញវិជ្ជមានកូវីដ.១៩។ ក្រុមការងារ បានបញ្ជាក់ថា ចំពោះស្ត្រី ដែលស្លាប់ ដោយវិជ្ជមានកូវីដ ក្នុងមណ្ឌលចត្តាឡីស័ក កម្រិត២ ត្រូវក្រុមគ្រូពេទ្យ យកសាកសពទៅបូជាតាមបច្ចេកទេសសុខាភិបាល៕ ប៊ុន ធឿន

## ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា ១ថ្ងៃ ជិត ២០០នាក់ រកឃើញអ្នកឆ្លងជំងឺកូវីដ ៤៣នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ១៩ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២០:២៨

បន្ទាយមានជ័យ៖ ពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា ១ថ្ងៃ ជិត ២០០នាក់ រកឃើញអ្នកឆ្លងជំងឺកូវីដ មានចំនួន ៤៣នាក់ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ នៅមណ្ឌលសំចតច្រកអូរបីជាន់ ក្នុងស្រុកអូរជ្រៅ។

លោក លី សុវណ្ណារិទ្ធ អភិបាលស្រុកអូរជ្រៅ ទទួលតួនាទីថ្មី ជាអភិបាលរងខេត្តបន្ទាយមានជ័យ បានប្រាប់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ថា ត្រឹមម៉ោង ៥ល្ងាច ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ស្រុកអូរជ្រៅ ទទួលពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ មានចំនួន ១៤៧នាក់ ស្រី ៧០នាក់ បានយកសំណាក់ធ្វើតេស្តរហ័ស (Rapid Test) លទ្ធផលវិជ្ជមានកូវីដ.១៩ មានចំនួន ៤៣នាក់ ស្រី ២១នាក់ ក្មេង ២នាក់ ក្នុងនោះ មានប្រជាពលរដ្ឋ រស់នៅខេត្តបន្ទាយមានជ័យ ចំនួន ៣៤នាក់ ខេត្តបាត់ដំបង មានចំនួន ៦នាក់ ខេត្តសៀមរាប មានចំនួន ៣នាក់។

លោក បានបញ្ជាក់ថា នៅពេលដែលប្រទេសថៃ ឆ្លងកូវីដ ដែលកំពុងរីករាលដាល ហើយត្រូវបានកន្លែងការងារ ដែលប្រជាពលរដ្ឋខ្មែរ ធ្វើការនៅប្រទេសថៃ មិនមានការងារធ្វើ ពួកគេបានត្រឡប់មកវិញ ក្នុង ១ថ្ងៃ ជិត ២០០នាក់។ ក្រុមការងារទទួល ហើយពិនិត្យសុខភាព និងយកសំណាកធ្វើតេស្ត បើរកឃើញវិជ្ជមានកូវីដ.១៩ ត្រូវបានបញ្ជូន មកមណ្ឌលកងរ៉ា ក្រុងសិរីសោភ័ណ ដើម្បីព្យាបាល និងអ្នកដែលអវិជ្ជមានកូវីដ ត្រូវបានបញ្ជូន ទៅដាក់មណ្ឌលវិទ្យាល័យសម្តេចឪ ក្រុងសិរីសោភ័ណ ដើម្បីធ្វើចត្តាឡីស័ក រយៈពេល ២១ថ្ងៃ តាមការណែនាំរបស់ក្រសួងសុខាភិបាល។ លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា នៅពេលដែលជំងឺឆ្លងកូវីដ ដែលកំពុងឆ្លងរីករាលទូទាំងប្រទេស ហើយពលករខ្មែរ ដែលត្រឡប់បីប្រទេសថៃ ចូលកម្ពុជា ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានចំនួន ៨៨៣៦៥នាក់ ស្រី ៣៩៨៨៧នាក់៕ ប៊ុន ធឿន

## សមត្ថកិច្ចឃាត់ខ្លួន ពលករខ្មែរ ០៥នាក់ និង មេខ្យល់ជនជាតិថៃម្នាក់

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

(បន្ទាយមានជ័យ)៖ សមត្ថកិច្ចតម្រួតខ្លងលឹក សហការជាមួយអាជ្ញាធរស្រុកអារញ្ញ ទាហានកងវរយឈុតខ្មៅទី១.២០៥ បានឃាត់ខ្លួនពលករខ្មែរចំនួន ០៥នាក់ និងមេខ្យល់ជនជាតិថៃម្នាក់ នៅបរិវេណប៉ុស្ត៍ត្រួតពិនិត្យភូមិម៉ៃឌីង៉ាម ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ កាលពីថ្ងៃម្សិលមិញ។

អគ្គស្នងការដ្ឋាននគរបាលជាតិ ឱ្យដឹងថា ពលករខ្មែរ ០៥នាក់ ១-ឈ្មោះ ស្រី អ៊ីន ភេទស្រី អាយុ៣១ឆ្នាំ ។ ២-ឈ្មោះ លៀង ឡូន ភេទស្រី អាយុ២៩ឆ្នាំ ។ ៣-ឈ្មោះ ចាន់ ណារត្ន័ ភេទប្រុស អាយុ៣៧ឆ្នាំ ។ ៤-ឈ្មោះ អៀតសូម ភេទស្រី អាយុ២៣ឆ្នាំ ។ ៥-ឈ្មោះ ស៊ីង រ៉ាត់ ភេទប្រុស អាយុ១៨ឆ្នាំ ។ ចំណែកមេខ្យល់ជនជាតិថៃមានឈ្មោះ ចេតតា គង់ ភេទប្រុស អាយុ២៩ឆ្នាំ រួមទាំងវត្ថុតាង រថយន្តភីកអាប់ តូយ៉ូតាមួយគ្រឿង។ ក្រោយពីឃាត់ខ្លួនពលករទាំង ០៥នាក់ សមត្ថកិច្ចបាននាំមកសួរនាំ និងធ្វើកំណត់ហេតុចាប់ឃាត់ខ្លួន ។ ចំពោះមេខ្យល់ជនជាតិថៃ សមត្ថកិច្ចបានធ្វើការចោទប្រកាន់ពីបទ លួចដឹកជញ្ជូនពលករបរទេសឆ្លងដែនដោយខុសច្បាប់ ។

ពលករខ្មែរ០៥នាក់ ប្រាប់សមត្ថកិច្ចថា ពួកគេធ្វើការនៅផ្សារថៃ និងត្រូវការធ្វើដំណើរវិលត្រឡប់ ទៅប្រទេសកម្ពុជាវិញ ដោយសារស្ថានការណ៍ការរាតត្បាតជម្ងឺកូវីដ-១៩ កាន់តែរីករាលដាលខ្លាំងឡើងនោះ បានជួលរថយន្តដឹកមកព្រំដែនខេត្តស្រះកែវ តម្លៃក្នុងម្នាក់ ១,៥០០បាត។ ក្រោយពីសមត្ថកិច្ចសួរចម្លើយរួចរាល់ ពលករទាំងនោះត្រូវបានបញ្ជូនទៅឲ្យសមត្ថកិច្ចជំនាញខ្លងលឹក ចាត់ការតាមច្បាប់បន្ត៕

## ថៃបានអនុម័តទៅលើសំណើរដើម្បីអនុញ្ញាតឱ្យពលករចំណាកស្រុកដែលមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា បន្តការស្នាក់ នៅនិងធ្វើការក្នុងប្រទេសថៃបន្តទៀត

https://www.facebook.com/CHNChannelNews/ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ម៉ោង ១០:៤៣:៥៥

យោងតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានឱ្យដឹងថា គណៈរដ្ឋមន្ត្រីថៃបានអនុម័តទៅលើសំណើរ ដើម្បីអនុញ្ញាតឱ្យក្រុមពលករចំណាកស្រុកចំនួន ៤ ក្រុមដែលមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា បន្តការស្នាក់ នៅនិងធ្វើការនៅប្រទេសថៃ ដោយស្របច្បាប់រហូតដល់ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំក្រោយ ដើម្បីអនុញ្ញាតឱ្យពួកគេធ្វើការបែងចែកស្ថានភាពការងារ និងការអនុញ្ញាតការងារដូចដែលបានតម្រូវដោយបទបញ្ញាកាលពីពេលមុន។

កាសែត Bangkok Post បានដកស្រង់សំដីរបស់រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin ដែលបាននិយាយថា សេចក្តីសម្រេចនេះត្រូវបានឈានដល់នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថៃ កាលពីថ្ងៃទី ១៣ ខែកក្កដាកន្លងទៅ។ កាលពីមុន រដ្ឋាភិបាលថៃបានសម្រេចអនុញ្ញាតឱ្យពលករចំណាកស្រុកមកពីប្រទេសទាំងនេះស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសនេះជាបណ្តោះអាសន្នតាមរយៈសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីចំនួន ៣ ដែលរួមមានសេចក្តីសម្រេចកាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៩ សេចក្តីសម្រេចកាលពីថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០២០ និងសេចក្តីសម្រេចកាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២០ ។ មានពលករចំណាកស្រុកជាច្រើននាក់ទៀតដែលមានប័ណ្ណការងារហួសសុពលភាពបន្ទាប់ពីពួកគេមិនបានស្វែងរកនិយោជកថ្មីក្នុងរយៈពេល ៣០ថ្ងៃដែលជាតម្រូវការរបស់ច្បាប់ បន្ទាប់ពីការចាកចេញ ឬការបាត់បង់ការងារពីមុន។ ទោះជាយ៉ាងណា ការពន្យាពេលការអនុញ្ញាតិរបស់ពួកគេ គឺនឹងត្រូវបញ្ចប់នៅពេលឆាប់ៗនេះ ហើយជាមួយនឹងការបិទខ្ទប់នៅតាមព្រំប្រទល់ដោយសារតែជំងឺរាតត្បាតកូវីដ-១៩ ពលករចំណាកស្រុកទាំងនោះភាគច្រើនប្រថុយនឹងភាពខុសច្បាប់ប្រសិនបើមិនមានវិធានការណ៍អ្វីមួយណានោះ។

កាលពីថ្ងៃទី ២៦ ខែមករា រដ្ឋាភិបាលថៃបានសម្រេចចផ្តល់សិទ្ធិដល់ពួកគេបន្ថែមទៀតដែលអនុញ្ញាតឱ្យពលករចំណាកស្រុកស្នាក់នៅរហូតដល់ចន្លោះពីថ្ងៃទី ៣១ ខែកក្កដា ដល់ថ្ងៃទី ៦ ខែកញ្ញា អាស្រ័យទៅលើកាលបរិច្ឆេទផុតកំណត់នៃប័ណ្ណការងាររបស់ពួកគេ។ ទោះជាយ៉ាងណា ជាមួយនឹងជំងឺរាតត្បាតដែលនៅតែមិនមានសញ្ញានៃការបន្ធូរបន្ថយនោះ ឥឡូវនេះពលករចំណាកស្រុកកំពុងប្រឈមនឹងការបាត់បង់ឋានៈជាពលករចំណាកស្រុកស្របច្បាប់នៅក្នុងប្រទេសថៃ។ លោករដ្ឋមន្ត្រី Suchart បាននិយាយថា រដ្ឋាភិបាលបានសម្រេចអនុញ្ញាតឱ្យពលករចំណាកស្រុកមកពីប្រទេសទាំងនេះស្នាក់នៅ និងធ្វើការរហូតដល់ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំក្រោយ ដើម្បីអនុញ្ញាតឱ្យពួកគេបែងចែកស្ថានភាពការងាររបស់ពួកគេ និងចុះឈ្មោះសម្រាប់ប័ណ្ណការងារ៕

## ពលករខ្មែរនៅថៃដែលឆ្លងជំងឺកូវីដ-១៩ កំពុងខ្វះសេវាថែទាំសុខភាព

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 19/07/2021 - 14:32

*ពលករខ្មែរនៅថៃរាប់រយនាក់ កំពុងប្រឈមកង្វះការថែទាំយកចិត្តទុកដាក់ព្យាបាលពីសំណាក់អាជ្ញាធរថៃ ខណៈដែលពួកគេបានឆ្លងជំងឺកូវីដ-១៩។ មន្ត្រីទទួលបន្ទុកផ្នែកពលកររបស់អង្គការសង់ត្រាល់ ប្រាប់វិទ្យុបារាំងអន្តរជាតិ ពីប្រទេសថៃមកថា ស្ថានភាពពលករខ្មែរដែលឆ្លងជំងឺកូវីដ-១៩នៅពេលនេះ ត្រូវដាក់សម្រាកឲ្យព្យាបាលនៅកន្លែងដែលពួកគេស្នាក់នៅ ដោយសារតែមន្ទីរពេទ្យមួយចំនួននៅប្រទេសថៃប្រឈមនឹងសភាពចង្អៀតណែន។*

ទោះបីជាមានការមើលថែខ្លះពីសំណាក់ក្រុមគ្រូពេទ្យក្នុងប្រទេសថៃតាមបណ្តាទីក្រុងមួយចំនួនក្តី ក៏ប៉ុន្តែសម្រាប់ពលករខ្មែរដែលកំពុងរស់នៅទីក្រុងបាងកក កំពុងប្រឈមនឹងស្ថានការណ៍ស្រួចស្រាល់ ដោយសារតែមិនមានស្បៀងអាហារ និងថ្នាំសង្កូវផ្គត់ផ្គង់ នៅខណៈដែលពួកគេកំពុងសម្រាកព្យាបាលជំងឺកូវីដ-១៩នៅតាមផ្ទះ និងជំរុំ។ នេះបើតាមការបញ្ជាក់ពីលោកលឹង សុផុន មន្ត្រីអង្គការសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស Central ប្រាប់វិទ្យុបារាំងអន្តរជាតិពីទីក្រុងឈុនបុរី ប្រទេសថៃនៅថ្ងៃចន្ទទី១៩កក្កដានេះ។ បើតាមលោកលឹង សុផុន ពលករខ្មែរដែល

ឆ្លងជំងឺកូវីដ-១៩ ជាពលករធ្វើការតាមការដ្ឋានសំណង់ដែលភាគច្រើនពួកគេមិនមានឯកសារគ្រប់គ្រាន់ ទើបថៅកែក្រុមហ៊ុន និងក្រុមគ្រូពេទ្យមិនអើពើ។ ស្ថិតក្នុងស្ថានការណ៍ពិបាកគ្រប់គ្រង ដែលមានចំនួនអ្នកឆ្លងជាប្រចាំថ្ងៃរាប់ម៉ឺននាក់ ជាពិសេសនៅក្នុងទីក្រុងបាងកកផ្ទាល់តែម្តង ក្រសួងការងារថៃកាលពីថ្ងៃទី៥កន្លងទៅ បានចេញនូវសេចក្តីសម្រេចក្នុងការបញ្ឈប់ការធ្វើតេស្តរកជំងឺកូវីដ-១៩ទៅលើពលករប្រមាណ៣ម៉ឺននាក់ ដែលរួមមានទាំងពលករខ្មែរ។ តាមសេចក្តីសម្រេច គឺដោយសារតែមន្ទីរពេទ្យថៃកំពុងប្រឈមខ្វះខាតបរិក្ខារវេជ្ជសាស្ត្រ និងកន្លែងដាក់សម្រាកព្យាបាលថ្ងៃជំងឺកូវីដ-១៩។

លោក ហ៊្វីល រ៉ូប៊ីតសុន នាយករងទទួលបន្ទុកតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានសរសេរលើបណ្តាញធ្វីតធ័ររបស់ខ្លួន កាលពីថ្ងៃពុធកន្លងទៅថា នេះជាការរើសអើងនិងរំលោភបំពានលើសិទ្ធិទទួលបានការព្យាបាលរបស់ជនចំណាកស្រុកនៅក្នុងប្រទេសថៃ។ ដោយលោកចាត់ទុកថា នេះជាសកម្មភាពមួយគួរឲ្យស្អប់ខ្ពើម និងមិនអាចទទួលយកបាន។

តាមរយៈស្ថានការណ៍កាន់តែស្រួចស្រាល់នេះ លោកលឹង សុផុន ក៏បានឲ្យដឹងដែរថា ពលករខ្មែរបច្ចុប្បន្នកំពុងស្វះស្វែងរកដំណោះស្រាយ និងការអន្តរាគមន៍តាមរយៈស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ដោយជួយសម្របសម្រួលធ្វើយ៉ាងណាឲ្យពួកគេអាចទទួលបានការយកចិត្តទុកដាក់ព្យាបាលពីក្រុមគ្រូពេទ្យថៃ និងម្យ៉ាងទៀតអាចជួយសម្រួលពួកគេអាចត្រលប់ចូលមកកម្ពុជាវិញ។

គួរបញ្ជាក់ថា យោងតាមរបាយការណ៍ បច្ចុប្បន្នកម្ពុជាមានពលករជាង១លានកំពុងរស់នៅប្រកបរបរនៅប្រទេសថៃ ក្នុងបរិការណ៍កូវីដ-១៩។ ចំនួននេះមានការថយចុះជាង១លាននាក់ ដោយសារពួកគេខ្លះបានត្រលប់ចូលមកកម្ពុជាវិញជាបន្តបន្ទាប់៕

## ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១

### លោក ហ៊ុន ម៉ានិត ស្នើឱ្យបណ្ដាខេត្តនៅទូទាំងប្រទេសរៀបចំកន្លែងធ្វើចត្តាឡីស័ក សម្រាប់ពលករខ្មែរវិលមកពីថៃ

https://www.postkhmer.com/national/ ម៉ុំ គន្ធា | Publication date 20 July 2021 | 13:12 ICT

**ភ្នំពេញៈ** ប្រធានអនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញចូលប្រទេសនិងចត្តាឡីស័ក លោក ហ៊ុន ម៉ានិត ស្នើឱ្យខេត្តនៅទូទាំងប្រទេស ត្រូវរៀបចំកន្លែងធ្វើចត្តាឡីស័កសម្រាប់ត្រៀមទទួលពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ ដែលតម្រូវឱ្យធ្វើចត្តាឡីស័កនៅតាមខេត្ត ឬស្រុកកំណើតរបស់ពួកគេរយៈពេល ២១ ថ្ងៃ ដើម្បីតាមដានរកវីរុសបំប្លែងថ្មីប្រភេទដែលតា (Delta)។

យោងតាមសារសំឡេងដែល ភ្នំពេញ ប៉ុស្តិ៍ ទទួលបាននៅថ្ងៃទី ២០ ខែកក្កដានេះ លោក ហ៊ុន ម៉ានិត លើកឡើងថា លោកបានធ្វើការពិភាក្សាគ្នាជាមួយគណៈកម្មការប្រតិបត្តិ និងគណៈកម្មការអន្តរក្រសួង ដោយសម្រេចឱ្យគ្រប់ខេត្តទាំងអស់ត្រូវរៀបចំកន្លែងធ្វើចត្តាឡីស័កដើម្បីទទួលពលករមកពីតាមព្រំដែន។ បើតាមលោក ហ៊ុន ម៉ានិត ការធ្វើចត្តាឡីស័ករយៈពេល ២១ ថ្ងៃនេះ គឺការធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កនៅតាមខេត្តចំនួន ១៤ ថ្ងៃ និងធ្វើចត្តាឡីស័ករយៈពេល ៧ ថ្ងៃទៀតក្នុងស្រុកកំណើតរបស់ពួកគេ។

លោកបញ្ជាក់ថា៖ «តាមការពិនិត្យ គឺវីរុសបំប្លែងថ្មីប្រភេទដែលតា គឺក្នុងរយៈពេល ១៤ ថ្ងៃ យើងមិនអាចទាន់មើលឃើញទេ។ ដូចនេះហើយ យើងប្រហែលជាត្រូវការរៀបចំមណ្ឌលចត្តាឡីស័ក ដោយកំណត់អ្នកស្រុកណាគឺត្រូវដាក់ឱ្យធ្វើចត្តាឡីស័កនៅស្រុកនោះ បន្ទាប់ពីខាងព្រំដែនបញ្ជូនពួកគាត់មកកាន់ខេត្តកំណើតរបស់ពួកគាត់»។

យោងតាមសេចក្ដីជូនដំណឹងរបស់ក្រសួងសុខាភិបាល កាលពីថ្ងៃទី ១៦ ខែកក្កដា បានឱ្យដឹងថា ប្រទេសកម្ពុជា បានរយើញវីរុសបំប្លែងថ្មីប្រភេទដែលតា (Delta) សរុបចំនួន ៧៥ ករណីហើយ ជាករណីនាំចូលទាំងអស់។ ប៉ុន្តែ ដោយសារតែការបារម្ភពីការឆ្លងចូលនៃវីរុសបំប្លែងថ្មីនេះចូលទៅក្នុងសហគមន៍ ទើបមានការកែប្រែនូវការធ្វើចត្តាឡីស័កសម្រាប់ពលករខ្មែរដែលចូលមកក្នុងប្រទេសកម្ពុជា៕

## ប្រទេសថៃ៖ ពលករចំណាកស្រុកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ាទទួលបានការស្នាក់នៅបន្ត

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០២១

យោងតាមប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកបានឱ្យដឹងថា គណៈរដ្ឋមន្ត្រីថៃ បានអនុម័តទៅលើសំណើរដើម្បីអនុញ្ញាតឱ្យក្រុមពលករចំណាកស្រុកចំនួន ៤ ក្រុម ដែលមកពីប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា បន្តការស្នាក់ នៅនិងធ្វើការនៅប្រទេសថៃដោយស្របច្បាប់រហូតដល់ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំក្រោយ ដើម្បីអនុញ្ញាតឱ្យពួកគេធ្វើការបែងចែកស្ថានភាពការងារ និងការអនុញ្ញាតការងារដូចដែលបានតម្រូវដោយបទបញ្ជាកាលពីពេលមុន។

កាសែត Bangkok Post បានដកស្រង់សំដីរបស់រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin ដែលបាននិយាយថា សេចក្ដីសម្រេចនេះត្រូវបានឈានដល់នៅក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីថៃ កាលពីថ្ងៃទី ១៣ ខែកក្កដាកន្លងទៅ។ កាលពីមុន រដ្ឋាភិបាលថៃបានសម្រេចអនុញ្ញាតឱ្យពលករចំណាកស្រុកមកពីប្រទេសទាំងនេះស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសនេះជាបណ្ដោះអាសន្នតាមរយៈសេចក្ដីសម្រេចរបស់គណៈរដ្ឋមន្ត្រីចំនួន ៣ ដែលរួមមានសេចក្ដីសម្រេចកាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ ២០១៩ សេចក្ដីសម្រេចកាលពីថ្ងៃទី ៤ ខែសីហា ឆ្នាំ ២០២០ និងសេចក្ដីសម្រេចកាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២០ ។ មានពលករចំណាកស្រុកជាច្រើននាក់ទៀតដែលមានប័ណ្ណការងារហួសសុពលភាពបន្ទាប់ពីពួកគេមិនបានស្វែងរកនិយោជកថ្មីក្នុងរយៈពេល ៣០ថ្ងៃដែលជាតម្រូវការរបស់ច្បាប់ បន្ទាប់ពីការចាកចេញ ឬការបាត់បង់ការងារពីមុន។ ទោះជាយ៉ាងណា ការពន្យាពេលការអនុញ្ញាតិរបស់ពួកគេ គឺនឹងត្រូវបញ្ចប់នៅពេលឆាប់ៗនេះ ហើយជាមួយនឹងការបិទខ្ទប់នៅតាមព្រំប្រទល់ដោយសារតែជំងឺរាតត្បាតកូវីដ-១៩ ពលករចំណាកស្រុកទាំងនោះភាគច្រើនប្រថុយនឹងភាពខុសច្បាប់ប្រសិនបើមិនមានវិធានការណ៍អ្វីមួយណានោះ។

កាលពីថ្ងៃទី ២៦ ខែមករា រដ្ឋាភិបាលថៃបានសម្រេចផ្ដល់សិទ្ធិដល់ពួកគេបន្ថែមទៀតដែលអនុញ្ញាតឱ្យពលករចំណាកស្រុកស្នាក់នៅរហូតដល់ចន្លោះពីថ្ងៃទី ៣១ ខែកក្កដា ដល់ថ្ងៃទី ៦ ខែកញ្ញា អាស្រ័យទៅលើកាលបរិច្ឆេទផុតកំណត់នៃប័ណ្ណការងាររបស់ពួកគេ។ ទោះជាយ៉ាងណា ជាមួយនឹងជំងឺរាតត្បាតដែលនៅតែមិនមានសញ្ញានៃការបន្ធូរបន្ថយនោះ ឥឡូវនេះពលករចំណាកស្រុកកំពុងប្រឈមនឹងការបាត់បង់ឋានៈជាពលករចំណាកស្រុកស្របច្បាប់នៅក្នុងប្រទេសថៃ។ លោករដ្ឋមន្ត្រី Suchart បាននិយាយថា រដ្ឋាភិបាលបានសម្រេចអនុញ្ញាតឱ្យពលករចំណាកស្រុកមកពីប្រទេសទាំងនេះស្នាក់នៅ និងធ្វើការរហូតដល់ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំក្រោយ ដើម្បីអនុញ្ញាតឱ្យពួកគេបែងចែកស្ថានភាពការងាររបស់ពួកគេ និងចុះឈ្មោះសម្រាប់ប័ណ្ណការងារ៕ (ប្រភព VNA បកប្រែដោយលោក យា ចិន្តាឧន្តី) សម្រួលផ្សាយដោយ៖ ជូ កុសល

## ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ២០នាក់ មាន ៨នាក់ ឆ្លងវិជ្ជមានកូវីដ.១៩ នៅពេលទទួលពលករខ្មែរត្រឡប់ពីថៃ

https://kohsantepheapdaily.com.kh/ Banteay Meanchey២០ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២០:០១

បន្ទាយមានជ័យ៖ ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ២០នាក់ មាន៨នាក់ ដែលឆ្លងវិជ្ជមានកូវីដ.១៩ នៅពេលទទួលពលករខ្មែរត្រឡប់ពីថៃ។ ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ បានអោយដឹងថា ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ដែលកំពុងធ្វើការងារទទួលពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ ដែលមានចំនួន ២០ នាក់ រហូតដល់ពេលនេះ បានឆ្លងវិជ្ជមានកូវីដ.១៩ មានចំនួន ៨នាក់។ ក្នុងនោះ ១២នាក់ ដែលកំពុងធ្វើការងារ ដែលមាន មន្ត្រីសុខាភិបាល មន្ត្រីរដ្ឋបាលខេត្តបន្ទាយមានជ័យ និងមន្ត្រីសាលាស្រុកអូរជ្រៅ កម្លាំងនគរបាលវរៈការពារព្រំដែន និងកម្លាំងយោធា។ មន្ត្រីរូបនោះ បានបញ្ជាក់ថា នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ នេះ ក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ ស្រុកអូរជ្រៅ បានទទួលពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃ មានចំនួន ១៩៤នាក់ ស្រី ៨៨នាក់ ហើយបានយកសំណាកធ្វើតេស្តលទ្ធផលវិជ្ជមាន មានចំនួន ៤៩នាក់ ស្រី ២៥នាក់ ក្មេងចំនួន ៥ នាក់។ មន្ត្រីរូបនោះ បានបញ្ជាក់ថា បើប្រៀបធៀបថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១ ក្រុមការងារបានទទួលពលករខ្មែរ ដែលត្រឡប់ពីថៃមានចំនួន ១៤៧នាក់ ស្រី ៧០នាក់ ហើយរកឃើញវិជ្ជមានកូវីដ.១៩ មានចំនួន ៤៣នាក់ ស្រី ២១នាក់ ក្មេង ៣នាក់ ហើយអ្នកដែលរកឃើញវិជ្ជមានកូវីដ.១៩ ត្រូវបានរថយន្តសង្គ្រោះដឹកទៅមណ្ឌលកងវ៉ាក្រុងសិរីសោភ័ណ ដើម្បីព្យាបាល និងអ្នកដែលវិជ្ជមានកូវីដ.១៩ ត្រូវបញ្ជូនទៅមណ្ឌលវិទ្យាល័យសម្តេចឪ ដើម្បីធ្វើចត្តាឡីស័ករយៈពេល ២១ថ្ងៃ។ ប៊ុន ធឿន

## ពលករខ្មែរនៅម៉ាឡេស៊ីត្អូញត្អែរពីទុក្ខលំបាកខ្លាំងក្រោយពេលបាត់បង់ការងារជាច្រើនខែដោយសារកូវីដ

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ2021-07-19

ពលករខ្មែរជាច្រើននាក់ រស់នៅប្រទេសម៉ាឡេស៊ី កំពុងជួបទុក្ខលំបាកក្នុងជីវភាព ក្រោយពេលបាត់បង់ការងារធ្វើ និងប្រឈមផ្លូវច្បាប់ អំឡុងពេលប្រទេសនេះរឹតបន្តឹងវិធានការទប់ស្កាត់ជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលជំរុញរដ្ឋាភិបាលកម្ពុជាឱ្យប្រើប្រាស់តួនាទីរបស់ខ្លួនជួយដោះស្រាយទុក្ខលំបាករបស់ពលករ ដែលកំពុងនៅក្រៅប្រទេសទាំងនោះ។ ពលករខ្មែរជាច្រើននាក់ ដែលកំពុងធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី កំពុងដាច់ស្បៀងអាហារស្របពេលរដ្ឋាភិបាលប្រទេសមួយនេះរឹតបន្តឹងលើពលករបរទេសធ្វើការខុសច្បាប់ និងប្រកាសដាក់ប្រទេសក្នុងភាពអាសន្ន ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩។

ពលការិនីម្នាក់មានស្រុកកំណើតនៅខេត្តតាកែវ កញ្ញា សៀង វណ្ណៈ រៀបរាប់ប្រាប់ថា កញ្ញាបាត់បង់ការងារ៦ខែមកហើយ ដោយបច្ចុប្បន្នកញ្ញាកំពុងស្នាក់នៅផ្ទះជួលរបស់កម្មករដែលមានកម្មករខ្មែរជាងប្រមាណ ១រយនាក់។ កញ្ញាបន្តថា អាជ្ញាធរម៉ាឡេស៊ីបន្តរឹតបន្តឹងនិងហាមឃាត់មិនឱ្យពលករបរទេសចល័តទីកន្លែងធ្វើការ ក្នុងអំឡុងពេលរីករាលដាលនៃជំងឺកូវីដនេះទេ។ កម្មការិនីរូបនេះឱ្យដឹងទៀតថា កញ្ញាកំពុងធ្វើការងារខុសច្បាប់ ដោយសារតែថៅកែនៅកន្លែងការងារចាស់ដកហូតលិខិតឆ្លងដែន ហើយថៅកែនោះថែមទាំងតម្រូវឱ្យកញ្ញាបង់ប្រាក់ចំនួន ៥.០០០រីងហ្គីត ឬប្រមាណ ១.៣០០ដុល្លារ ដើម្បីយកលិខិតឆ្លងដែនត្រឡប់មកវិញ ប៉ុន្តែនាងមិនមានប្រាក់នោះទេ។ កញ្ញាស្នើឱ្យស្ថានទូតខ្មែរជួយផ្តល់ស្បៀងហារ និងអន្តរាគមន៍ដើម្បីវិលត្រឡប់ទៅស្រុកកំណើតវិញ៖ «ដំបូងឡើយខ្ញុំមកធ្វើនេះស្របច្បាប់ទេ ដល់ពេលការអនុញ្ញាតលើលិខិតឆ្លងដែនខ្ញុំថ្លៃពេក ដូចថា ចំណូលខ្ញុំបានប៉ុណ្ណឹង អត់មានលទ្ធភាព។ លិខិតឆ្លងដែនខ្ញុំផុតទៅហើយ ឥឡូវលិខិតឆ្លងដែននៅថៅកែខ្ញុំដាច់ខែហ្នឹង។ ដល់ពេលអ៊ីចឹងយើងទាមទារទៅយករបស់យើងមកវិញ គេទារបង់ថ្លៃអ៊ីចឹង ខ្ញុំសុខចិត្តចោលលិខិតឆ្លងដែន»។

ស្រដៀងគ្នានេះដែរ ពលការិនីធ្វើការនៅម៉ាឡេស៊ីម្នាក់ទៀត លោកស្រី ទឹម សោភ័ណ្ឌ រៀបរាប់ប្រាប់អាស៊ីសេរីនៅថ្ងៃទី១៩ កក្កដាថា រោងចក្រផលិតស្រោមដៃដែលលោកស្រីធ្វើការបានព្យួរការងារជាងពីរខែមកហើយ ដូច្នេះលោកស្រីនិងការកម្មករខ្មែរជាច្រើននាក់ទៀតកំពុងជួបទុក្ខលំបាកផ្នែកជីវភាពដោយខ្វះហារហូបចុក និងបង់

ថ្លៃបន្ទប់ជួលជាដើម។ ស្ត្រីវ័យ៣៣ឆ្នាំរូបនេះលើកឡើងទៀតថាលោកស្រី និងកម្មករផ្សេងទៀតមិនអាចចេញទៅរកការងារធ្វើនៅកន្លែងផ្សេងបាននោះទេ ដោយសារពួកគាត់បារម្ភពីវិធានការរបស់អាជ្ញាធរម៉ាឡេស៊ីៈ «ពិបាកព្រោះអីខ្ញុំអត់ហ៊ានចេញទៅណាផង ទៅរកអីក៏ខ្លាចទៅរកអីក៏ខ្លាចនៅស្រុកគេតាមច្បាប់គេខ្លាចគេចាប់អីទៅពិបាក យើងអត់មានលុយអីផង ណាមួយមិនមែនស្រុកយើងហ្នឹងទៀត ខ្ញុំសុំឱ្យជួយខាងខ្ញុំធ្វើម៉េចឱ្យខ្ញុំមានកម្លាំងទៅមុខទៅដើម្បីរកលុយចិញ្ចឹមបងប្អូនកូនចៅពុកម៉ែនៅស្រុកខ្មែរទៀតមិនដឹងធ្វើមិច ខ្ញុំឱ្យគាត់ជួយពួកខ្ញុំនៅខាងម៉ាឡេស៊ីនេះបើពួកខ្ញុំជួលពួកគាត់នៅខ្មែរបានអីហូប»។

វិទ្យុអាស៊ីសេរី មិនអាចទាក់ទងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាល លោក ផៃ ស៊ីផាន អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ លោក កុយ គួង និងមន្ត្រីទទួលបន្ទុកការងារស្ថានទូតខ្មែរប្រចាំម៉ាឡេស៊ី លោក លី ហា ដើម្បីសុំការឆ្លើយតបជុំវិញរឿងនេះ បានទេ នៅថ្ងៃទី១៩ កក្កដា។ ប៉ុន្តែស្ថានទូតខ្មែរប្រចាំប្រទេសម៉ាឡេស៊ី កាលពីថ្ងៃទី១៤ កក្កដា បានជូនដំណឹងទៅពលរដ្ឋ ពលករ-ពលការិនីខ្មែរ ដែលកំពុងស្នាក់នៅនិងធ្វើការនៅប្រទេសនេះថា រដ្ឋាភិបាលម៉ាឡេស៊ីបានបន្តកម្មវិធីធ្វើមាតុភូមិនិវត្តន៍ឡើយវិញដោយស្ម័គ្រចិត្ត (Repatriation Recalibration Programme) រហូតដល់ថ្ងៃទី៣១ ខែធ្នូ រហូតដល់បញ្ចប់កម្មវិធីចាក់វ៉ាក់សាំង។ ស្ថានទូតខ្មែរឱ្យដឹងថា អគ្គនាយកដ្ឋានអន្តរប្រវេសន៍ម៉ាឡេស៊ីបានរៀបចំបញ្ជរពិសេសនៅអាកាសយានដ្ឋានអន្តរជាតិកូឡាឡាំពួរ (KLIA) ដើម្បីជួយសម្រួលដល់ជនបរទេសខុសច្បាប់ទាំងអស់ ដែលមានបំណងវិលត្រឡប់ទៅប្រទេសកំណើតរបស់ខ្លួនវិញ។ សេចក្តីជូនដំណឹងបញ្ជាក់ថា ជនបរទេសខុសច្បាប់ទាំងអស់ត្រូវបំពេញឯកសារនិងលក្ខខណ្ឌដូចជាថតចម្លងលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរ ដោយភ្ជាប់សំបុត្រយន្តហោះត្រឡប់ទៅប្រទេសកំណើត រួមជាមួយការបង់ថ្លៃផាកពិន័យចំនួន ៥០០រីងហ្គីត ឬប្រមាណជិត ១៣០ដុល្លារ ហើយត្រូវធ្វើតេស្តអវិជ្ជមានកូវីដ១៩ (RT-PCR Test)។

ទោះជាយ៉ាងណា ពលករខ្មែរធ្វើការនៅប្រទេសម៉ាឡេស៊ី អះអាងថា ស្ថានទូតខ្មែរនៅប្រទេសនេះហាក់មិនអើពើពីទុក្ខលំបាកពលរដ្ឋខ្មែរនេះទេ។ ពួកគាត់ចង់វិលត្រឡប់ទៅស្រុកខ្មែរវិញដែរ ព្រោះខ្លាចអាជ្ញាធរម៉ាឡេស៊ីចាប់ខ្លួនផង និងដោយសារអត់ការងារធ្វើផង ប៉ុន្តែពេលនេះពួកគាត់មិនមានប្រាក់សម្រាប់ធ្វើដំណើរ ជាពិសេស ពួកគេពិបាកទាក់ទងមន្ត្រីស្ថានទូត ដើម្បីសុំកិច្ចអន្តរាគមន៍។

ជុំវិញរឿងនេះមន្ត្រីអង្គការសង់ត្រាល់ (CENTRAL) ទទួលបន្ទុកសិទ្ធិការងារលោក ឌី ថេហូយ៉ា សង្កេតឃើញថា អំឡុងពេលរីករាលដាលជំងឺកូវីដ១៩ ពលករខ្មែរធ្វើការនៅក្រៅប្រទេសពុំសូវទទួលបានកិច្ចអន្តរាគមន៍ពីស្ថានទូតខ្មែរនោះទេ។ លោកយល់ថា ពលករដែលជួបទុក្ខលំបាកគួរហ៊ានរាយការណ៍ពីស្ថានភាពរបស់ខ្លួនទៅរដ្ឋាភិបាល ឬមន្ត្រីស្ថានទូត ឬអង្គការសង្គមស៊ីវិល និងបង្ហាញទុក្ខកង្វល់របស់ខ្លួននៅលើបណ្តាញសង្គម ដើម្បីជំរុញឱ្យរដ្ឋាភិបាលឆ្លើយតបបន្ទាន់អំពីបញ្ហាទាំងអស់នេះ។ មន្ត្រីសង្គមស៊ីវិលរូបនេះ ទទូចឱ្យរដ្ឋាភិបាលកម្ពុជាតាមរយៈស្ថានទូតគួរសហការជាមួយរដ្ឋាភិបាលម៉ាឡេស៊ី ដើម្បីសម្របសម្រួលផ្លូវច្បាប់ និងឆ្លើយតបបន្ទាន់ជុំវិញទុក្ខកង្វល់របស់ពលករខ្មែររស់នៅសមរម្យៈ «អ៊ីចឹងភាគីសំខាន់បួន ទីមួយខ្លួនគាត់ផ្ទាល់មានន័យថាពលករផ្ទាល់ក៏ត្រូវតែបង្ហាញទុក្ខកង្វល់របស់ខ្លួនឯង ទីពីរគឺស្ថានទូតស្ថានកុងស៊ុលដែលតំណាងឱ្យរដ្ឋហ្នឹងគួរដឹងរៀបចំយ៉ាងមិចដើម្បីរកដំណោះស្រាយឱ្យពួកគាត់ ទីបីពាក់ព័ន្ធនឹងប្រទេសដែលទទួលត្រូវដឹងពីស្ថានភាពបែបហ្នឹងដែលត្រូវពិភាក្សាយោបល់យ៉ាងមិចរវាងរដ្ឋកម្ពុជាជាមួយនឹងប្រទេសដែលទទួលហ្នឹងត្រូវរកដំណោះស្រាយឱ្យពួកគាត់ ទី៤ អង្គការសង្គមស៊ីវិលធ្វើការលើវិស័យហ្នឹងនៅប្រទេសម៉ាឡេស៊ីសហការគ្នាតើយើងអាចធ្វើបានកន្លែងណា»។

លោក ឌី ថេហូយ៉ា គូសបញ្ជាក់ថា ចាប់តាំងពីដើមឆ្នាំ២០២០ កម្មករខ្មែរធ្វើការនៅក្រៅប្រទេសប្រឈមបញ្ហាអស់សុពលភាពឯកសារស្របច្បាប់ ដែលពួកគេរងគ្រោះដោយសារការកេងប្រវ័ញ្ចកម្លាំងពលកម្ម បាត់បង់ការងារសម្រាប់ផ្គត់ផ្គង់ជីវភាព ប្រឈមការគំរាមកំហែងផ្លូវច្បាប់ និងមិនទទួលបានការយកចិត្តទុកដាក់ត្រឹមត្រូវផ្នែក

សុខភាពអំឡុងពេលអាជ្ញាធរប្រទេសដែលពួកគេធ្វើការអនុវត្តវិធានការទប់ស្កាត់ជំងឺកូវីដ១៩។ របាយការណ៍របស់អង្គការសង់ត្រាល់បង្ហាញថា គិតត្រឹមឆ្នាំ២០២០ ពលករខ្មែរស្របច្បាប់ និងពលករខុសច្បាប់ មានចំនួនប្រមាណជាង ១០ម៉ឺននាក់ (១០០.០០០) កំពុងធ្វើការនៅក្នុងប្រទេសម៉ាឡេស៊ី។

អាជ្ញាធរម៉ាឡេស៊ីបន្តបិទខ្ទប់ប្រទេសនេះរយៈពេលជិត២ខែមកហើយ ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩ ហើយវិធានការរបស់អាជ្ញាធរម៉ាឡេស៊ីនេះ ហាមឃាត់អ្នកធ្វើដំណើរចាប់ពីម៉ោង ៨យប់ ដល់ម៉ោង ៨ព្រឹក និងហាមការប្រមូលផ្តុំគ្នាជាដើម។ ប្រសិនបើជនណាល្មើសនឹងបម្រាមនេះអាចនឹងត្រូវមានទោសដាក់ពន្ធនាគារ ៦ខែ ទៅ ១ឆ្នាំ និងពិន័យប្រាក់ ១ម៉ឺនរីងហ្គីត ឬស្មើប្រមាណ ២. ៥០០ដុល្លារ៕

## ក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស APHR ជំរុញរដ្ឋាភិបាលថៃនិងម៉ាឡេស៊ីជួយការពារនិងព្យាបាលជំងឺកូវីដ១៩ដល់ពលករចំណាកស្រុកដោយគ្មានការរើសអើង

https://www.rfa.org/khmer/news/ ដោយ មាន ឫទ្ធិ 2021-07-19

ក្រុមសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស ហៅកាត់ថា APHR ជំរុញដល់បណ្តារដ្ឋាភិបាលនៅតំបន់អាស៊ាន ជាពិសេសរដ្ឋាភិបាលថៃ (Thailand) និងម៉ាឡេស៊ី (Malaysia) ឱ្យចាត់វិធានការការពារ និងព្យាបាលជំងឺកូវីដ-១៩ ដល់មនុស្សគ្រប់រូប ដោយគ្មានការរើសអើងពាក់ព័ន្ធនឹងស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។ ការជំរុញនេះ ធ្វើឡើងនៅក្នុងសេចក្តីប្រកាសព័ត៌មានមួយផ្សាយនៅថ្ងៃទី១៩ ខែកក្កដា ស្របពេលដែលករណីឆ្លងជំងឺកូវីដ-១៩ កំពុងកើនឡើងខ្លាំងនៅក្នុងប្រទេសថៃ និងម៉ាឡេស៊ី ព្រមទាំងនៅតាមបណ្តាប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ាន។

តំណាងរាស្ត្រឥណ្ឌូណេស៊ី (Indonesia) និងជាសមាជិក សភាអាស៊ានដើម្បីសិទ្ធិមនុស្ស ហៅកាត់ថា APHR លោកស្រី មឺរស៊ី បារេនស៍ (Mercy Barends) ថ្លែងក្នុងសេចក្តីប្រកាសព័ត៌មានថា ស្របពេលដែលយើងទាំងអស់គ្នាកំពុងរងការប៉ះពាល់ដោយសារជំងឺរាតត្បាតសាកលនេះ រដ្ឋាភិបាលនានាកំពុងផាត់ចោលពលករចំណាកស្រុក ចេញពីគោលនយោបាយគាំពារសង្គម និងសុខភាពសាធារណៈរបស់ពួកគេ។ លោកស្រីថា ការណ៍នេះបានទុកឱ្យពលករចំណាកស្រុកទាំងនោះ ប្រឹងប្រែងតស៊ូរស់នៅដោយខ្លួនឯង។ លោកស្រីព្រមានថា ប្រទេសទាំងអស់នឹងមិនអាចរួចផុតពីវិបត្តិសុខភាពនេះបានឡើយ ប្រសិនបើប្រទេសទាំងនោះមិនផ្តល់នូវការថែទាំដល់មនុស្សគ្រប់រូប រួមទាំងពលករចំណាកស្រុកផង។ តំណាងរាស្ត្រឥណ្ឌូណេស៊ីរូបនេះ ផ្តល់អនុសាសន៍ថា គោលនយោបាយរបស់រដ្ឋាភិបាលត្រូវធានាថា ពលករចំណាកស្រុកមានលទ្ធភាពទទួលបានដូចៗគ្នានូវជំនួយ ការធ្វើតេស្ត សេវាថែទាំព្យាបាលសុខភាព និងការចាក់វ៉ាក់សាំងជាបន្ទាន់ដោយគ្មានការភ័យខ្លាចឡើយ។

ស្របពេលដែលប្រទេសថៃ និងប្រទេសម៉ាឡេស៊ី មានការកើនឡើងជារៀងរាល់ថ្ងៃនៃករណីឆ្លង និងស្លាប់ពីជំងឺកូវីដ-១៩ ពលករចំណាកស្រុកនៅក្នុងប្រទេសទាំងពីរនេះ កំពុងទទួលរងនូវផលប៉ះពាល់ធ្ងន់ធ្ងរដាច់ពីពលរដ្ឋនៃប្រទេសទាំងនេះ។ ករណីឆ្លងរាលដាលយ៉ាងខ្លាំងត្រូវបានគេរកឃើញក្នុងចំណោមសហគមន៍របស់ពលករចំណាកស្រុក ដោយសារតែស្ថានភាពរស់នៅរបស់ពួកគេខ្វះអនាម័យ និងមានភាពចង្អៀតណែន ដែលធ្វើឱ្យពួកគេត្រូវប្រឈមនឹងហានិភ័យខ្ពស់នៃការឆ្លងជំងឺកូវីដ-១៩។ ក្នុងពេលជាមួយគ្នានេះ ពលករចំណាកស្រុកជាច្រើនបានបាត់បង់ការងារធ្វើ បាត់បង់ចំណូលប្រចាំថ្ងៃ ហើយត្រូវប្រឈមនឹងកង្វះស្បៀងអាហារ និងទឹកស្អាតប្រើប្រាស់។ ពួកគេបន្តជួបនូវការរើសអើងដែលបានរារាំងពួកគេមិនឱ្យទទួលបាននូវសេវាថែទាំព្យាបាលសុខភាព និងជំនួយផ្សេងៗពីរដ្ឋាភិបាល។

ជាក់ស្តែង ពលករចំណាកស្រុកខ្មែរនៅទូទាំងប្រទេសថៃ មានប្រមាណ៩ពាន់នាក់ហើយ បានឆ្លងជំងឺកូវីដ-១៩ ស្ថិតក្រោមការបិទខ្ទប់របស់អាជ្ញាធរថៃ ខ្វះខាតចំណីអាហារ និងសេវាថែទាំសុខាភិបាល។ អាជ្ញាធរថៃផ្តល់អាទិ

ភាពដល់ពលរដ្ឋថៃរបស់ខ្លួនមុនពលករខ្មែរ និងពលករចំណាកស្រុកជនជាតិផ្សេងទៀត ក្នុងការទទួលការព្យាបាល និងថែទាំសុខភាព។ ពលករខ្មែរទាំងនេះ បន្តអំពាវនាវឱ្យរដ្ឋាភិបាលថៃ និងខ្មែរ ជួយសង្គ្រោះអាយុជីវិតរបស់ពួកគាត់ជាបន្ទាន់ ខណៈស្ថានភាពឆ្លងជំងឺកូវីដ-១៩ ក្នុងចំណោមសហគមន៍របស់ពួកគាត់កាន់តែដុនដាប។

## ពលករខ្មែរឆ្លងជំងឺកូវីដ១៩នៅប្រទេសថៃមួយចំនួនបន្តដង្ហោយហៅរដ្ឋាភិបាលជួយសង្គ្រោះអាយុជីវិត

https://www.rfa.org/khmer/news/ ដោយ មួង ណារ៉េត 2021-07-19

ពលករខ្មែរដែលឆ្លងជំងឺកូវីដ-១៩ នៅប្រទេសថៃថ្លែងថា នៅពេលនេះស្ថានភាពរបស់ពួកគាត់កាន់តែលំបាកហើយគ្មានលទ្ធភាពជួយខ្លួនឯងបានទេ។ ពលការិនីមានស្រុកកំណើតនៅខេត្តបាត់ដំបងលោកស្រី វិត ស្រីមុំ ប្រាប់វិទ្យុអាស៊ីសេរីនៅព្រឹកថ្ងៃទី១៨ ខែកក្កដាថា ថៅកែជនជាតិថៃបានបង្ខាំងលោកស្រីនិងពលករខ្មែរជាច្រើននាក់ទៀត នៅក្នុងការដ្ឋានសំណង់នៅក្រុងបាងកកប្រហែល ២ខែហើយ ពុំមានគ្រូពេទ្យណាមកព្យាបាលជំងឺលោកស្រីនៅឡើយទេ។ ស្ត្រីវ័យ៣២ឆ្នាំរូបនេះ បន្ថែមថា សព្វថ្ងៃនេះសុខភាពរបស់លោកស្រីចុះខ្សោយនិងគ្មានកម្លាំងកំហែងដូចពេលមិនទាន់មានជំងឺកូវីដ-១៩ឡើយ ពីព្រោះលោកស្រីគ្មានអាហារហូបចុកគ្រប់គ្រាន់៖ «ដូចអ្នកទោសអីចឹងឯងរាល់ថ្ងៃនេះ គេថាពួកខ្ញុំអ្នកជាប់កូវីដអីចឹងគេមិនឱ្យយើងចេញទៅណាទេ គេថា មានអីហូបក៏ហូបហ្នឹងទៅ។ ខ្ញុំបន់ឱ្យតែបានចេញក្រៅទេ បងគិតមើលយើងជាប់ត្រឹមកន្លះខែអីវាលំបាកហើយ តែពួកខ្ញុំឡើងចង់២ខែហើយ នេះលើសសម័យប៉ុល ពតទៀត ខ្ញុំមិនដែលទាន់ប៉ុល ពត ទេខ្ញុំមកទាន់សម័យកូវីដ គេចាប់ឃុំខ្លួនវេទនា។ ម្យ៉ាងទៀតអារឿងបាយហូប មិនបានហើយម្នាក់ៗភ័យរឿងកូវីដទៀត ព្រោះអីអត់បានទៅពេទ្យសោះ បើមើលនៅក្នុងហ្វេសប៊ុកឃើញតែងាប់ ហើយពួកខ្ញុំចប់កូវីដក៏នៅតែអីចឹង»។

ដូចគ្នានេះដែរ ពលការិនីធ្វើសំណង់នៅទីក្រុងបាងកកម្នាក់ទៀតលោកស្រី ស៊ឹម ស៊ាន ថ្លែងថា លោកស្រីព្រួយបារម្ភខ្លាចធ្លាក់ខ្លួនឈឺធ្ងន់ បណ្ដាលឱ្យស្លាប់បាត់បង់ជីវិតនៅស្រុកគេ ដោយខានបានជួបមុខឪពុកម្ដាយ។ ស្ត្រីវ័យ ៣៤ ឆ្នាំរូបនេះបញ្ជាក់ថា ចាប់តាំងពីលោកស្រីឆ្លងជំងឺកូវីដ-១៩មក ហូបចុកគ្រៀមក្រោះរហូត។បញ្ហានេះធ្វើឱ្យលោកស្រីមានសុខភាពទ្រុឌទ្រោម និងគ្មានកម្លាំងកំហែងក្នុងខ្លួននោះទេ៖ «វាលំបាកខ្លាំងតែមែនទែន ខ្ញុំមិនដែលធ្លាប់ជួបប្រទះដែរ ពេលមកជួបខ្លួនឯងផ្ទាល់ខ្ញុំវាលំបាកខ្លាំងមិនដឹងនិយាយយ៉ាងណាទេ ណាមួយយើងមិនមានអីហូបណាមួយយើងមិនដឹងចេញទៅណាក៏វាធុញថប់វាមិនដឹងថា បានចេញថ្ងៃណាទេ។ កាលខ្ញុំឈឺដើមទ្រូងខ្លាំង កាលគេទើបត្រួតសុខភាពរួច ឈឺខ្លាំងមែនទែន ខ្ញុំដើរមួយទល់ព្រឹកខ្ញុំមិនដែលហ៊ានដេកទេ ខ្ញុំខ្លាចតែដេកទៅវាថប់វាទៅមែនទែន»។

ពលករខ្មែរនៅកណ្ដាលទីក្រុងបាងកកមួយក្រុមនេះ មានគ្នាជាង ៧០ នាក់ ពួកគាត់បានឆ្លងជំងឺកូវីដ-១៩ទាំងអស់គ្នាប្រហែល ២ខែមកហើយ មិនទាន់បានជាសះស្បើយនៅឡើយទេ។ ពួកគាត់ត្រូវបានថៅកែថៃបង្ខាំងនៅក្នុងការដ្ឋានសំណង់ ដោយផ្ដល់ស្បៀងអាហារបន្តិចបន្តួចសម្រាប់ហូបចុកប៉ុណ្ណោះ។

អាជ្ញាធរថៃបន្តបិទខ្ទប់ទីក្រុងបាងកកនិងខេត្តចំនួន ៥ នៅជុំវិញនោះ ព្រមទាំងខេត្តចំនួន ៤ ទៀតនៅភាគខាងត្បូងជាប់ប្រទេសម៉ាឡេស៊ី (Malaysia) រហូតដល់ថ្ងៃទី២ ខែសីហា ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩។ វិធានការរបស់អាជ្ញាធរថៃនេះ ហាមឃាត់មនុស្សធ្វើដំណើរចាប់ពីម៉ោង៩យប់ដល់ម៉ោង ៤ ទៀបភ្លឺ និងហាមការប្រមូលផ្ដុំគ្នាលើសពី ៥ នាក់។ ប្រសិនបើជនណាល្មើសនឹងបម្រាមនេះអាចនឹងត្រូវមានទោសដាក់ពន្ធនាគារ ១ឆ្នាំ និងពិន័យជាប្រាក់ ៤ម៉ឺនបាត ឬស្មើប្រមាណ ១ពាន់ ៣០០ដុល្លារ (១.៣០០)។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីសុំអត្ថាធិប្បាយជុំវិញក្ដីកង្វល់របស់ពលករខ្មែរនេះបានទេនៅថ្ងៃទី១៨ ខែកក្កដា។ ប៉ុន្តែមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ទទួលបន្ទុកផ្នែកពល

ករលោក គឹម ចំរើន បានបង្ហោះសារនៅក្នុងហ្វេសប៊ុករបស់លោកនៅថ្ងៃទី១៨ ខែកក្កដាថា អាជ្ញាធរថៃនឹងបិទខ្ទប់ខេត្តចំនួន៣បន្ថែមទៀត នៅក្បែរទីក្រុងបាងកក រួមមានខេត្តឈុនបុរី (Chhunbori) ឆាក់ឈើងសៅ (Chhak Cheungsao) និង ខេត្តអយុទ្យា (Ayutthaya) ចាប់ពីថ្ងៃទី២០ ខែកក្កដា ដល់ថ្ងៃទី២ ខែសីហា។ ក្នុងស្ថានភាពបែបនេះ លោកអំពាវនាវសុំឱ្យពលករខ្មែរទាំងអស់ត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរថៃឱ្យបានខ្ជាប់ខ្ជួន ដើម្បីឱ្យរួចផុតពីការឆ្លងជំងឺកាចសាហាវនេះ។

ទោះជាយ៉ាងណា មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករលោក ឌី ថេហ្គយ៉ា មានប្រសាសន៍ថា វិធានការរបស់អាជ្ញាធរនេះបានប៉ះពាល់យ៉ាងខ្លាំងដល់ការរស់នៅរបស់ពលករខ្មែរ ដែលរដ្ឋាភិបាលកម្ពុជាគួរតែជួយសង្គ្រោះអាយុជីវិតរបស់ពួកគាត់ជាបន្ទាន់។ លោកបញ្ជាក់ថា រដ្ឋាភិបាលថៃមិនសូវអើពើជួយដល់ពលករខ្មែរនោះទេ ហើយពលករភាគច្រើនកំពុងស្នាក់នៅក្នុងការដ្ឋានសំណង់យ៉ាងលំបាកលំបិនតាមយថាកម្ម ដោយគ្មានថ្នាំព្យាបាលជំងឺពួកគាត់នោះឡើយ៖ «បើនិយាយពីអសុវត្ថិភាពវាអសុវត្ថិភាពទាំងអំពីជំងឺឆ្លង ទាំងការទទួលរងការគាបសង្កត់ កេងប្រវ័ញ្ច និងការជួញដូរអីជាដើមហ្នឹង អីចឹងវាអសុវត្ថិភាពទាំងអស់។ យើងឃើញថា រកកន្លែងណាថា សុវត្ថិភាពហ្នឹង មិនឃើញទេ មកទល់ពេលនេះ យើងអាចនិយាយបានថា ដូចជាក្បាលអ្នកណាសង់អ្នកហ្នឹង។ ខ្ញុំក៏មើលថា រដ្ឋាភិបាលថៃក្ដី រដ្ឋាភិបាលខ្មែរក្ដី ហ្នឹងក៏ក្រពុលមុខជាមួយនឹងរឿងផ្សេងៗ អារឿងផ្សេងៗហ្នឹងហើយដែលធ្វើឱ្យពួកគាត់មិនយកចិត្តទុកដាក់ជួយដល់ជនរងគ្រោះ»។

របាយការណ៍របស់អង្គការសង់ត្រាល់បង្ហាញថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់ និងមិនស្របច្បាប់មានជិត ២លាន (២.០០០.០០០) នាក់ ធ្វើការនៅប្រទេសថៃ។ ក្រសួងសុខាភិបាលថៃឱ្យដឹងថា ចាប់តាំងពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី១២ ខែកក្កដា មានពលករខ្មែរជាង ៨ពាន់ ៦០០នាក់ (៨.៦២៥) ហើយបានឆ្លងជំងឺកូវីដ១៩ ក្នុងនោះមានពលករមួយចំនួនកំពុងធ្លាក់ខ្លួនឈឺធ្ងន់៕

## ពលករខ្មែរនៅថៃជិត៩ពាន់នាក់ឆ្លងជំងឺកូវីដ-១៩ ខណៈពលករខ្លះប្រឈមការដាច់ស្បៀង

https://vodkhmer.news/ លោក ត្រាន់ តិចសេង| ១៩ កក្កដា ២០២១ម៉ោង ២២:២៩

មន្ត្រីសង្គមស៊ីវិលអះអាងថា មានពលករខ្មែរប្រមាណជិត៩ ០០០នាក់ (៨ ៨៥៩នាក់) បានឆ្លងជំងឺកូវីដ-១៩ នៅក្នុងប្រទេសថៃ និងរាប់ម៉ឺននាក់ផ្សេងទៀតកំពុងជាប់ក្នុងតំបន់បិទខ្ទប់ ខណៈតួលេខឆ្លងថ្មីក្នុងប្រទេសក្បែរខាងកម្ពុជាមួយនេះ បានហក់ឡើងដល់ជាង១០ ០០០ករណីក្នុងមួយថ្ងៃៗចាប់ពីចុងសប្ដាហ៍មុនមក។

មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ប្រចាំប្រទេសថៃ លោក លឹង សុផុន ប្រាប់ វីអូឌី នៅថ្ងៃទី១៩ ខែកក្កដានេះថា យ៉ាងហោចណាស់ មានពលករខ្មែរប្រមាណជិត៩ ០០០នាក់បានឆ្លងជំងឺកូវីដ-១៩ ក្នុងរលកទី៣ នៃការឆ្លងសហគមន៍ក្នុងប្រទេសថៃ ចាប់ពីខែមេសាមក។ លោកបន្តថា ស្ថានភាពឆ្លងនៅពេលនេះ គឺកំពុងស្ថិតក្នុងការព្រួយបារម្ភខ្លាំង ហើយការចម្លងថ្មីបានចាប់ផ្ទុះឡើងជាបន្តបន្ទាប់នៅតាមសហគមន៍ពលករបរទេសក្នុងវិស័យរោងចក្រ ដែលក្នុងនោះមានពលករកម្ពុជា ភូមា និងឡាវ ខណៈកាលពីខែមុន គឺផ្ទុះនៅតាមសហគមន៍ពលករក្នុងវិស័យសំណង់។ លោកបន្ថែមថា៖ **«ឥលូវកន្លែងខ្លះ ពួកគាត់ខ្វះស្បៀងអាហារ ហើយនិងពួកគាត់មានការឆ្លង ហើយពួកគាត់អត់មានថ្នាំគ្រាប់ថ្នាំអី! សូម្បីតែកន្លែង Camp [ខ្ទម] កសាងដែលបងប្អូនពលករស្នាក់នៅហ្នឹង! ពួកគាត់ទាក់ទងមកខ្ញុំ ឱ្យខ្ញុំចុះធ្វើអន្តរាគមន៍ជួយ ដើម្បីឱ្យយកគាត់ចេញពីកន្លែងហ្នឹង ព្រោះអីមានការឆ្លងហើយ តែអត់មានមន្ទីរពេទ្យ ឬអត់មានពេទ្យ ឬថៅកែណាចុះជួយពួកគាត់។»** លោកបន្ថែមថា៖ **«បងប្អូនពលករដែលគាត់មានការខ្វះខាតហ្នឹង ប្រឈមខ្លាំងមែនទែន! មិនដឹងថាដំណាក់កាលណាទេ! ប៉ុន្តែឃើញមានការព្រួយបារម្ភច្រើនមែនទែន។ ភាគច្រើនពួកគាត់ចង់ត្រឡប់ទៅស្រុកវិញ តែមិនដឹងថាត្រូវត្រឡប់តាមណា។ មួយទៀត បើ**

**សិនត្រឡប់ទៅខ្មែរវិញ គាត់ដាក់ចត្តាឡីស័កនៅតាមព្រំដែន ណាមួយគាត់មិនដឹងថាទៅហ្នឹង ខ្លាចយករោគទៅឆ្លងនៅខ្មែរ»។**

ពលករខ្មែរបម្រើការនៅរោងចក្រដំឡើងម៉ាស៊ីនដេរនៅខេត្តឈុន បុរី អ្នកស្រី ឈន់ ស៊ាប ប្រាប់ វីអូឌី ឱ្យដឹងថា ពលករខ្មែរធ្វើការជាមួយអ្នកស្រីរាប់សិបនាក់បានរកឃើញវិជ្ជមានជំងឺកូវីដ-១៩ រាប់ទាំងស្វាមីរបស់អ្នកស្រីផងដែរ។ ស្ត្រីវ័យ៣៧ឆ្នាំរូបនេះបន្តថា គាត់ត្រូវបានបញ្ជូនទៅមណ្ឌលថែទាំអ្នកជំងឺកម្រិតស្រាលនៅបន្ទាយយោធាមួយកន្លែងក្នុងខេត្ត ខណៈស្វាមីអ្នកស្រីត្រូវបានបញ្ជូនសម្រាកព្យាបាលដាច់ពីគ្នានៅមន្ទីរពេទ្យធំ ដោយសារគាត់មានបញ្ហាសួតធ្ងន់ធ្ងរ។ អ្នកស្រី ឈន់ ស៊ាប និយាយថា៖ **«ច្រើនពូ! ខ្មែរយើងនៅច្រើនណាស់ ១០០នាក់ជាងឯណោះ! ចម្រុះពូអើយ មានខ្មែរយើង ភូមា ប្រុសក៏ដោយប្រុស ស្រីក៏ដោយស្រី ច្រើនណាស់»**។ ប្រភពដដែលបន្ថែមថា គាត់មិនដឹងឆ្លងជំងឺផ្លូវដង្ហើមថ្មីពីពេលណាឬតាមណានោះទេ ប៉ុន្តែគាត់ថា នៅពេលគាត់មានអាការក្តៅខ្លួន ក្អក និងហត់ ហើយលេបថ្នាំច្រើនថ្ងៃមិនធូរ ក៏សម្រេចទៅធ្វើតេស្តសំណាកនៅថ្ងៃទី១៣ ខែកក្កដា ក៏រកឃើញវិជ្ជមានតែម្តង។ អ្នកស្រីបន្ថែមថា ពលករដែលរកឃើញវិជ្ជមានត្រូវបានបញ្ជូនទៅព្យាបាល ឯអ្នកអវិជ្ជមានត្រូវបន្តការងារដដែល ដោយខាងរោងចក្រមិនមានការផ្អាកដំណើរការនោះទេ។ ពលករចំណាកស្រុកពីខេត្តត្បូងឃ្មុំរូបនេះ បន្តថា គាត់បារម្ភខ្លាចមានបញ្ហាឆ្លងជំងឺសារជាថ្មីនៅពេលត្រឡប់ទៅធ្វើការវិញ ប៉ុន្តែដើម្បីដោះស្រាយបញ្ហាជីវភាព គាត់មិនមានជម្រើសនោះទេ។ អ្នកស្រីនិយាយថា៖ **«ចេះតែព្រួយបារម្ភដែរទៅមុខទៀត យើងមិនដឹងធ្វើម៉េច បើយើងវាគ្មានលុយគ្មានកាក់ ចេះតែទ្រាំទៅ»**។

ស្វាមីរបស់អ្នកស្រី ឈន់ ស៊ាប ឈ្មោះ នុត ហឿង ឱ្យដឹងថា លោកកំពុងសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យរបស់រដ្ឋមួយកន្លែងតែម្នាក់ឯង ដោយអ្នកជំងឺដទៃទៀតសុទ្ធតែជាជនជាតិថៃ។ លោកថា លោកមានបញ្ហាក្នុងការទំនាក់ទំនាក់តិចតួច ជាមួយគ្រូពេទ្យ ដោយសារលោកមិនសូវចេះនិយាយភាសាថៃ។ ពលករចំណាកស្រុកទៅធ្វើការនៅប្រទេសថៃអស់រយៈពេល៧ឆ្នាំរូបនេះ ប្រាប់ថា គាត់មានអាការក្អក ក្តៅខ្លួន រាក ក្អួតចង្អោរ និងថប់ដង្ហើម ប៉ុន្តែក្រោយពីសម្រាកព្យាបាលបានមួយរយៈដោយការប្រើថ្នាំលេបនិងចាក់មក លោកក៏បានធូរស្រាលច្រើន។ យ៉ាងណា លោកថា លោកមិនទាន់មានកម្លាំងឡើងវិញនៅឡើយ ដោយសារសួតរបស់លោកមានបញ្ហាដោយសារវីរុសកូវីដ-១៩។ ពលករវ័យ៤៤ឆ្នាំរូបនេះបន្ថែមថា លោកបារម្ភពីបញ្ហាសុខភាព បន្ទាប់ពីរងការវាយលុកពីវីរុសផ្លូវដង្ហើមថ្មីដែលធ្វើឱ្យគាត់មិនមានកម្លាំងគ្រប់គ្រាន់អាចបន្តការងារនៅទីនោះបាន។ លោក នុត ហឿង និយាយថា៖ **«យើងខ្លាចយើងជាទៅ ធ្វើការវិញទៅ វាលាប់ឡើងវិញ! សម្រេចចិត្តថា ជាទៅ ប្រហែលជាសុំគេទៅផ្ទះវិញហើយ»**។

កាលពីខែមិថុនា រដ្ឋាភិបាលថៃបានសម្រេចបិទខ្ទប់តំបន់លំនៅដ្ឋានរបស់ពលករសំណង់អន្តោប្រវេសន៍នៅទូទាំងក្រុងបាងកក និងតាមបណ្តាខេត្តជុំវិញទីក្រុងដែលមានពលរដ្ឋរស់នៅជាង៨លាននាក់នេះ រយៈពេល១ខែ ដើម្បីកាត់ផ្តាច់រលកចម្លងក្នុងសហគមន៍។ វិធានការនេះបានធ្វើឱ្យពលករមួយចំនួនប្រឈមនឹងបញ្ហាខ្វះស្បៀងអាហារប្រចាំថ្ងៃ។

ពលករខ្មែរម្នាក់បម្រើការផ្នែកសាងសង់អគារសាធារណៈនៅខេត្តណាខនប៉ាធំ លោក មិត្ត សារ៉ា ថ្លែងថា លោកនិងភរិយាកំពុងប្រឈមបញ្ហាដាច់ស្បៀងអាហារនិងលុយកាក់ បន្ទាប់ពីលោកមិនមានការងារធ្វើអស់រយៈពេល២ខែ ហើយត្រូវជាប់ក្នុងតំបន់ក្រហមរយៈពេល១ខែថែមទៀត។ លោកថា បញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងប្រទេសថៃ បានធ្វើឱ្យប៉ះពាល់ដល់ការងារសាងសង់របស់ពលករចំណាកស្រុកក្នុងតំបន់របស់លោកប្រមាណពី ៥០ទៅ៦០ភាគរយ។ លោកថា លោកនិងពលករដទៃទៀតដែលស្នាក់នៅនិងធ្វើការជាមួយគ្នាប្រមាណជា២០នាក់ បានស្នើក្រុមហ៊ុនឱ្យជួយអន្តរាគមន៍ ប៉ុន្តែក្រុមហ៊ុនមិនទាន់មានចម្លើយនៅឡើយ ក្រៅពីឱ្យរង់ចាំបណ្ណាធានារ៉ាប់រងសង្គមពីរដ្ឋ។ លោកបន្ថែមថា៖ **«ចាប់អារម្មណ៍ខ្លាំង គឺពេលវេលាដែលយើងមិនបានធ្វើការផង ហើយប្រឈមនឹងការ**

**ដាច់សៀង ហើយប្រឈមនឹងជំងឺកូវីដណាដែលវានៅជុំវិញខ្លួនយើង ហើយក៏គិតដល់ស្រុកដល់ស្រែដែរ ចង់ត្រឡប់ទៅវិញ»។** បុរសវ័យ៤៤ឆ្នាំ មានកូន៤នាក់ផ្ញើនៅឪពុកម្ដាយនៅស្រុកកំណើតនាខេត្តសៀមរាប បន្តថា លោកចង់ត្រឡប់ទៅស្រុកកំណើតវិញ ជួបជុំក្រុមគ្រួសារ ប៉ុន្តែលោកបារម្ភខ្លាចជួបបញ្ហាឆ្លងជំងឺនៅតាមផ្លូវធ្វើដំណើរ និងត្រូវធ្វើចត្តាឡីស័ក១៤ថ្ងៃនៅព្រំដែនទៀត។ លោកថា៖ **«មិនដឹងទៅណាទៅណីទេ ចង់ទៅមុខក៏មិនបាន ថយក្រោយក៏មិនបាន»។**

វីអូឌី មិនអាចទាក់ទងស្ថានទូតថៃប្រចាំប្រទេសកម្ពុជា និងអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង ដើម្បីសុំការអធិប្បាយជុំវិញបញ្ហារបស់ពលករខ្មែរបានទេ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១នេះ។ ដោយឡែក បើតាមលោក កុយ គួយ ពលករខ្មែរប្រមាណ១លាននាក់កំពុងស្នាក់នៅនិងធ្វើការនៅក្នុងប្រទេសថៃ ខណៈរបាយការណ៍ពីអង្គការសង់ត្រាល់ថា ពលករខ្មែរដែលចំណាកស្រុកទៅធ្វើការនៅក្នុងប្រទេសនេះទាំងស្របច្បាប់និងមិនស្របច្បាប់ គឺមានប្រមាណ១លាន៦សែននាក់៕

## ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១

### តុលាការឧទ្ធរណ៍ជម្រះបណ្តឹងស្ត្រី០២នាក់ ម៉ែ និង កូន ពាក់ព័ន្ធការនាំនារីខ្មែរម្នាក់ទៅលក់នៅចិន!!!!

https://cen-news.com/ Posted ByPen Srey NeatJuly 21, 2021

ភ្នំពេញ ៖ សាលាឧទ្ធរណ៍ ភ្នំពេញ កាលពីព្រឹក ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២១ បានបើកសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ស្ត្រីជាប់ចោទ ០២នាក់ ដែលត្រូវជាម្តាយនិងកូន ជាប់ពាក់ព័ន្ធនឹងការនាំចេញស្ត្រីខ្មែរម្នាក់ នាំចេញទៅរៀបការប្តីនៅចិន ប្រព្រឹត្តកាលពីអំឡុងឆ្នាំ២០១៦។

លោក ពៅ ភូស៊ិន ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ សាលាឧទ្ធរណ៍ភ្នំពេញ បានថ្លែងឲ្យដឹងក្នុងសវនាការថា ជនជាប់ចោទទាំង០២នាក់ ខាងលើនេះ មាន ឈ្មោះ ទី ១ ឈ្មោះ ជា រឿង ភេទស្រី អាយុ ៥០ ឆ្នាំត្រូវជាម្តាយ និង ទី២ ឈ្មោះ ប៉ាក់ ដានី ភេទស្រី អាយុ ២៦ ឆ្នាំ។ លោកចៅក្រមបានបញ្ជាក់ថា ក្នុងចំណោមជនជាប់ចោទទាំង០២នាក់នេះ ជនជាប់ចោទ ឈ្មោះ ជា រឿង ត្រូវបានតុលាការខេត្តកណ្តាល កាលពីថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២៥២០ កាត់ទោស ដាក់ពន្ធនាគារកំណត់ ០៤ ឆ្នាំ ចំណែកឯ ឈ្មោះ ប៉ាក់ ដានី ត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារ កំណត់ ០២ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ ការនាំយកចេញ ដោយមិនស្របច្បាប់ សម្រាប់នាំឆ្លងដែនតាមមាត្រា ១១ នៃ ច្បាប់ស្តីពីជាការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ ។

តុលាការខេត្តខេត្តកណ្តាល ក៏បានបង្គាប់ឲ្យពួកគេទាំងពីរនាក់ រួមគ្នាសងលុយចំនួនមួយម៉ឺនដុល្លារអាមេរិកទៅឱ្យយរបស់ជនរងគ្រោះ ឈ្មោះ ហង្ស នី ដែលជាភាគីដើមបណ្តឹង។ លោកបានបន្ថែមថា តែពួកគេបានប្តឹងជំទាស់នឹងសាលក្រមរបស់តុលាការខេត្តកណ្តាល មកសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីសុំបន្ធូរបន្ថយទោស និង បញ្ចុះថ្លៃសងជំងឺចិត្ត។ ពួកគេត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩។ នាពេលសវនាការ, ជនជាប់ចោទទាំង០២ បានឆ្លើយសារភាពកំហុស និង សុំឱ្យតុលាការឧទ្ធរណ៍ បន្ធូរបន្ថយ និង បញ្ចុះការសងជំងឺចិត្ត ពីព្រោះ ពួកគេមិនមានលទ្ធភាពរកលុយសង ដើម្បីសងទៅភាគីរងគ្រោះបាននោះឡើយ។ សំណុំរឿងក្តីនេះ,, សាលាឧទ្ធរណ៍ភ្នំពេញ លើកពេលប្រកាសសាលដីកា នៅព្រឹក ថ្ងៃទី ២ ខែ កក្កដាឆ្នាំ ២០២១៕ ដោយ: ចន្ទា ភា

### ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ អំណើនបទល្មើសបច្ចេកវិទ្យា បទល្មើសព្រហ្មទណ្ឌ គ្រឿងញៀន ការជួញដូរមនុស្ស និងសកម្មភាពបក្ខពួកឡុក នៅតាមមូលដ្ឋាន នៅតែជាកង្វល់

https://cen-news.com/ Posted ByPen Srey NeatJuly 21, 2021

ខេត្តបន្ទាយមានជ័យៈ នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បានរៀបចំប្រជុំ ស្តីពីផែនការសកម្មភាពសម្រាប់ឆមាសទី០២ ឆ្នាំ២០២១ ក្រោមអធិបតីភាព លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ និងមានការចូលរួមពីអស់លោក លោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ ជាស្នងការរង លោក អធិការនគរបាលក្រុង ស្រុក ទាំង០៩និងមេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង០៤ ។

ដើម្បីឲ្យរាល់ភារកិច្ចទាំងឡាយទទួលបានជោគជ័យ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ដាក់ផែនការបានជំរុញដល់គ្រប់បណ្តាអង្គភាពចំណុះស្នងការដ្ឋាន គឺត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួន សម្រាប់ឲ្យមន្ត្រីក្នុងអង្គភាពក្រោមឱវាទរបស់ខ្លួន អនុវត្តឲ្យចំទិសដៅ និងទទួលបានលទ្ធផលល្អ ។ ប្រសិនបើអង្គភាពមួយមិនមានការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តទេនោះ គឺអង្គភាពនោះការអនុវត្តភារកិច្ចរបស់ខ្លួនមិនទទួលបានលទ្ធផលល្អនោះឡើយ។ ដូច្នេះគ្រប់បណ្តាអង្គភាពគឺត្រូវតែរៀបចំផែនការសកម្មភាពរបស់ខ្លួន ដោយផ្ញើមកស្នងការដ្ឋាន (សេនាធិការដ្ឋាន) ដើម្បីឲ្យមានមូលដ្ឋានរៀបចំជាផែនការរួមសម្រាប់សកម្មភាពរបស់យើងអនុវត្តជាក់ស្តែង ឲ្យមានប្រសិទ្ធភាពនិងទទួលបានជោគជ័យ ។

លោកឧត្តមសេនីយ៍ស្នងការបានបញ្ជាក់ថាៈ សភាពការណ៍នៃកំណើនបទល្មើសបច្ចេកវិទ្យា បទល្មើសព្រហ្មទណ្ឌ បទល្មើសគ្រឿងញៀន ការជួញដូរមនុស្ស និងសកម្មភាពបង្កអុកឡុក នៅតាមមូលដ្ឋាន នៅតែជាកង្វល់ ។ មិនត្រឹមតែប៉ុណ្ណោះ កំណើននៃគ្រោះថ្នាក់ និងការកកស្ទះចរាចរណ៍ រួមទាំងកំណើនយានយន្តយ៉ាងគំហុក ស្របពេលផ្លូវថ្នល់កំពុងកែលម្អ និងការគ្រប់គ្រងទ្រូងផ្លូវ ចិញ្ចើមផ្លូវនៅមានកម្រិតផងនោះ បានធ្វើឲ្យសណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវគោកជួបបញ្ហាប្រឈម ។ជាមួយគ្នានោះ ដើម្បីដោះស្រាយរាល់បញ្ហាទាំងនោះ បានរលូនគឺយើងត្រូវតែរៀបចំផែនការ ដើម្បីអនុវត្ត។ នៅក្នុងដំណាក់កាលនៃការឆ្លងរាតត្បាតជម្ងឺកូវីដ១៩បង្កឲ្យមានហានិភ័យគម្រាមកំហែងដល់សុខភាពសាធរណៈ និងអាយុជីវិតមនុស្សលើសលលោក ។ លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ បានក្រើនរំលឹកដល់អស់លោក ជាថ្នាក់ដឹកនាំបណ្តាអង្គភាពនីមួយៗ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ថែរក្សាសុខភាព មានអនាម័យឲ្យបានល្អ ដោយអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល លាងដៃនិងសាប៊ូឬជែល ពាក់ម៉ាស់ រក្សាម្លាតពិសេសគឺអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាលពាការពារនិងពាកុំ ឲ្យបានខ្ជាប់ខ្ជួន ដើម្បីរួមគ្នាទប់ស្កាត់ការឆ្លងរាលដាលជម្ងឺដ៏កាចសាហាវនេះ ចូលក្នុងសហគមន៍ ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ

http://cambodiapolice.com/policekh/ 4:24 pm 20 កក្កដា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ លោកវរសេនីយ៍ឯក ញៅ ថារ៉ុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ នៅថ្ងៃអង្គារ ១១កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បានចាត់តាំងកម្លាំងនគរបាលប៉ុស្តិ៍ព្រំដែន ចំណុះវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ សហការជាមួយកម្លាំងយោធា ចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្នុងភូមិសាស្ត្រប៉ុស្តិ៍គ្រប់គ្រងៈ

១-នគរបាលប៉ុស្តិ៍ព្រំដែនគីឡូ១៣ បានចេញល្បាតចាប់ពីចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ដល់ចំណុចភូមិឈើទាល ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

២-នគរបាលប៉ុស្តិ៍ព្រំដែនគីឡូ៩ បានចេញល្បាតចាប់ពីចំណុចភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ដល់ចំណុចភូមិស្ពានយោល ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង។

៣-នគរបាលប៉ុស្តិ៍ព្រំដែនកូនភ្នំបានចេញល្បាតចាប់ពីចំណុចភូមិសាស្រ្ត ភូមិចំកាល្ហុង ឃុំតាស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង ដល់ចំណុចភូមិសាស្រ្ត ភូមិកូនភ្នំខាងជើង ឃុំស្តា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

៤-នគរបាលប៉ុស្តិ៍ព្រំដែនភ្នំព្រឹកបានចេញល្បាតចាប់ពីចំណុចភូមិសាស្រ្តភូមិបេងស្អាត ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបងដល់ចំណុចភូមិសាស្រ្តភូមិស្រឡៅ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ៕

## នគរបាលការពារព្រំដែនសំយ៉ោង បង្រ្កាបឃាត់ខ្លួនជនជាតិវៀតណាមចំនួន០៥នាក់ លួចឆ្លងដែនខុសច្បាប់ចូលមកកម្ពុជា នៅចំណុចខ្សែបន្ទាត់ព្រំដែន កម្ពុជា -វៀតណាម

https://cen-news.com/ Posted ByPen Srey NeatJuly 21, 2021

ខេត្តស្វាយរៀង ៖ អនុវត្តតាមបទបញ្ជាដ៏មុឺងម៉ាត់របស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត និងក្រោមការដឹកនាំបញ្ជាផ្ទាល់ ពីលោកឧត្តមសេនីយ៍ទោ កឹង យន ស្នងការនគរបាលខេត្ត ក្នុងការងារទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមព្រំដែន នគរបាលការពារព្រំដែនសំយ៉ោង សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ បង្រ្កាបឃាត់ខ្លួនជនជាតិវៀតណាម លួចឆ្លងដែនខុសច្បាប់ចូលមកកម្ពុជា ចំនួន០៥នាក់ នៅចំណុចខ្សែបន្ទាត់ព្រំដែន កម្ពុជា -វៀតណាម។

នគរបាលការពារព្រំដែនសំយ៉ោង បានឲ្យដឹងថា នៅយប់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនសំយ៉ោង វរ៦០៩ ប៉ុស្តិ៍នគរបាលរដ្ឋបាលបន្ទាយក្រាំង សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ បានល្បាតចល័ត បង្រ្កាបជនជាតិវៀតណាម លួចឆ្លងដែនខុសច្បាប់ចូលមកកម្ពុជា ចំនួន០៥នាក់ ស្រី០៣នាក់ នៅចំណុច ខ្សែបន្ទាត់ព្រំដែន ( កម្ពុជា) ស្ថិតនៅភូមិប្រចន្រ្ទា ឃុំបន្ទាយក្រាំង ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង -(វៀតណាម)ស្ថិតនៅភូមិទ្រុងចិន ឃុំថាយប៊ុនទ្រុង ស្រុកវិញហ៊ឹង ខេត្តឡុងអាន ។

គួររំលឹកផងដែរថា កម្លាំងនគរបាលការពារព្រំដែនយើង សហការជាមួយកម្លាំងពាក់ព័ន្ធ បានទប់ស្កាត់ជនបរទេសឆ្លងដែនខុសច្បាប់ ចូលមកកម្ពុជា និងឃាត់ខ្លួនមេខ្យល់ កសាងសំនុំរឿងចាត់ការតាមច្បាប់ជាបន្តបន្ទាប់ ៕

រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ក្រសួងការបរទេស នៅមិនទាន់ទទួលបានព័ត៌មានផ្លូវការ អំពីចំនួនពលករខ្មែរ ឆ្លងជំងឺកូវីដនៅថៃ នៅឡើយទេ

https://cen-news.com/ Posted ByPen Srey NeatJuly 20, 2021

ភ្នំពេញ ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅមិនទាន់មានព័ត៌មានផ្លូវការ អំពីចំនួនពលករខ្មែរដែលឆ្លងជំងឺកូវីដ នៅក្នុងប្រទេសថៃនៅឡើយទេ។ ដោយស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ កំពុងតែធ្វើការជាមួយអាជ្ញាធរថៃ។ នេះបើតាមការបញ្ជាក់របស់លោកកុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា នៅមុននេះបន្តិច។ ការបញ្ជាក់របស់អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានធ្វើឡើង បន្ទាប់ពីន្ត្រីគម្រោងនៃអង្គការសង់ត្រាល់ ប្រចាំនៅប្រទេសថៃ បានផ្សព្វផ្សាយព័ត៌មានថា គិតមកដល់ជិតចុងខែកក្កដា ឆ្នាំ២០២១នេះ ពលករខ្មែរប្រមាណ ៩ពាន់នាក់ហើយ ដែលកំពុងរស់នៅនិងធ្វើការនៅប្រទេសថៃ បានឆ្លងជំងឺកូវីដ-១៩ ខណៈពលករខ្មែរជាស្រ្តីម្នាក់នៅថៃ ទើបនឹងបាត់បង់ជីវិតដោយសារជំងឺនេះ។

អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង បានបញ្ជាក់ថា "យើងមិនទាន់មានព័ត៌មានផ្លូវការច្បាស់លាស់ អំពីចំនួនពលករខ្មែរដែលឆ្លង Covid ទេ។ ស្ថានទូតកំពុងធ្វើការជាមួយអាជ្ញាធរថៃ ផ្ទៀងផ្ទាត់ចំនួន និងឈ្មោះពលករ ព្រោះអាចច្រឡំជាមួយពលករឡាវ និងមីយ៉ាន់ម៉ា"។

ចំណែកលោក លឹង សុផុន មន្ត្រីគម្រោងនៃអង្គការសង់ត្រាល់ប្រចាំ នៅប្រទេសថៃ បានប្រាប់សារព័ត៌មានក្នុងស្រុកថា ពលករខ្មែរប្រមាណ ៩ពាន់នាក់ ដែលឆ្លងកូវីដ-១៩ ភាគច្រើនជាពលករសំណង់។ ពលករខ្មែរដែលធ្វើការផ្នែកសំណង់ក្នុងទីក្រុងបាងកក មានប្រមាណ ៧ម៉ឺននាក់ ហើយពួកគេ ប្រឈមនឹងការឆ្លងជំងឺកូវីដ-១៩ ខ្លាំងជាងគេ។ ប្រភពដដែលបានបន្តថា ពលករខ្មែរដែលឆ្លងជំងឺកូវីដ-១៩ កំពុងជួបការលំបាកជាច្រើន ដូចជា បាត់បង់ការងារ បាត់បង់ចំណូល ខ្វះថវិកា និងខ្វះស្បៀង ជាដើម។ ពលករខ្មែរខ្លះ ដែលឆ្លងជំងឺកូវីដ-១៩ មិនបានទៅព្យាបាលត្រឹមត្រូវនៅមន្ទីរពេទ្យឡើយ បើទោះបីជារដ្ឋាភិបាលថៃ ប្រកាសថា នឹងព្យាបាលគ្រប់ជនបរទេសទាំងស្របច្បាប់ទាំងខុសច្បាប់ក៏ដោយ។ ពលករខ្មែរ ដែលមិនបានទទួលការព្យាបាលត្រឹមត្រូវ ភាគច្រើនគឺជាអ្នក ដែលគ្មានឯកសារគ្រប់គ្រាន់ ឬមិនស្របច្បាប់ ហើយថៅកែ មិនបានយកចិត្តទុកដាក់។ នេះបើតាមព័ត៌មានពីលោក សុផុន ដដែល ដោយលោក បន្ថែមថា មានតែពលករខ្មែរ ដែលមានឯកសារគ្រប់គ្រាន់ ឬស្របច្បាប់ និងត្រូវបានថៅកែយកចិត្តទុកដាក់ប៉ុណ្ណោះ ដែលទទួលបានការព្យាបាលត្រឹមត្រូវនៅមន្ទីរពេទ្យ។

គួរបញ្ជាក់ថា គិតត្រឹមថ្ងៃទី២០ ខែកក្កដា ប្រទេសថៃមានឆ្លងជំងឺកូវីដ១៩ មានចំនួន ៤២៦,៤៧៥ នាក់ , អ្នកជាសះស្បើយមានចំនួន ២៩៦,២០៨ នាក់ អ្នកកំពុងព្យាបាលមានចំនួន ១២៦,៧៦៥នាក់ និងស្លាប់មានចំនួន ៣៥០២នាក់៕ រក្សាសិទ្ធិដោយៈ ចេស្តារ

## មន្ត្រីទូតកម្ពុជាជំរុញឱ្យមន្ទីរពេទ្យនៅថៃយកចិត្តទុកដាក់ព្យាបាលពលករខ្មែរដែលឆ្លងកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 21/07/2021 - 09:29 ដោយ៖វណ្ណ សុគន្ធា

*ក្រសួងការបរទេសកម្ពុជានៅព្រឹកថ្ងៃពុធនេះ បានចេញមកបញ្ជាក់ឱ្យដឹងថា មន្ត្រីស្ថានទូតកម្ពុជាកំពុងធ្វើការជាមួយអាជ្ញាធរ និងមន្ទីរពេទ្យនៅថៃ ដើម្បីជំរុញឱ្យយកចិត្តទុកដាក់ថែទាំ និងព្យាបាលពលករខ្មែរដែលបានឆ្លងជំងឺកូវីដ១៩។ ការបញ្ជាក់នេះ គឺធ្វើឡើងបន្ទាប់ពីមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់បានបង្ហាញថា ពលរដ្ឋខ្មែរនៅប្រទេសថៃដែលបានឆ្លងជំងឺកូវីដ១៩ មិនទទួលបានថែទាំ និងព្យាបាលដោយយកចិត្តទុកដាក់ឡើយ។តាមសង់ត្រាល់គឺពលករខ្មែរនៅទីនោះប្រមាណជិត១ម៉ឺននាក់ហើយបានឆ្លងជំងឺកូវីដ១៩*។

លោកលឹង សុផុន មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ប្រចាំនៅប្រទេសថៃបានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិកាលពីល្ងាចថ្ងៃអង្គារថា ពលករខ្មែរនៅក្នុងប្រទេសថៃប្រមាណ៩ពាន់នាក់ហើយបានឆ្លងជំងឺកូវីដ១៩ ។ ក្នុងនោះ ភាគច្រើននៅក្នុងទីក្រុងបាងកក និងខេត្តដែលជាតំបន់ក្រហមមួយចំនួនទៀតដូចជាខេត្តសាមុត ប្រាកាន ណាក់ខនប៉ាក់ធុម ប៉ាក់ធុមថានី ឈុនប៊ុរី និងខេត្តស្រះកែវជាដើម។ ចំពោះពលករខ្មែរដែលឆ្លងកូវីដ១៩ទាំងនេះ លោកលឹង សុផុន បានគូសបញ្ជាក់ថា ពួកគេទទួលបានព្យាបាលមិនដូចគ្នាឡើយ ពោល គឺពលករដែលមានលិខិតឆ្លងដែន មានទិដ្ឋាការ និងប័ណ្ណការងារត្រឹមត្រូវ ហើយមានការយកចិត្តទុកដាក់ពីថៅកែទៀតនោះ គឺពួកគេទទួលបានការព្យាបាលសមរម្យ។ ប៉ុន្តែ ចំពោះពលករដែលមិនទាន់បានប័ណ្ណការងារពេញលេញ អ្នកមានប័ណ្ណផុតសុពលភាព និងពលករខុសច្បាប់វិញ គឺមិនមានការយកទុកចិត្តទុកនាំពួកគេទៅមន្ទីរពេទ្យ និងមិនទទួលបានការព្យាបាលបានដិតដល់ឡើយ។

ជុំវិញបញ្ហានេះ វិទ្យុបារាំងអន្តរជាតិបានព្យាយាមទាក់ទងទៅកាន់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ ដើម្បីសុំការបញ្ជាក់ និងបំភ្លឺដែរ តែមិនទាន់ទទួលបានការឆ្លើយតបនៅឡើយទេមកដល់ពេលនេះ។ ប៉ុន្តែ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោកកុយ គួង បានអះអាងជំនួសប្រាប់វិទ្យុបារាំងអន្តរជាតិនៅព្រឹកថ្ងៃពុធនេះថា ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃកំពុងខិតខំសហការជាមួយអាជ្ញាធរ និងក្រុមហ៊ុនថៃ ដើម្បីជួយដល់ពលករខ្មែរដែលកំពុងជួបការលំបាកខ្លាំងនៅក្នុងប្រទេសថៃ។ ជាមួយគ្នានេះ មន្រ្តីទូតកម្ពុជាក៏កំពុងខិតខំសហការជាមួយមន្ទីរពេទ្យឱ្យយកចិត្តទុកដាក់ព្យាបាលពលករខ្មែរដែលបានឆ្លងជំងឺCovid១៩ផងដែរ។

ចំណែក ចំនួនពលករខ្មែរឆ្លងជំងឺកូវីដ១៩នៅថៃវិញ ក្រសួងការបរទេសកម្ពុជាបានអះអាងថា មិនទាន់មានព័ត៌មានផ្លូវការច្បាស់លាស់នៅឡើយទេ ដោយថា ស្ថានទូតកម្ពុជានៅថៃកំពុងធ្វើការជាមួយអាជ្ញាធរថៃ ដើម្បីផ្ទៀងផ្ទាត់ចំនួន និងឈ្មោះពលករ ព្រោះអាចច្រឡំជាមួយពលករបរទេសផ្សេងៗទៀត។ យ៉ាងណាក៏ដោយ ពលករខ្មែរជាច្រើនចង់វិលត្រឡប់ចូលប្រទេសកំណើតវិញ ដោយសារទី១.ពួកគេបារម្ភពីការឆ្លងជំងឺកូវីដ១៩ និងទី២. ខ្លាចទទួលការព្យាបាលមិនដិតដល់នៅក្នុងប្រទេសថៃ។ នេះបើតាមការបញ្ជាក់ឱ្យដឹងរបស់លោកលឹង សុផុន៕

## ទូតកម្ពុជានៅម៉ាឡេស៊ី ចុះចែកស្បៀងដល់ប្រជាជន និងពលករខ្មែរ ជួបការលំបាកខ្លាំង ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩

https://cen-news.com/ Posted ByPen Srey NeatJuly 21, 2021

ភ្នំពេញ ៖ ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអង្គការក្នុងស្រុក សប្បុរសជនម៉ាឡេស៊ី និងភ្នាក់ងារស្ម័គ្រចិត្ត បានបន្តចុះចែកស្បៀងអាហារ ដល់ប្រជាជន និងពលករខ្មែរ ដែលកំពុងជួបការលំបាកខ្លាំង នៅក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ ធូន់ធូរនៅតាមបណ្តារដ្ឋមួយចំនួនជិត ១០០គ្រួសារ។ នេះបើតាមការឲ្យដឹងពីលោកកុយ គួង អ្នកនាំពាក្យក្រសួងបការបរទេសកម្ពុជា។

អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា បានបន្តថា ការបន្តចុះចែកស្បៀងអាហារ ដល់ប្រជាជន និងពលករខ្មែរ ដែលកំពុងជួបការលំបាកខ្លាំងនៅក្នុងអំឡុង ពេលនៃការរាតត្បាតជំងឺកូវីដ-១៩ ធូន់ធូរ នៅតាមបណ្តារដ្ឋមួយមានដូចជាៈ កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បានសហការជាមួយអង្គការ Elshaddai Center នាំយកជំនួយជាស្បៀងអាហារ ជូនប្រជាជនខ្មែរ កំពុងជួបការលំបាក ចំនួន១០គ្រួសារ នៅ Kuala Terrenganu រដ្ឋ Terrenganu។ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ បានសហការជាមួយអង្គការ Makan4Migrants យកជំនួយជាស្បៀងអាហារជូន ប្រជាជនខ្មែរកំពុងជួបការ លំបាកចំនួន ០៤គ្រួសារ នៅ Rawang រដ្ឋ Selangor។ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២១ បានសហការជាមួយអង្គការ Youth With A Mission Malaysia យកជំនួយជាស្បៀងអាហារ ជូនប្រជាជនខ្មែរកំពុងជួបការលំបាក ចំនួន១០គ្រួសារ នៅ Ipoh រដ្ឋPerak។

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ បានសហការជាមួយក្រុមសប្បុរសជនម៉ាឡេស៊ី យកជំនួយជាស្បៀងអាហារ ជូនប្រជាជនខ្មែរកំពុងជួបការលំបាក ចំនួន៤៤គ្រួសារ នៅ Sungai Tiram និង Kota Tinggi រដ្ឋ Johor។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ បានសហការជាមួយក្រុមសប្បុរសជនម៉ាឡេស៊ី យកជំនួយជាស្បៀងអាហារ ជូនប្រជាជនខ្មែរកំពុងជួបការលំបាក ចំនួន១១គ្រួសារ នៅរដ្ឋ Penang។ ហើយថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ ស្ថានទូតបាននាំយកជំនួយ ជាស្បៀងអាហារជូនប្រជាជនខ្មែរ កំពុងជួបការលំបាក ចំនួន១០គ្រួសារ នៅ Kampong Pandan ទីក្រុងគូឡាឡាំពួរ។ ប្រភពដដែលបានបញ្ជាក់ថា ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី នឹងបន្តជួយដោះស្រាយ ការលំបាកទាំងនេះ ជាបន្តទៀតរហូតដល់ស្ថានភាពកូវីដ-១៩ មានការធូរស្រាលឡើងវិញ៕ ដោយៈ ចេស្តារ

## ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១

# មន្ត្រីអំពាវនាវកុំឱ្យពលរដ្ឋឆ្លងដែនទៅថៃ ខណៈការបង្ក្រាបការជួញដូរមនុស្ស ៦ ខែកើនឡើង

https://www.postkhmer.com/ រី សុចាន់ | Publication date 22 July 2021 | 08:57 ICT

**ភ្នំពេញៈ** មន្ត្រីក្រសួងមហាផ្ទៃអំពាវនាវដល់ពលរដ្ឋ មិនត្រូវឆ្លងដែនរកការងារធ្វើនៅប្រទេសថៃនោះទេ ក្នុងកាលៈទេសៈនេះ ព្រោះវាអាចបង្កហានិភ័យ ខណៈក្នុងរយៈពេល ៦ ខែដើមឆ្នាំនេះ ការបង្ក្រាបការជួញដូរមនុស្សពីសមត្ថកិច្ចកម្ពុជា បានកើនឡើងខ្ពស់ដែលមានជិត ២០០ ករណី បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំមុនគឺមានត្រឹមតែជាង ៦០ ករណីប៉ុណ្ណោះ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីម្សិលមិញថាៈ «ក្នុង ៦ ខែដើមឆ្នាំ ២០២០ អាហ្នឹងមាន ៦៣ ករណី ហើយដល់ពេលមកដល់ឆ្នាំ ២០២១ គឺ ៦ ខែដើមឆ្នាំដូចគ្នាហ្នឹង មាន ១៩៨ ករណី។ បើនិយាយពីការងារដែលយើងធ្វើហ្នឹងច្រើន»។ លោកស្រីបញ្ជាក់ថា ខណៈពលករចំណាកស្រុកជាច្រើននាក់បានវិលត្រឡប់ពីប្រទេសថៃមកកម្ពុជាវិញ ក៏មានពលរដ្ឋកម្ពុជាមួយចំនួនត្រូវបានមេខ្យល់នាំឆ្លងដែនខុសច្បាប់ទៅប្រទេសថៃវិញផងដែរ ដែលធ្វើឱ្យពួកគេទទួលរងនូវការបោកប្រាស់ពីឈ្មួញ។ លោកស្រី ជូ ប៊ុនអេង បានបន្តថាៈ «ប៉ុន្តែមានន័យថាគឺជាមុខរបររបស់ឈ្មួញដែលគាត់ជួញដូរមនុស្សហ្នឹងហើយ ដោយសារតែពួកគាត់ហ្នឹងឆ្លៀតឱកាសដោយនឹកឃើញថា ប្រហែលជារដ្ឋាភិបាលហ្នឹង ព្រងើយកន្តើយហើយ [ព្រោះ] ជាប់ដៃជាមួយនឹងកូវីដអ៊ីចឹង។ ប៉ុន្តែការពិតទៅ យើងមិនបានបោះបង់ការងារហ្នឹងទេ»។ លោកស្រីបញ្ជាក់ថា ការបង្ក្រាបការនាំចេញមនុស្សឆ្លងដែនដោយមិនស្របច្បាប់ទៅកាន់ប្រទេសថៃនេះ មានចំនួនច្រើនជាងគេគឺ ១២១ ករណី។

កាលពីមុនអំពើជួញដូរមនុស្សភាគច្រើនត្រូវបានរាយការណ៍ពីជនរងគ្រោះពីក្រៅប្រទេសមកវិញ ប៉ុន្តែនៅពេលនេះពលរដ្ឋកម្ពុជាមិនអាចធ្វើដំណើរឆ្លងដែនទៅកាន់ប្រទេសជិតខាងបានទេ ដោយសារមានការបិទព្រំដែនដើម្បីបង្ការជំងឺកូវីដ ១៩។ លោកស្រី រដ្ឋលេខាធិការ បានបន្ថែមថាៈ «យើងបង្ក្រាបដើម្បីបង្ការកុំឱ្យគាត់ចេញដោយសារតែនៅក្នុងដំណាក់កាលនេះគឺប្រទេសជិតខាងគេបានបិទព្រំដែននៅក្នុងរឿងកូវីដហើយ។ អ៊ីចឹងប្រសិនបើយើងចេញក្នុងពេលនេះគឺគ្មានសុវត្ថិភាពទេ»។ លោកស្រីបញ្ជាក់ទៀតថា ក្នុងរយៈពេល ៦ ខែដើមឆ្នាំនេះសាលាដំបូងរាជធានី ខេត្ត បានធ្វើការពាក់ព័ន្ធអំពើជួញដូរមនុស្សជាង ៤០០ ករណី ហើយចំណាត់ការរបស់ចៅក្រមស៊ើបសួរលើអំពើជួញដូរនេះ មានជាង ៣០០ ករណី ខណៈការសម្រេចក្តីចុងក្រោយរបស់តុលាការមានជាង ២០០ ករណី។ ជាមួយគ្នានេះ លោកស្រី ជូ ប៊ុនអេង បានអំពាវនាវដល់ប្រជាពលរដ្ឋក្នុងដំណាក់កាលនៃការរាតត្បាតជំងឺរាតត្បាតនេះ មិនគួរសម្រេចចិត្តឆ្លងដែនដោយខុសច្បាប់ទៅកាន់ប្រទេសថៃនោះទេ ព្រោះវាមិនមែនជាឱកាសល្អនោះទេ។

វានឹងនាំឱ្យពួកគេមិនអាចសម្រេចបានគោលដៅ អាចចាញ់បោកមេខ្យល់ ខាតបង់ពេលវេលា និងប្រាក់កាស ពិសេសហានិភ័យឆ្លងជំងឺកូវីដ ១៩។ លោកស្រីបានបន្តថា ប្រសិនបើមានមេខ្យល់នាំប្រជាពលរដ្ឋចេញទៅកាន់ប្រទេសថៃ ហើយត្រូវការប្រាក់ជាមុនជាថ្នូរនឹងផលប្រយោជន៍ផ្សេងៗ ទោះបីក្នុងមធ្យោបាយណាក៏ដោយនៅក្នុងដំណាក់កាលបច្ចុប្បន្ននេះប្រជាពលរដ្ឋភាគច្រើននឹងត្រូវបានឆបោកដោយមេខ្យល់។ លោកស្រី ជូ ប៊ុនអេង បានបន្ថែមទៀតថាៈ «ក្នុងករណីកន្លងមកហ្នឹង គឺមានមេខ្យល់ដែលនាំយកទៅបោះចោលនៅតាមព្រំដែនហ្នឹងមិនតិចទេ ហើយក៏មានមេខ្យល់ជាជនជាតិគេទៅទៀត ជាជនជាតិថៃហ្នឹងដែលមកយកប្រជាពលរដ្ឋខ្មែរទៅហ្នឹងគឺគេមកចាំទទួលនៅទល់ដែន។ អ៊ីចឹងដល់ពេលយកទៅ យកទៅដាក់ចោល។ មានបញ្ហាខ្លះដាក់ចោលក្នុងវត្ត តាមព្រៃ រួចហើយប៉ូលិសមកចាប់ទៅ»។ ទីបំផុត គេចាប់មេខ្យល់មិនដែលបាន ខាងគេ [ថៃ] ហ្នឹង»។

លោក អំ សំអាត នាយករងទទួលបន្ទុកកម្មវិធីឃ្លាំមើលនៃអង្គការលីកាដូប្រាប់ភ្នំពេញ-ប៉ុស្តិ៍កាលពីម្សិលមិញថា លោកទទួលស្គាល់អាជ្ញាធរមានការបង្ក្រាប និងទប់ស្កាត់លើការជួញដូរមនុស្សបានច្រើនករណី ប៉ុន្តែបញ្ហានេះនៅតែជាកង្វល់ និងក្ដីបារម្ភនៅឡើយ ព្រោះក៏វាអាចនឹងបន្តកើតមានតទៅទៀតដែរ។ លោកបានថ្លែងថា៖ «អ៊ីចឹងធ្វើយ៉ាងម៉េច កម្ពុជាយើងត្រូវតែពង្រឹងបន្ថែមនូវកិច្ចការពារ និងការបង្ក្រាបទៅលើការជួញដូរមនុស្សនេះ។ នៅក្នុងប្រទេសយើងគឺត្រូវតែមានការផ្សព្វផ្សាយ និងការអប់រំបន្ថែមសម្រាប់ប្រជាពលរដ្ឋដើម្បីឱ្យមានការយល់ដឹងអំពីការជួញដូរមនុស្ស ហើយរួមគ្នាក្នុងការទប់ស្កាត់ និងបង្ការពីការជួញដូរមនុស្ស»។ លោក អំ សំអាត ថ្លែងថា អាជ្ញាធរត្រូវពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធការជួញដូរមនុស្សដោយត្រូវបង្ក្រាប និងស្វែងរកចាប់ខ្លួនជនដែលពាក់ព័ន្ធនឹងការជួញដូរមនុស្សមកអនុវត្តតាមផ្លូវច្បាប់ទោះបីអ្នកប្រព្រឹត្តមានឋានន្តរស័ក្តិ ឬអ្នកណាក៏ដោយ។ លោកបានបញ្ជាក់ថា៖ «កម្ពុជាត្រូវតែបង្កើនកិច្ចប្រតិបត្តិការជាមួយនឹងបណ្ដាប្រទេសជិតខាងបន្ថែមទៀតដើម្បីទប់ស្កាត់ក្នុងការឆ្លងដែនឬក៏ជាមួយនឹងបណ្ដាប្រទេសនៅក្នុងតំបន់អាស៊ានក៏ដូចជាបណ្ដាប្រទេសមួយចំនួនទៀត»៕

## ១ថ្ងៃរកឃើញឆ្លងថ្មី៩៧នាក់ ពលករពីថៃ៧៨នាក់ និងស្លា.ប់កើន៦៨នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey២២ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៤:៤៩

ខេត្តបន្ទាយមានជ័យ ៖ រយៈពេល១ថ្ងៃ ករណីឆ្លងកូវីដ១៩ នៅក្នុងសហគមន៍ មានចំនួន៩៧នាក់ និងពលករត្រឡប់ពីថៃចំនួន៧៨នាក់ ចំណែកអ្នកស្លា.ប់ដោយសារកូវីដ១៩ បានកើនឡើងដល់៦៨នាក់ នេះបើគិតត្រឹមរហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ នៅខេត្តបន្ទាយមានជ័យ។

លោក លី សុវណ្ណារិទ្ធ អភិបាលរងខេត្តបន្ទាយមានជ័យ បានប្រាប់ថា នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ នៅខេត្តបន្ទាយមានជ័យ រកឃើញអ្នកវិជ្ជមានកូវីដ១៩ ក្នុងសហគមន៍មានចំនួន៩៧នាក់ ក្នុងនោះស្រី៥៣នាក់ និងពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ ក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ រកឃើញវិជ្ជមានកូវីដ១៩ចំនួន៧៨នាក់ ក្នុងនោះស្រី៣៩នាក់ ចំណែកអ្នកស្លា.ប់ដោយសារវិជ្ជមានកូវីដ១៩ មានបានកើងឡើងរហូតដល់៦៨នាក់ហើយ។ លោកបានបញ្ជាក់ថា នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ នេះពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកម្ពុជាវិញ តាមច្រកអូរបើជាន់ស្រុកអូរជ្រៅ មានចំនួន២៣២នាក់ ក្នុងនោះស្រី១១១នាក់ ដែលក្រុមការងារទទួលពិនិត្យសុខភាព និងយកសំណាកធ្វើតេស្តរកមេរោគកូវីដ១៩ ជាលទ្ធផលមានវិជ្ជមានកូវីដ១៩ ចំនួន៧៨នាក់ ក្នុងស្រី៣៩នាក់ ។ ចំណែកប្រជាពលរដ្ឋខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជាវិញ តាមច្រកក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានចំនួន៨៨.៩០៣នាក់ ក្នុងនោះស្រី៤០.១៣១នាក់។

លោក លី សុវណ្ណារិទ្ធ បានបញ្ជាក់ថា នៅក្នុងព្រឹត្តិការណ៍ ២០កុម្ភៈ ឆ្នាំ២០២១នេះ អ្នកវិជ្ជមានកូវីដ១៩ សរុបមានចំនួន៨.៧៤២នាក់ ក្នុងនោះស្រី៤.៣៦០នាក់, ជាសះស្បើយដោយកូវីដ១៩ មានចំនួន៦,០៤៨នាក់ ក្នុងនោះស្រី៣.០៤៦នាក់ និងអ្នកវិជ្ជមានកូវីដ១៩ ដែលកំពុងសម្រាកព្យាបាលមានចំនួន២.៦២៨នាក់ ក្នុងនោះស្រី១.២៧០នាក់ រីឯអ្នកដែលស្លា.ប់ដោយសារកូវីដ១៩ បានកើនឡើងរហូតដល់៦៨នាក់ ក្នុងនោះស្រី៣២នាក់ (ស្លា.ប់ក្រៅមន្ទីរពេទ្យមានចំនួន៧នាក់ ដែលមានជនជាតិបរទេសមានចំនួន៥នាក់ ស្រី២នាក់ មានជនជាតិថៃ២នាក់ និងជនជាតិឥណ្ឌូនេស៊ីមានចំនួន៣នាក់)៕

## លោក កុយ កួង៖ រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ ដល់ពលករខ្មែរ នៅថៃ ឆ្លងជំងឺកូវីដ១៩

https://dap-news.com/national/ ByPH104Posted on July 22, 2021

**ភ្នំពេញ ៖ អ្នកនាំពាក្យ ក្រសួងការបរទេសខ្មែរ លោក កុយ គួង បានលើកឡើងថា គិតត្រឹមថ្ងៃនេះ មិនទាន់មានតួលេខផ្លូវការ ច្បាស់លាស់ អំពីចំនួនពលករខ្មែរ នៅប្រទេសថៃ ឆ្លងជំងឺកូវីដ១៩ នៅឡើយទេ ប៉ុន្តែទោះមិនទាន់ដឹង ផ្លូវការ យ៉ាងណាក៏ដោយ ក៏ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានឲ្យភាគីពាក់ព័ន្ធទាំងនៅខ្មែរ និងថៃ យកចិត្តទុកដាក់លើពួកគេ** ។ លោកថា ការយកចិត្តទុកដាក់នេះ គឺបានផ្តល់គ្រឿងឧបភោគបរិភោគ កន្លែងស្នាក់នៅ និងជួយឲ្យជំរុញឲ្យ បានចាក់វ៉ាក់សាំងជាដើម ។ ការថ្លែងរបស់លោក កុយ គួង នេះក្រោយពីវិទ្យុអាស៊ីសេរីកាលពីថ្ងៃ១៩ កក្កដា បាន ផ្សាយថា "ពលករខ្មែរឆ្លងជំងឺកូវីដ១៩ នៅប្រទេសថៃមួយចំនួន បន្តដង្ហោយហៅរដ្ឋាភិបាល ជួយសង្គ្រោះអាយុជីវិត" ។ លោក កុយ គួង បានប្រាប់មជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល តាមប្រព័ន្ធតេឡេក្រាម នៅថ្ងៃ២២ កក្កដា យ៉ាងដូច្នេះ ថា "រាជរដ្ឋាភិបាលតាមរយៈក្រសួង ការបរទេស បានជំរុញស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជា នៅប្រទេសថៃឲ្យ បន្តសម្របសម្រួល ជាមួយអាជ្ញាធរថៃ ជាពិសេសក្រសួងការបរទេស ក្រសួងសុខាភិបាល ក្រសួងការងារថៃ និងមជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ១៩ (CCSA) សុំអន្តរាគមន៍ ដើម្បីបន្តយកចិត្តទុកដាក់ ថែរក្សា ទទួលការចាក់វ៉ាក់សាំង និងព្យាបាលកូវីដ១៩ បើមានសភាពធ្ងន់ធ្ងរខ្លាំង ដូចជាការពន្លឿនការរកគ្រែ និងឡានពេទ្យមកទទួល ពលករខ្មែរដែលឆ្លងកូវីដ-១៩ ទៅព្យាបាលទាន់ពេលវេលា" ។

លោកបន្តថា ក្រសួងបានជំរុញឲ្យស្ថាន អគ្គកុងស៊ុលកម្ពុជា នៅទីនោះបន្តចុះសួរសុខទុក្ខ និងចែកអំណោយជាគ្រឿង ឧបភោគបរិភោគ ជូនពលករក្នុង ពេលមានការបិទខ្ទប់តាមលទ្ធភាព និង ស្ថានភាពជាក់ស្តែងដល់បងប្អូន ដែលជួបការលំបាកខ្លាំងបំផុត និងបន្ថែមទៅលើអ្វីដែលអាជ្ញាធរ និងនិយោជកបានជួយគាំពារ និងឧបត្ថម្ភរួចហើយដែរ ។ ជាពិសេសបន្តផ្សព្វផ្សាយ វិធានការនានា ដែលដាក់ចេញដោយបណ្តាក្រសួង/ស្ថាប័ន នៃរាជរដ្ឋាភិបាលទាំងពីរកម្ពុជា និងថៃ ដើម្បីទប់ស្កាត់ជំងឺកូវីដ-១៩ ព្រមទាំងផ្តល់ការប្រឹក្សា ផ្តល់កម្លាំងចិត្ត និងបន្តអំពាវនាវដល់បងប្អូនពលករខ្មែរ ឲ្យចូលរួមអនុវត្តវិធានការ ទាំងនេះដោយអត់ធ្មត់ និងខ្ជាប់ខ្ជួន ។ លោក កុយ គួង បន្ថែមថា លើសពីនេះក៏បានជំរុញ ឲ្យអគ្គកុងស៊ុលកម្ពុជា បន្តផ្សព្វផ្សាយការអប់រំអំពី ការថែទាំសុខភាពក្នុងអំឡុង ការផ្ទុះការរាតត្បាត ជំងឺកូវីដ-១៩ ដើម្បីឲ្យប្រយ័ត្នការពារ ថែរក្សាសុខភាពផ្ទាល់ខ្លួន ។ បន្តកិច្ចការជាប្រចាំផ្សេងទៀតរបស់ស្ថានទូត និងស្ថានអគ្គកុងស៊ុលដូចជា៖ ការដោះស្រាយវិវាទការងារ, ការជួយពលករដែលកើតឧប្បទ្ទវហេតុក្នុងពេលធ្វើការ, ការជួយរកការងារថ្មីសម្រាប់ អ្នកបាត់បង់ការងារ, ការសម្រួលផ្តល់ឯកសារចាំបាច់ផ្សេងៗ ។

សូមរំលឹកថា នៅក្នុងប្រទេសថៃ មានពលករជាង ៩ពាន់នាក់ បានឆ្លងកូវីដ១៩ ប៉ុន្តែពួកគាត់ថា ពុំសូវត្រូវបានយកចិត្តទុកដាក់ពីអាជ្ញាធរថៃ ស្របពេលដែលប្រទេសនេះ កំពុងជួបប្រទះរលកថ្មី នៃការឆ្លងរោគរាតត្បាតកូវីដ១៩ និងកូវីដបម្លែងថ្មីប្រភេទ Delta ៕

## ស្ថានទូតកម្ពុជានៅប្រទេសថៃ នាំយកអំណោយចែកជូនពលករខ្មែរ ចំនួន១៣០គ្រួសារ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២២ កក្កដា ២០២១ដោយ sopheak khoun

នាព្រឹកថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១នេះ ទោះបីជាប្រទេសថៃ បានចេញវិធានការរឹតបន្តឹងថ្មីដើម្បីទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ ជាពិសេសការធ្វើដំណើរឆ្លងតំបន់ ឬខេត្តក៏ដោយ ក៏ស្ថានទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសថៃបាននាំយកអំណោយ ដែលមានគ្រឿងឧបភោគបរិភោគ ចុះចែកដល់បងប្អូនពលករខ្មែរចំនួន១៣០គ្រួសារ នៅទីតាំងចំនួន២កន្លែង។ នេះបើតាមការបញ្ជាក់ពីស្ថានទូត នារសៀលថ្ងៃទី២២ ខែកក្កដានេះ។ បើតាមស្ថានទូត ទី១- នៅការដ្ឋានសំណង់ស្ថិតនៅសង្កាត់ចមកុន ខណ្ឌចតុចក្រ ក្រុងបាងកក មានបងប្អូនពលករខ្មែរចំនួន៩០គ្រួសារ។ ទី២- ការដ្ឋានសំណង់ស្ថិតនៅឃុំបាងភ្លីយ៉ៃ ស្រុកបាងភ្លី ខេត្តសមុទ្រប្រាកាន មានពលករខ្មែរចំនួន ៤០គ្រួសារ។

សូមបញ្ជាក់ថា ការចុះចែកអំណោយនេះ គឺបានការចូលរួមសហការ និងជួយសម្រួលពីអាជ្ញាធរពាក់ព័ន្ធថៃ រួមមានតំណាងខាងសុខាភិបាលថៃ និងក្រសួងការងារថៃ ដោយអនុវត្តតាមវិធានការរបស់សុខាភិបាលក្នុងការការពារ និងទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ យ៉ាងខ្ជាប់ខ្ជួន៕ (ដោយ)៖ កោះកែវ

## អង្គការសង់ត្រាល់ រកឃើញពលករខ្មែរនៅថៃប្រមាណ ៩ ០០០ នាក់ បានឆ្លងជំងឺកូវីដ ១៩

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 22 July 2021 | 12:23 ICT

**ភ្នំពេញៈ** មន្ត្រីឃ្លាំមើលសិទ្ធិការងារ (សង់ត្រាល់) ប្រចាំប្រទេសថៃ បានឲ្យដឹងថាគិតមកទល់ពេលនេះចំនួនពលករខ្មែរដែលបានឆ្លងជំងឺកូវីដ ១៩ នៅប្រទេសថៃ មានប្រមាណ ៩០០០នាក់ ខណៈចំនួនឆ្លងសរុបក្នុងប្រទេសនេះពី ១ ថ្ងៃ ទៅ ១ ថ្ងៃ មានការកើនឡើងរហូតដល់ខ្ទង់ម៉ឺននាក់។

លោក លឹម សុផុន ជាក្រុមការងារនៃអង្គការសង់ត្រាល់ប្រចាំប្រទេសថៃ បានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ នៅថ្ងៃទី ២២ កក្កដានេះថា បងប្អូនពលករខ្មែរបានឆ្លងកូវីដ ១៩ នៅប្រទេសថៃ គឺមានប្រមាណ ៩ ០០០ នាក់។ លោកបានអះអាងថា តួលេខនេះគឺយោងតាមការប្រកាសរបស់ក្រសួងសុខាភិបាលថៃ ដែលបានធ្វើបច្ចុប្បន្នភាព ចំពោះអ្នកឆ្លងនៅក្នុងប្រទេសនេះសរុបមកទល់ពេលនេះ ។ លោកបានរៀបរាប់ថា៖ «ទាំងនេះ គឺចំនួនបងប្អូនខ្មែរយើងឆ្លងនៅថៃ ជាពិសេសគឺបងប្អូនពលករខ្មែរ។ សម្រាប់ចំនួនទូទៅដែលឆ្លងក្នុងប្រទេសថៃ គឺមានការឆ្លងកាន់តែច្រើនក្នុង ១ ថ្ងៃៗឆ្លងរហូតដល់ជាង១ម៉ឺននាក់ ខណៈរដ្ឋាភិបាលប្រកាសបិទមិនឲ្យមានការចរាចរដល់ទៅ ១០ ខេត្ត ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ ១៩»។ លោក លឹម សុផុន ដែលបានតាមដានស្ថានការណ៍ពលករខ្មែរនៅប្រទេសថៃ ជាប់ជាប្រចាំ បានបញ្ជាក់ថាការដ្ឋាននៅទីក្រុងបាងកក និងខេត្តជុំវិញនេះចំនួន ១០ ខេត្ត គឺត្រូវរដ្ឋាភិបាលថៃប្រកាសបិទខ្ទប់។ ស្ថានការណ៍នេះ បានធ្វើឲ្យពលករខ្មែរក៏ប្រឈមនឹងបញ្ហាលំបាកផងដែរ ជាពិសេសពលករដែលរស់នៅ និងធ្វើការខុសច្បាប់។

លោកបានបញ្ជាក់ថា៖ «ក្នុងអំឡុងពេលបិទបងប្អូននេះ រដ្ឋាភិបាលថៃក៏បានប្រកាសផ្តល់ប្រាក់ឧបត្ថម្ភដល់ពលករដែលតម្រូវឱ្យផ្អាកការងារប្រមាណ៧ពាន់បាត ក្នុង ១ ខែ រួមជាមួយនឹងស្បៀងអាហារមួយចំនួនផងដែរ។ ប៉ុន្តែយ៉ាងណា ការផ្តល់ប្រាក់ឧបត្ថម្ភទាំងនេះ គឺទទួលបានសម្រាប់តែពលករដែលធ្វើការស្របច្បាប់ប៉ុណ្ណោះ»។ លោកបានបន្តថា៖ «ចំណែកពលករដែលរស់នៅនិងធ្វើការដោយខុសច្បាប់ គឺមិនត្រូវទទួលបានអត្ថប្រយោជន៍ទាំងនេះទេ ដូច្នេះខ្ញុំរំពឹងថា រដ្ឋាភិបាលខ្មែរ នឹងបន្តពិភាក្សាបន្តទៀត ជាមួយរដ្ឋាភិបាលថៃ ដើម្បីជួយដល់ពលករខ្មែរដែលកំពុងប្រឈមនឹងបញ្ហាទាំងនេះ»។

តាមតួលេខដែលប្រកាសពីប្រទេសថៃ ក្នុង ១ ថ្ងៃ ប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសនេះបានឆ្លងជំងឺកូវីដ ១៩ ដល់ទៅរាប់ម៉ឺននាក់ និងស្លាប់ដល់ទៅជិត ១០០ នាក់ ខណៈខេត្តដែលផ្ទុះជំងឺនេះ មិនមានកន្លែងដាក់អ្នកជំងឺនោះទេ ជាហេតុនាំឲ្យអ្នកជំងឺគ្មានកន្លែងព្យាបាលនិងត្រូវរង់ចាំកន្លែងព្យាបាលនៅខាងក្រៅមន្ទីរពេទ្យ។ នេះបើតាមមន្ត្រីឃ្លាំងមើលសិទ្ធិការងារខាងលើ៕

## អាជ្ញាធរខេត្តប៉ៃលិន ត្រៀមខ្លួនជាស្រេច ក្នុងការទទួលពលករឆ្លងដែនពីប្រទេសថៃ

https://kohsantepheapdaily.com.kh/ ២២ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២៣:០៨

ខេត្តប៉ៃលិន៖ សេចក្តីរាយការណ៍ពីព្រំដែនកម្ពុជា-ថៃ បានឱ្យដឹងថា ក្នុង១ថ្ងៃៗ ពលករឆ្លងដែនពីប្រទេសថៃចូលមកក្នុងប្រទេសកម្ពុជា តាមច្រកទ្វារអន្តរជាតិព្រំ ក្នុងភូមិផ្សារព្រំ ឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន មិនតិចជាង ៤០ ទៅ ៥០នាក់នោះឡើយ ដោយមានថ្ងៃខ្លះ ឡើងរហូតដល់ ៧០នាក់ ទៅ ៨០នាក់ឯណោះ។ ភាគច្រើន ពលករទាំងនោះ មិនត្រឹមតែជាពលរដ្ឋរស់នៅក្នុងខេត្តប៉ៃលិននោះឡើយ គឺមកពីតាមបណ្តាខេត្តនានាក្នុង

ប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ អាជ្ញាធរខេត្ត ត្រៀមខ្លួនជាស្រេច ក្នុងការទទួលពួកគាត់ឱ្យចូលកន្លែងធ្វើចត្តាឡីស័ក ដើម្បីពិនិត្យរកមើលវីរុសកូវីដ ១៩ លុះធ្វើតេស្តហើសឃើញផ្ទុកមេរោគនេះ ក្រុមគ្រូពេទ្យ រៀបចំបញ្ជូនទៅកន្លែងព្យាបាល ដែលបានរៀបចំទុកជាស្រេច។

ជាក់ស្តែង នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១នេះ មានពលករឆ្លងដែនពីប្រទេសថៃ ប្រមាណ ៥០ ទៅ ៦០ នាក់ កំពុងនាំគ្នា ចូលមកក្នុងប្រទេសកម្ពុជា ខណៈនៅទីនោះ មានការផ្ទុះឡើងនៃជំងឺកូវីដ ១៩ គួរឱ្យព្រួយបារម្ភ។ ទោះបីជាយ៉ាងណា ក្រុមគ្រូពេទ្យ ក្រុមយុវជន ស.ស.យ.ក ខេត្ត និងមន្ត្រីប្រចាំការ នៅតាមគោលដៅ ច្រកទ្វារ និងច្រករបៀង មិនបណ្តែតបណ្តោយឱ្យពលករណាម្នាក់ របូតចូលមកក្នុងខេត្តប៉ៃលិន ដោយមិនបានពិនិត្យ ឱ្យបានដិតដល់នោះឡើយ។ ប្រភពព័ត៌មាន បានឱ្យដឹងថា តាំងពីព្រឹករហូតមកដល់រសៀលថ្ងៃដដែល មានពលករឆ្លងដែនមកពីប្រទេសថៃ ចូលក្នុងប្រទេសកម្ពុជា ប្រមាណ ៥២នាក់ ក្នុងនោះ អ្នករស់នៅខេត្តបាត់ដំបង ចំនួន ២១នាក់ (ស្រី ៨នាក់ ក្មេង ៤នាក់) អ្នករស់នៅខេត្តបន្ទាយមានជ័យ ចំនួន ១៨នាក់ (ស្រី ៩នាក់ ក្មេង ៣នាក់) អ្នករស់នៅខេត្តកំពង់ស្ពឺម្នាក់ អ្នករស់នៅខេត្តព្រៃវែង ៧នាក់ (ស្រីម្នាក់) អ្នករស់នៅខេត្តក្រចេះ ៣នាក់ (ស្រីម្នាក់ ក្មេង ២នាក់) និងអ្នករស់នៅខេត្តប៉ៃលិន ២នាក់ (ស្រីម្នាក់) រកឃើញបុរសម្នាក់ រស់នៅក្នុងខេត្តប៉ៃលិន មានផ្ទុកវីរុសកូវីដ ១៩។

ប្រភពព័ត៌មានពីឯកឧត្តម ហុក សុផល អភិបាលរងខេត្តប៉ៃលិន និងជាប្រធាន អនុគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ ១៩ ប្រចាំការច្រកទ្វារអន្តរជាតិព្រំ និងច្រករបៀង បានបញ្ជាក់ថា ក្នុង ១ថ្ងៃៗ ពលករឆ្លងដែនពីប្រទេសថៃ ចូលមកក្នុងទឹកដីខេត្តប៉ៃលិន មិនក្រោម ៥០នាក់នោះឡើយ ហើយរដ្ឋបាលខេត្តប៉ៃលិន ត្រៀមខ្លួនជាស្រេច ក្នុងការទទួលពួកគាត់ ដាក់នៅកន្លែងចត្តាឡីស័ក រួចពិនិត្យព្យាបាល ក្នុងករណីរកឃើញវីរុសកូវីដ ១៩។ តែអ្នកដែលមិនទាន់រកឃើញ គឺឱ្យស្នាក់នៅ ធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃសិន ទើបអនុញ្ញាតឱ្យទៅស្រុកកំណើតរបស់ខ្លួន។ ឯកឧត្តមបញ្ជាក់ថា ទោះបីជាពលករ រស់នៅខេត្តណាក៏ដោយ គឺអាជ្ញាធរខេត្តប៉ៃលិន ជាអ្នកទទួលខុសត្រូវ ដោយយកពួកគាត់ ទៅដាក់នៅកន្លែង ដែលបានរៀបចំថ្មីៗ បន្ថែមទៀត ហើយក៏មានអ្នកជាសះស្បើយចេញទៅស្រុកកំណើតជាបណ្តើរៗ និងមានពលករមកពីប្រទេសថៃ ជាបន្តបន្ទាប់ផងដែរ។ ទោះបីជាយ៉ាងណា ក្រុមគ្រូពេទ្យ និងមន្ត្រីជំនាញ នៅតែផ្លាស់ប្តូរវេណគ្នា ប្រចាំការជាប់ជានិច្ច មិនរអ៊ូរទាំ ឬត្អូញត្អែរនោះឡើយ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺដ៏កាចសាហាវមួយនេះ ចូលក្នុងសហគមន៍៕ នីយ៉ា

## ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១

### ផ្សព្វផ្សាយជំងឺកូវីដ១៩ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១

(ភ្នំពេញ)៖ នាព្រឹកថ្ងៃនេះ នៅសាលាសង្កាត់ឃ្មួញ ខណ្ឌសែនសុខ សាខាកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE ) ចុះអប់រំផ្សព្វផ្សាយពីវិធីកាត់បន្ថយហានិភ័យពីការឆ្លងជំងឺកូវីដ១៩ និងវិធានការបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។ គោលបំណង នៃការចុះអប់រំផ្សព្វផ្សាយ ដើម្បីអប់រំផ្សព្វផ្សាយជូនដល់ពួកគាត់ឲ្យកាន់តែយល់ច្បាស់ថែមទៀតពីជំងឺកូវីដ១៩ និងបន្តអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣ ការពារ និង ៣ កុំ របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សំដៅចូលរួមប្រយុទ្ធប្រឆាំងទប់ស្កាត់ការរីករាលដាលជំងឺឆ្លងកូវីដ១៩ ទាំងអស់គ្នា។ ចំណុចមួយទៀត បញ្ច្រាប និងចែករំលែកនូវចំណេះដឹងពីសិទ្ធិកុមារ ការរំលោភបំពាន របៀបរាយការណ៍ និងវិធានការបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ៕

## ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកជំងឺកូវីដ ចំនួន១៦៥នាក់ ក្នុងនោះជាពលករមកពីប្រទេសថៃ ចំនួន១៤៧នាក់

http://freshnewsasia.com/ 2021-07-23 09:30pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១នេះ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន១៦៥ករណីបន្ថែមទៀត តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) ខណៈមិនមែនអ្នកជាសះស្បើយ។ បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ ដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅថ្ងៃទី២២ ខែកក្កដានេះ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង១៦៥នាក់ ក្នុងនោះអ្នកជំងឺចំនួន ០៥នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និងចំនួន ១៤៧នាក់ទៀត ជាពលករទើបមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងចំនួន១៣នាក់ទៀត ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៣ ខែកក្កដានេះ ខេត្តឧត្តរមានជ័យ បានរកឃើញជំងឺកូវីដ១៩ ចំនួន ៣,៦៥២ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ៣,៣៨៤ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន ២៦៨ករណី បានព្យាបាលជាសះស្បើយចំនួន ៦២២នាក់ កំពុងសម្រាកព្យាបាលចំនួន ៣,០២២នាក់ និងស្លាប់បាត់បង់ជីវិត ៨នាក់ផងដែរ៕

## លោក នេត សាវឿន ស្នើឱ្យប៉ុស្តិ៍ច្រកទ្វារព្រំដែន ត្រូវគ្រប់គ្រងឱ្យបាននូវបញ្ជីពលករ ពីក្រៅប្រទេស និងអ្នកបើកបររថយន្ត

https://postkhmer.com/national/ មុំ គន្ធា | Publication date 23 July 2021 | 18:30 ICT

**ភ្នំពេញ៖** លោក នេត សាវឿន អគ្គស្នងការនគរបាលជាតិ និងជាអនុប្រធានគណៈប្រតិបត្តិ នៃគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ (គ.អ.ក) ទទួលបន្ទុកអនុគណៈកម្មការច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក បានស្នើឱ្យប៉ុស្តិ៍ច្រកទ្វារព្រំដែនទ្វេភាគី និងអន្តរជាតិ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ត្រូវគ្រប់គ្រងឱ្យបាន នូវបញ្ជីពលករចំណូលស្រុកពីក្រៅប្រទេស អ្នកបើកបររថយន្ត ស្លាកលេខរថយន្ត និងអាសយដ្ឋានទំនាក់ទំនងឱ្យបានត្រឹមត្រូវ។

ការស្នើដូចនេះ ធ្វើឡើងនៅក្នុងកិច្ចប្រជុំដកពិសោធន៍ការងារគ្រប់គ្រងស្ថានការណ៍កូវីដ១៩ របស់អនុគណៈកម្មការ គ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក នៅតាមបណ្តាខេត្តជាប់ព្រំដែន នាថ្ងៃទី២៣ ខែកក្កដានេះ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើនរូប។ កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំប្រមូលផ្តុំអំពីស្ថានការណ៍ក្នុងការអនុវត្តការងារបង្ការ ទប់ស្កាត់ ការឆ្លងរាលដាល នៃជំងឺកូវីដ១៩ ដោយប្រមូលផ្តុំធាតុចូលទាំងចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងសំណូមពរ ដើម្បីយកជាមូលដ្ឋានកែលម្អផែនការសកម្មភាព និងចាត់វិធានការបំពេញបន្ថែម សំដៅចូលរួមបង្ការ ទប់ស្កាត់ និងកាត់ផ្តាច់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ ពិសេសបង្ការ ទប់ស្កាត់ការផ្ទុះក្នុងសហគមន៍នូវជំងឺកូវីដ១៩ បំប្លែងថ្មី Delta។

លោក នេត សាវឿន បានលើកឡើងថា លេខាធិការដ្ឋាន នៃអនុគណៈកម្មការច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ត្រូវបូកសរុបបញ្ហាប្រឈម និងសំណូមពររបស់អង្គប្រជុំ ដាក់ជូនគណៈកម្មការអន្តរក្រសួង ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ពិនិត្យដោះស្រាយ។ លោកបានបន្តថា៖ «យើងត្រូវរួមគ្នាទាំងការងារដឹកនាំ កម្លាំង ធនធាន មធ្យោបាយ សម្ភារ ក្នុងការដោះស្រាយ ដើម្បីចូលរួមបង្ការ ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងពិសេសការពារប្រកបដោយ ប្រសិទ្ធភាព លើការនាំចូលឆ្លងរាតត្បាតនូវមេរោគបំប្លែងថ្មី Delta»។

ក្នុងកិច្ចប្រជុំនេះ ក៏មានការចូលរួមពី លោក ហ៊ុន ម៉ានិត អគ្គនាយកនៃអគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ច ក្រសួងការពារជាតិ និងជាអនុប្រធានអនុគណៈកម្មការច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក និងលោក

ហ៊ិន ម៉ាណែត អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក និងជាអនុប្រធានគណៈប្រតិបត្តិ (គ.អ.ក) បានចូលរួមផ្ដល់យោបល់បំពេញបន្ថែម សំដៅជំរុញឱ្យការអនុវត្តភារកិច្ចរបស់អនុគណៈកម្មការគ្រប់គ្រងច្រកទ្វារចេញ-ចូលប្រទេស និងការធ្វើចត្តាឡីស័ក ឱ្យមានដំណើរការកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត៕

## ត្រៀមយកវិទ្យាល័យអន្លង់វិល ជាទីតាំងធ្វើចត្តាឡីស័កសម្រាប់ពលករមកពីប្រទេសថៃ

https://www.kampucheathmey.com/ 24/07/2021

លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបង រួមជាមួយមន្ត្រីនៃមន្ទីរពាក់ព័ន្ធបានចុះពិនិត្យទីតាំងសាលាវិទ្យាល័យអន្លង់វិល ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ដើម្បីត្រៀមរៀបចំធ្វើជាមណ្ឌលចត្តាឡីស័ក ក្នុងការត្រួតពិនិត្យសុខភាពសម្រាករយៈពេលចំនួន១៤ថ្ងៃ ក្រោយពីបងប្អូនពលករបានវិលត្រឡប់ពីប្រទេសថៃវិញគឺត្រូវបញ្ជូនឲ្យមកកាន់មណ្ឌលចត្តាឡីស័កនៅទីនេះតែម្តង។ ក្នុងឱកាសចុះពិនិត្យនារសៀលថ្ងៃទី២៣ ខែកក្កដា លោក ងួន រតនៈ បានមានប្រសាសន៍ឲ្យដឹងថា ទីតាំងដែលត្រូវគ្រោងរៀបចំនេះ យ៉ាងហោចណាស់ចំនួន០៣ទីតាំងផ្សេងៗគ្នា ក្នុងស្រុកសង្កែសម្រាប់ត្រៀមទទួលបងប្អូនពលករក្រោយពីបានវិលត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែននានា ដូចជាខេត្តឧត្តរមានជ័យ និងខេត្តមួយចំនួនទៀត ក្រៅពីពលករចូលមកតាមច្រកនានា នៃខេត្តបាត់ដំបង។

លោក សុខ ហឿន អភិបាលស្រុកសង្កែ ក៏បានបញ្ជាក់ឲ្យដឹងដែរថា តាមតម្រូវការចាំបាច់របស់រដ្ឋបាលខេត្តអាជ្ញាធរស្រុកអាចផ្តល់ទីតាំង និងរៀបចំ ចំនួន៣កន្លែងដើម្បីធ្វើជាមណ្ឌលចត្តាឡីស័កសម្រាប់ត្រួតពិនិត្យសុខភាពពលករដែលវិលត្រឡប់ពីប្រទេសថៃ តាមច្រករបៀងនានា នៃខេត្តបាត់ដំបង និងពលករមកពីតាមបណ្តាខេត្តមួយចំនួនក្នុងការសម្រាកនៅរយៈពេល១៤ថ្ងៃ ដើម្បីត្រួតពិនិត្យសុខភាពយកវត្ថុសំណាកធ្វើតេស្តរកមេរោគកូវីដ-១៩ មុននឹងឲ្យវិលត្រឡប់ទៅកាន់លំនៅដ្ឋាន និងស្រុកកំណើតរបស់ខ្លួនវិញក្រោយពីធ្វើតេស្ត"អវិជ្ជមាន"។ លោកអភិបាលស្រុកបានបន្តថា ទីតាំងសាលារៀនដែលត្រូវរៀបចំមាន៣ទីតាំងផ្សេងគ្នាក្នុងស្រុកនេះយ៉ាងហោចណាស់អាចទទួលបងប្អូនពលករសរុបប្រមាណ១៣ន់នាក់ អាចមកសម្រាកក្នុងមណ្ឌលចត្តាឡីស័កដើម្បីអនុវត្តតាមវិធានការរយៈពេល១៤ថ្ងៃបានដោយមានផាសុខភាពល្អ ដើម្បីឲ្យក្រុមគ្រូពេទ្យតាមដានលើសុខភាពរបស់ពួកគេជាប្រចាំខណៈដែលពលករដែលត្រូវមកសម្រាកតាមដានរោគសញ្ញានៅទីនេះ គឺជាពលករចម្រុះដែលបានមកពីតាមបណ្តាខេត្តនានាក្រោយពួកគេបានវិលត្រឡប់មកពីប្រទេសថៃតាមច្រកព្រំដែនដែលស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យដែលនិងត្រូវបញ្ជូនមកកាន់ទីនេះផងដែរ៕ អត្ថបទ ៖ សៅ សារិទ្ធ

## ពលករខ្មែរម្នាក់ចេញពីប្រទេសថៃ អាការៈហត់ខ្លាំងមកដល់ប៉ុស្តិ៍ត្រួតពិនិត្យដេកស្លាប់ភ្លាមៗ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២៤ កក្កដា ២០២១ដោយ Dy Bunnara

បន្ទាយមានជ័យ៖ ពលករខ្មែរពីរនាក់ប្តីប្រពន្ធ បានឆ្លងដែនពីប្រទេសថៃចូលមកកម្ពុជា តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយបុរសជាប្តីបានស្លាប់នៅកន្លែងត្រួតពិនិត្យពលករ ដោយសារជំងឺកូវីដ១៩ នៅវេលាម៉ោង ៩ និង១០នាទីថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២១។ បើតាមអាជ្ញាធរ ពលករទាំងពីរនាក់ប្តីប្រពន្ធ ធ្វើការនៅខេត្តផាធុមថានីប្រទេសថៃរយៈពេល២ឆ្នាំមកហើយ។ ជនរងគ្រោះឈ្មោះ សៀន ឌុម ភេទប្រុស អាយុ៥២ឆ្នាំ (ពិការជើងទាំងសងខាង និងគោមខ្វង) រស់នៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ចំណែកប្រពន្ធឈ្មោះ យិន វ៉ាន់ អាយុ៥៦ឆ្នាំ ភេទស្រី រស់នៅភូមិឃុំជាមួយគ្នា។ បើតាមរបាយការណ៍ពីអាជ្ញាធរ បុរសជាប្តីមានអាការៈហត់ខ្លាំង ទើបបណ្តាលឲ្យស្លាប់ភ្លាមៗនៅកន្លែងក្រុមការងារចម្រុះច្រកអូរបីជាន់។

ក្រុមគ្រូពេទ្យបានយកសំណាកធ្វើតេស្តរហ័ស គឺមានវិជ្ជមានទាំង២នាក់ប្តីប្រពន្ធ។ សពត្រូវបានរថយន្តពេទ្យដឹកយកទៅភ្នំបាក់ ក្រុងសិរីសោភ័ណ ខេត្ត បន្ទាយមានជ័យដើម្បីបូជា៕ អត្ថបទ៖ ពៅ

## មេខ្យល់ ២នាក់លួចនាំពលករចេញទៅប្រទេសថៃខុសច្បាប់ ត្រូវបានឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ២៤ កក្កដា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ កម្លាំងការពារ វរសេនាតូច៩១១ កម្លាំងប៉ុស្តិ៍បឹងសាគូ សហការជាមួយកម្លាំងយោធាកងពល៥១ បានធ្វើការឃាត់ខ្លួនមេខ្យល់បាន២នាក់ បម្រុងនាំពលករទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ នៅវេលាម៉ោង៤.២៥ទៀបភ្លឺ ចូលថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ ២០២១ នៅចំណុចខាងមុខកាស៊ីណូDNA ភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយបែត ខេត្តបន្ទាយមានជ័យ។ វរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍បឹងសាគូ បានប្រាប់ឲ្យដឹងថា មេខ្យល់ទាំង២នាក់១ឈ្មោះ ឡូញ ឡែម ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិចាន់គិរី សង្កាត់ប៉ោយប៉ែត ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ២ឈ្មោះ សាន សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ រស់នៅភូមិប៉ោយប៉ែត សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

លោកបានបញ្ជាក់ឲ្យដឹងបន្តទៀតថា ក្រោយពីសមត្ថកិច្ចចំរុះឃាត់ខ្លួនធ្វើការសួរនាំ និងធ្វើការត្រួតពិនិត្យឃើញមានទូរសព្ទដៃ១គ្រឿង មានសារជាសម្លេងឆ្លើយឆ្លងគ្នា ចាំទទួលមនុស្សនៅខាងក្រោយផ្សារឡុងក្លឿប្រទេសថៃ និងមានម៉ូតូ១គ្រឿង ម៉ាកហុងដា C125 ផលិតឆ្នាំ2019 ពណ៌ខ្មៅ គ្មានស្លាកលេខ។ ដោយយោងតាមបញ្ជារបស់លោកមេបញ្ជាការរង ទទួលទិសឲ្យនាំជនសង្ស័យទាំងពីរនាក់ និងវត្ថុតាង បញ្ជូនទៅទីបញ្ជាការវរសេនាតូច៩១១ ដើម្បីសួរនាំ និងចាត់ការតាមនីតិវិធីច្បាប់បន្ត៕ *ដោយ ៖ រ៉ាន់ ណាង*

## ឃាត់ខ្លួនស្ត្រីជនជាតិថៃ៣នាក់ ខណៈកំពុងព្យាយាមឆ្លងដែនខុសច្បាប់

https://thekhmerpress.com/ By KhmerpressJuly 25, 2021

ខេត្តបន្ទាយមានជ័យ៖ ស្ត្រីជនជាតិថៃ 3នាក់ បានកំពុងព្យាយាមឆ្លងដែនខុសច្បាប់ ត្រូវបានកម្លាំងនគរបាលការពារព្រំដែនគោកបឹងសាគូ នៃវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ 911 និងកម្លាំងយោធាកងពល51 បានសហការគ្នាឃាត់ខ្លួន កាលពីវេលាម៉ោង 9 និង 00 នាទីព្រឹកថ្ងៃទី 25 ខែកក្កដា ឆ្នាំ2021 ត្រង់ចំណុច ក្រោយអគារប៉ារ៉ាមិក ភូមិក្បាលស្ពាន១ សង្កាត់/ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីសួរនាំ។

លោកវរសេនីយ៍ត្រី រស់ ពិសិដ្ឋ នាយប៉ុស្តិ៍នគរបាលកាពារព្រំដែនបឹងសាគូ បានថ្លែងថា ការចាប់ខ្លួនជនជាតិថៃទាំងបីនាក់គឺធ្វើឡើងខណៈពេលដែលពួកគេកំពុងព្យាយាមឆ្លងដែនខុសច្បាប់។ យោងការសួរនាំស្ត្រីទាំងបីនាក់បានប្រាប់ថា មានមេខ្យល់ខ្មែរថៃ ជាអ្នកសម្រប សម្រួលក្នុងការរត់ផ្លូវ ពេលនេះមុខសញ្ញាមេខ្យល់បានកំពុងរត់គេចខ្លួន។ ស្ត្រីជនជាតិថៃទាំងបីរួមមាន 1-ឈ្មោះ Suphatta Nakmanee អាយុ២៥ឆ្នាំ 2-ឈ្មោះ Wilaiwan Aphisermsakun អាយុ២២ឆ្នាំ 3-ឈ្មោះ Kanatsanan Promjuntuek អាយុ៣៩ឆ្នាំ ពួកគេទាំង៣នាក់រស់នៅខេត្តស្រះកែវ។ បច្ចុប្បន្នក្រោយសួរនាំស្ត្រីជនជាតិថៃទាំង០៣ នាក់ ត្រូវបានបញ្ជូនទៅខាងនគរបាល អន្តោ ប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតដើម្បីសួរនាំនិងចាត់ការបន្តតាមនីតិវិធី៕

## សពពលករខ្មែរម្នាក់ស្លាប់ដោយជំងឺកូវីដ-១៩ ត្រូវថៃបញ្ជូនមកច្រកអន្តរជាតិអូរស្មាច់

https://www.kampucheathmey.com/ ថ្ងៃអាទិត្យ ២៥ កក្កដា ២០២១ដោយ Sonya

**ឧត្តរមានជ័យ៖** ពលករខ្មែរម្នាក់បានបាត់បង់ជីវិតនៅក្នុងប្រទេសថៃដោយសារជំងឺកូវីដ-១៩ត្រូវបានអាជ្ញាធរថៃដឹកជញ្ជូនយកមកប្រគល់ដល់អាជ្ញាធរកម្ពុជានៅព្រំដែន តាមច្រកអូរស្មាច់ក្នុងក្រុងសំរោង នាថ្ងៃទី២៥ ខែកក្កដា

ឆ្នាំ២០២១។ សាកសពពលករដែលស្លាប់ដោយសារជំងឺកូវីដ-១៩ឈ្មោះ ម៉ៅ សុវណ្ណ ភេទប្រុស អាយុ៥៧ឆ្នាំ មានអាស័យដ្ឋានស្ថិតនៅភូមិបឹងព្រៃ ឃុំឫស្សី ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ បន្ទាប់ពីបានពិនិត្យ និងទទួលយកសាកសពដោយក្រុមគ្រូពេទ្យកម្ពុជាប្រចាំមាត់ច្រកអូរស្មាច់រួចមក សាកសពត្រូវបានក្រុមការងារយកទៅបូជា នៅឈាបនដ្ឋានខេត្តឧត្តរមានជ័យ។ គួរបញ្ជាក់ថា គិតត្រឹមល្ងាចថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ ខេត្តឧត្តរមានជ័យបានរកឃើញជំងឺកូវីដ-១៩ ចំនួន ៣,៨១៤ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ៣,៥៣៥ ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈចំនួន ២៧៩ករណី ជាសះស្បើយចំនួន ៦៤០នាក់ កំពុងសម្រាកព្យាបាលចំនួន ៣,១៦៦នាក់ និងស្លាប់ចំនួន ៨នាក់៕ **អត្ថបទ៖ ណារី**

# ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១

## សម្ដេចក្រឡាហោម ៖ ពលករចំណាកស្រុកជាង ១សែន ៥ម៉ឺននាក់ ត្រឡប់មកពីក្រៅប្រទេសវិញ

https://cen-news.com/ Posted ByPen Srey NeatJuly 26, 2021

ភ្នំពេញ ៖ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ថា រយៈពេល ៦ខែ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២១នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៥០.៨៨៥នាក់ ដែលក្នុងនោះមានស្ត្រី៥៤.៥៥៦នាក់ និង អនីតិជន៥៦៤នាក់ មានស្រី១៥៧នាក់។ សម្ដេចក្រឡាហោមបានបន្តថា អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានប្រមូលទិន្នន័យជាប្រចាំរបស់រដ្ឋបាលរាជធានី ខេត្ត នូវចំនួនពលករ វិលត្រឡប់ជារៀងរាល់ថ្ងៃ ក្នុងអំឡុងពេលនៃការរីករាលដាលជម្ងឺកូវីដ ១៩ សរុបប្រមាណ ៦៣.២៦៩នាក់ មានស្ត្រីប្រមាណ ២៧.១៦២នាក់។

សម្ដេចក្រឡាហោម ស ខេង បានបន្តទៀតថា កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន៦ បានធ្វើការងារបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុក ទៅរកការងារធ្វើ នៅក្រៅប្រទេសដោយខុសច្បាប់ បានចំនួន៨២លើក មនុស្សចំនួន៥៩៣នាក់ មានស្ត្រី១៩៧នាក់ ជាអនីតិជន ៣៤នាក់ ស្រី ០៧នាក់ ក្នុងនោះមានខេត្តបាត់ដំបងចំនួន៣០លើក ខេត្តកោះកុងចំនួន២៧លើក បន្ទាយមានជ័យចំនួន៨លើក តាកែវចំនួន៩លើក និងស្វាយរៀងចំនួន៥លើក។ ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត៕ រក្សាសិទ្ធិដោយ៖ ចេស្តារ

## សម្ដេចក្រឡាហោម អំពាវនាវបងប្អូនជនរួមជាតិ បន្តចូលរួមសហការជាមួយអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធទាំងអស់ នៅក្នុងការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស

https://cen-news.com/ Posted ByPen Srey NeatJuly 26, 2021

ភ្នំពេញ ៖ នៅថ្ងៃទី២៦ ខែកក្កដានេះ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានជម្រាបជូនបងប្អូនជនរួមជាតិ អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ សម្រេចបានក្នុងរយៈពេល៦ខែ ឆ្នាំ២០២១។ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២១នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានប្រមូលទិន្នន័យជាប្រចាំរបស់រដ្ឋបាលរាជធានី ខេត្ត នូវចំនួនពលករ វិលត្រឡប់ជារៀងរាល់ថ្ងៃ ក្នុងអំឡុងពេលនៃការរីករាលដាលជម្ងឺកូវីដ ១៩ សរុបប្រមាណ ៦៣.២៦៩នាក់ មានស្ត្រីប្រមាណ ២៧.១៦២នាក់។ ជាមួយគ្នានេះដែរ អគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំង

ស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៥០.៨៨៥នាក់ ដែលក្នុងនោះមានស្ត្រី៥៤.៥៥៦នាក់ និង អនីតិជន ៥៦៤នាក់ មានស្រី១៥៧នាក់។ កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន៦ បានធ្វើការងារបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅរកការងារ ធ្វើនៅក្រៅប្រទេសដោយខុសច្បាប់ បានចំនួន៨២លើក មនុស្សចំនួន៥៩៣នាក់មានស្ត្រី១៩៧នាក់ ជាអនីតិជន ៣៤នាក់ ស្រី ០៧នាក់ ក្នុងនោះមាន ខេត្តបាត់ដំបងចំនួន៣០លើក ខេត្តកោះកុងចំនួន២៧លើក បន្ទាយមានជ័យចំនួន៨លើក តាកែវចំនួន៩លើក និងស្វាយរៀងចំនួន៥លើក។ ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត។

នៅក្នុងរយៈពេលមួយឆមាសនេះ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទបានចំនួន១.០៧៤លើក លើគោលដៅ៣១៨គោលដៅ មានចំនួនមនុស្សសរុបចំនួន១.២៤៩នាក់ក្នុងនោះមានស្ត្រី ១.០៣៦នាក់ និងបានធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកំសាន្ត ដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ។

ដោយឡែកនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ គឺក្រុមការងារអនុវត្តច្បាប់ នៃច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ២១១គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ព្រមទាំងបានទំនាក់ទំនងទៅ នារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស ក្នុងនោះសាធារណរដ្ឋកូរ៉េ ១៣នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។ នៅក្នុងឆមាសទី១នេះដែរ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៩៨ករណីលើ៦៣ករណី កើនឡើងចំនួន ១៣៥ករណី ធៀបនឹងឆ្នាំ២០២០ ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ២៩១នាក់ និងបានសង្គ្រោះជនរងគ្រោះចំនួន ៧២១នាក់ ក្នុងនោះមានៈ អាយុក្រោម១៥ឆ្នាំ ៨៨នាក់ អាយុ១៥-១៧ឆ្នាំ ៦៣នាក់ និងអាយុពី១៨ឆ្នាំឡើង ៥៧០នាក់ ដោយប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២៥នាក់ និងប្រគល់ឱ្យគ្រួសារ ៦៩៦នាក់។

ចំណែកសាលាដំបូងរាជធានី-ខេត្តវិញ ក្នុងរយៈពេលដូចគ្នានេះ បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទទួលបានលទ្ធផលដូចខាងក្រោមនេះ

១.ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត មានសរុបចំនួន ៤៤១ករណី ជនរងគ្រោះចំនួន ៤៨៦នាក់(ស្រី ២៣៧នាក់) ក្នុងនោះមានអនីតិជន ១៤២នាក់(ស្រី៧៥នាក់) ជនត្រូវចោទមានចំនួន ៤៣៨នាក់(ស្រី ១៦២នាក់) ក្នុងនោះមានអនីតិជន ១៥នាក់(ស្រី ០២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ៣៤៤ករណី តម្កល់ទុកឥតចាត់ការ ១០ករណី បញ្ជូនរឿងទៅជម្រះផ្ទាល់ ០៧ករណី និងកំពុងចាត់ការចំនួន ៨០ករណី។

២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៣៣២ករណី ជនរងគ្រោះចំនួន ៥៣៤នាក់ (ស្រី ៣០៤នាក់) ក្នុងនោះមានអនីតិជន ១៣៨នាក់(ស្រី ១២៣នាក់) ជនត្រូវចោទមានចំនួន ៥២៩នាក់ (ស្រី ១០២នាក់) ក្នុងនោះមានអនីតិជន ៧៥នាក់ (ស្រី ១០នាក់) ក្នុងនោះបានចំណាត់ការ (បញ្ជូនទៅជម្រះចំនួន ១១៧ករណី លើកលែងចោទ ០៥ករណី និងកំពុងចាត់ការចំនួន ២១០ករណី)។

៣.ដំណាក់កាលថៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ២០៤ករណី ជនរងគ្រោះចំនួន ២៧០នាក់(ស្រី ១៥៦នាក់) ក្នុងនោះមានអនីតិជន ៨៣នាក់(ស្រី ៧៥នាក់) ជនជាប់ចោទសរុប ១៩៩នាក់(ស្រី ៨១នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរ ០២នាក់ ពិន័យជាប្រាក់ ០១នាក់ រួចផុតពីបទចោទ ០៤នាក់ រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៦៥ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ៣៧នាក់ និងកំពុងចាត់ការ ១៣៩ករណី)។

សម្តេច ស ខេង បានថ្លែងថា ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងនាមគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ខ្ញុំសូមវាយតម្លៃ និងកោតសរសើរខ្ពស់ ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ គ្រប់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំណុះឱ្យ គ.ជ.ប.ជ ទាំងអស់ដែលបានខិតខំប្រឹងប្រែង បំពេញភារកិច្ចដោយមិនខ្លាចនឿយហត់ ពិសេសនៅក្នុងអំឡុងពេល នៃការរីករាលដាលជំងឺកូវីដ-១៩ដ៏គ្រោះថ្នាក់ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស ធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជា អាចសម្រេចបាននូវភារកិច្ចបំរើជាតិ និងប្រជាជន លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ឆ្លៀតនៅក្នុងឱកាសនេះដែរ សម្តេចក្រឡាហោម ក៏សូមអំពាវនាវបងប្អូនជនរួមជាតិ បន្តចូលរួមសហការជាមួយអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធទាំងអស់នៅក្នុងការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សនេះ នៅតាមមូលដ្ឋានរបស់បងប្អូន តាមរយៈការមិនប្រព្រឹត្តអំពើល្មើស ការរាយការណ៍អំពីអំពើល្មើស និងការចូលរួមផ្សព្វផ្សាយ ពន្យល់អប់រំណែនាំដល់សាច់ញាតិ បងប្អូន អ្នកភូមិផងឱ្យមានការយល់ដឹងពីគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស ដែលស្តែងឡើងតាមរយៈអាពាហ៍ពិពាហ៍ មិនស្របច្បាប់ទៅក្រៅប្រទេស ការធ្វើចំណាកស្រុកខុសច្បាប់ និងការប្រើឧបាយកលទុច្ចរិតអូសទាញ ឃោសនា ក្រោមរូបភាពផ្សេងទៀតរបស់ជនល្មើស ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ដឹងថាគ្រួសារកើតកូវីដ-១៩ ក៏បង្ខំចិត្តនាំគ្នាដើរត្រឡប់មកកម្ពុជាវិញ

https://kohsantepheapdaily.com.kh/ Banteay Meanchey២៥ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២១:០៥

ខេត្តបន្ទាយមានជ័យ ៖ គ្រួសាមួយបាននាំគ្នាវិលត្រឡប់ពីទឹកដីថៃដើរទាំងប្រថុយប្រថានចូលមកកម្ពុជាវិញ ព្រោះស្ត្រីជាប្រពន្ធធ្លាក់ខ្លួនឈឺសង្ស័យកើតកូវីដ-១៩ នេះបើតាមប្រភពពីនគរបាលការពារបន្ទាត់ព្រំដែន។ គ្រួសារខាងលើមានគ្នា៥នាក់(កូន៣នាក់ប្រុស១)ជាអាជីវករលក់ដូរនៅផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ និងមានទីលំនៅក្នុងសង្កាត់ប៉ោយប៉ែត។ គ្រួសានេះត្រូវបានកម្លាំងជួរមុខរួមមាននគរបាលការពារព្រំដែនគោកលេខ៩១១ និងយោធាកងពល៥១ ធ្វើការឃាត់សួរនាំនៅចំណុចខាងមុខស្ពាហ្គោល ក្នុងភូមិសាមគ្គីមានជ័យសង្កាត់ប៉ោយប៉ែត នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ក្រោយឃើញពួកគាត់ដើរឆ្លងព្រំដែនពីទឹកដីថៃចូលមកកម្ពុជាដោយខ្លួនឯង។

តាមប្រភពថា ក្រោយសាកសួរគ្រួសារខាងលើប្រាប់ថា ពួកគាត់ធ្លាប់ទាក់ទងជនសង្ស័យ២នាក់ឲ្យជួយយកឆ្លងដែនកាលពីវេលាទបបភ្លឺ ថ្ងៃទី២៤ ខែកក្កដាម្សិលមិញ តែជនសង្ស័យទាំង២នាក់នោះត្រូវសមត្ថកិច្ចឃាត់ខ្លួន។ ដោយសារស្ថានភាពគ្រួសារ(ស្ត្រីជាប្រពន្ធ)ធ្លាក់ខ្លួនឈឺមិនអាចនៅដីថៃបន្តបានក៏បង្ខំចិត្តនាំគ្នាឆ្លងដែនចូលមកកម្ពុជាដោយខ្លួនឯងតែម្តង។ ប្រភពថា ក្រោយសាកសួរ និងធ្វើកំណត់ហេតុគ្រួសា១នេះត្រូវបានគេបញ្ជូនតាមរថយន្តយោធាយកទៅធ្វើចត្តាឡីស័កនៅទីតាំងមួយក្នុងក្រុងប៉ោយប៉ែត។ ប្រភពថា ក្រោយធ្វើតេស្តគ្រួសាមួយនេះមានអ្នកកើតកូវីដ-១៩។ បើដូច្នេះមែនពិតជាសំណាងល្អហើយដែលកម្លាំងជួរមុខទប់ស្កាត់ និងដឹងទាន់ពេល កុំឲ្យរីករាលដាលបន្តទៅអ្នកដទៃ៕ ដោយ ៖ មុតសារុន

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៣០នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាបៈ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប ប្រចាំថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦ៈ០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៣០នាក់ ស្រី ១៦៣នាក់ ក្នុងនោះកុមារា ០០នាក់ កុមារី ០០នាក់ មានដូចខាងក្រោមៈ

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែតៈ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់ៈ ចំនួន ១៩នាក់ ស្រី ៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃៈ ចំនួន ៥នាក់ ស្រី ៣នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបងៈ ចំនួន ៣នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៥-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ៤នាក់ ស្រីចំនួន ១នាក់ ។

៦-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៩៧នាក់ ស្រី ១៤៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។ ចំពោះពលករមកតាមច្រកអូរស្មាច់នេះ មិនមែនមានតែបងប្អូនពលករខេត្តសៀមរាបទេ គឺរួមទាំងបណ្តាខេត្តផ្សេងទៀតផងដែរ ។

សូមបញ្ជាក់ថាៈ ពួកគាត់ទាំង ២៣០នាក់ ស្រី ១៦៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតា តម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ នៅតាមបណ្តុសខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ។ ដោយឡែក ពលករមកតាមច្រកព្រំដែនអូរស្មាច់ ខេត្តឧត្តរមានជ័យ ត្រូវបានបញ្ជូនមកខេត្តសៀមរាប ទាំងអស់ ក្រោយពីពិនិត្យសុខភាពបឋមរួច នៅថ្ងៃទី២៤ ខែកក្កដានេះ ក្រុមការងារបានបញ្ជូនពលករ ដែលមកពីបណ្តាខេត្តតាមព្រំដែន មានចំនួន ១៩៧នាក់ ស្រី ១៤៩នាក់ ( មកពីច្រកព្រំដែនអូរស្មាច់ ខេត្តឧត្តរមានជ័យ) ហើយនៅថ្ងៃនេះដែរ បណ្តាខេត្តតាមព្រំដែនដូចជា ខេត្តបាត់ដំបង, បន្ទាយមានជ័យ និងខេត្តប៉ៃលិន បានបញ្ជូនពលករមកខេត្តសៀមរាប ចំនួន ៣០នាក់ ស្រី ១១នាក់ ផងដែរ ក្រោយពីបញ្ចប់ធ្វើចត្តាឡីស័ក១៤ថ្ងៃ នៅព្រំដែន៕ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយៈ ធូ កុសល

## ប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ចូលមកតាមច្រកអន្តរជាតិ សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៤៧នាក់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០២១

សៀមរាបៈ ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប ប្រចាំថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦ៈ០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត,

ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ, ច្រកព្រំ ខេត្តប៉ៃលិន និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៤៧នាក់ ស្រី ៥៨នាក់ ក្នុងនោះកុមារ ១នាក់ កុមារី ០០នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៣នាក់ ស្រី ៦នាក់ កុមារ ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤នាក់ ស្រី ១នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៥-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

៦-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ១២៩នាក់ ស្រី ៥៣នាក់ កុមារ ០០នាក់ កុមារី ០០នាក់។ ចំពោះពលករមកតាមច្រកអូរស្មាច់នេះ មិនមែនមានតែបងប្អូនពលករខេត្តសៀមរាបទេ គឺរួមទាំងបណ្តាខេត្តផ្សេងទៀតផងដែរ ។

សូមបញ្ជាក់ថា៖ ពួកគាត់ទាំង ១៤៧នាក់ ស្រី ៥៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម និងយកសំណាកពលករទាំងអស់ មានដូចជា ក្នុងករណីសុខភាពធម្មតាតម្រូវឱ្យធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័ក រយៈពេល ១៤ថ្ងៃ នៅតាមបណ្តុសខេត្ត នៃច្រកព្រំដែនខេត្តនោះ។ ក្នុងករណី មានវិជ្ជមាន ក៏តម្រូវដាក់ឱ្យព្យាបាល នៅតាមខេត្ត នៃច្រកព្រំដែនខេត្តនោះផងដែរ។ ដោយឡែក ពលករមកតាមច្រកព្រំដែនអូរស្មាច់ ខេត្តឧត្តរមានជ័យ ត្រូវបានបញ្ជូនមកខេត្តសៀមរាប ទាំងអស់ ក្រោយពីពិនិត្យសុខភាពបឋមរួច នៅថ្ងៃទី២៣ ខែកក្កដានេះ ក្រុមការងារបានបញ្ជូនពលករ ដែលមកពីបណ្តាខេត្តតាមព្រំដែន មានចំនួន ១២៩នាក់ ស្រី ៥៣នាក់ ( មកពីច្រកព្រំដែនអូរស្មាច់ ខេត្តឧត្តរមានជ័យ)៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករខ្មែរ ដែលទើបវិលត្រឡប់មកពីប្រទេសថៃ ចំនួន១៦១នាក់ ត្រូវបានរកឃើញថា «មានវិជ្ជមានជំងឺកូវីដ១៩»

https://kbn.news/ July 26, 2021

**ឧត្តរមានជ័យ៖** រដ្ឋបាលខេត្តឧត្តរមានជ័យ បានឲ្យចេញសេចក្តីប្រកាសរកឃើញអ្នកឆ្លងកូវីដ-១៩ ថ្មីចំនួន ១៩៦នាក់បន្ថែមទៀត ដែលនៅក្នុងនោះមាន ៣៤នាក់ គឺជាពលករដែលកំពុងធ្វើចត្តាឡីស័ក ចំណែក១៦១នាក់ផ្សេងទៀតគឺ ជាពលករខ្មែរដែលទើបវិលត្រឡប់មកពីប្រទេសថៃ តាមច្រកទ្វារព្រំដែនអន្តរជាតិអូស្មាច់ ។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ រដ្ឋបាលខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ។

សូមបញ្ជាក់ថា មកទល់ពេលនេះខេត្តឧត្តរមានជ័យ មានអ្នកជំងឺកូវីដ១៩ ជាង៤ពាន់នាក់ ករណីនាំចូលពីបរទេស ជិត៤ពាន់នាក់ និងករណីពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ជិត៣០០នាក់ ហើយបានព្យាបាលជាសះស្បើយជាង៦០០នាក់និងស្លាប់ចំនួន៨នាក់ និង កំពុងសម្រាកព្យាបាលជាង៣ពាន់នាក់ ៕

## ខេត្តប៉ៃលិន បង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដចំនួន ១៧៦នាក់ ក្នុងនោះជាពលករចំនួន ១៦៦នាក់ ដែលផ្ទេរមកពីខេត្តឧត្តរមានជ័យ

http://freshnewsasia.com/ 2021-07-26 02:09pm

**(ប៉ៃលិន)៖** រដ្ឋបាលខេត្តប៉ៃលិន បានប្រកាសពីការរកឃើញ និងបង្ហាញអត្តសញ្ញាណអ្នកវិជ្ជមានកូវីដ១៩ ចំនួន១៧៦នាក់ តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) ដែលរកឃើញនាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ដែលចេញផ្សាយដោយក្រសួងសុខាភិបាលនៅព្រឹកនេះ។ នេះបើតាមសេចក្តីប្រកាសព័ត៌មាន ដែលបណ្តាញ Fresh News ទទួលបាននៅថ្ងៃទី២៦ ខែកក្កដានេះ។

បើតាមសេចក្តីប្រកាសព័ត៌មានបានបញ្ជាក់ថា អ្នកជំងឺកូវីដ១៩ទាំង១៧៦នាក់ខាងលើនេះ ក្នុងនោះមានអ្នកជំងឺចំនួន ត្រូវបានក្រុមការងារឆ្លើយបន្ទាន់ របស់មន្ទីរសុខាភិបាលខេត្ត ប្រចាំការតាមគោលបានឃើញចំនួន ១០ករណី ខណៈអ្នកជំងឺចំនួន ១៦៦នាក់ ជាពលករដែលផ្ទេរមកពីខេត្តឧត្តរមានជ័យ។ រដ្ឋបាលខេត្តបានអំពាវនាវចំពោះអ្នកដែលបានប្រាស្រ័យទាក់ទងប៉ះពាល់ដោយផ្ទាល់ ឬប្រយោលជាមួយបុគ្គលវិជ្ជមានកូវីដ១៩ ខាងលើ សូមដាក់ខ្លួនដាច់ដោយឡែកតាមដានសុខភាពរយៈពេល១៤ថ្ងៃ និងរាយការណ៍មកអាជ្ញាធរ ដើម្បីយកសំណាកនិងធ្វើចត្តាឡីស័ក៕

## ក្តៅៗ: ករណីជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ទៅរកការងារ បែរជាត្រូវបង្ខាំងមនុស្សទុក បង្អត់បាយ ដកលិខិតឆ្លងដែន និងទូរស័ព្ទ

https://dap-news.com/national/ BySS107 Posted on July 26, 2021

ភ្នំពេញ៖ មានករណីស្ត្រីចំនួន ៣រូបត្រូវបានដាក់បង្ខាំង នៅក្នុងទីតាំងដូចបង្ហាញនៅក្នុងរូបភាពនេះដោយ ប៉ាស្ព័រ និងទូរស័ព្ទត្រូវបានដកហូតដោយបង្ខំ និងធូន់ធ្ងរថែមទៀតនោះ គឺបង្អត់បាយ។ បុរសជាស្វាមី ស្ត្រីរងគ្រោះ ឈ្មោះ Murad Durak ជនជាតិTurkey បានឲ្យមជ្ឈមណ្ឌលព័ត៌មានដើមអម្ពិលដឹងថា ភរិយារបស់គាត់ឈ្មោះ Jene Miras Martinez ជនជាតិហ្វីលីពីន បានស្វែងការធ្វើតាមរយៈក្រុមហ៊ុន MVRF resources ltd. Co. ដែលជាក្រុមហ៊ុនជ្រើសរើសបុគ្គល។ លោក បានរៀបរាប់ថា ចាប់តាំងពីថ្ងៃ ទី២២ ខែកក្កដា ឆ្នាំ២០២១ មកភរិយារបស់លោក ត្រូវបានបង្ខាំងទុក ដោយក្នុងនោះក៏មាន ស្ត្រីរងគ្រោះ ចំនួន២នាក់ផ្សេងទៀត ជាជនជាតិអាហ្វ្រិក ផងដែរ។ លោក សំណូមពរឲ្យអាជ្ញាធរមានសមត្ថកិច្ចជួយស្វែងរក យុត្តិធម៌ភរិយារបស់លោក នឹងស្ត្រីរងគ្រោះព្រមទាំងវិធានការផ្លូវច្បាប់ចំពោះ ក្រុមហ៊ុននិងអ្នកពាក់ព័ន្ធជុំវិញការជួញដូរមនុស្សនេះផង។

ខាងក្រោមនេះជាលេខទូរស័ព្ទស្វាមីរបស់ជនរងគ្រោះ +855 78 728 546 និងជាទីតាំងដែលជនរងគ្រោះត្រូវគេបង្ខាំងទុក https://goo.gl/maps/Y1Tohj9ZcsGo3ixr6

# ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១

## លោកជំទាវ ម៉ែន សំអន ៖ ប្រកាសទទួលស្គាល់សមាសភាពគណៈកម្មការសាខា សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ២៦ កក្កដា ២០២១ដោយ Sorn Phanith

លោកជំទាវកិត្តិសង្គហបណ្ឌិតឧបនាយករដ្ឋមន្ត្រី ម៉ែន សំអន បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាស ទទួលស្គាល់សមាសភាពគណៈកម្មការសាខា សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រសួងមហាផ្ទៃ តាមរយៈប្រព័ន្ធ ZOOM ដែលជារបៀបធ្វើការតាមគន្លងថ្មី នាថ្ងៃច័ន្ទទី ២៦ ខែកក្កដា ឆ្នាំ២០២១។ លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន រដ្ឋមន្ត្រីក្រសួង ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានសមាគម

នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក៏បាននាំនូវការផ្តាំផ្ញើ សួរសុខទុក្ខ និងការនឹករលឹកពីសំណាក់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធាន កាកបាទក្រហមកម្ពុជា និងជាប្រធានកិត្តិយសសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ជូនដល់អង្គពិធីទាំងមូល។

លោកជំទាវកិត្តិសង្គហបណ្ឌិត ក៏បានថ្លែងនូវការកោតសរសើរចំពោះ លោកជំទាវ ជូ ប៊ុនអេង និងថ្នាក់ដឹកនាំរបស់ស្ត្រីគ្រប់លំដាប់ថ្នាក់ នៃក្រសួងមហាផ្ទៃ ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងស្មារតីទទួលខុសត្រូវក្នុងការបំពេញភារកិច្ចក្នុងរយៈពេលកន្លងមក រហូតទទួលបានជោគជ័យគួរជាទីមោទនៈ ដែលបានជំរុញមន្ត្រីរាជការជានារីបានរួមចំណែកកាន់តែសកម្មថែមទៀតក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយចាត់ទុក"ស្ត្រីជាឆ្អឹងខ្នងនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម"ក្រោមការដឹកនាំរបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលជាសេនាធិការឲ្យរាជរដ្ឋាភិបាលកម្ពុជា ។ ក្នុងខណៈពេលដែលគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព អភិវឌ្ឍន៍របស់ក្រសួងពុំទាន់បានបង្កើតយ៉ាងណាក៏ដោយ ។

ដោយឡែកថ្ងៃនេះ លោកជំទាវ ជូ ប៊ុនអេង ក៏បានត្រូវប្រកាសទទួលស្គាល់ជាប្រធានគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍របស់ក្រសួងមហាផ្ទៃ រួមជាមួយសមាជិកា ២៩រូបទៀតក្រោមឱវាទផងដែរ តាមរយៈ សេចក្តីសម្រេចលេខ ០៦១/២០ នកសអ/សសរ របស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០។

ទន្ទឹមនឹងនេះផងដែរលោកជំទាវកិត្តិសង្គហបណ្ឌិត ក៏បានផ្តល់អានុសាសន៍ ជូនដល់សមាសភាពគណៈកម្មាធិការសមាគមនារី នៃក្រសួងមហាផ្ទៃដែលត្រូវបានប្រកាសជាផ្លូវការនាថ្ងៃនេះ នូវអនុសាសន៍ មួយចំនួន ដូចខាងក្រោម៖

១-បំផុសចលនា អប់រំ ផ្សព្វផ្សាយឲ្យបានទូលំទូលាយជាប្រចាំ តាមគ្រប់រូបភាពនិងគ្រប់មធ្យោបាយនូវគោលនយោបាយ ខ្លឹមសារ សេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាល។ ជាពិសេស ចូលរួមអនុវត្តឲ្យបាននូវគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព ក្នុងនោះត្រូវផ្តោតសំខាន់លើការផ្តល់សេវាសាធារណៈឲ្យបានឆាប់រហ័សប្រកបដោយប្រសិទ្ធិភាព មិនត្រូវបង្កការលំបាក អាក់ខានដល់ប្រជាពលរដ្ឋឡើយ បើទោះបីជាការផ្តល់ និងការទទួលសេវាមិនបានជួបជុំគ្នាច្រើនក៏ដោយ ។

២-ពង្រឹងរបៀបរបបធ្វើការងារ អនុវត្តិនូវតួនាទីភារកិច្ច និងត្រូវបែងចែកភារកិច្ច និងការទទួលខុសត្រូវ ដល់ថ្នាក់ដឹកនាំ នៃគណៈកម្មការសាខាសមាគម នារីក្រសួងដែលទើបបានតែងតាំងនាពេលនេះ ត្រូវរៀបឲ្យមានរបបប្រជុំ និងរបៀបរបបដោះស្រាយបញ្ហា ដើម្បីការពារផលប្រយោជន៍ដល់ស្ត្រី នៅក្រសួងមហាផ្ទៃក៏ដូចជាផលប្រយោជន៍ស្ត្រីនៅថ្នាក់ក្រោមជាតិផងដែរ ។

៣-អនុវត្តឲ្យបានជោគជ័យ នូវផែនការសកម្មភាពសម្រាប់រយៈពេល៤ឆ្នាំ (២០២០-២០២៣) របស់សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ ដើម្បីតម្រង់ទិសទៅដណ្តើមជោគជ័យក្នុងការបោះឆ្នោត ២០២២-២០២៣ ។

៤-ជំរុញឱ្យស្ត្រីដែលមានតួនាទី ត្រូវខិតខំបំពេញតួនាទី ភារកិច្ចតាមជំនាញនីមួយៗក្នុងការកសាងនិងបង្កើនសមត្ថភាព ជំនឿជឿជាក់លើខ្លួនឯង ដើម្បីឱ្យស្ត្រី ទទួលបានឋានៈតួនាទី និងចូលរួមធ្វើសេចក្តីសម្រេចឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

៥-ត្រូវបន្តផ្សព្វផ្សាយលក្ខន្តិកៈរបស់សមាគមនារី ពង្រឹងសមាជិកចាស់ និងពង្រីកសមាជិកថ្មី និង បង្កើតអនុសាខាសមាគមនារីរបស់ក្រសួងមហាផ្ទៃឲ្យសមស្រប តាមបច្ចុប្បន្នភាពរបស់ក្រសួងមហាផ្ទៃ ។

៦-ពង្រឹងនិងថែរក្សានូវស្មារតីសាមគ្គីភាព ឯកភាពគ្នាខាងទស្សនៈ គោលជំហរ នយោបាយសតិអារម្មណ៍ ចាត់តាំងឲ្យកាន់តែរឹងមាំ។ ជាពិសេសត្រូវចេះសហការ និងទទួលយកនូវការដឹកនាំនិងការផ្តល់យោបល់ជាមួយថ្នាក់ដឹកនាំក្រសួង។

៧-ត្រូវធ្វើរបាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំរបស់ក្រសួង និងសមាគមនារីថ្នាក់កណ្តាល៕**អត្ថបទ៖ វិមាន**

## ករណីជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ទៅរកការងារ បែរជាត្រូវបង្ខាំងមនុស្សទុក បង្អត់បាយ ត្រូវបានកម្លាំងសមត្ថកិច្ចបង្ក្រាបបានហើយ

https://dap-news.com/national/ BySS107Posted on July 26, 2021

ភ្នំពេញ៖ ករណីជួញដូរមនុស្ស នៅខេត្តព្រះសីហនុ ទៅរកការងារ បែរជាត្រូវបង្ខាំងមនុស្សទុក បង្អត់បាយ និងបានដកលិខិតឆ្លងដែន និងទូរស័ព្ទ ជនរងគ្រោះទុក នៅព្រលប់ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ត្រូវបានកម្លាំងសមត្ថកិច្ចជួយអន្តរាគមន៍បង្ក្រាបបានហើយ ក្នុងនោះមនុស្សរហូតដល់ទៅ១១នាក់ ដែលត្រូវបានបង្ខាំងទុក។ ការរំដោះបាននេះ ក្រោយពីមជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល បានធ្វើការផ្សព្វផ្សាយព័ត៌មាន អំពីករណីជួញដូរខាងលើ នៅព្រឹកថ្ងៃដដែលនេះ ខណៈដែលនៅព្រលប់ថ្ងៃដដែល ត្រូវបានកម្លាំងសមត្ថកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ បានចុះអន្តរាគមន៍ដល់ទីតាំងផ្ទាល់ ដែលជាលទ្ធផល មិនត្រឹមតែ ស្ត្រីរងគ្រោះ៣រូបនោះទេ ដែលត្រូវបានដោះលែង ក្នុងក៏មានស្ត្រីរងគ្រោះផ្សេងទៀតសរុប១១នាក់ ក្នុងនោះស្ត្រី៣នាក់ ជាជនជាតិអាហ្វ្រិកនិងមួយចំនួនទៀតជាជនជាតិហ្វីលីពីន ហើយក៏មានជនជាតិផ្សេងទៀតផងដែរ ដែលត្រូវបានដោះលែង។សម្រាប់ព័ត៌មានលម្អិតមជ្ឈមណ្ឌលព័ត៌មានដើមអម្ពិល នឹងធ្វើការជម្រាបជូនពេលក្រោយ៕

## ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកជំងឺកូវីដ ចំនួន១៦៦នាក់ ក្នុងនោះ១៤៧នាក់ ជាពលករទើបមកពីថៃ ខណៈជាសះស្បើយ៣០នាក់

http://freshnewsasia.com/ 2021-07-26 09:24pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១នេះ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន ១៦៦ករណីបន្ថែមទៀត តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) ខណៈព្យាបាលជាសះស្បើយចំនួន ៣០នាក់។ បើតាមសេចក្តីប្រកាសព័ត៌មាន របស់រដ្ឋបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង១៦៦នាក់ ក្នុងនោះអ្នកជំងឺចំនួន៦នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និងចំនួន១៤៧នាក់ទៀត ជាពលករទើបមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងចំនួន ១៣នាក់ទៀត ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។ សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៦ ខែកក្កដានេះ ខេត្តឧត្តរមានជ័យ បានរកឃើញជំងឺកូវីដ១៩ ចំនួន៤,១៧៦ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ៣,៨៨៣ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន ២៩៣ករណី បានព្យាបាលជាសះស្បើយចំនួន ៦៨៥នាក់ កំពុងសម្រាកព្យាបាលចំនួន ៣,៣៨៣នាក់ និងស្លាប់បាត់បង់ជីវិត ៨នាក់ផងដែរ៕

## ៤នាក់ដើរត្រឡប់ពីថៃ តេស្តឃើញវិជ្ជមានកូវីដ១៩ទាំងអស់

https://kohsantepheapdaily.com.kh/ Banteay Meanchey២៧ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ០៩:០៧

ខេត្តបន្ទាយមានជ័យ៖ ប្តីប្រពន្ធ២គូបានវិលត្រឡប់ពីថៃដោយខ្លួនឯង តាមច្រករបៀងចំណុចភូមិសាស្ត្រមុខស្ពាហ្គោល ក្នុងភូមិសាមគ្គីមានជ័យសង្កាត់ និងក្រុងប៉ោយប៉ែត ប៉ុន្តែពួកគេត្រូវបានរកឃើញវិជ្ជមានកូវីដ ។ នេះបើតាមប្រភពឲ្យដឹងពីកម្លាំងជួរមុខ ។ ពលរដ្ឋទាំង៤នាក់ខាងលើ ជាកម្មករធ្វើការនៅផ្សាររុងក្លឿ ស្រុកអារញ្ញ ខេត្តស្រះកែវ ត្រូវបានកម្លាំងជួរមុខរួមមាននគរបាលការពារព្រំដែនគោកលេខ៩១១ ប៉ុស្តិ៍បឹងសាគួ សហការជាមួយ

កម្លាំងយោធាកងពល៥១ ធ្វើការឃាត់សួរនាំកាលពីរសៀលថ្ងៃទី២៥ កក្កដា២០២១ ខណៈពួកគាត់នាំគ្នាដើរវិលត្រឡប់ពីដីថៃចូលមកកម្ពុជាចំណុចមុខស្ពាហ្គោល ស្ថិតក្នុងភូមិសាមគ្គីមានជ័យ សង្កាត់កើតហេតុ។

ពលរដ្ឋទាំង៤នាក់ ១គ្រួសារ មានទីលំនៅសង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ និង១គ្រួសាររស់នៅសង្កាត់និងក្រុងប៉ោយប៉ែត ។ អនុវត្តតាមបទបញ្ជាថ្នាក់លើ កម្លាំងជួរមុខទាំងនគរបាលការពារព្រំដែនគោក និងយោធាបានសហការគ្នាយាមកាម និងល្បាតទប់ស្កាត់បានរាល់បទល្មើស ពិសេសឃាត់បានពលរដ្ឋវិលត្រឡប់ពីថៃមានផ្ទុកកូវីដទាន់ពេលវេលាជាបន្តបន្ទាប់។ ពលរដ្ឋទាំង២គ្រួសារនេះ ក្រោយសាកសួរកម្លាំងជួរមុខបានបញ្ជូនតាមរថយន្តយោធាទៅធ្វើចត្តាឡីស័កនៅអនុវិទ្យាល័យហ៊ុនសែនស្រះត្រា ចតាមវិធានការរបស់ក្រសួងសុខាភិបាល។ ប្រភពថា ពលរដ្ឋទាំង៤នាក់ ខាងជំនាញធ្វើតេស្តិហើយរកឃើញមានផ្ទុកកូវីដ៕

## ៣៧នាក់ ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទជួញដូរមនុស្ស

https://kohsantepheapdaily.com.kh/ Phnom Penh២៧ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៥:០៩

រាជធានីភ្នំពេញ ៖ រយៈពេល៦ខែតុលាកាបានផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៣៧នាក់ ពាក់ព័ន្ធករណីជួញដូរមនុស្ស និងកំពុងចាត់ការ ១៣៩ករណី ដោយយោងតាមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត បានចំណាត់ការសរុបចំនួន៤៤១ករណី ជនរងគ្រោះចំនួន ៤៨៦នាក់ (ស្រី២៣៧នាក់) ក្នុងនោះមានអនីតិជន១៤២នាក់ (ស្រី៧៥នាក់) ជនត្រូវចោទមានចំនួន ៤៣៨នាក់ (ស្រី ១៦២នាក់) ក្នុងនោះមានអនីតិជន១៥នាក់(ស្រី ០២នាក់) ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន ៣៤៤ករណី តម្កល់ទុកឥតចាត់ការ ១០ករណី បញ្ជូនរឿងទៅជម្រះផ្ទាល់ ០៧ករណី និងកំពុងចាត់ការចំនួន៨០ករណី នេះយោងតាមរបាយការណ៍ក្នុងរយៈពេល៦ខែចាប់ខែមករា រហូតដល់ខែមិថុនាឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ឲ្យដឹង និងបានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

រីឯចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ៣៣២ករណី ជនរងគ្រោះចំនួន ៥៣៤នាក់ (ស្រី ៣០៤នាក់) ក្នុងនោះមានអនីតិជន ១៣៨នាក់(ស្រី ១២៣នាក់) , ជនត្រូវចោទមានចំនួន ៥២៩នាក់ (ស្រី ១០២នាក់) ក្នុងនោះមានអនីតិជន ៧៥នាក់ (ស្រី ១០នាក់), ក្នុងនោះបានចំណាត់ការ (បញ្ជូនទៅជម្រះចំនួន១១៧ករណី លើកលែងចោទ ០៥ករណី និងកំពុងចាត់ការចំនួន ២១០ករណី)។ ដោយឡែកដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន ២០៤ករណី ជនរងគ្រោះចំនួន ២៧០នាក់(ស្រី ១៥៦នាក់) ក្នុងនោះមានអនីតិជន ៨៣នាក់(ស្រី ៧៥នាក់), ជនជាប់ចោទសរុប ១៩៩នាក់ (ស្រី ៨១នាក់) និងប្រភេទចំណាត់ការ(ទោសព្យួរ០២នាក់ ពិន័យជាប្រាក់ ០១នាក់ រួចផុតពីបទចោទ ០៤នាក់ រំលត់បណ្តឹងអាជ្ញាគ្មាន ចាត់ការរួច ៦៥ករណី ផ្តន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ ចំនួន៣៧នាក់ និងកំពុងចាត់ការ ១៣៩ករណី) ៕

## ត្រឹម៦ខែបង្ក្រាបការជួញដូរមនុស្ស១៩៨ករណី និងរំដោះជនរងគ្រោះសរុប៧៣១នាក់

https://kohsantepheapdaily.com.kh/ Phnom Penh២៧ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៥:៣៤

រាជធានីភ្នំពេញ ៖ នៅក្នុងឆមាសទី១ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា កងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៩៨ករណី លើ៦៣ករណី កើនឡើងចំនួន ១៣៥ករណី ធៀបនឹងឆ្នាំ២០២០ ហើយឃាត់ខ្លួនជនសង្ស័យបញ្ជូន

ទៅសាលាដំបូងចំនួន ២៩១នាក់ និងបានសង្គ្រោះជនរងគ្រោះចំនួន ៧២១នាក់ ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ ៨៨នាក់, អាយុ១៥-១៧ឆ្នាំ ៦៣នាក់ និងអាយុពី១៨ឆ្នាំឡើង ៥៧០នាក់ ដោយប្រគល់ឱ្យមន្ទីរសង្គមកិច្ច ២៥នាក់ និងប្រគល់ឱ្យគ្រួសារ ៦៩៦នាក់។ នេះបើយោងតាមហ្វេសប៊ុកផ្លូវការរបស់សម្ដេចក្រឡាហោមឲ្យដឹង។

នៅហ្វេសប៊ុកដដែលបានឲ្យដឹងទៀតថា នៅក្នុងរយៈពេលមួយឆមាសនេះ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទបានចំនួន១.០៧៤លើក លើគោលដៅ ៣១៨គោលដៅ មានចំនួនមនុស្សសរុបចំនួន១.២៤៩នាក់ ក្នុងនោះមានស្ត្រី ១.០៣៦នាក់ និងបានធ្វើសកម្មភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកំសាន្ត ដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ។

ដោយឡែកនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ គឺក្រុមការងារអនុវត្តច្បាប់ នៃច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងសម្ភាសន៍ ពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ២១១គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ព្រមទាំងបានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស ក្នុងនោះសាធារណរដ្ឋកូរ៉េ ១៣នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថា អាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

ជាមួយនោះដែរ ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២១នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានប្រមូលទិន្នន័យជាប្រចាំរបស់រដ្ឋបាលរាជធានី-ខេត្ត នូវចំនួនពលករវិលត្រឡប់ជារៀងរាល់ថ្ងៃ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ ១៩ សរុបប្រមាណ ៦៣.២៦៩នាក់ មានស្ត្រីប្រមាណ ២៧.១៦២នាក់។ ជាមួយគ្នានេះដែរ អគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១៥០.៨៨៥នាក់ ដែលក្នុងនោះមានស្ត្រី៥៤.៥៥៦នាក់ និង អនីតិជន៥៦៤នាក់ មានស្រី១៥៧នាក់ ។

សម្ដេចក្រឡាហោមស ខេង ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ក៏បានអំពាវនាវបងប្អូនជនរួមជាតិបន្តចូលរួមសហការជាមួយអាជ្ញាធរនិងមន្ត្រីពាក់ព័ន្ធទាំងអស់នៅក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ នៅតាមមូលដ្ឋានរបស់បងប្អូន តាមរយៈការមិនប្រព្រឹត្តអំពើល្មើស ការរាយការណ៍អំពីអំពើល្មើស និងការចូលរួមផ្សព្វផ្សាយ ពន្យល់ អប់រំណែនាំដល់សាច់ញាតិ បងប្អូន អ្នកភូមិផងឱ្យមានការយល់ដឹងពីគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស ដែលស្ដែងឡើងតាមរយៈអាពាហ៍ពិពាហ៍មិនស្របច្បាប់ទៅក្រៅប្រទេស ការធ្វើចំណាកស្រុកខុសច្បាប់និងការប្រើឧបាយកលទុច្ចរិតអូសទាញ ឃោសនា ក្រោមរូបភាពផ្សេងទៀតរបស់ជនល្មើស ៕

## ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកជំងឺកូវីដ ១៨៨នាក់ទៀត ក្នុងនោះ ១១៤នាក់ ជាពលករទើបមកពីថៃ និងជាសះស្បើយ ២៦នាក់

http://freshnewsasia.com/ 2021-07-27 09:17pm

**(ឧត្តរមានជ័យ)៖** រដ្ឋបាលខេត្តឧត្តរមានជ័យ នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១នេះ បានបង្ហាញអត្តសញ្ញាណអ្នកជំងឺកូវីដ១៩ ចំនួន ១៨៨ ករណីបន្ថែមទៀត តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) ខណៈព្យាបាលជាសះស្បើយចំនួន ២៦ នាក់។ បើតាមសេចក្ដីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង ១៨៨ នាក់ ក្នុងនោះអ្នកជំងឺចំនួន ៧១ នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និងចំនួន ១១៤ នាក់

ទៀត ជាពលករទើបមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងចំនួន ៣ នាក់ទៀត ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។ សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៧ ខែកក្កដានេះ ខេត្តឧត្តរមានជ័យបានរកឃើញជំងឺកូវីដ១៩ ចំនួន ៤,៣៦៥ ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ៤,០៦៨ ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន ២៩៦ ករណី បានព្យាបាលជាសះស្បើយចំនួន ៧១១ នាក់ កំពុងសម្រាកព្យាបាលចំនួន ៣,៦៤៥ នាក់ និងស្លាប់បាត់បង់ជីវិត ៨ នាក់ផងដែរ៕

## មេខ្យល់ ២នាក់ទៀត ត្រូវបានប៉ូលិស ចាប់បញ្ជូនទៅតុលាការខេត្តបន្ទាយមានជ័យ

https://kohsantepheapdaily.com.kh/ Banteay Meanchey២៧ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២២:២៩

ខេត្តបន្ទាយមានជ័យ៖ ជនសង្ស័យជាមុខសញ្ញាមេខ្យល់នាំមនុស្សឆ្លងដែន ដោយខុសច្បាប់ ត្រូវបានកម្លាំងនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនខ្លួន ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១។

លោកវរសេនីយ៍ទោ បោន សីហា អធិការស្ដីទី នគរបាលក្រុងប៉ោយប៉ែត បានឲ្យដឹងថា ជនសង្ស័យទាំង ២ នាក់ មានឈ្មោះ ១/-ឡូញ លេម ភេទប្រុស អាយុ ២០ឆ្នាំ ស្នាក់នៅភូមិចាន់គីរី សង្កាត់និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ២/-ឈ្មោះ សែន សំនាង ហៅ កែ ភេទប្រុស អាយុ ៣៥ឆ្នាំ ស្នាក់នៅភូមិប្រជាធម្មកើត សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ជនទាំង ២នាក់នេះ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ បានឃាត់ខ្លួន ពីបទនាំមនុស្សឆ្លងដែន ដោយមិនស្របច្បាប់ នៅចំណុចមាត់អូរព្រំដែនម្តុំកាស៊ីណូ ក្នុងភូមិសាស្រ្ត ក្រុងប៉ោយប៉ែត រួចប្រគល់ឲ្យនគរបាលជំនាញនៃអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត នៅវេលាម៉ោង ១ និង ៣០នាទីរសៀលថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ ដើម្បីរៀបចំសំណុំរឿង បញ្ជូនទៅស្នងការដ្ឋាននគរបាលខេត្ត ចាត់ការបន្តតាមនីតិវិធីច្បាប់។

របាយការណ៍របស់វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៩១១ បានបញ្ជាក់ថា ជនសង្ស័យទាំង ២នាក់នេះ ជាមុខសញ្ញាយ៉ាងសកម្ម ក្នុងករណីនាំមនុស្សឆ្លងដែនដោយខុសច្បាប់។ លោកអធិការស្ដីទី បានបញ្ជាក់ថា តាមការសួរនាំ ជនសង្ស័យទាំង ២នាក់ បានសារភាពថា នៅមុនពេលចាប់ខ្លួន ពួកគេទាំង ២នាក់ មានឈ្មោះ ខា លក់ដូរនៅផ្សាររុងគ្លឿ បានទាតតាមទូរសព្ទ ឲ្យជួយឃ្លាំចាំមើលផ្លូវសមត្ថកិច្ច ព្រោះគាត់ ចង់នាំកូនរបស់គាត់ ៣ នាក់ (ស្រី ២នាក់) ឲ្យឆ្លងដែនមកខ្មែរវិញ។ បើបានសម្រេចឈ្មោះ ខានោះ បានសន្យាឲ្យថ្លៃមើលផ្លូវម្នាក់ ២០០ បាត ទៅ ៣០០បាត។ ប៉ុន្តែដោយខាងសមត្ថកិច្ចថៃ ចាំឃ្លាំមើលឈ្មោះខាពេក ឈ្មោះខានោះ មិនហ៊ាន ក៏នាំកូនគាត់ទាំង ៣នាក់ ទៅផ្សាររុងគ្លឿវិញ ហើយពួកគេ ក៏នាំគ្នា ត្រឡប់មកដីខ្មែរវិញ បានប្រហែល ១០ម៉ែត្រ ពីមាត់អូរព្រំដែន ក៏ត្រូវនគរបាលចាប់ខ្លួនតែម្តង។

លោកវរសេនីយ៍ឯក ឡាយ នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា ជនសង្ស័យឈ្មោះ ឡូញ លេម និងឈ្មោះ សែន សំណាង ហៅ កែ ត្រូវបានប៉ូលិសរៀបចំសំណុំរឿងបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនិតិវិធីច្បាប់ហើយ៕

# ជនជាតិខ្មែរម្នាក់បានស្លាប់ដោយសារជំងឺកូវីដ-១៩ នៅប្រទេសថៃ និងរកឃើញជនជាតិថៃចំនួន១០នាក់ដែលត្រលប់មកពីកម្ពុជាវិញមានជំងឺកូវីដ-១៩

https://www.khmertimeskh.com/ 28/07/2021

កាលពីថ្ងៃអង្គារ មជ្ឈមណ្ឌលរដ្ឋបាលកូវីដ-១៩ របស់ប្រទេសថៃ (Centre for Covid-19 Situation Administration) បានរាយការណ៍ថា ក្នុងចំណោមអ្នកស្លាប់ចំនួន១១៨នាក់ មានម្នាក់ដែលជាពលករចំណាកស្រុកកម្ពុជា។ អ្នកស្លាប់ចំនួន៥៦នាក់ មានប្រវត្តិជំងឺលើសឈាម និង៣៦ នាក់ទៀតមានជំងឺទឹកនោកផ្អែម។ ចំណែក៤៤នាក់ទៀតអាចបណ្តាលមកពីពួកគេរស់នៅតំបន់ ឬក៏បានទៅលេងកន្លែងដែលផ្ទុះជំងឺ ខណៈ២៣អ្នកទៀតគឺបានឆ្លងមកពីសមាជិកក្រុមគ្រួសារ។ បន្ថែមពីនេះ មានជនជាតិថៃ១០នាក់ ដែលបានត្រលប់មកពីកម្ពុជា ហើយបានរកឃើញថាមានជំងឺកូវីដ-១៩ វិជ្ជមាន។ ពួកគេស្ថិតនៅក្នុងចំណោម៣៩ករណីកូវីដ-១៩ នាំចូល ដែលបានរាយការណ៍ដោយមជ្ឈមណ្ឌល។

ក្រសួងសុខាភិបាលសាធារណៈបានប្រកាសនៅព្រឹកថ្ងៃអង្គារថា ប្រទេសថៃមានអ្នកស្លាប់ថ្មីដោយសារជំងឺកូវីដ-១៩ ចំនួន១១៨ នាក់ និងករណីកូវីដ-១៩ថ្មីចំនួន១៤,១៥០ ក្នុងរយៈពេល២៤ម៉ោងមុន។ ចំនួនករណីឆ្លងថ្មីនេះបានធ្វើអោយករណីឆ្លងថ្មីមានការធ្លាក់ចុះ ប៉ុន្តែចំនួនអ្នកស្លាប់មានការកើនឡើង បើប្រៀបធៀបទៅនឹងចំនួនប្រជាជនទូទាំងប្រទេសដែលបានប្រកាសកាលពីថ្ងៃច័ន្ទ។ ក្នុងចំណោមករណីថ្មីចំនួន១៤,១៥០ មានករណីចំនួន១៣,៩០៥ត្រូវបានរកឃើញពីសំណាក់ប្រជាជនទូទៅនិង២៤៥ករណីទៀតត្រូវបានរកឃើញពីអ្នកជាប់ពន្ធនាគារ។ ករណីជំងឺកូវីដ-១៩ថ្មីមានចំនួន១៤,១៥០ ដែលបានរកឃើញកាលពី២៤ម៉ោងមុន មានករណីចំនួន១៣,៨៥៥ ដែលបានរកឃើញឆ្លងនៅក្នុងប្រទេស និងចំនួន៣៩ករណី ទៀតជាករណីនាំចូល។ ប្រភព: Bangkokpost

# ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចំនួន ០៣នាក់

http://cambodiapolice.com/policekh/ 8:31 am 27 កក្កដា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនគីឡូ៩ ចំនួន៥នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ភុន ហ៊ាង នាយប៉ុស្តិ៍ស្តីទី សហការជាមួយកម្លាំងយោធាផ្នែកសឹករងសំពៅលូនចំនួន ០២នាក់ ដឹកនាំដោយលោកនាយចំណង់ ហ៊ី វ៉ាន់ មេបញ្ជាការរង ខ កម្លាំងយោធាវរសេនាតូច ៥៣៣ ចំនួន ០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ឯក ពៅ ចំរើន មេបញ្ជាការរង គ កម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំជ្រៃសីមា ចំនួន ០២នាក់ បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុច នៃភូមិសាស្រ្តភូមិស្ពានយោល ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន ០៣នាក់ ស្រី០១នាក់ ក្មេង០១នាក់ ។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងសមត្ថកិច្ចបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ពលរដ្ឋខ្មែរចេញពីថៃមកស្រុកវិញ រកឃើញកើតកូវីដ១៩ មិនក្រោម១០០នាក់ទេក្នុង១ថ្ងៃៗ

https://kohsantepheapdaily.com.kh/ Oddar Meanchey២៨ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៤:១៨

ខេត្តឧត្តរមានជ័យ ៖ ពលករខ្មែរដែលធ្វើដំណើរចាកចេញពីប្រទេសថៃវិលត្រឡប់មកស្រុកកំណើតតាមច្រកទ្វារអន្តរជាតិអូរស្មាច់ ក្នុងមួយថ្ងៃមានចំនួន៤០០នាក់ ទៅ៥០០នាក់ ហើយត្រូវបានគ្រូពេទ្យយកសំណាកទៅធ្វើតេស្តរកឃើញអ្នកវិជ្ជមានកូវីដ១៩ មិនក្រោមពី១០០នាក់នោះទេ ស្ថិតនៅក្នុងភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

បើតាមលោក សមុទ្រ សុខនី គ្រូពេទ្យផ្នែកចត្តាឡីស័កប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់ បានឱ្យប្រាប់ឱ្យដឹងកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ ថា ពលករខ្មែរដែលធ្វើការនៅក្នុងប្រទេសថៃ គិតត្រឹមក្នុងខែកក្កដានេះ គឺបាននាំគ្នាធ្វើដំណើរចាកចេញពីប្រទេសថៃ សម្រុកចូលមកស្រុកកំណើតវិញក្នុងមួយថ្ងៃ គឺចាប់ពីចំនួន៤០០នាក់ទៅ៥០០នាក់ ខណៈនោះក្នុងចំណោមមនុស្សទាំងនេះ ត្រូវគ្រូពេទ្យផ្នែកចត្តាឡីស័ក បានយកសំណាកទៅធ្វើតេស្តរកឃើញអ្នកវិជ្ជមានកូវីដ១៩ គឺមិនក្រោមចំនួន១០០នាក់នោះទេ ហើយក៏ត្រូវបានបញ្ជូនទៅតាមមណ្ឌលព្យាបាល និងមណ្ឌលធ្វើចត្តាឡីស័កនីមួយៗក្នុងខេត្តឧត្តរមានជ័យហើយ។

យោងតាមរបាយការណ៍ក្រុមការងារថ្នាក់ខេត្តឧត្តរមានជ័យ ដែលចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១នេះ បានបញ្ជាក់ឱ្យដឹងថា ក្រុមការងារខេត្ត និងក្រុមគ្រូពេទ្យផ្នែកចត្តាឡីស័ក បានខិតខំធ្វើការចុះស្រាវជ្រាវ តាមដានពិនិត្យរកឃើញអ្នកជំងឺកូវីដ១៩ ក្នុងករណីនាំចូលពីបរទេស និងករណីពាក់ព័ន្ធក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈផងដែរ។ ហើយខណៈពេលនេះផងដែរ ក្រុមអាជ្ញាធរ និងក្រុមគ្រូពេទ្យ ក៏បានចុះធ្វើការពន្យល់ និងណែនាំដល់ប្រជាពលរដ្ឋត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការនានារបស់ក្រសួងសុខាភិបាល និងវិធានការ «៣ការពារ ៣កុំ» ឱ្យបានខ្ជាប់ខ្ជួន ៕

## ៦ ខែ សមត្ថកិច្ចបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទបាន ១៩៨ ករណី

https://www.postkhmer.com/national/ វ៉ន ដារ៉ា | Publication date 28 July 2021 | 13:44 ICT

**ភ្នំពេញៈ** រយៈពេល ៦ ខែឆ្នាំនេះ សមត្ថកិច្ចជំនាញនៃក្រសួងមហាផ្ទៃបានបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន ១៩៨ ករណី កើនឡើង ១៣៥ ករណី បើធៀបនឹងឆ្នាំ ២០២០។ នេះបើតាមរបាយការណ៍របស់ក្រសួងមហាផ្ទៃ ចេញកាលពីថ្ងៃទី ២៦ កក្កដា។ របាយការណ៍ឱ្យដឹងថា ឆមាសទី ១ ឆ្នាំនេះសមត្ថកិច្ចជំនាញពាក់ព័ន្ធបានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទសរុបបាន ១៩៨ ករណី កើនឡើងចំនួន ១៣៥ ករណី ធៀបនឹងឆ្នាំ ២០២០។ ក្នុងនោះបានឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅតុលាការ ២៩១ នាក់ និងបានសង្គ្រោះជនរងគ្រោះ ៧២១ នាក់ ក្នុងនោះមានអាយុក្រោម ១៥ ឆ្នាំ ៨៨ នាក់ អាយុ ១៥-១៧ ឆ្នាំ ៦៣ នាក់ និងអាយុពី ១៨ ឆ្នាំឡើង ៥៧០ នាក់។ រយៈពេល ១ ឆមាសនេះ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្តបានល្បាតឃ្លាំមើលគោលដៅ សង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទបានចំនួន ១ ០៧៤ លើក លើគោលដៅ ៣១៨ គោលដៅ មានមនុស្សសរុបចំនួន ១ ២៤៩ នាក់ ក្នុងនោះមានស្ត្រី ១ ០៣៦ នាក់។ សមត្ថកិច្ចក៏បានធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទតាមគោលដៅបម្រើសេវាកម្សាន្តដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ។ នេះបើតាមរបាយការណ៍។

លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃកាលពីថ្ងៃទី ២៦ កក្កដា បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ គ្រប់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំណុះឱ្យ គ.ជ.ប.ជ ទាំងអស់ដែលបាន

ខិតខំប្រឹងប្រែងបំពេញភារកិច្ចដោយមិនខ្លាចនឿយហត់ ពិសេសនៅក្នុងអំឡុងពេល នៃការរីករាលដាលជំងឺកូវីដ ១៩ ដ៏គ្រោះថ្នាក់ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស ធ្វើឱ្យរាជរដ្ឋាភិបាលអាចសម្រេចបាននូវភារកិច្ចបម្រើជាតិ និងប្រជាជនលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ លោកបានថ្លែងថា៖ «ខ្ញុំក៏សូមអំពាវនាវបងប្អូនជនរួមជាតិបន្តចូលរួមសហការជាមួយអាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធទាំងអស់នៅក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ នៅតាមមូលដ្ឋានរបស់បងប្អូន តាមរយៈការមិនប្រព្រឹត្តអំពើល្មើស រាយការណ៍អំពីអំពើល្មើស និងការចូលរួមផ្សព្វផ្សាយ ពន្យល់ អប់រំណែនាំដល់សាច់ញាតិ បងប្អូន អ្នកភូមិផងឱ្យមានការយល់ដឹងពីគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស»។ លោកបន្តអំពាវនាវដល់ប្រជាពលរដ្ឋឱ្យសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនេះ ដោយចូលរួមផ្សព្វផ្សាយពន្យល់ អប់រំណែនាំដល់សាច់ញាតិ បងប្អូន អ្នកភូមិផងដែលស្តែងឡើងតាមរយៈអាពាហ៍ពិពាហ៍មិនស្របច្បាប់ទៅក្រៅប្រទេស ការធ្វើចំណាកស្រុកខុសច្បាប់ និងការប្រើឧបាយកលទុច្ចរិតអូសទាញ ឃោសនាក្រោមរូបភាពផ្សេងៗ។

របាយការណ៍ឱ្យដឹងដែរថា អគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុកត្រឡប់មកពីក្រៅប្រទេសវិញទាំងស្របច្បាប់ និងមិនស្របច្បាប់សរុបចំនួន ១៥០ ៨៨៥ នាក់ ដែលក្នុងនោះមានស្ត្រី ៥៤ ៥៥៦ នាក់ និងអនីតិជន ៥៦៤ នាក់ មានស្រី ១៥៧ នាក់។

ចំណែកកម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តចំនួន ៦ បានធ្វើការងារបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេសដោយខុសច្បាប់បានចំនួន ៨២ លើកមានមនុស្សចំនួន ៥៩៣ នាក់ មានស្ត្រី ១៩៧ នាក់ ជាអនីតិជន ៣៤ នាក់។ ក្នុងនោះមានខេត្តបាត់ដំបង ៣០ លើក ខេត្តកោះកុង ២៧ លើក បន្ទាយមានជ័យ ៨ លើក តាកែវ ៩ លើក និងស្វាយរៀង ៥ លើក។ «ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ សមត្ថកិច្ចក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យធ្វើចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត»។ បើតាមរបាយការណ៍។

លោក អំ សំអាត នាយករងអង្គការលីកាដូ បានលើកឡើងថា អង្គការសង្គមស៊ីវិលដែលធ្វើការទាក់ទងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារនៅតែជំរុញ និងលើកទឹកចិត្តឱ្យអាជ្ញាធរពាក់ព័ន្ធ និងរាជរដ្ឋាភិបាល ចាត់វិធានការបន្ថែមទៀតទប់ស្កាត់ និងបង្ក្រាបលើករណីជួញដូរមនុស្សដែលមានដូចជា ការជួញដូរកម្លាំងពលកម្ម ការជួញដូរផ្លូវភេទ អាជីវកម្មផ្លូវភេទ និងទម្រង់នៃការជួញដូរមនុស្សផ្សេងទៀតឱ្យមានប្រសិទ្ធភាព។ លោកបានថ្លែងថា៖ « មធ្យោបាយនៃការអប់រំឱ្យប្រជាពលរដ្ឋមានការយល់ដឹងពីការជួញដូរមនុស្ស ការចូលរួមសហការជាមួយអាជ្ញាធរក្នុងការទប់ស្កាត់ និងការបង្ក្រាបការជួញដូរមនុស្ស ការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹងធានាថា ជនដែលប្រព្រឹត្ត និងពាក់ព័ន្ធនឹងការជួញដូរមនុស្ស ត្រូវតែនាំទៅតុលាការ ដើម្បីអនុវត្តតាមផ្លូវច្បាប់ ទោះបីអ្នកនោះមានតួនាទី និងឋានន្តរស័ក្តិប៉ុនណាក៏ដោយជារឿងចាំបាច់»។ លោកបន្តថា រដ្ឋាភិបាលគួរបង្កើនកិច្ចសហការជាមួយប្រទេសជិតខាង និងក្នុងតំបន់ដើម្បីទប់ស្កាត់ និងបង្ក្រាបលើការជួញដូរមនុស្ស និងបង្កើតមណ្ឌលសុវត្ថិភាព ដើម្បីការពារជនរងគ្រោះដោយការជួញដូរមនុស្ស។ បើតាមលោកសំអាត នៅឆ្នាំ ២០២០ កម្ពុជា ត្រូវបានអាមេរិកចាត់ចំណាត់ថ្នាក់លេខ ២ ស្ថិតនៅក្រោមការឃ្លាំមើលលើការជួញដូរមនុស្សដដែលក្នុងប៉ុន្មានឆ្នាំជាប់ៗគ្នា។ ចំណាត់ថ្នាក់នេះបង្ហាញថា ករណីនៃការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទស្ថិតក្នុងភាពគួរឱ្យបារម្ភដដែល៕

## ពលករខ្មែរនៅថៃ ត្រូវពន្យារពេលត្រឡប់មកកម្ពុជា រហូតដល់ការបិទខ្ទប់ខេត្តទាំង ៨ បានបញ្ចប់

https://news.sabay.com.kh/ ថ្ងៃ29/07/2021 ម៉ោង 08:51

ពលករខ្មែរទាំងអស់ ដែលរស់នៅព្រះរាជាណាចក្រថៃឡង់ដ៍ ត្រូវពន្យារពេលនៃការវិលត្រឡប់របស់ខ្លួនមកកាន់ប្រទេសកម្ពុជា រហូតដល់មានការបិទខ្ទប់ខេត្តត្រូវបានបញ្ចប់។ នេះបើតាមការបញ្ជាក់នៅក្នុងប្រការ ៧

នៃសារាចរ ស្តីពីការដាក់ចេញយុទ្ធនាការពង្រឹងវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ នៅថ្ងៃទី ២៨ កក្កដា ឆ្នាំ២០២១។

យោងតាមសារាចរខាងលើ ដោយសារខេត្តដែលត្រូវបានបិទខ្ទប់ ភាគច្រើនមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រថៃឡង់ដ៍ និងដើម្បីធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ប្រភេទដែលតា (Delta) ក្នុងខេត្តដែលត្រូវបានបិទខ្ទប់ ប្រគល់ភារកិច្ចជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើទំនាក់ទំនងជាបន្ទាន់ជាមួយភាគីថៃ ដើម្បីបិទព្រំដែនជាបណ្តោះអាសន្នសម្រាប់អ្នកដំណើរចេញ-ចូល លើកលែងតែការដឹកជញ្ជូនទំនិញ និងករណីពិសេសដែលមានការអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ច ជាអាទិ៍ ករណីអ្នកជំងឺសង្គ្រោះបន្ទាន់។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការគ្នា ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការអនុវត្តវិធានការបិទខ្ទប់សម្រាប់ បណ្តាខេត្តកម្ពុជា ដែលមានព្រំប្រទល់ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ ព្រមទាំងសម្របសម្រួលជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចថ ដើម្បីផ្តល់ការគាំពារចាំបាច់នានាដល់ពលករខ្មែររស់នៅព្រះរាជាណាចក្រថៃឡង់ដ៍ ក៏ដូចជាសម្របសម្រួលជាមួយពលករខ្មែររស់នៅព្រះរាជាណាចក្រថៃឡង់ដ៍ ដែលមានបំណងវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ឱ្យពន្យារពេលនៃការវិលត្រឡប់របស់ខ្លួន រហូតដល់ការបិទខ្ទប់នេះត្រូវបានបញ្ចប់។ បន្ថែមពីនេះ គណៈអភិបាលខេត្តនៃខេត្តជាប់ព្រំប្រទល់ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ ត្រូវបង្កើនកិច្ចសហការ និងការសម្របសម្រួលជាមួយបណ្តាខេត្តនៃព្រះរាជាណាចក្រថៃឡង់ដ៍ ដែលជាសមភាគីរបស់ខ្លួន ដើម្បីធានាដល់ការអនុវត្តនូវបណ្តាវិធានការខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់ ៕

## នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អញ្ជើញដឹកនាំក្រុមការងារទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពាក់ព័ន្ធជាមួយដៃគូសន្ទនា !

http://nokorwatnews.com/ 28/07/2021

ភ្នំពេញ៖ បើយោងតាមប្រភពពី នាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងមហាផ្ទៃ បានបញ្ជាក់អោយដឹងថា, នៅទីស្តីការក្រសួងមហាផ្ទៃ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១នេះ លោក នាយឧត្តមសេនីយ៍ ប៉ោ ភក្តិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា អញ្ជើញដឹកនាំក្រុមការងារក្រសួងមហាផ្ទៃទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនក្នុងក្របខណ្ឌអាស៊ាន (SOMTC) ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពាក់ព័ន្ធជាមួយប្រទេសដៃគូសន្ទនា (SOMTC + Dialogue Partner) លើវិស័យនានានៃការងារឧក្រិដ្ឋកម្មឆ្លងដែន ដោយមានការចូលរួមពីអនុប្រធាន សមាជិក នៃក្រុមការងារ SOMTC ព្រមទាំងមន្ត្រីបង្គោលទទួលផែនការងារពាក់ព័ន្ធជាច្រើនរូបផងដែរ។

គួរបញ្ជាក់ថា កិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូសន្ទនា គឺជាផ្នែកមួយនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានលើកទី២១ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រព្រឹត្តឡើងកាលពីម្សិលមិញ ហើយកិច្ចប្រជុំពិគ្រោះយោបល់នេះ មានរយៈពេល២ថ្ងៃ គឺថ្ងៃទី២៨ និង២៩ ខែកក្កដា ឆ្នាំ២០២១។ កិច្ចប្រជុំពិគ្រោះយោបល់នេះគឺជាឱកាសដ៏មានសារៈសំខាន់សម្រាប់ក្រុមការងារ SOMTC ក្នុងការពិភាក្សាលើការអនុវត្តផែនការការងារ ក៏ដូចជាឯកសារពាក់ព័ន្ធផ្សេងៗ និងការផ្លាស់ប្តូរនូវទស្សនៈ មតិយោបល់ពីប្រតិភូចូលរួមលើកិច្ចសហប្រតិបត្តិការ រវាងបណ្តាប្រទេសអាស៊ាន និងប្រទេសជាដៃគូសន្ទនា ដើម្បីឲ្យការអនុវត្តការប្រយុទ្ធប្រឆាំង និងទប់ស្កាត់នូវសកម្មភាពឧក្រិដ្ឋកម្មឆ្លងដែនក្នុងតំបន់កាន់តែប្រសិទ្ធភាព៕

## ខេត្តឧត្តរមានជ័យ បន្តរកឃើញអ្នកជំងឺកូវីដ ចំនួន២០១នាក់ទៀត ក្នុងនោះ ១៦៩នាក់ជាពលករទើបមកពីប្រទេសថៃ

https://khmernote.com.kh/ July 29, 2021 Khmernote Media

រដ្ឋបាលខេត្តឧត្តរមានជ័យ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១នេះ បានរកឃើញអ្នកជំងឺកូវីដ១៩ ចំនួន ២០១ករណីបន្ថែមទៀត តាមរយៈការធ្វើតេស្តរហ័ស (Rapid Test) ខណៈព្យាបាលជាសះស្បើយចំនួន១៣នាក់។ បើតាមសេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា ក្នុងចំណោមអ្នកជំងឺកូវីដទាំង ២០១នាក់ ក្នុងនោះមានអ្នកជំងឺចំនួន ១២នាក់ ជាពលករកំពុងធ្វើចត្តាឡីស័ក និងចំនួន១៦៩នាក់ទៀត ជាពលករទើបមកពីប្រទេសថៃ តាមច្រកអន្តរជាតិអូរស្មាច់ និងចំនួន ២០នាក់ទៀត ក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។

សូមបញ្ជាក់ថា គិតត្រឹមថ្ងៃទី២៨ ខែកក្កដានេះ ខេត្តឧត្តរមានជ័យបានរកឃើញជំងឺកូវីដ១៩ ចំនួន ៤,៥៦៥ករណី ក្នុងនោះករណីនាំចូលពីបរទេសចំនួន ៤,២៤៩ករណី និងករណីឆ្លងក្នុងសហគមន៍ ២០ កុម្ភៈ ចំនួន៣១៦ ករណី បានព្យាបាលជាសះស្បើយចំនួន ៧២៤ នាក់ កំពុងសម្រាកព្យាបាលចំនួន ៣,៨៣៣នាក់ និងស្លាប់បាត់បង់ជីវិត ៨នាក់ផងដែរ៕

## ឃាត់ពលរដ្ឋខ្មែរ៣នាក់ លួចឆ្លងដែនពីថៃចូលមក

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៩ កក្កដា ២០២១ដោយ deth leng

សមត្ថកិច្ចប៉ុស្តិ៍ព្រំដែនគោកបឹងសាគូ បានឃាត់ខ្លួនពលករខ្មែរចំនួន ៣ នាក់លួចឆ្លងដែនពីប្រទេសថៃចូលមកម្ពុជា នៅចំណុចខាងមុខស្តារវីឡា ភូមិព្រៃព្រិច សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ កម្លាំងចម្រុះបានប្រាប់ឱ្យដឹងថា ប្រជាពលរដ្ឋ ប្រុស ស្រី ចំនួន៣ នាក់ដែលជាអាជីវករផ្សារឡុងក្លឿ បានជិះរថយន្តតាកូម៉ា មករង់ចាំបងប្អូន ៣ នាក់ដែលកំពុងធ្វើដំណើរលួចឆ្លងដែនចូលមកតាមរយៈមេខ្យល់។ ជនទាំង៣នាក់នេះកំពុងឲ្យមេខ្យល់ដឹកជញ្ជូនមកពីថៃ យកមកដាក់ផ្ទះរបស់ពួកគេ ហើយក៏ត្រូវកម្លាំងដេញស្ទាត់ឃាត់ បាននៅចំណុចសាលា២ជាន់។

តាមការសួរនាំពីឈ្មោះ ហួត ដេវីត បានប្រាប់កម្លាំងថា ពួកគាត់ត្រូវក្រុមមេខ្យល់ដឹកជញ្ជូនតាមឡានម៉ាកកាមរី ស្លាកលេខថៃ ចេញពីផ្សាររុងក្លឿ មកមានគ្នាប្រហែល១៣នាក់ ក្នុងនោះមានអ្នកនាំផ្លូវ២នាក់ ហើយត្រូវបានក្រុមមេខ្យល់ប្រមូលយកលុយក្នុងម្នាក់ចំនួន ៦ ពាន់បាត ដោយសន្យាថាជូនពួកគាត់ដល់ផ្ទះ តែមិនទាន់ដល់គោលដៅផង ត្រូវបានសមត្ថកិច្ចឃាត់សួរនាំតែម្តង។ ជនសង្ស័យ និងវត្ថុតាង ព្រមទាំងអាជីវករ ត្រូវបានកម្លាំងចំរុះបញ្ជូនទៅទីបញ្ជាការវរៈសួរនាំបន្ត៕ ដោយៈ វ៉ាន់ ណាង

## ពលករខ្មែរមួយចំនួន នាំគ្នាត្រឡប់ទៅកម្ពុជាវិញទាំងឈឺ ដោយសារគ្មានលទ្ធភាពព្យាបាលនៅថៃ

https://www.rfa.org/khmer/ ដោយ ទីន ហ្សាការីយ៉ា2021-07-27

ពលករខ្មែរធ្វើការនៅប្រទេសថៃ កំពុងឆ្លងជំងឺកូវីដ១៩ (Covid-19) កាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ស្ថានភាពបែបនេះធ្វើឱ្យពលករខ្លះ បាននាំកូនធ្វើដំណើរទាំងឈឺទៅព្យាបាលជំងឺកូវីដ១៩ នៅកម្ពុជាវិញ ដោយសារគ្មានលទ្ធភាពព្យាបាលនៅមន្ទីរពេទ្យប្រទេសថៃ។ សង្គមស៊ីវិលជំរុញឲ្យមន្ត្រីស្ថានទូតខ្មែរនៅប្រទេសថៃបន្ថែមការយកចិត្តទុកដាក់ និងរកយន្តការជួយពលករ។ រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ មានពលករជាច្រើនបានធ្វើដំណើរទាំងយប់ និងខ្លះទៀតប្រថុយនាំគ្នាត្រឡប់ទៅកម្ពុជាវិញ ទាំងដឹងថា ខ្លួនមានជំងឺកូវីដ១៩។

ពលករសំណង់ម្នាក់ នៅខេត្តមួយជាប់ក្រុងបាងកកលោក គា រ៉ាវី ដែលសង្ស័យថា ខ្លួនមានជំងឺកូវីដ១៩ ក៏ត្រៀមខ្លួនត្រឡប់ទៅប្រទេសកម្ពុជាវិញដែរ ព្រោះមន្ទីរពេទ្យនានានៅប្រទេសថៃ មិនទទួលឲ្យលោកចូលសម្រាកព្យាបាលទេ។ លោកឲ្យដឹងថា ពលករនៅការដ្ឋានជាមួយគ្នាជាច្រើននាក់ បានត្រឡប់ទៅកម្ពុជាវិញជាបន្តបន្ទាប់អស់ហើយ នៅសល់មិនដល់ ១០នាក់ទេនៅពេលនេះ។ លោកបញ្ជាក់ទៀតថា ទោះបីជាមានការបិទខ្ទប់ការដ្ឋានសំណង់ និងទីប្រជុំជនមួយចំនួន ក៏កំណើនការឆ្លងកូវីដ១៩ ក្នុងប្រទេសថៃនៅតែច្រើន ហើយតាមមន្ទីរពេទ្យបដិសេធទទួលយកអ្នកជំងឺកូវីដ១៩ ជាពិសេសគឺ ក្រុមពលករបរទេសតែម្តង។ លោកបន្តថា ពួកលោកក៏គ្មានលទ្ធភាពបង់ថ្លៃធ្វើតេស្តរកជំងឺកូវីដ១៩ ហើយថែមទាំងគ្មានគ្រូពេទ្យមកយកសំណាកពួកលោកទៀត៖ «ចុះទៅខ្មែរម្សិលមិញប៉ុន្មាន ហើយបី បួនថ្ងៃហ្នឹង ចុះទៅចង់អស់ហើយ។ នៅខ្ញុំប៉ុន្មាននាក់ហ្នឹង ជាប់ក្នុង (ការដ្ឋាន) ហ្នឹងទេដឹង។ ខ្ញុំថា នៅចាំមើលព្យាបាលបន្តិចសិនបង។ (អ្នកជំងឺ) វាច្រើនពេកណាបង។ ណាមួយពេទ្យគេមិនមើលខ្មែរយើងផងគេបិទយើងចោលក្នុងកន្លែងកសាង (ការដ្ឋានសំណង់) ដដែលៗ ហ្នឹង»។

ចំណែកពលករម្នាក់ទៀត ជាអ្នកលក់តាមចិញ្ចើមថ្នល់ លោកស្រី តឹក ហៀង ក៏គ្មានជម្រើសអ្វីក្រៅពីនាំកូនតូចប្រថុយត្រឡប់ទៅស្រុកកំណើតវិញដែរ ប្រសិនបើឆ្លងកូវីដ១៩។ ទោះជាយ៉ាងណា លោកស្រី នឹងព្យាយាមទ្រាំនៅក្នុងបន្ទប់ជួល ហើយរកវិធីព្យាបាលខ្លួនឯងឲ្យអស់លទ្ធភាព មុននឹងសម្រេចចិត្តថាប្រថុយធ្វើដំណើរត្រឡប់ទៅកម្ពុជាវិញ ឬយ៉ាងណា៖ «ទៅផ្ទះ ក៏វាមិនងាយស្រួល ព្រោះវាមានជំងឺជាប់នៅខ្លួន។ អ៊ីចឹងហើយ បើតាមគំនិតបងបើសិនជាយើងកើតពិតមែនសុខចិត្តរក្សាខ្លួនឯងនៅក្នុងហាង (បន្ទប់) ហ្នឹងបណ្តោយ ហើយប្រើថ្នាំខ្មែរយើងដូចខ្ទឹមម្រេច ស្លឹកក្រូច ស្លឹកគ្រៃអ្វីស្លង់អ៊ីចឹងណា។ តែបើថាឲ្យ Call ទៅស្ថានទូត ក៏មិនដឹងថា គេជួយអ្វីយើងបានដែរ»។

រដ្ឋាភិបាលកម្ពុជា និងថៃមិនទាន់បង្ហាញថា មានពលករខ្មែរធ្វើការនៅប្រទេសថៃ ប៉ុន្មាននាក់ហើយ បានឈឺធ្ងន់ និងស្លាប់ដោយសារជំងឺកូវីដ១៩ នោះទេ ស្របពេលដែលអត្រាឆ្លងកូវីដ១៩ នៅថៃ មានជាងមួយម៉ឺនប្រាំពាន់ (១៥.០០០) នាក់ ក្នុងមួយថ្ងៃ។ រដ្ឋាភិបាលទាំង២ ក៏មិនទាន់បានបង្ហាញយន្តការណាមួយ ដើម្បីគាំទ្រដល់ពលករខ្មែរដែលឆ្លងកូវីដ១៩ ដែរ ក្រៅពីឲ្យប្រុងប្រយ័ត្នដោយខ្លួនឯង និងស្តាប់តាមការណែនាំរបស់អាជ្ញាធរថៃ។

ជុំវិញករណីនេះ អាស៊ីសេរីមិនអាចសុំការបញ្ជាក់ពីមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ និងអ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង បានដែរ នៅថ្ងៃទី២៧កក្កដា។ តែយ៉ាងណា លោក កុយ គួង បានប្រាប់សារព័ត៌មានវីអូអេ (VOA) ថា ស្ថានទូតកំពុងធ្វើការជាមួយអាជ្ញាធរថៃ ដើម្បីផ្ទៀងផ្ទាត់ចំនួន និងឈ្មោះពលករដែលឆ្លងកូវីដ១៩ នៅប្រទេសថៃ ព្រោះខ្លាចច្រឡំជាមួយពលករប្រទេសផ្សេង។ លោកអះអាងថា ស្ថានទូត និងស្ថានអគ្គកុងស៊ុលកម្ពុជានៅប្រទេសថៃ កំពុងខិតខំសហការជាមួយអាជ្ញាធរថៃ ជួយសម្របសម្រួលដល់ពលករខ្មែរ ដែលកំពុងជួបការលំបាកខ្លាំងពេលឆ្លងជំងឺកូវីដ១៩។

ផ្ទុយពីការលើកឡើងនេះ ពលករ និងអ្នកឃ្លាំមើលសិទ្ធិពលករក្នុងប្រទេសថៃ សង្កេតឃើញថា មន្ត្រីស្ថានទូតខ្មែរអសកម្ម ក្នុងកិច្ចការជួយពលករខ្មែរ ដែលកំពុងឆ្លងជំងឺកូវីដ១៩។ មន្ត្រីផ្នែកអន្តោប្រវេសន៍ប្រចាំប្រទេសថៃនៃអង្គការសង់ត្រាល់ (CENTRAL) លោក លឹង សុផុន ឲ្យដឹងថា ពលករខ្មែរឆ្លងកូវីដ១៩ ទ្រង់ទ្រាយធំកាន់តែច្រើនឡើយ ដោយតំបន់ខ្លះឆ្លងរាប់រយនាក់មួយថ្ងៃ។ លោកបន្តថា ពលករខ្លះទៀត ត្រូវបានថៅកែបង្ខាំងទុកក្នុងបន្ទប់ជួល ឬការដ្ឋានសំណង់ចោលនៅពេលឆ្លងកូវីដ១៩។ ដូច្នេះទើបពលករនាំគ្នាសម្រុកទៅប្រទេសកម្ពុជាវិញ ទោះបីដឹងថា ខ្លួនឆ្លងជំងឺកូវីដ១៩ ក៏ដោយ។ ចំណែកការជួយអន្តរាគមន៍ពីមន្ត្រីស្ថានទូតខ្មែរវិញនោះ សង្គមស៊ីវិលរូបនេះ សង្កេតឃើញថា មានភាពយឺតយ៉ាវខ្លាំងណាស់។ លោកជំរុញឲ្យស្ថានទូត និងរដ្ឋាភិបាលកម្ពុជារកយន្តការបន្ថែមទៀត ដើម្បីស្នើសុំទៅរដ្ឋាភិបាលថៃ និងជួយអន្តរាគមន៍ដោយផ្ទាល់ ជួយពលករ ដែលឆ្លងជំងឺកូវីដ១៩ ឲ្យបានទទួលសេវាសុខាភិបាលត្រឹមត្រូវ៖ «(ពលករ) ភាគច្រើន គាត់ថា គាត់បានទំនាក់ទំនងទៅខាងស្ថាប័នទូត ទៅខាងកុងស៊ុលអ្វីដែរ តែអត់មានអ្នកណាគាត់លើកទូរស័ព្ទផ្តល់យោបល់ជូនពួកគាត់អ៊ីចឹងណា ហើយនៅពេលដែល

ពួកគាត់ឆ្លងកូវីដអ្វីអ៊ីចឹងទៅ គេទុកចោល ហើយអត់មានថៅកែដោះស្រាយរកថ្នាំរកអ្វីឲ្យពួកគាត់ ដល់អ៊ីចឹងទៅពួកគាត់ភ័យ ហើយគាត់មិនដឹងជាទាក់ទងអ្នកណាអ្វីអ៊ីចឹងណា»។

របាយការណ៍របស់ក្រសួងសុខាភិបាលថៃ បង្ហាញថា ចាប់តាំងពីថ្ងៃទី១ មករា ដល់ថ្ងៃទី២២ ខែកក្កដា មានពលករខ្មែរជាងមួយម៉ឺន (១ម៉ឺន) នាក់ បានឆ្លងជំងឺកូវីដ១៩។ ក្នុងនោះមានពលករធ្លាក់ខ្លួនឈឺធ្ងន់ និងភាគច្រើនទៀត ស្នាក់នៅការដ្ឋានសំណង់តាមយថាកម្មដោយគ្មានគ្រូពេទ្យព្យាបាលជំងឺទេ៕

## ឃាត់ខ្លួនជនជាតិថៃ ១២នាក់ ដែលបម្រុងលួចឆ្លងដែន មកធ្វើការនៅកម្ពុជា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ២៩ កក្កដា ២០២១ដោយ sopheak khoun

ជនជាតិថៃចំនួន១២នាក់ ត្រូវបានតម្រួតការពារព្រំដែនថៃលេខ១២ ឃាត់ខ្លួន នៅក្បែរខ្សែបន្ទាត់ព្រំដែន ខណៈដែលពួកគេ បម្រុងលួចឆ្លងដែនចូល មកក្នុងប្រទេសកម្ពុជា ដើម្បីរកការងារធ្វើ។ ការឃាត់ខ្លួននេះ បានធ្វើឡើង កាលពីព្រលប់ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ត្រង់ចំណុចភូមិ៩ ឃុំណូនម៉ាកម៉ុន ស្រុកគោកខ្សូង ខេត្តស្រះកែវ ប្រទេសថៃ បន្ទាប់ពីការរាតត្បាតនៃជំងឺកូវីដ-១៩ កាន់តែមានសភាពធ្ងន់ធ្ងរ ពិសេសគឺមេរោគបម្លែងខ្លួន ដែលតា និងអាល់ហ្វា។ ជនជាតិថៃទាំង១២នាក់ គឺមានប្រុស៥នាក់ និងស្រី៧នាក់ ដោយពួកគេមកពីខេត្តស្រះកែវ ៣នាក់ ខេត្តច័ន្ទបុរី ៣នាក់ ខេត្តកានចៈណាក់បុរីម្នាក់ ខេត្តសាមុទ្រសាខនម្នាក់ ខេត្តឈៀងម៉ៃម្នាក់ ខេត្តខនកែនម្នាក់ ខេត្តប្រាជីនបុរីម្នាក់ និងខេត្តនគរណាយ៉ុកម្នាក់ផងដែរ។ ពួកគេបានសារភាពថា ការលួចឆ្លងដែននេះ គឺអាចធ្វើឲ្យពួកគេសល់កម្រៃ ពីការជួលមេខ្យល់នាំផ្លូវ ដោយចូលទៅធ្វើការ នៅក្នុងកាស៊ីណូអនឡាញ នាក្រុងប៉ោយប៉ែត បើទៅដល់ទីនោះក្រុមហ៊ុន នឹងជួយគ្រប់យ៉ាង រួមទាំងការហូបចុក និងការស្នាក់នៅ៕ (ដោយ)៖ សោ និយមវត្ថ

# ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១

## សមត្ថកិច្ចឃាត់ខ្លួនពលករខ្មែរ៦នាក់ ពេលលួចឆ្លងដែនពីថៃខុសច្បាប់

http://freshnewsasia.com/ 2021-07-29 01:04pm

(បន្ទាយមានជ័យ)៖ កម្លាំងប៉ុស្តិ៍ព្រំដែនគោកបឹងសាគូ នៃវរសេនាតូចការពារព្រំដែន៩១១ សហការជាមួយកម្លាំងចម្រុះ បានសមត្ថកិច្ចឃាត់ខ្លួនពលករខ្មែរ៦នាក់ ពេលលួចឆ្លងដែនពីថៃខុសច្បាប់។ ការបង្ក្រាបបទល្មើសលួចឆ្លងដែន និងអ្នកចាំទទួលនេះ បានធ្វើឡើងនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ ម្សិលមិញ នៅចំណុចខាងមុខស្តារវីឡា ភូមិព្រៃព្រិច សង្កាត់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

នគរបាលប៉ុស្តិ៍ព្រំដែនគោកបឹងសាគូ បានបញ្ជាក់ប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ប្រចាំខេត្តបន្ទាយមានជ័យ ឱ្យដឹងនៅព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១នេះថា ប្រជាពលរដ្ឋចំនួន៣នាក់ ដែលទៅទទួលអ្នកលួចឆ្លងដែនពីថៃ បានជិះរថយន្តមានម៉ាក Tacoma ពណ៌ទឹកប្រាក់ ពាក់ស្លាកលេខ សៀមរាប 2C-7317 មានឈ្មោះ ចេង មួយហួង ភេទស្រី អាយុ២៥ឆ្នាំ អាជីវកផ្សារឡុងគ្លឿ ប្រទេសថៃ, ឈ្មោះ ចេង គឹមសែ ភេទប្រុស អាយុ២៩ អាជីវករផ្សារឡុងគ្លឿ ប្រទេសថៃ មានទីលំនៅភូមិបាលិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ, ឈ្មោះ ហៃ សុភ័ក្រ្ត ភេទប្រុស អាយុ៣៥ឆ្នាំ ត្រូវបងប្អូនឈ្មោះ ចេង គឹមសែ ជាអ្នកបើករថយន្តមានទីលំនៅភូមិបាលិលេយ្យ២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ កម្លាំងប៉ុស្តិ៍ព្រំដែនគោកបឹងសាគូ បានបន្ថែមថា ចំណែកអ្នកមកពីប្រទេសថៃនោះមានឈ្មោះ ហួត ដេវីត ភេទប្រុស អាយុ១៩ឆ្នាំ អាជីវករផ្សារឡុងគ្លឿ ប្រទេសថៃ, ឈ្មោះ ហួត ហួរ ភេទស្រី អាយុ៦០ឆ្នាំ អាជីវករផ្សារឡុងគ្លឿ ប្រទេសថៃ មានទីលំនៅភូមិ បា

លិលេយ្យ១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងឈ្មោះ កុក បញ្ញា ភេទប្រុស អាយុ៤៣ឆ្នាំ ជាមេខ្យល់។

ជនទាំង៣នាក់នេះ កំពុងឱ្យមេខ្យល់ដឹកជញ្ជូនមកពីថៃ យកមកដាក់ផ្ទះរបស់ពួកគេ ហើយក៏ត្រូវកម្លាំងដេញស្ទាក់ឃាត់ បាននៅចំណុចសាលា២ជាន់ និងបានដកហូត ទូរស័ព្ទដៃ ២គ្រឿង ក្នុងនោះមានសម្លេងឆ្លើយឆ្លងគ្នាតាម Line អំពីរឿងនាំមនុស្សលួចឆ្លងដែនដោយខុសច្បាប់។

តាមការសួរនាំពីឈ្មោះ ហួត ដេវីត បានប្រាប់កម្លាំងសមត្ថកិច្ចថា ពួកគេត្រូវក្រុមមេខ្យល់ដឹកជញ្ជូនតាមឡានម៉ាកកាមរី ស្លាកលេខថៃ ចេញពីផ្សាររុងក្លឿ មកមានគ្នាប្រហែល ១៣នាក់ ក្នុងនោះមានអ្នកនាំផ្លូវ២នាក់ ហើយត្រូវបានក្រុមមេខ្យល់ប្រមូលយកលុយក្នុងម្នាក់ចំនួន ៦,០០០បាត ដោយសន្យាថា ជូនពួកគាត់ដល់ផ្ទះ តែមិនទាន់ដល់គោលដៅផង ត្រូវបានសមត្ថកិច្ចឃាត់សួរនាំតែម្តង។ ជនសង្ស័យ និងវត្ថុតាងព្រមទាំងអាជីវករ ត្រូវបានកម្លាំងចម្រុះបញ្ជូនទៅទីបញ្ជាការរវៈសួរនាំបន្ត៕

## ក្រោយបិទខ្ទប់ព្រំប្រទល់ខេត្តនិងច្រកព្រំដែនកម្ពុជា-ថៃ ស្រាប់តែពលករនាំគ្នាសម្រុកចូល

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៩ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ១៦:៣៨

ខេត្តបន្ទាយមានជ័យ ៖ ក្រោយពេលរាជរដ្ឋាភិបាលបិទខ្ទប់ព្រំប្រទល់ខេត្ត និងបិទច្រកព្រំដែនកម្ពុជា-ថៃ ពលករបានសម្រុកចូលមកកម្ពុជា តាមច្រកអូរបីជាន់១ថ្ងៃជិត៣០០នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដ-១៩ជិត ១០០នាក់ នៅថ្ងៃទី២៩ កក្កដា ឆ្នាំ២០២១ នៅច្រកអូរបីជាន់ ស្រុកអូរជ្រៅ ។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យបានប្រាប់ថា រាជរដ្ឋាភិបាលកម្ពុជាសេចក្តីសម្រេចស្តីពីការបិទខ្ទប់ភូមិសាស្រ្តចំនួន៨ខេត្ត ក្នុងនោះ មានខេត្តបន្ទាយមានជ័យដែលត្រូវបានបិទព្រំដែនដើម្បីទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ.១៩ប្រភេទ ដែលតា(DELTA)។ ជាបណ្តោះអាសន្ន សម្រាប់រយៈពេល១៤ថ្ងៃចាប់ពីវេលាម៉ោង២៣ និង៥៩នាទី នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ សំដៅទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍ ដែលបណ្តាលមកពីមេរោគកូវីដ.១៩ប្រភេទដែលតា(DELTA)។ ជាក់ស្តែង នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ភូមិសាស្រ្តខេត្តបន្ទាយមានជ័យ នៅច្រកអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ក្រុមការងារមណ្ឌលសំចតបានទទួលពលករខ្មែរ ដែលត្រឡប់ពីប្រទេសថៃចូលមកកម្ពុជាវិញ រយៈពេល១ថ្ងៃជិត៣០០នាក់ ហើយរកឃើញអ្នកវិជ្ជមានកូវីដ.១៩ជិត១០០នាក់ ដែលត្រូវបានបញ្ជូនទៅមណ្ឌលព្យាបាល និងអ្នកវិជ្ជមានកូវីដ.១៩ត្រូវបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ។

នៅពេលដែលក្រុមការងារមណ្ឌលសំចតច្រកអូរបីជាន់ស្រុកអូរជ្រៅទទួលពលករខ្មែរដែលត្រឡប់ពីប្រទេសថៃចូលមកម្ពុជាវិញ ត្រូវបានក្រុមការងារជូនអាហារសម្រន់ ហើយពិនិសុខភាព និងយកសំណាក ធ្វើតេស្តបើរកឃើញវិជ្ជមានកូវីដ.១៩ត្រូវបានបញ្ជូនទៅព្យាបាលនិងអ្នកអវិជ្ជមានកូវីដ.១៩បញ្ជូនទៅធ្វើចត្តាឡីស័ករយៈពេល២១ថ្ងៃ៕

## ខេត្តបន្ទាយមានជ័យបង្កើតមណ្ឌលចត្តាឡីស័ក ៥ ទីតាំងទៀត ខណៈក្នុង ១ ថ្ងៃ មានពលករមកពីថៃជាង ១០០ នាក់

https://www.postkhmer.com/ ឡាយ សាមាន | Publication date 29 July 2021 | 14:31 ICT

**បន្ទាយមានជ័យៈ** រដ្ឋបាលខេត្តបន្ទាយមានជ័យបាន និងកំពុងរៀបចំបង្កើតមណ្ឌលចត្តាឡីស័ក និងកន្លែងព្យាបាលជំងឺកូវីដ ១៩ កម្រិតស្រាល ៥ ទីតាំងបន្ថែមទៀត ដើម្បីត្រៀមទទួលពលរដ្ឋខ្មែរត្រឡប់ពីប្រទេសថៃ ដោយក្នុង ១ ថ្ងៃ ជាមធ្យមមានពលករជាង ១០០ នាក់ ហើយក្នុង ១ ថ្ងៃខេត្តនេះ រកឃើញអ្នកឆ្លងជាមធ្យមពី ៧០ ទៅ ៨០ នាក់។

ប្រធានមន្ទីរព័ត៌មានខេត្តបន្ទាយមានជ័យ លោក សេក សុខុម ប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ថា ដោយសារតែចំនួនពលករចំណាកស្រុកវិលត្រឡប់ពីប្រទេសថៃមកវិញមានចំនួនច្រើន ទើបរដ្ឋបាលខេត្តសម្រេចសាងសង់មណ្ឌលបន្ថែម។ លោកថា៖ «ដោយសារនៅប្រទេសថៃ គេព្យាបាលជំងឺកូវីដ ១៩ សុទ្ធតែចំណាយលុយ ហើយនៅថៃគេបិទការដ្ឋានចឹងពលរដ្ឋខ្មែរនៅទីនោះ សម្រុកមកស្រុកខ្មែរវិញ ព្រោះរដ្ឋាភិបាលយើងមានគោលនយោបាយព្យាបាលពួកគាត់អត់អស់លុយទេ»។ លោកបន្តថា កន្លងមកអាជ្ញាធរធ្វើចត្តាឡីស័កពលករនៅតាមព្រំដែន តែដោយសារមណ្ឌលនៅតាមព្រំដែនពេញទើបរដ្ឋបាលខេត្តរៀបចំមណ្ឌលបន្ថែមនិងមួយចំនួនទៀតបញ្ជូនទៅទីតាំងកំណើតរៀងៗខ្លួន។ លោកថា៖ «នៅពេលធ្វើតេស្តរហ័សបើរកអត់ឃើញវិជ្ជមានកូវីដទេ គឺយើងបញ្ជូនគាត់ទៅស្រុកកំណើត ប៉ុន្តែគាត់ត្រូវធ្វើតេស្តម្តងទៀតមុនពេលចូលទៅក្នុងមណ្ឌលចត្តាឡីស័កក្នុងស្រុកដើម្បីការពារសុវត្ថិភាពអ្នកធ្វើចត្តាឡីស័ក»។ លោកឱ្យដឹងដែរថា ក្នុងថ្ងៃៗពលករខ្មែរវិលពីថៃមកស្រុកវិញមានជាង ១០០ នាក់ ក្នុងនោះរកឃើញអ្នកវិជ្ជមានកូវីដ១៩ ប្រមាណ ២០ នាក់។

លោក សុខុម ឱ្យដឹងថា សម្រាប់កន្លែងព្យាបាលជំងឺកូវីដ ១៩ កម្រិត-ស្រាល និងមណ្ឌលចត្តាឡីស័ក ដែលរដ្ឋបាលខេត្ត បាននិងកំពុងរៀបចំរួមមាននៅ វិទ្យាល័យភ្នំធំ ផ្សារធំប៉ុរីជ័យ និងផ្សារចំការតាដោក ស្រុកមង្គលបុរី។ ចំណែក ២ កន្លែងទៀតស្ថិតនៅ វិទ្យាល័យខ្លាកូន និងស្ថិតនៅដីក្រុមហ៊ុនឯកជន ១ កន្លែង ដែលស្ថិតនៅភូមិខ្លាកូនថ្មី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ។ លោកឱ្យដឹងថា ក្នុង ១ មណ្ឌលអាចផ្ទុកអ្នកធ្វើចត្តាឡីស័កបានចន្លោះពី ៥០០ ទៅ ៧០០ នាក់ ឬអាចដល់ខ្ទង់ ១ ពាន់ នាក់អាស្រ័យលើការរៀបចំទីតាំងនោះ។ សម្រាប់ខេត្តបន្ទាយមានជ័យគឺមាន ៩ ស្រុក-ក្រុង ដោយក្នុងនោះ រដ្ឋបាលខេត្តបានរៀបចំមណ្ឌលចត្តាឡីស័ក និងកន្លែងព្យាបាលជំងឺកូវីដ ១៩ នៅតាមស្រុក និងក្រុងនីមួយៗផងដែរ។ លោកថា៖ «នៅតាមស្រុកយើងមានមណ្ឌលចត្តាឡីស័ករួចអស់ហើយស្រុកខ្លះមាន១ ស្រុកខ្លះមាន២ ចំណែកមណ្ឌលព្យាបាលវិញក៏មានស្ទើរគ្រប់ស្រុកដែរ ហើយនៅខេត្តយើងក៏បានសាងសង់ឈាបនដ្ឋានសម្រាប់បូជាសព ដោយសារជំងឺកូវីដ ១៩ ផងដែរ»។ បើតាមលោក សុខុម សម្រាប់ពលករ-ខ្មែរដែលផ្ទុកវីរុសកូវីដបំប្លែងថ្មី ប្រភេទ Delta គឺអាជ្ញាធរដាក់នៅមណ្ឌលព្យាបាលដាច់ដោយឡែកពីអ្នកផ្ទុកវីរុសកូវីដ ១៩ ធម្មតា។

ជាមួយគ្នានេះដែរ អភិបាលខេត្តបន្ទាយមានជ័យលោក អ៊ុំ រាត្រី ក៏បានសម្រេចបង្កើតក្រុមការងារថ្នាក់ខេត្តដើម្បីគ្រប់គ្រង ថែទាំ និងព្យាបាលអ្នកជំងឺកូវីដ នៅតាមផ្ទះ។ យោងសេចក្តីសម្រេចរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ចុះថ្ងៃទី ២៧ ខែកក្កដាឱ្យដឹងថា៖ «រដ្ឋបាលក្រុង ស្រុក ត្រូវរៀបចំបង្កើតក្រុមការងារថ្នាក់ក្រុង ស្រុក ដើម្បីថែទាំ និងព្យាបាលអ្នកជំងឺកូវីដ ១៩ នៅតាមផ្ទះ។ លោកបញ្ជាក់ថា ក្នុងនាមអាជ្ញាធរខេត្តបានប្តេជ្ញាខ្ពស់ក្នុងការសម្របសម្រួលដឹកនាំ ប្រតិបត្តិការងារ ថែទាំ ព្យាបាលអ្នកជំងឺកូវីដ ១៩ តាមផ្ទះនេះឱ្យបានជោគជ័យក្នុងនោះរដ្ឋបាលខេត្តបានរៀបចំក្រុមការងារប្រចាំការងារខេត្ត និងជាក្រុមតាមស្រុក/ក្រុង និងក្រុមប្រចាំការ Hotline និងក្រុមគ្រូពេទ្យ។ «ជាជំហានដំបូងនេះ រដ្ឋបាលខេត្តនឹងដាក់ឱ្យដំណើរការ ថែទាំ ព្យាបាលតាមផ្ទះ ចំពោះក្រុងប៉ោយប៉ែត និងក្រុងសិរីសោភ័ណ»។

ក្រសួងសុខាភិបាលឱ្យដឹងថា គិតត្រឹមថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០២១ ចំនួនអ្នកធ្វើចត្តាឡីស័កនៅខេត្តបន្ទាយមានជ័យមាន ៤ ១០៤ នាក់ ខណៈអ្នកស្លាប់ដោយសារជំងឺនេះមានប្រមាណ ១០០ នាក់។ រីឯអ្នកឆ្លងកូវីដជាមធ្យមក្នុង ១ ថ្ងៃរកឃើញចន្លោះពី ៧០ ទៅ ៨០ នាក់ និងអ្នកព្យាបាលជាសះស្បើយប្រហែលពី ៥០ ទៅ ៦០ នាក់៕

## ពលរដ្ឋ ៦នាក់ ឆ្លងទឹកអូរពីប្រទេសថៃមកខ្មែរវិញ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន រួចបញ្ជូនទៅធ្វើចត្តាឡីស័ក

https://gntimes.com/ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១

បន្ទាយមានជ័យ៖ ប្រជាពលរដ្ឋខ្មែរចំនួន ៦នាក់ បានឆ្លងដែនហែលទឹកកាត់អូរព្រំដែនចេញពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ ត្រូវបានកម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនគោកប៉ុស្តិ៍ក្បាលស្ពាន នៃវរៈសេនាតូចលេខ ៨៩១ ឃាត់ខ្លួននៅវេលាម៉ោងជាង ៤ទាបភ្លឺ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០២១ ត្រង់ចំណុចគោលដៅរោងម៉ាស៊ីនដីក្រុមហ៊ុន «ក្រេនដាយម៉ន» ស្ថិតក្នុងភូមិអូរជ្រៅ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

លោកវរៈសេនីយ៍ត្រី សែម សាមឿន នាយប៉ុស្តិ៍នគរបាលការពារព្រំដែនគោក បានឲ្យដឹងថា ប្រជាពលរដ្ឋទាំង ៦នាក់ដែលត្រូវឃាត់ខ្លួនខាងលើ ទី១-ឈ្មោះ ហុង សារ៉ន ភេទប្រុស អាយុ ៣៧ឆ្នាំ, ទី២-ឈ្មោះ ម៉ៅ រិទ្ធី ភេទប្រុស អាយុ ៣៤ឆ្នាំ, ទី៣-ឈ្មោះ អ៊ី រស្មី ភេទប្រុស អាយុ ៣២ឆ្នាំ, ទី៤-ឈ្មោះ ហុង ស្រីរៀម ភេទស្រី អាយុ ៣០ឆ្នាំ, ទី៥-ឈ្មោះ ហុង យូអ៊ីន ភេទស្រី អាយុ ៨ឆ្នាំ និងទី៦-ឈ្មោះ អ៊ំ គីមអ៊ី ភេទស្រី អាយុមួយខួបកន្លះ ។ អ្នកទាំងអស់គឺជាអាជីករលក់ដូរនៅផ្សាររោងក្បឿរប្រទេសថៃ ដែលមានទីលំនៅក្នុងភូមិក្បាលស្ពាន២ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ លោកវរៈសេនីយ៍ត្រី សែម សាមឿន បានបញ្ជាក់ឲ្យដឹងថា ប្រជាពលរដ្ឋទាំង ៦នាក់នោះ ត្រូវបានបញ្ជូនយកទៅធ្វើតេស្តរកមេរោគកូវីដ-១៩ នៅចំណុចសំចត (CQ2) នៃសាលាវិទ្យាល័យនិមិត្ត ស្ថិតក្នុងភូមិនិមិត្ត សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងធ្វើចត្តាឡីស័កដើម្បីតាមដានសុខភាពបន្ត ៕ អត្ថបទ រឿង ចន្ទ្រា

## លោក ហេង សួរ ប្រាប់ពលករខ្មែរនៅថៃ កុំឱ្យឆ្លងដែនមកខ្មែរ ព្រោះព្រំដែនបិទហើយ

http://freshnewsasia.com/ 2021-07-29 09:05pm

**(ភ្នំពេញ)៖** លោក ហេង សួរ រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានណែនាំទៅពលករខ្មែរកំពុងធ្វើការនៅក្នុងប្រទេសថៃ កុំចេញពីកន្លែងស្នាក់នៅដើម្បីឆ្លងដែនត្រឡប់មកខ្មែរវិញ ព្រោះព្រំដែនត្រូវបានបិទហើយ។ លោក ហេង សួរ បានលើកឡើងលើទំព័រហ្វេសប៊ុកនៅយប់ថ្ងៃទី២៩ ខែកក្កដា នេះថា «**ចាប់ពីម៉ោងនេះតទៅ សូមបងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃទាំងអស់ កុំចល័តចេញពីកន្លែង ដែលខ្លួនកំពុងស្នាក់នៅឆ្ពោះមកព្រំដែនកម្ពុជា-ថៃ។ បើទោះបីជាបងប្អូនមានធុរៈចាំបាច់ ឬចប់ការងារត្រូវវិលត្រឡប់មកវិញ ក៏ត្រូវពន្យារពេលយ៉ាងហោចណាស់ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១នេះ**»។

លោក ហេង សួរ បានបញ្ជាក់ថា ចំពោះមុខនេះ ប្រសិនបើពលករធ្វើដំណើរមកព្រំដែនកម្ពុជា-ថៃ តាមមធ្យោបាយណាក៏ដោយ គឺនឹងត្រូវអាជ្ញាធរមានសមត្ថកិច្ចថៃ តម្រូវឱ្យធ្វើដំណើរវិលត្រឡប់ទៅកន្លែងដើមវិញ។ ម្ចាស់រថយន្ត ឬមេខ្យល់ ដែលដឹកជញ្ជូនពលករ គឺល្មើសនឹងបំរាមរបស់អាជ្ញាធរថៃ ដូច្នេះត្រូវប្រឈមនឹងការចាត់វិធានការច្បាប់ផងដែរ។

សូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបិទការធ្វើដំណើរឆ្លងព្រំដែនកម្ពុជា-ថៃ ចាប់ពីយប់ថ្ងៃទី២៩ ខែកក្កដា រហូតដល់ថ្ងៃទី១២ ខែសីហា ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ជាពិសេសមេរោគបំប្លែងថ្មីដែលតា (Delta)។ ការធ្វើដំណើរឆ្លងព្រំដែនអនុញ្ញាតតែការដឹកទំនិញ និងការធ្វើដំណើរចាំបាច់តែប៉ុណ្ណោះ៕

## សាលាឧទ្ធរណ៍បន្ធូរបន្ថយទោស បុរសរត់ឡានតាក់ស៊ីម្នាក់ ដាក់០៥ ឆ្នាំ ពាក់ព័ន្ធការលក់ពលករខ្មែរ ០៦ នាក់ ធ្វើជាទាសករកម្មករ នេសាទត្រី នៅសមុទ្រថៃ

https://cen-news.com/ Posted ByPen Srey NeatJuly 29, 2021

ភ្នំពេញ ៖ សាលាឧទ្ធរណ៍ ភ្នំពេញ កាលពីថ្ងៃទី ២៨ ខែ កក្កដាឆ្នាំ ២០២១ បានប្រកាសសាលដីកា លើបណ្តឹងឧទ្ធរណ៍ របស់ បិតាជាប់ចោទ ដែលត្រូវបានតុលាការខេត្តសៀមរាប កាត់ទោស ដាក់ពន្ធនាគារ កំណត់ ០៨ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងករណី ជួញដូរមនុស្សឆ្លងដែន ខុសច្បាប់ប្រព្រឹត្តកាលពីអំឡុងឆ្នាំ ២០០៩។ សាលាឧទ្ធរណ៍

បានសម្រេច តម្កល់សាលក្រមរបស់តុលាការខេត្តសៀមរាប ចុះបរិច្ឆេទថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៧ តែ បានបន្ធូរបន្ថយទោស គាត់ពីជាប់ពន្ធនាគារ ០៨ ឆ្នាំ មក ០៥ ឆ្នាំ នៅក្នុងពន្ធនាគារ តែបើកផ្លូវឱ្យគាត់ប្ដឹងសារទុក្ខ ទៅកាន់តុលាការកំពូល តាមច្បាប់កំណត់។

លោកចៅក្រម ប្លង់ សំណាង ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃសាលាឧទ្ធរណ៍ភ្នំពេញ បានថ្លែងថា ជនជាប់ចោទ មានឈ្មោះ ណាក់ សម្បត្តិ ភេទប្រុស អាយុ ៣៩ ឆ្នាំ មុខរបរមុនចាប់ខ្លួន ជាអ្នកបើកបររថយន្តតាក់ស៊ី មានទីលំនៅឃុំកំពង់ក្ដី ស្រុកជីក្រែង ខេត្តសៀមរាប។ ជនជាប់ចោទត្រូវបានជាប់ចោទ ពីបទ៖ « នាំចេញដោយមិនស្របច្បាប់ សម្រាប់ឆ្លងដែន» តាមបញ្ញត្តិ មាត្រ១១ នៃច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស នឹងអំពើអាជីវកម្មផ្លូវភេទ។

លោកចៅក្រមបានបន្ថែមថា ជនជាប់ចោទត្រូវបានចាប់ឃុំខ្លួន នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ តាមបណ្ដឹងជនរងគ្រោះចំនួន ០៦នាក់ ដែលជាពលករចំណាកស្រុក ដែលបានប្ដឹងជនជាប់ចោទ ណាល់ សម្បត្តិ និងជនជាប់២នាក់ ម្នាក់មានឈ្មោះ ង៉ែត ផល្លា អាយុ ៤០ និង ឈ្មោះ មឿត គៀ អាយុ ៤២ ឆ្នាំ មកកាន់សមត្ថកិច្ចនគរបាលជំនាញថា៖ បានជួញដូរពួកគេ ទៅធ្វើការងារ ជាកម្មករសំណង់ នៅប្រទេសថៃ តែបានលក់ពួកគេ ទៅធ្វើជាកម្មករនេសាទត្រី នៅលើកប៉ាល់នេសាទថៃ និងត្រូវបានពួកថៅកែថៃ បង្ខំឱ្យធ្វើការងារ ទាំងយប់ទាំងថ្ងៃ ដោយគ្មានប្រាក់ខែ និងត្រូវបានរស់នៅតែនៅកប៉ាល់នេសាទ និងនៅលើមហាសមុទ្រ អស់រយៈពេលជាង០៧ ឆ្នាំ។

គួរបញ្ជាក់ថា នៅក្នុងសំណុំរឿងក្ដីព្រហ្មទណ្ឌនេះ ជនជាប់ចោទ ០២នាក់ ឈ្មោះ ង៉ែត ផល្លា និង មឿត គៀ ដែលជាមេខ្យល់ ក៏ត្រូវបានចាប់ខ្លួន និងត្រូវជាប់ទោសម្នាក់ៗ ចំនួន ០៩ ឆ្នាំផងដែរ៕ រក្សាសិទ្ធិដោយ៖ ចន្ទា ភា

## ពលរដ្ឋខ្មែរ ២នាក់ ជាប់ពន្ធនាគារ ត្រូវបានអាជ្ញាធរថៃ ដោះលែងឱ្យមកស្រុកវិញ

https://kohsantepheapdaily.com.kh/ Oddar Meanchey ២៩ ខែ កក្កដា ឆ្នាំ ២០២១ ម៉ោង ២២:០៣

ខេត្តឧត្តរមានជ័យ៖ ក្រុមអាជ្ញាធរថៃ បានធ្វើការដោះលែងពលរដ្ឋខ្មែរ ២នាក់ ចេញពីពន្ធនាគារឱ្យមានសេរីភាពវិញ កាលពីវេលាម៉ោង ១១ និង២៥នាទី ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ នាំខ្លួនយកមកប្រគល់ឱ្យអាជ្ញាធរកម្ពុជា តាមច្រកទ្វារអន្តរជាតិជាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ពលរដ្ឋខ្មែរដែលក្រុមអាជ្ញាធរថៃ ដោះលែងឈ្មោះ កន ហឿន ភេទប្រុស អាយុ ២១ឆ្នាំ រស់នៅភូមិថ្នល់បែង ឃុំត្បែង ស្រុកគូលែន ខេត្តព្រះវិហារ និងម្នាក់ទៀត ឈ្មោះ ជិត ថេង ភេទប្រុស អាយុ ៣៥ឆ្នាំ រស់នៅភូមិចារ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ អ្នកទាំងពីរ ចាប់ខ្លួនថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ ចោទពីបទឆ្លងដែន កាប់ឈើក្រញូង ចូលតាមច្រកតាសឹម ជាប់គុក នៅស្រុកខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ។

ក្រុមអាជ្ញាធរកម្ពុជា បម្រើការងារច្រកទ្វារអន្តរជាតិជាំ បានឱ្យដឹង ពលរដ្ឋខ្មែរ ២នាក់ ក្រោយពីបានទទួលពីក្រុមអាជ្ញាធរថៃរួច សមត្ថកិច្ចបានធ្វើការអប់រំ និងធ្វើកិច្ចសន្យាឱ្យបញ្ឈប់ឆ្លងដែនខុសច្បាប់បន្តទៀត បន្ទាប់មកលោកគ្រូពេទ្យ ប្រចាំការ នៅច្រកអន្តរជាតិជាំ ក៏បានធ្វើតេស្ត យកសំណាករកជំងឺ COVID ១៩ លទ្ធផលអវិជ្ជមាន បញ្ជូនបន្តទៅធ្វើចត្តាឡីស័ក នៅសាលាបឋមសិក្សាអន្លង់វែង៕ ឱម សារឿន

# ពលករខ្មែរនៅថៃប្រតិកម្មនឹងរដ្ឋាភិបាលខ្មែរបិទខ្ទប់ព្រំដែនមិនឱ្យពួកគេត្រឡប់នៅកម្ពុជាវិញ

https://www.rfa.org/khmer/ ដោយ ម៉ៅ សុជានី 2021-07-29

ពលករខ្មែរធ្វើការនៅប្រទេសថៃមួយចំនួនខកចិត្តនឹងរដ្ឋាភិបាល ដែលសម្រេចបិទខ្ទប់ព្រំដែនមិនឱ្យពួកគេវិញត្រឡប់ទៅកម្ពុជាវិញអំឡុងពេលនេះ។ ពលករទាំងនោះ ចាត់ទុកវិធានការរបស់រដ្ឋាភិបាលលោក ហ៊ុន សែន នេះថា ជាការមិនគិតគូរដល់ពលរដ្ឋខ្លួនឯង ដែលកំពុងរស់នៅលំបាកនៅក្រៅប្រទេស។ មន្ត្រីសង្គមស៊ីវិលយល់ថា ការបិទខ្ទប់នេះមិនមែនជាដំណោះស្រាយល្អនោះទេ ហើយវានឹងធ្វើឱ្យពលកររស់នៅកាន់តែលំបាក។ ពលករខ្មែរមួយចំនួនធ្វើការនៅប្រទេសថៃ ថ្លែងថា ពួកគេរស់នៅប្រទេសថៃយ៉ាងលំបាកវេទនា ដូច្នេះពួកគេចង់វិលត្រឡប់ទៅកម្ពុជាវិញ ដើម្បីបានជួបក្រុមគ្រួសារក្នុងគ្រាអាសន្ននេះ។

ពលករធ្វើការសំណង់នៅទីក្រុងបាងកក លោក ឈឺន ឈុន រៀបរាប់ប្រាប់វិទ្យុអាស៊ីសេរីថា ពលករខ្មែរធ្វើការជាមួយលោកជាច្រើននាក់ចង់ត្រឡប់ទៅកម្ពុជាវិញអំឡុងពេលនេះ ពីព្រោះមិនអាចអត់ទ្រាំនៅប្រទេសថៃបន្តទៀតបានទេ ដោយសារគ្មានប្រាក់ទិញអាហារហូបចុកប្រចាំថ្ងៃផង និងខ្លាចឆ្លងជំងឺកូវីដ១៩ផង។ ពលករវ័យ៣៦ឆ្នាំរូបនេះ បន្តថា ពលករខ្មែរធ្វើការជាមួយលោកចំនួន២៦នាក់ត្រូវបានថៅកែថៃបង្ខាំងនៅក្នុងបន្ទប់ជាង១ខែមកហើយ ដោយពុំមានអាជ្ញាធរណាផ្ដល់ស្បៀងអាហារដល់ពួកគាត់នោះទេ៖ «ប្រទេសគេយើងទៅពឹងអ្នកណាហើយទៅជឿម្ហូបអាហារទៅណាក៏អត់កើតដែរ។ អីចឹងអាចលំបាកវេទនាអ្នកឆ្លងកូវីដ គឺលំបាកបណ្ដោយអ្នកណាអត់បានគឺអត់លុយឱ្យថ្លៃបន្ទប់ជួល គឺអត់បណ្ដោយ ដល់អីចឹងគឺវេទនាបណ្ដោយ។ រដ្ឋាភិបាលបិទខ្ទប់៨ខេត្តហ្នឹងគឺខ្ញុំទទួលយកអត់បានទេ ដូចគាត់សម្លាប់ពលករខ្មែរដែលរស់នៅប្រទេសថៃបណ្ដោយ ស្លាប់ដូចជាអ្នកខ្លះ កើតជំងឺកូវីដដល់អីចឹងនៅប្រទេសថៃគេអត់ទទួលមើល ហើយយើងព្យាបាលខ្លួនឯង ខ្លះអត់ការងារអត់លុយកាក់»។

ដូចគ្នានេះដែរ ពលករធ្វើការនៅផ្សារទំនើបនៅទីក្រុងបាងកក លោក ឡុង សុភាន់ ថ្លែងថា ពលករខ្មែរធ្វើការនៅតំបន់លោករាប់រយនាក់អត់ការងារធ្វើជិត២ខែហើយ ដោយគ្មានអាជ្ញាធរណាឧបត្ថម្ភស្បៀងអាហារដល់ពួកគាត់ឡើយ។ ពលកររូបនេះបន្តថា មួយរយៈនេះមានពលករខ្លះបាននាំគ្នាត្រឡប់ទៅស្រុកកំណើតវិញ ដោយសារគ្មានលទ្ធភាពរស់នៅប្រទេសថៃ។ បន្ថែមពីនេះលោកថា មានពលករខ្លះបានឆ្លងជំងឺកូវីដ១៩ ហើយពួកគាត់នាំគ្នាដេកឈឺនៅក្នុងបន្ទប់រៀងខ្លួនតាមយថាកម្ម ដោយគ្មានថ្នាំលេបព្យាបាលជំងឺឡើយ៖ «ធ្វើអីចឹងអត់ល្អវាលំបាកយើងអត់បានត្រឡប់ទៅផ្ទះអីចឹង ហើយណាមួយគេអត់ទទួលខុសត្រូវយើងផង វាលំបាកណាស់។ នៅនេះវាអត់ការងារអីចឹងជំងឺវារាតត្បាតខ្លាំងផង អត់ហ៊ាននៅទេ។ ខ្ញុំផ្ដាំផ្ញើទៅលោកនាយករដ្ឋមន្ត្រីសុំឱ្យជួយពលករខ្មែរនៅនេះផង ឱ្យម៉េចបានទៅដល់ផ្ទះដោយសុវត្ថិភាពផង»។

ស្រដៀងគ្នានេះ ពលករមួយក្រុមទៀតធ្វើការសំណង់ទីក្រុងបាងកកថ្លែងថា ពួកគេរស់នៅប្រទេសថៃសព្វថ្ងៃវេទនាខ្លាំងមិនធ្លាប់ជួបប្រទះពីមុនមកនោះទេ ។ ពលករទាំងនេះបន្តថា ចាប់តាំងពីផ្ទុះការរាតត្បាតជំងឺកូវីដ១៩ខ្លាំងនៅទីក្រុងបាងកកមក ថៅកែថៃបានបង្ខាំងពួកគេនៅក្នុងបន្ទប់រហូត ដោយមិនអនុញ្ញាតឱ្យពួកគេចេញទៅខាងក្រៅបានឡើយ ។ ពួកគាត់និយាយថា រស់នៅប្រទេសថៃធុញថប់ ហើយខ្លះមានសុខភាពទ្រុឌទ្រោម ដូច្នេះហើយបានជាពួកគេចង់ត្រឡប់ទៅកម្ពុជាវិញ៖ «ព្រោះនៅនេះវាអត់មានការងារធ្វើ ណាមួយអត់មានអីហូបអីចឹងយើងប្រថុយប្រថាន ទៅផ្ទះទៅដើម្បីជួបជុំគ្រួសារដើម្បីបាននៅផ្ទះគ្រាន់រកអីបានខ្លះៗបើយើងនៅនេះទៀតមានតែនៅស្លាប់ទឹកដីគេ។ ធុន់ធូរមែនទែន ត្រង់ថាពួកខ្ញុំរស់ពឹងការងារមួយថ្ងៃហ្នឹងហើយអត់មានការងារហ្នឹងទៀតពួកខ្ញុំអត់មានប្រាក់កម្រៃទេ ហើយអ្នកផ្ទះខ្ញុំត្រូវការលុយ គឺលំបាកមែនទែន។ បើយើងនៅនេះលំបាកទាំងការហូបចុក យើងទៅផ្ទះមិនបានហើយលំបាកកន្លែងឃុំឃាំងហ្នឹងធ្វើឱ្យជីវិតកាន់តែលំបាក»។ ក្រុមពលករទាំងនេះ ចាត់ទុកវិធានការរបស់រដ្ឋាភិបាលបិទខ្ទប់ព្រំដែនជាប់ប្រទេសថៃថា ប្រៀបដូចការសម្លាប់ពួកគេទាំងរស់។

ប្រតិកម្មរបស់ក្រុមពលករទាំងនេះធ្វើឡើង បន្ទាប់ពីរដ្ឋាភិបាលបានបិទខ្ទប់ខេត្តចំនួន ៨ ជាប់ព្រំដែនថៃ រយៈពេល ១៤ថ្ងៃ ដោយគិតចាប់ពាក់កណ្ដាលអាធ្រាត្រ ថ្ងៃទី២៩ ខែកក្កដា រហូតដល់ថ្ងៃទី ១២ ខែសីហា ក្រោមហេតុផលដើម្បីទប់ស្កាត់ការឆ្លងរាលដាលកូវីដ១៩ បំប្លែងថ្មី ប្រភេទ ដែលតា (Delta)។ ខេត្តដែលត្រូវបិទខ្ទប់បណ្ដោះអាសន្នទាំងនោះរួមមាន ខេត្តកោះកុង ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្ដរមានជ័យ ព្រះវិហារ និងខេត្តសៀមរាប។ បន្ថែមពីនេះរបបក្រុងភ្នំពេញក៏បញ្ជាឱ្យក្រសួងការបរទេស និងក្រសួងការងារ ទាក់ទងភាគីថៃជាបន្ទាន់ ដើម្បីបិទព្រំដែនមិនឱ្យពលករចេញចូលបណ្ដោះអាសន្ន លើកលែងតែងការដឹកជញ្ជូនទំនិញ និងករណីពិសេសមានអ្នកជំងឺសង្គ្រោះបន្ទាន់។ បន្ថែមពីនេះរបបឯកបក្សបញ្ជាឱ្យក្រសួងទាំងពីរ និងអាជ្ញាធរខេត្តជាប់ព្រំដែនទាំងនោះឱ្យសម្របសម្រួលជាមួយអាជ្ញាធរថៃដើម្បីពន្យារពេលពលករខ្មែរវិលត្រឡប់មកកម្ពុជាវិញទៀតផង។ ជាមួយគ្នានេះ រដ្ឋាភិបាលក៏តម្រូវឱ្យអភិបាលខេត្តក្រុងទាំងអស់ បិទខ្ទប់អាជីវកម្ម សកម្មភាពការងារ មុខរបរនានា ហាមការជួបជុំ ដែលមានមនុស្សលើសពី ១០នាក់ និងការហាមឃាត់ការដើរហើរ ចាប់ពីម៉ោង៩យប់ រហូតដល់ម៉ោង ៣ទៀបភ្លឺជាដើម។ វិធានការនេះ ធ្វើឡើងបន្ទាប់ពីកម្ពុជារកឃើញអ្នកឆ្លងមេរោគ កូវីដ១៩ បំប្លែងថ្មីប្រភេទដែលតា (Delta) កាន់តែច្រើនកើតចេញពីពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ។

អាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យរដ្ឋាភិបាលកម្ពុជា លោក ផៃ ស៊ីផាន និងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ដើម្បីឆ្លើយតបនឹងទុក្ខកង្វល់របស់ក្រុមពលករនេះបាននៅឡើយទេ នៅថ្ងៃទី ២៩ កក្កដា។ ទោះជាយ៉ាងណា មន្ត្រីអង្គការសង់ត្រាល់ទទួលបន្ទុកផ្នែកពលករលោក ឌី ថេហូយ៉ា យល់ថា វិធានការរបស់រដ្ឋាភិបាលនេះមិនមែនជាដំណោះស្រាយល្អនោះទេ ពីព្រោះនឹងធ្វើឱ្យពលករខ្មែររងទុក្ខលំបាកកាន់តែខ្លាំង ដោយសារមិនអាចត្រឡប់ទៅកម្ពុជាវិញបាននៅក្នុងគ្រាអាសន្ននេះ៖ «ជាការសំណូមពររបស់ខ្ញុំគឺថាធ្វើយ៉ាងម៉េចស្ដាប់សំឡេង ពីអ្នករងគ្រោះហើយ ធ្វើគោលនយោបាយឱ្យឆ្លើយតបចំពោះបញ្ហាហ្នឹងទៅ យើងក៏រស់គេរស់។ អីចឹងជីវិតក្រុមគ្រួសាររបស់យើងហ្នឹងគឺថារស់ស្រួលដេកពូក មានលុយមានឡានមានម៉ាស៊ីនត្រជាក់ ចំណែកឯមនុស្សរាប់លាននាក់ ពួកគាត់រងគ្រោះយើងអត់ដឹងពីសុខទុក្ខពួកគាត់ ហើយយើងជាអ្នកក្ដោបក្ដាប់គោលនយោបាយ យើងមិនយល់ពីបញ្ហាថា តើយើងធ្វើគោលនយោបាយឱ្យឆ្លើយតបឬមួយយើងចេះតែធ្មេចភ្នែកសុខតែខ្លួនឯងទៅ អ្នកណាលំបាកយ៉ាងម៉េចក៏យើងអត់ខ្វល់ដែរយ៉ាងម៉េចកើត»។

រដ្ឋាភិបាលថៃបានបិទខ្ទប់ទីក្រុងបាងកក និងខេត្តចំនួន៨នៅជុំវិញនោះ ចាប់តាំងពីថ្ងៃទី១២ ខែកក្កដាដល់ថ្ងៃទី២ សីហាដើម្បីទប់ស្កាត់ជំងឺកូវីដ១៩។ ការបិទខ្ទប់នេះបានធ្វើឱ្យពលករខ្មែរនៅតំបន់នោះអត់ការងារធ្វើឱ្យហើយត្រូវបានថៅកែបង្ខាំងឱ្យនៅក្នុងបន្ទប់ ដោយផ្ដល់ស្បៀងអាហារបន្តិចបន្តួចប៉ុណ្ណោះ។

របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរជិត ២លាននាក់កំពុងធ្វើការនៅប្រទេសថៃ។ ក្រសួងសុខាភិបាលថៃឱ្យដឹងថា ចាប់ពីថ្ងៃទី១ មករា ដល់ថ្ងៃទី២២ កក្កដាមានពលករខ្មែរជាង១ ម៉ឺននាក់ហើយបានឆ្លងជំងឺកូវីដ១៩។ ក្នុងនោះពលករខ្លះបានធ្លាក់ខ្លួនឈឺធ្ងន់ ហើយអ្នកខ្លះទៀតរស់នៅក្នុងបន្ទប់ក្នុងការដ្ឋានសំណង់តាមយថាកម្មដោយគ្មានគ្រូពេទ្យណាព្យាបាលជំងឺឡើយ៕